# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍

# អង្កេតមនុស្សមាត្រកម្ពុជា ២០០៨


រៀបចំដោយ :

វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ



ឧបត្ថម្ភដោយ :

អង្គការយូនីសេហ្វ និងអង្គការយូអ៊ិនឌីភី ប្រចាំកម្ពុជា

ខែ ឧសភា ឆ្នាំ២០០៩

# បុព្វកថា

ខ្ញុំមានការសប្បាយរីករាយណាស់ ចំពោះអង្កេតមនុស្សមាត្រកម្ពុជា ដែលបានធ្វើឡើងដោយជោគជ័យ លើកទី១ ក្នុងឆ្នាំ២០០៨ ។ ការអង្កេតនេះឧបត្ថម្ភថវិកា និងបច្ចេកទេស ដោយអង្គការ យូនីសេហ្វ និង អង្គការ យូអិនឌីភី ប្រចាំនៅកម្ពុជា ។ វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ និងអគ្គនាយកដ្ឋានផែនការ ក្រសួងផែនការ ជាភ្នាក់ងារអនុវត្តន៍គម្រោង។ វិទ្យាស្ថានជាតិស្ថិតិ ទទួលខុសត្រូវគ្រប់គ្រងគម្រោងនេះ។ ការចុះប្រតិបត្តិការ សំភាសន៍ នៅមូលដ្ឋាននៃការអង្កេតនេះ បានចាប់ផ្តើមនៅ ខែវិច្ឆិកា ដល់ ដើម ខែធ្នូ ឆ្នាំ២០០៨ ។

របាយការណ៍នេះ បង្ហាញពីរបកគំហើញសំខាន់ៗនៃអង្កេតមនុស្សមាត្រកម្ពុជា ឆ្នាំ២០០៨ រួមមាន ពត៌មានប្រជាសាស្ត្រ ស្ថានភាពអាហារូបត្ថម្ភរបស់ស្ត្រី និងកុមារ និងផលប៉ះពាល់នៃថ្លៃម្ហូបអាហារ និងពត៌មាន ទាក់ទងនឹងសុខភាព ដូចជាជម្ងឺ ជាដើម ។

របកគំហើញសំខាន់ៗពីការអង្កេតនេះ នឹងសង្ឃឹមថាត្រូវបានប្រើប្រាស់ដោយអ្នករៀបចំគោលនយោបាយ និងអ្នកធ្វើផែនការនានា ដើម្បីវាយតម្លៃពីលក្ខណៈប្រជាសាស្ត្រ ស្ថានភាពសុខភាព និងស្ថានភាពអាហារូបត្ថម្ភ របស់ស្ត្រី និងកុមារ ដើម្បីបង្កើតនូវគោលនយោបាយប្រជាសាស្ត្រ និងសុខភាព និងកម្មវិធីផ្សេងៗ របស់ប្រទេស កម្ពុជា ។ កម្មវិធីអាហារូបត្ថម្ភស្ត្រី និងកុមារ នឹងត្រូវបានពង្រីកឱ្យប្រសើរឡើងដើម្បីកាត់បន្ថយគំលាតរវាង ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមកិច្ចនៃបណ្តាប្រទេសអាស៊ានផ្សេងទៀត ។

ខ្ញុំសូមវាយតម្លៃខ្ពស់ចំពោះ អង្គការ យូនីសេហ្វ និង អង្គការ យូអិនឌីភី ដែលបានគាំទ្រគម្រោងនេះ ទាំង ថវិកា និងបច្ចេកទេស ។ ខ្ញុំសូមអរគុណចំពោះការខិតខំរបស់ **ឯកឧត្តម អ៊ុក ចាយ** រដ្ឋលេខាធិការ ក្រសួង ផែនការ **ឯកឧត្តម សន ស៊ីថន** អគ្គនាយកវិទ្យាស្ថានជាតិស្ថិតិ **លោកស្រី វិរ៉ូនីកា ម៉ែរដោណ្ណា** ប្រធានកម្មវិធីការរស់រានរបស់កុមារ **លោក តីធំរ ឡេត** និង **លោក អ៊ុន សំអឿន** នៃអង្គការយូនីសេហ្វ និងសមាជិកក្រុមការងារអាហារូបត្ថម្ភ ដទៃទៀត ដែលបានចូលរួមចំណែកក្នុងការ អង្កេតនេះ ។

ខ្ញុំសូមថ្លែងអំណរគុណចំពោះមន្ត្រីទាំងអស់ ដែលបានចូលរួមក្នុងការអនុវត្ត កែច្នៃទិន្នន័យ និងវិភាគ លទ្ធផល និងសរសេររបាយការណ៍នៃការអង្កេតនេះ និងជាពិសេសចំពោះវិទ្យាស្ថានជាតិស្ថិតិ និងអគ្គនាយកដ្ឋាន ផែនការ ដែលបានចូលរួមចំណែកធ្វើឱ្យការអង្កេតនេះ ទទួលបានជោគជ័យ ។

ក្រសួងផែនការ

រាជធានីភ្នំពេញ

ខែ ឧសភា ឆ្នាំ ២០០៩

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រី ក្រសួងផែនការ**

**ឆាយ ថន**

# សេចក្តីថ្លែងអំណរគុណ

អង្កេតមនុស្សមាត្រកម្ពុជា ឆ្នាំ២០០៨ ជាការអង្កេតលើកដំបូងនៅប្រទេសកម្ពុជា ។ ការអង្កេតនេះ ត្រូវបានឧបត្ថម្ភថវិកា និងបច្ចេកទេស ដោយអង្គការ យូនីសេហ្វ និងអង្គការ យូអិនឌីភី ។ ការអង្កេតនេះត្រូវបាន អនុវត្តដោយវិទ្យាស្ថានជាតិស្ថិតិ ក្នុងកិច្ចសហការជាមួយអគ្គនាយកដ្ឋានផែនការ ក្រសួងផែនការ ។ ការអង្កេត នេះ បានជ្រើសរើសគ្រួសារគំរូចំនួន ៨ ០០០ គ្រួសារ ពីភូមិចំនួន ៨០០ ភូមិគំរូ ។ អត្រាឆ្លើយតប គឺប្រមាណជា ៩៨ ភាគរយ ។

ការអនុវត្តការអង្កេតនេះទទួលជោគជ័យ គឺដោយសារសហប្រតិបត្តិការជិតស្និទ្ធ និងការខិតខំរបស់ ស្ថាប័ន និងបុគ្គលិកទាំងអស់ ។ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះ **ឯកឧត្តម ឆាយ ថន** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ និង **ឯកឧត្តម អ៊ុក ចាយ** រដ្ឋលេខាធិការក្រសួងផែនការ ក្នុង ការគាំទ្រ និងលើកទឹកចិត្ត តាំងពីដំណាក់កាលផែនការរហូតដល់ការសរសេររបាយការណ៍លទ្ធផលអង្កេត ។ ខ្ញុំសូមវាយតម្លៃខ្ពស់ចំពោះការរួមចំណែករបស់ **លោកស្រី ទិអ៊ូរីភា ប៉ែរដោហ្គា** ប្រធានកម្មវិធីការរស់រាន របស់កុមារ **លោក ភីធ័រ ឡេត** និង **លោក អ៊ុន សំអឿន** នៃយូនីសេហ្វ លោកទីប្រឹក្សាអង្កេត **លោក ដូអែល កុងឃើល** និងក្រុមការងារវិភាគរបាយការណ៍អង្កេត ។

ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះមន្ត្រីត្រួតពិនិត្យ និងមន្ត្រីសំភាសន៍របស់វិទ្យាស្ថានជាតិស្ថិតិ និងមន្ត្រីរបស់មន្ទីរផែនការរាជធានី ខេត្ត ដែលបានខិតខំធានាឱ្យការអង្កេតនេះ មានគុណភាព និងទាន់ពេលវេលា និងអរគុណចំពោះ អ្នកឆ្លើយដែលបានផ្តល់ព័ត៌មាន សម្រាប់ផលិតទិន្នន័យសំរាប់ប្រទេសជាតិ ។

ជាទីបញ្ចប់ខ្ញុំសូមអរគុណចំពោះក្រុមការងារស្នូលនៃការអង្កេតមកពីវិទ្យាស្ថានជាតិស្ថិតិ និង អគ្គនាយកដ្ឋានផែនការនៃក្រសួងផែនការ ។

**អគ្គនាយកវិទ្យាស្ថានជាតិស្ថិតិ**

រាជធានីភ្នំពេញ

ខែ ឧសភា ឆ្នាំ២០០៩

**សន ស៊ីថន**

## មាតិកាអត្ថបទ


អង្កេតមនុស្សសាស្ត្រកម្ពុជា ២០០៨

បុព្វកថា........................................................................I

សេចក្តីថ្លែងអំណរគុណ........................................................II

មាតិកាអត្ថបទ....................................................................III

ពាក្យសរសេរកាត់..........................................................X

សេចក្តីសង្ខេបអំពីរបកគំហើញ..........................................១

សេចក្តីផ្តើម និងគោលបំណង............................................១៤

ស្ថានភាពទូទៅរបស់អង្កេត...............................................១៩

ជំពូកទី១......................................................................២៥

**បណ្តាសូចនាករសម្រាប់ចាត់ថ្នាក់បន្ទាន់**

១. មនុស្សមាត្រ និងកង្វះមីក្រូសារជាតិ.................................២៦

១.១. មនុស្សមាត្រកុមារ.....................................................២៧

ក. ទម្ងន់ធៀបនឹងកម្ពស់..................................................២៨

ខ. កម្ពស់ធៀបនឹងអាយុ....................................................៣០

គ. ទម្ងន់ធៀបនឹងអាយុ.....................................................៣៣

១.២. មនុស្សមាត្រស្ត្រី.......................................................៤១

១.៣. ស្ត្រីមានផ្ទៃពោះ និងជម្ងឺខ្វាក់មាន់..................................៤៤

២. ជម្ងឺកុមារ.....................................................................៤៥

២.១. ជម្ងឺរលាកផ្លូវដង្ហើម...................................................៤៦

២.២. ជម្ងឺរាក.....................................................................៥១

២.៣. គ្រុនក្តៅ.....................................................................៥៥

៣. យុទ្ធសាស្ត្រដោះស្រាយបន្ទាន់ និងការប្រើប្រាស់អាហារ...............៥៧

៣.១. ទំនាក់ទំនងការប្រើប្រាស់អាហារ និងយុទ្ធសាស្ត្រដោះស្រាយបន្ទាន់.......៥៧

៣.២. ការប្រើប្រាស់អាហារ......................................................៦០

៣.៣. យុទ្ធសាស្ត្រដោះស្រាយបន្ទាន់ផ្សេងៗ......................................៦៦

ជំពូកទី២.....................................................................................៦៩

**ការជ្រើសរើសសូចនាកររបស់ថ្នាក់ក្រោមជាតិ**

១. មនុស្សមាត្រកុមារ.......................................................................៧០

១.១. ថ្នាក់ខេត្ត .........................................................................៧០

១.២. លក្ខណៈប្រវត្តិបន្ថែមផ្សេងៗ ..................................................៧៥

២. មនុស្សមាត្រស្ត្រី .......................................................................៧៩

ថ្នាក់ខេត្ត .........................................................................៧៩

៣. ជម្ងឺកុមារ ...............................................................................៨០

ថ្នាក់ខេត្ត .........................................................................៨០

៤. មនុស្សមាត្រ និងជម្ងឺតាមលំនៅដ្ឋានមិនទាន់រៀបរយ នៅទីក្រុងភ្នំពេញ ........................៨៣

ជំពូកទី៣ ...................................................................................៨៨

**របៀបផ្តល់អាហារបន្ថែមដល់ទារក និងកុមារតូច**

១. ទំហំទារកនៅពេលកើត ...............................................................៨៩

២. ស្ថានភាពបំបៅកូនដោយទឹកដោះម្តាយ និងការផ្តល់អាហារបន្ថែម ..................៩១

ជំពូកទី៤ ...................................................................................៩៦

**សេវាសុខភាពអាហារូបត្ថម្ភ**

១. ការផ្តល់បន្ថែមគ្រាប់ថ្នាំជីវជាតិអា ដល់កុមារ និងការទំលាក់ព្រូនសម្រាប់កុមារ .....៩៧

២. ការផ្តល់បន្ថែមគ្រាប់ថ្នាំជាតិដែក ដល់មាតា និងការទំលាក់ព្រូនសម្រាប់ស្ត្រីកំឡុងពេលមានផ្ទៃពោះ និងការផ្តល់បន្ថែមគ្រាប់ថ្នាំជីវជាតិអា ក្រោយពេលសម្រាល ...........៩៩

៣. ការពិនិត្យផ្ទៃពោះ មុនពេលសម្រាល ..........................................១០៣

៤. ការប្រើប្រាស់អំបិលអ៊ីយ៉ូដតាមគ្រួសារ .............................................១០៤

ជំពូកទី៥ .................................................................................១០៦

**សេចក្តីសន្និដ្ឋាន និងអនុសាសន៍**

ជំពូកទី៦ ..........................................................................១១៧

**វិធីសាស្ត្រធ្វើអង្កេត**

ឯកសារយោង ..........................................................................១២៧

ឧបសម្ព័ន្ធ ..........................................................................១៣០

ឧបសម្ព័ន្ធទី១ : រជ្ជូវកាល ..........................................................................១៣១

ជម្ងឺកុមារតាមខែនិមួយៗ

មនុស្សមាត្រស្ត្រី និងកុមារតាមខែនិមួយៗ

ឧបសម្ព័ន្ធទី២ : ការគណនាឡើងវិញតាមវិធីសាស្ត្ររបស់ CDHS ........................១៣៦

មនុស្សមាត្រកុមារឆ្នាំ២០០០

មនុស្សមាត្រកុមារឆ្នាំ២០០៥

ជម្ងឺកុមារ

ឧបសម្ព័ន្ធទី៣ : បញ្ជីមន្ត្រីចូលរួមការអង្កេតមនុស្សមាត្រកម្ពុជា ២០០៨ ..................១៤៤

ឧបសម្ព័ន្ធទី៤ : កម្រងសំណួរអង្កេតមនុស្សមាត្រកម្ពុជា ២០០៨ .........................១៤៨

បញ្ជីតារាង

ក.ម៉ាទ្រីសផែនការសម្រាប់អង្កេត ........................................................................២៥
តារាងលេខ ១ : សូចនាការអាហារូបត្ថម្ភតាមរយៈកម្រិតទ្រព្យធនធានសម្បត្តិ .....................២៨
តារាងលេខ ២ : ទម្ងន់ធៀបនឹងកម្ពស់របស់កុមារដែលមានអាយុចាប់ពី ០ ទៅ ៥៩ ខែ ............២៩
តារាងលេខ ៣ : កម្ពស់ធៀបនឹងអាយុរបស់កុមារដែលមានអាយុចាប់ពី ០ ទៅ ៥៩ ខែ ............៣១
តារាងលេខ ៤ : ទម្ងន់ធៀបនឹងអាយុរបស់កុមារដែលមានអាយុចាប់ពី ០ ទៅ ៥៩ ខែ .............៣៤
តារាងលេខ ៥ : សូចនាករមនុស្សមាត្ររបស់មាតា ..................................................៤២
តារាងលេខ ៦ : ជម្ងឺខ្វាក់មាន់របស់មាតា .....................................................................៤៤
តារាងលេខ ៧ : រោគសញ្ញាជម្ងឺរលាកផ្លូវដង្ហើមរបស់កុមារតាមរូបមន្ត ឆ្នាំ២០០៥ .................៥០
តារាងលេខ ៨ : ស្ថានភាពជម្ងឺរាករបស់កុមារ .....................................................៥៤
តារាងលេខ ៩ : ស្ថានភាពគ្រុនក្តៅរបស់កុមារ ......................................................៥៦
តារាងលេខ ១០ : ការប្រើប្រាស់អាហាររបស់កុមារដែលមានអាយុចាប់ពី ៦ ទៅ ៣៥ ខែ ..........៦៤
តារាងលេខ ១១ : ការប្រើប្រាស់អាហាររបស់មាតាដែលមានអាយុចាប់ពី ១៥ ទៅ ៤៩ ឆ្នាំ ........៦៥
តារាងលេខ ១២ : ភាគរយគ្រួសារប្រើប្រាស់យុទ្ធសាស្ត្រដោះស្រាយបញ្ហាបន្ទាន់ចំពោះមុខ អំឡុងពេល ៣០ ថ្ងៃ មុនអង្កេតដោយអង្កេតមនុស្សមាត្រកម្ពុជា ឆ្នាំ២០០៨ .................៦៨
តារាងលេខ ១៣ : មនុស្សមាត្រកុមារតាមខេត្ត-ក្រុង ..................................................៧១
តារាងលេខ ១៤ : មនុស្សមាត្រកុមារតាមប្រភេទការងាររបស់ឪពុក ...............................៧៦
តារាងលេខ ១៥ : មនុស្សមាត្រកុមារតាមប្រភេទការងាររបស់ម្តាយ ...............................៧៦
តារាងលេខ ១៦ : មនុស្សមាត្រកុមារតាមប្រភេទកម្មសិទ្ធិកាន់កាប់ដីស្រែចំការ ....................៧៧
តារាងលេខ ១៧ : មនុស្សមាត្រកុមារតាមប្រភេទផលិតកម្មអង្ករ .................................៧៨
តារាងលេខ ១៨ : មនុស្សមាត្រកុមារតាមការបកស្រាយពីបញ្ហាកង្វះថវិកា ........................៧៨
តារាងលេខ ១៩ : មនុស្សមាត្រមាតាតាមខេត្ត-ក្រុងចែកតាមតំបន់ ................................៧៩
តារាងលេខ ២០ : រោគសញ្ញារលាកផ្លូវដង្ហើមរបស់កុមារតាមខេត្ត-ក្រុងចែកតាមតំបន់ ............៨០
តារាងលេខ ២១ : ជម្ងឺរាករបស់កុមារតាមខេត្ត-ក្រុងចែកតាមតំបន់ ................................៨១
តារាងលេខ ២២ : គ្រុនក្តៅរបស់កុមារតាមខេត្ត-ក្រុងចែកតាមតំបន់ ..............................៨២
តារាងលេខ ២៣ : មនុស្សមាត្រកុមារតាមលំនៅដ្ឋានមិនទាន់រៀបរយនានានៅទីក្រុងភ្នំពេញ ......៨៤
តារាងលេខ ២៤ : មនុស្សមាត្រមាតាតាមលំនៅដ្ឋានមិនទាន់រៀបរយនានានៅទីក្រុងភ្នំពេញ ......៨៥
តារាងលេខ ២៥ : ជម្ងឺរបស់កុមារតាមលំនៅដ្ឋានមិនទាន់រៀបរយនានានៅទីក្រុងភ្នំពេញ .........៨៥

តារាងលេខ ២៦ : ការប្រើប្រាស់អាហាររបស់កុមារតាមលំនៅដ្ឋានមិនទាន់រៀបរយនានា
នៅទីក្រុងភ្នំពេញ ....................................................................៨៧
តារាងលេខ ២៧ : ទំហំរបស់ទារក តាមលក្ខណៈជីវប្រវត្តិផ្សេងៗ ...................................៩០
តារាងលេខ ២៨ : ស្ថានភាពនៃការចិញ្ចឹមកូនដោយទឹកដោះម្តាយ និងអាហារ .......................៩២
តារាងលេខ ២៩ : ស្ថានភាពនៃការចិញ្ចឹមកូនដោយទឹកដោះម្តាយ និងអាហារតាមទីកន្លែងរស់នៅ ៩៤
តារាងលេខ ៣០ : ស្ថានភាពនៃការចិញ្ចឹមកូនដោយទឹកដោះម្តាយ និងអាហារ តាមបណ្តា
លំនៅដ្ឋានមិនទាន់រៀបរយនានានៅទីក្រុងភ្នំពេញ ...............................៩៥
តារាងលេខ ៣១ : សេវាសុខភាពសម្រាប់កុមារតាមលក្ខណៈប្រវត្តិផ្សេងៗ ..........................៩៨
តារាងលេខ ៣២ : សេវាសុខភាពសម្រាប់មាតាតាមលក្ខណៈប្រវត្តិផ្សេងៗ ........................១០១
តារាងលេខ ៣៣ : ចំនួនស្ត្រីដែលបានទៅពិនិត្យថៃទាំផ្ទៃពោះមុនពេលសម្រាល ...................១០៣
តារាងលេខ ៣៤ : ការប្រើប្រាស់អំបិលអ៊ីយ៉ូដតាមលក្ខណៈគ្រួសារ ................................១០៥
តារាងលេខ ៣៥ : នីតិវិធីនៃការចាត់ចំណាត់ថ្នាក់ចូលទៅក្នុងកង្វះអាហារូបត្ថមតាមដំណាក់កាលនីមួយ
និងរបកគំហើញរបស់អង្កេតមនុស្សមាត្រកម្ពុជា ឆ្នាំ២០០៨ ...................១០៩

បញ្ជីរូបភាព

រូបភាពលេខ ១ : និន្នាការប្រែប្រួលកង្វះអាហារូបត្ថម្ភនៃភាពស្គមរបស់កុមារ ......................៣០
រូបភាពលេខ ២ : និន្នាការប្រែប្រួលកង្វះអាហារូបត្ថម្ភនៃភាពក្រិនរបស់កុមារ .....................៣២
រូបភាពលេខ ៣ : និន្នាការប្រែប្រួលកង្វះអាហារូបត្ថម្ភរបស់កុមារកង្វះទម្ងន់ .......................៣៥
រូបភាពលេខ ៤ : និន្នាការប្រែប្រួលកង្វះអាហារូបត្ថម្ភរបស់កុមារក្នុងខែដូចគ្នា .....................៣៦
រូបភាពលេខ ៥ : និន្នាការប្រែប្រួលកង្វះអាហារូបត្ថម្ភរបស់កុមារតាមតំបន់រស់នៅ ................៣៧
រូបភាពលេខ ៦ : និន្នាការប្រែប្រួលកង្វះអាហារូបត្ថម្ភរបស់កុមារតាមតំបន់រស់នៅ និងធនធានគ្រួសារ ...............................................................................................................៣៨
រូបភាពលេខ ៧ : និន្នាការប្រែប្រួលកង្វះអាហារូបត្ថម្ភរបស់កុមារកង្វះទម្ងន់តាមអាយុ .............៣៩
រូបភាពលេខ ៨ : កុមារកង្វះទម្ងន់តាមអាយុ .....................................................................៤០
រូបភាពលេខ ៩ : និន្នាការប្រែប្រួលកង្វះអាហារូបត្ថម្ភរបស់កុមារស្គមតាមអាយុ ....................៤១
រូបភាពលេខ ១០ : និន្នាការប្រែប្រួលមនុស្សមាត្ររបស់មាតា ..............................................៤៣
រូបភាពលេខ ១១ : និន្នាការប្រែប្រួលប្រេវ៉ាឡង់ជម្ងឺខ្វាក់មាន់របស់មាតា ..............................៤៥
រូបភាពលេខ ១២ : សំណូរកំណត់រោគសញ្ញាជម្ងឺរលាកផ្លូវដង្ហើមរបស់កុមារ តាមអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ឆ្នាំ២០០៥ ..................................................៤៧
រូបភាពលេខ ១៣ : និន្នាការប្រែប្រួលរោគសញ្ញាជម្ងឺរលាកផ្លូវដង្ហើមរបស់កុមារតាម រូបមន្តគណនា ឆ្នាំ២០០០......................................................៤៨
រូបភាពលេខ ១៤ : និន្នាការប្រែប្រួលរោគសញ្ញាជម្ងឺរលាកផ្លូវដង្ហើមរបស់កុមារតាម រូបមន្តគណនា ឆ្នាំ២០០៥ ......................................................៤៩
រូបភាពលេខ ១៥ : និន្នាការប្រែប្រួលរោគសញ្ញាជម្ងឺរលាកផ្លូវដង្ហើមរបស់កុមារក្នុងខែតែមួយ .....៥១
រូបភាពលេខ ១៦ : និន្នាការប្រែប្រួលជម្ងឺរាករបស់កុមារ ..................................................៥៣
រូបភាពលេខ ១៧ : និន្នាការប្រែប្រួលរបស់កុមារកើតគ្រុនក្តៅ ............................................៥៥
រូបភាពលេខ ១៨ : និន្នាការប្រែប្រួលក្នុងការប្រើប្រាស់យុទ្ធសាស្ត្រដោះស្រាយបញ្ហាបន្ទាន់ ដែលទាក់ទងនឹងអាហារ ......................................................៥៩
រូបភាពលេខ ១៩ : និន្នាការប្រែប្រួលក្នុងការប្រើប្រាស់អាហាររបស់កុមារ ..........................៦២
រូបភាពលេខ ២០ : និន្នាការប្រែប្រួលក្នុងការប្រើប្រាស់អាហាររបស់កុមារ និងម្តាយ .............៦៣
រូបភាពលេខ ២១ : យុទ្ធសាស្ត្រនានាដែលមិនទាក់ទងនឹងអាហារ ........................................៦៧
រូបភាពលេខ ២២ : ចំនួនកុមារកង្វះទម្ងន់ដែលមានអាយុក្រោម ៥ ឆ្នាំ តាមខេត្ត-ក្រុង ...........៧២

រូបភាពលេខ ២៣ : ចំនួនកុមារស្គមដែលមានអាយុក្រោម ៥ ឆ្នាំ តាមខេត្ត-ក្រុង...................៧៣
រូបភាពលេខ ២៤ : ចំនួនកុមារក្រិនដែលមានអាយុក្រោម ៥ ឆ្នាំតាមខេត្ត-ក្រុង ...................៧៣
រូបភាពលេខ ២៥ : និន្នាការប្រែប្រួលមនុស្សមាត្រកុមារតាមខេត្តរបស់តំបន់ឆ្នេរ និងបឹងទន្លេសាប៧៤
រូបភាពលេខ ២៦ : និន្នាការប្រែប្រួលមនុស្សមាត្រកុមារតាមខេត្តរបស់តំបន់ទំនាប ភ្នំ និងខ្ពង់រាប..៧៥
រូបភាពលេខ ២៧ : ស្ថានភាពបំបៅកូនដោយទឹកដោះម្ដាយនាពេលបច្ចុប្បន្នសម្រាប់ កុមារអាយុ
តិចជាងគេគិតជាអាយុតាមខែដោយអង្កេតមនុស្សមាត្រកម្ពុជា ឆ្នាំ២០០៨ ......៩៣

## ពាក្យសរសេរកាត់

| | |
|---|---|
| ផ.ផ.ស | ផលិតផលក្នុងស្រុកសរុប |
| ក្រ.ផ.ក | ក្រសួងផែនការ |
| វ.ជ.ស | វិទ្យាស្ថានជាតិស្ថិតិ |
| អ.ប្រ.ស.ក | អង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា |
| អ.ស.ស.ក | អង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា |
| ធ.អ.ជ | ធនាគារអភិវឌ្ឍន៍ជនបទ |
| ធ.អ.អ | ធនាគារអភិវឌ្ឍន៍អាស៊ី |
| ស.អ | សហគមន៍អឺរ៉ុប |
| ស.ស.រ | សន្ទស្សន៍មាឌរាងកាយ |
| ម.ជ.គ.ម.ទ | មជ្ឈមណ្ឌលជាតិគាំពារមាតា និង ទារក |
| ម.ក.អ.ស | មូលនិធិអង្គការសហប្រជាជាតិដើម្បីកុមារ |

# សេចក្តីសង្ខេប

អង្កេតមនុស្សមាត្រកម្ពុជា ឆ្នាំ២០០៨ ជាតំណាងថ្នាក់ជាតិដែលមានគំរូចំនួន ៧៤៩៥ គ្រួសារ និងមានកុមារអាយុពី ០ ទៅ ៥៩ ខែ ។ ការអង្កេតមាន ១៩ តំបន់ ឬទីកន្លែងនៅទូទាំងប្រទេស ។ អង្កេតមនុស្សមាត្រកម្ពុជា ឆ្នាំ២០០៨ រួមមានកុមារជាងប្រាំពីរពាន់នាក់ ដែលជាតំណាងថ្នាក់ជាតិដ៏ធំ ដែលមានរង្វាស់មនុស្សមាត្រទាំងស្ត្រី និងកុមារនៅទូទាំងប្រទេស ។ គោលបំនងចម្បងនៃការធ្វើអង្កេត គឺដើម្បីផ្តល់ព័ត៌មានជូនដល់អ្នកធ្វើនយោបាយ និងអ្នកធ្វើផែនការ ស្តីពីព័ត៌មាននៃស្ថានភាពអាហារូបត្ថម្ភក្នុងបរិបទការឡើងថ្លៃខ្ពស់នៃស្បៀងអាហារ ។ បន្ទាប់មកដើម្បីសិក្សាឱ្យបានស៊ីជម្រៅនូវទិន្នន័យដែលបានពីមនុស្សមាត្រក្នុងប្រទេស ដូចជា : បញ្ហាកង្វះមីក្រូសារជាតិ ការប្រើប្រាស់ចំណីអាហារ ជម្ងឺ យុទ្ធសាស្រ្តដោះស្រាយបន្ទាន់ ការផ្តល់អាហារបន្ថែមដល់ទារក និងកុមារតូច និងសេវាសុខភាព ត្រូវបានដាក់ចូលទៅក្នុងអង្កេត ។ ជាងនេះទៅទៀត អង្កេតថ្នាក់ជាតិបានជ្រើសរើសយកតំណាង ៤០០ គ្រួសារ បន្ថែមទៀតដែលរស់នៅក្នុងលំនៅដ្ឋានមិនទាន់រៀបរយនាទីក្រុងភ្នំពេញធ្វើជាគំរូដោយប្រើប្រាស់នូវវិធីសាស្រ្ត និងតារាងសំណួរដូចគ្នាទៅនឹងអង្កេតថ្នាក់ជាតិ ។

## មនុស្សមាត្រកុមារ

សូចនាករមនុស្សមាត្រកុមារ (ចំពោះកុមារដែលមានអាយុចាប់ពី ០ ទៅ ៥៩ ខែ) ដូចជា : កម្ពស់ ទម្ងន់ និងអាយុ ត្រូវបានដាក់បញ្ចូលក្នុងការអង្កេតនេះ ។ មានន័យថា អង្កេតវាស់នូវសូចនាករមនុស្សមាត្រកុមារទាំងអស់ ហើយត្រូវមានលក្ខណៈសមស្របទៅតាមការចង់បានរបស់អង្កេត ។ ការវាស់កម្ពស់ និងថ្លឹងទម្ងន់កុមារដែលទាញចេញពីអង្កេតនេះ គឺសម្រាប់ធ្វើការប្រៀបធៀបទៅនឹងសុខភាពកុមារអន្តរជាតិដែលបានចងក្រង និងណែនាំដោយអង្គការសុខភាពពិភពលោក (WHO) ២០០៦ ។

នៅក្នុងពាក់កណ្តាលទសវត្សមុន យើងឃើញមាននូវការរីកចម្រើនជាច្រើនលើស្ថានភាពអាហារូបត្ថម្ភរបស់កុមារ តាមរយៈលទ្ធផលនៃការអង្កេតប្រជាសាស្រ្ត និងសុខភាព ។ ប៉ុន្តែស្ថានភាពអាហារូបត្ថម្ភគ្រប់សូចនាករទាំងអស់របស់កុមារ ពុំសូវមានការប្រែប្រួលល្អប៉ុន្មានទេចាប់ពីឆ្នាំ២០០៥មក លើកលែងតែសូចនាករដែលវាស់វែងនូវការប្រែប្រួលរយៈពេលយូរប៉ុណ្ណោះ ដែលស្ថិតនៅក្នុងផ្លូវវិជ្ជមាន ។ តាមការប៉ាន់ស្មានចំនួនកុមារមានអាហារូបត្ថម្ភខ្សត់ខ្សោយក្នុងសេចក្តីសង្ខេបនេះ រួមបញ្ចូលទាំងស្ថានភាពអាហារូបត្ថម្ភខ្សត់ខ្សោយជាមធ្យម និងធ្ងន់ធ្ងរព្រមជាមួយគ្នា ។

សូចនាករដែលឆ្លើយតបនឹងរយៈពេលខ្លីក្នុងការប្រែប្រួល គឺភាពស្គមស្គាំង (ទម្ងន់ធៀបនឹងកម្ពស់) ។ ពីឆ្នាំ២០០០-២០០៥ ភាពស្គមរបស់កុមារនៅក្នុងប្រទេសកម្ពុជាមានការថយចុះចំនួន ១.៧ អត្រាភាគរយ ក្នុង ១ ឆ្នាំ ដោយចុះពី ១៦.៨ ភាគរយ មកនៅត្រឹម ៨.៤ ភាគរយ ។ លទ្ធផលការអង្កេត មនុស្សមាត្រកម្ពុជាឆ្នាំ២០០៨ បានបង្ហាញថា កុមារស្គមទូទាំងប្រទេសមានចំនួន ៨.៩

ភាគរយ ។ គួរបញ្ជាក់ថាការរីកចម្រើនថ្នាក់ជាតិ ចំពោះស្ថានភាពអាហារូបត្ថម្ភបច្ចុប្បន្នរបស់កុមារ បាននៅទ្រឹង និងពុំមានការប្រែប្រួលជាក់លាក់ណាមួយទេក្នុងន័យស្ថិតិ ចាប់តាំងពីឆ្នាំ២០០៥ មក ។ ជាលទ្ធផល សមាមាត្ររបស់កុមារស្គមមានចំនួនច្រើនជាង ៤ ដង ធៀបនឹងកុមារដែលត្រូវបានរកឃើញថាមានសុខភាពល្អ ។

កង្វះទម្ងន់ (ទម្ងន់ធៀបនឹងអាយុ) គឺឆ្លើយតបទៅនឹងការផ្លាស់ប្តូររយៈពេលខ្លី និងវែង ។ ពីឆ្នាំ ២០០០ ទៅ ឆ្នាំ២០០៥ កុមារកង្វះទម្ងន់បានថយចុះចំនួន ២.១ អត្រាភាគរយ ក្នុងមួយឆ្នាំ គឺចាប់ពី ៣៨.៤ ភាគរយ ទៅ ២៨.២ ភាគរយ ។ យ៉ាងណាមិញ លទ្ធផលនៃការអង្កេតមនុស្សមាត្របង្ហាញថា អត្រាកង្វះទម្ងន់ ដូចគ្នានឹងអត្រាភាពស្គមដែរ គឺមិនមានការប្រែប្រួលគួរឱ្យកត់សម្គាល់ទេ តាំងពីឆ្នាំ ២០០៥ មក (២៨.៨ ភាគរយ) ។ សមាមាត្រកុមារកង្វះទម្ងន់មានចំនួនជិត ១៣ ដង ខ្ពស់ជាងកុមារដែលមានសុខភាពល្អ។

ភាពគ្រិន (កម្ពស់ធៀបនឹងអាយុ) ប្រសិនបើក្មេងមានកម្ពស់ទាបធៀបនឹងអាយុរបស់ពួកគេ ។ ភាពគ្រិនមិនបានឆ្លើយតបទៅនឹងបុព្វហេតុបម្រែបម្រួលរយៈពេលខ្លីនោះទេ ។ អត្រាភាពគ្រិន គឺជាប្រភពមួយដ៏សំខាន់បង្ហាញនូវភាពរីកចម្រើនផ្នែកស្ថានភាពអាហារូបត្ថម្ភរបស់កុមារ ។ ចន្លោះពីឆ្នាំ ២០០០ ទៅឆ្នាំ២០០៥ ភាគរយនៃកុមារគ្រិនក្នុងប្រទេសកម្ពុជា បានថយចុះចំនួន ១.៣ អត្រាភាគរយក្នុងមួយឆ្នាំ ថយពី ៤៩.៧ ភាគរយ មកត្រឹម ៤៣.៣ ភាគរយ ។ ចំណែកលទ្ធផលការអង្កេតមនុស្សមាត្រ ឆ្នាំ២០០៨ បានបង្ហាញពីភាពគ្រិនរបស់កុមារមានចំនួន ៣៩.៥ ភាគរយ ។ ការធ្លាក់ចុះនេះបង្ហាញថា អត្រាគ្រិនកាន់តែប្រសើរឡើងជាងមុន ទោះជាវាមានភាពយឺតយ៉ាវនៅឡើយ ។ យ៉ាងណាមិញ សមាមាត្រភាពគ្រិននៅតែច្រើន គឺខ្ពស់ជាង ១៧ ដង ធៀបនឹងចំនួនកុមារដែលមានសុខភាពល្អ ។

ភាពយឺតយ៉ាវនៃការរីកចម្រើនសូចនាករស្គម និងកង្វះទម្ងន់ គឺជាករណីគួរឱ្យចាប់អារម្មណ៍ ។ អង្កេតធ្វើនៅក្នុងពេលវេលាខុសគ្នាត្រូវបានយកមកពិចារណា ក្នុងពេលធ្វើការវិភាគ ។ ប៉ុន្តែពេលវេលានៃការធ្វើអង្កេតនេះ មិនបានបង្កើតជាផលប៉ះពាល់ខ្លាំង ដល់ការងារព្យាករណ៍អំពីភាពខ្សត់ខ្សោយអាហារូបត្ថម្ភនោះទេ ។ លក្ខណៈវិនិច្ឆ័យមួយរបស់ International Phase Classification (IPC) សម្រាប់ការវាស់វែងលើវិបត្តិស្បៀងអាហារ និងការរស់នៅបង្ហាញថា កុមារស្គមដែលមានអាយុក្រោម ៥ ឆ្នាំ មានចំនួនច្រើនជាង ១០ ភាគរយ គឺខ្ពស់ជាងចំនួនធម្មតា និងខ្ពស់ជាងកម្រិតនៃការកើនឡើង ។ នៅថ្នាក់ជាតិ យើងមិនបានដឹងថាភាគរយកុមារស្គមកំពុងកើនឡើងពិតប្រាកដនោះទេ ពីព្រោះអង្កេតមនុស្សមាត្រធ្វើការប្រៀបធៀបតែជាមួយកម្រិតវិជ្ជមាននាឆ្នាំ២០០៥ ប៉ុណ្ណោះ ។ ប៉ុន្តែ យើងបានសន្និដ្ឋានថា កម្រិតរីកចម្រើនអាចកើតមានយ៉ាងពិតប្រាកដមុនពេលដែលវិបត្តិថ្លៃម្ហូបអាហារខ្ពស់ បានមកដល់នាឆ្នាំ ២០០៨ ។ ការរីកចម្រើនទំនងត្រូវបានកាត់បន្ថយ ឬធ្លាក់ចុះនៅតាមតំបន់មួយចំនួនរវាង

ឆ្នាំ ២០០៥ និងឆ្នាំ២០០៨ ។ ជាក់ស្តែង អត្រាកុមារស្គមនៅតាមតំបន់ទីប្រជុំជនក្រីក្របានកើនឡើងពី ៩.៦ ភាគរយ ទៅជិត ១៦ ភាគរយ ។

ទោះបីជាអត្រាភាពស្គមបានកើនឡើងច្រើននៅតាមតំបន់ទីប្រជុំជនក្រីក្រក៏ពិតមែន ប៉ុន្តែអត្រាកុមារស្គមរវាងតំបន់ទីប្រជុំជន និងតំបន់ជនបទមិនមានភាពខុសគ្នាទេ ជាទូទៅប្រហែល ៩ ភាគរយ ។ កុមារខ្វះទម្ងន់ និងកុមារក្រិនសរុបមានប្រហែលជា ១០ អត្រាភាគរយ ខ្ពស់ជាងនៅទីជនបទ ។ ប៉ុន្តែភាគរយនៅតំបន់ទីប្រជុំជន ក៏មានអត្រាខ្ពស់គួរសមដែរ ។ ប៉ុន្តែគួរបញ្ជាក់ថា ភាពក្រីក្រមិនមែនជាមូលហេតុតែមួយគត់បណ្តាលឱ្យមានអាហារូបត្ថម្ភខ្សត់ខ្សោយនោះទេ ។ សូម្បីតែកុមារដែលរស់នៅជាមួយគ្រួសារមានកម្រិតទ្រព្យសម្បត្តិស្តុកស្តម្ភ ក៏ជួបនូវបញ្ហាកង្វះអាហារូបត្ថម្ភដែរ (សូចនាករនានារបស់កុមារ) ។ បើធៀបទៅនឹងកុមារដែលមានសុខភាពល្អបរិបូណ៌ កុមាររស់នៅជាមួយគ្រួសារដែលមានទ្រព្យសម្បត្តិច្រើនជាងគេ ក៏សមាមាត្រកុមារក្រិនមានប្រហែលជា ១២ ដង ( ២៨.៦ ភាគរយ) ច្រើនជាង ៨ដង ចំពោះកុមារខ្វះទម្ងន់ (១៩.៣ ភាគរយ) និង ៤ ដង ចំពោះកុមារស្គម (៨.៩ ភាគរយ) ។ កុមារដែលឪពុកម្តាយមានការងារធ្វើជាលក្ខណៈអាជីពបង្ហាញនូវអាហារូបត្ថម្ភ ប្រសើរជាងកុមារដែលមានឪពុកម្តាយជាកសិករ និងពលករ ។ ក្នុងផ្នែកនេះដដែល ភាគរយរបស់កុមារក្រិនមានចំនួន ២៨.២ ភាគរយ កុមារកង្វះទម្ងន់ ១៩.៩ ភាគរយ និងកុមារស្គមមាន ៦.២ ភាគរយ ធៀបនឹងកុមារដែលមានសុខភាពល្អបរិបូណ៌ ។

អង្កេតមនុស្សមាត្រកម្ពុជា ឆ្នាំ២០០៨ ព្រមគ្នា និងការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ឆ្នាំ២០០៥ ចែកចេញជា ១៩ តំបន់ ក្នុងនោះមានខេត្តមួយចំនួនត្រូវបានបញ្ចូលគ្នាទៅជាតំបន់ ។ ដូចដែលបានរំពឹងទុក អាហារូបត្ថម្ភកុមារមានភាពប្រសើរនៅទីក្រុងភ្នំពេញ ។ ប៉ុន្តែកុមារស្គមនៅក្នុងតំបន់មិនទាន់រៀបរយនាទីក្រុងភ្នំពេញមានចំនួន ៨.៦ ភាគរយ ។ ចំនួននេះ ខ្ពស់ជាងនៅតាមខេត្តមួយចំនួន ក៏ដូចជាថ្នាក់ជាតិជាមធ្យម ជាទូទៅមានចំនួនខុសគ្នា ២ ទៅ ៣ អត្រាភាគរយ ។ នៅគ្រប់តំបន់ទាំងអស់របស់អង្កេតថ្នាក់ជាតិ កុមារក្រិនមានចំនួនជាង ៣០ ភាគរយ និងកុមារខ្វះទម្ងន់មានមួយភាគប្រាំ លើកលែងតែតំបន់ភ្នំពេញចេញប៉ុណ្ណោះ ។ តំបន់ចំនួន ១៥ ក្នុងចំណោមតំបន់ទាំង ១៩ ទូទាំងប្រទេស អត្រាភាពស្គមសរុបមានចំនួន ១០ភាគរយ ។ នៅខេត្តបន្ទាយមានជ័យ មានអត្រាកុមារស្គមខ្ពស់ជាងគេ ១១.៧ ភាគរយ ប៉ុន្តែពុំសូវមានភាពខុសប្លែកគ្នាខ្លាំងពីបណ្តាតំបន់ផ្សេងៗទៀតទេ ។ ខេត្តកំពង់ចាម មានចំនួនកុមារខ្សត់ខ្សោយអាហារូបត្ថម្ភខ្ពស់ជាងគេ ។ ការប៉ាន់ស្មានរបស់អង្កេតមនុស្សមាត្រ ឆ្នាំ២០០៨ បង្ហាញថា កុមារស្គមស្គាំងមានចំនួនប្រហែល ១៨.០០០នាក់ កុមារខ្វះទម្ងន់ ៥៤.០០០នាក់ និងកុមារក្រិនមានចំនួន ៦៨.០០០នាក់ ។ ខេត្តកំពង់ចាម និងខេត្តតាមតំបន់ផ្សេងទៀត

មានចំនួនកុមារខ្សត់ខ្សោយអាហារូបត្ថម្ភខ្ពស់គួរឱ្យកត់សម្គាល់ ។ រីឯខេត្តសៀមរាប និងខេត្តកណ្តាល ក៏ជាតំបន់ដែលមានតួលេខខ្ពស់គួរសមដែរ ។

ការប្រៀបធៀបស្ថានភាពអាហារូបត្ថម្ភរបស់កុមារ តាមកម្រិតធនធាន លក្ខណៈប្រវត្តិរបស់ឪពុកម្តាយ និងតំបន់ដែលកុមារកំពុងរស់នៅ បានបង្ហាញថា អាហារូបត្ថម្ភជាបញ្ហារបស់ជាតិ មានឥទ្ធិពលលើគ្រប់វិស័យទាំងអស់របស់សង្គម ។ នេះបញ្ជាក់ឱ្យឃើញថា ចរិកា ឬក៏លទ្ធភាពទិញអាហារមិនបានគ្រប់គ្រាន់ និងភាពក្រីក្រ មិនមែនជាកត្តាសំខាន់ជាងគេនោះទេ សម្រាប់ហេតុផលបញ្ហាកង្វះមីក្រូសារជាតិ ។ ប្រសិនណាបើវិធីសាស្ត្រចិញ្ចឹម និងរបៀបថែទាំកុមារមិនបានត្រឹមត្រូវ និងមិនខានដិតដល់ ក៏ត្រូវបានគិតថាជាកត្តាសំខាន់ដូចគ្នាផងដែរ ក្នុងការចូលរួមចំណែកបង្កឱ្យក្រុមកុមារខ្លះ ជួបនូវបញ្ហាអាហារូបត្ថម្ភខ្សត់ខ្សោយ ។

## ស្ថានភាពអាហារូបត្ថម្ភរបស់មាតា

សម្រាប់មនុស្សមាត្រស្ត្រី អង្កេតមនុស្សមាត្រកម្ពុជា ឆ្នាំ២០០៨ រួមបញ្ចូលនូវសូចនាករសំខាន់ចំនួនពីរ គឺរង្វាស់កម្ពស់ និងសន្ទស្សន៍មាឌរាងកាយ ។ សូចនាករទាំងពីរនេះ ត្រូវបានយកមកប្រើប្រាស់ដើម្បីតាមដានស្ថានភាពអាហារូបត្ថម្ភរបស់ស្ត្រី ។ ជារួម ការអង្កេតនេះរួមបញ្ចូលតែ ***ស្ត្រីណាដែលជាម្តាយរបស់កុមារដែលមានអាយុចាប់ពី ០ ទៅ ៥៩ ខែ ប៉ុណ្ណោះក្នុងគ្រួសារ*** ។ ការវិភាគលើមនុស្សមាត្រស្ត្រីនេះ គឺមានលក្ខណៈខុសប្លែកគ្នាពីការវិភាគលើមនុស្សមាត្រកុមារដែលមានអាយុក្រោម ៥ឆ្នាំ ពីព្រោះតែការប្រែប្រួលផ្នែកតំណពូជរបស់មនុស្សពេញវ័យ ។ ហេតុនេះ ចំនុចដែលត្រូវបានចាត់ទុកថាស្ត្រីណាស្គម ឬទាបជាខ្នាតអន្តរជាតិ ត្រូវបានកំណត់ឱ្យទាបបំផុត ខុសពីកុមារ ។

គ្រប់ស្ត្រីទាំងឡាយដែលមានកម្ពស់ទាបជាង ១៤៥ សង់ទីម៉ែត្រ សន្មត់ថាជាស្ត្រីដែលមានកម្ពស់ទាប ។ អង្កេតមនុស្សមាត្រ ឆ្នាំ២០០៨ បានឱ្យដឹងថា មាតាដែលមានកម្ពស់ទាបជាង ១៤៥ សង់ទីម៉ែត្រ មាន ចំនួន ៦.៣ ភាគរយ ។ តួលេខនេះ មានអត្រាភាគរយប្រហែល ១ ទាបជាងភាគរយដែលគណនាដោយ អ.ប្រ.ស.ក ២០០៥ (៧.៧ ភាគរយ)។ គួរបញ្ជាក់ថា អត្រាភាគរយខុសគ្នាចំនួន ១ មិនមានន័យសំខាន់ឡើយក្នុងអត្ថន័យស្ថិតិ ។ ស្ត្រីប្រហែល ១០ ភាគរយ ដែលមានអាយុចន្លោះពី ១៥ ដល់ ១៩ ឆ្នាំ មានកម្ពស់ទាប ។ ក្នុងពេលនេះដែរ ស្ត្រីពេញវ័យកំពុងមានផ្ទៃពោះចំនួន ២.៤ ភាគរយ ត្រូវបានរកឃើញថាមានកម្ពស់ទាប ។ បើយើងក្រលេកមើលតួលេខរបស់ស្ត្រីនៅតាមខេត្តវិញ កម្ពស់ទាបពុំមានការខុសប្លែកគ្នាគួរឱ្យកត់សម្គាល់នោះទេ លើកលែងតែតំបន់ដាច់ស្រយាលរបស់ខេត្តមួយចំនួនប៉ុណ្ណោះ ។ ខេត្តមណ្ឌលគីរី និងរតនៈគីរីមានចំនួនស្ត្រីទាបចំនួន ១៦.១ ភាគរយ ខ្ពស់ជាងជិត ៣ ដង

ធៀបនឹងថ្នាក់ជាតិជាមធ្យម ។ ខេត្តស្ទឹងត្រែង និងព្រះវិហារក៏មានចំនួនស្ត្រីទាប ក្នុងចំណាត់ថ្នាក់ខ្ពស់ដែរ ១១.៤ ភាគរយ ។

ដើម្បីកំណត់ថាស្ត្រីម្នាក់ស្គម ឬធាត់នោះ ទម្ងន់ធៀបនឹងកម្ពស់ និងសន្ទស្សន៍មាឌរាងកាយត្រូវបានធ្វើការគណនា ។ ស្ត្រីជាម្តាយទូទាំងប្រទេសចំនួន ១៦.១ ភាគរយ រាយការណ៍ថាស្គម និងចំនួន ៣.៧ ភាគរយ ត្រូវបានរាយការណ៍ថា ស្ថិតនៅក្នុងកម្រិតស្គមជាមធ្យម និងស្គមខ្លាំង ។ ចំណែកអត្រាភាគរយនៃភាពស្គមរបស់មាតាមានការថយចុះចំនួន ៣ ចាប់ពីឆ្នាំ២០០៥ មក ។ ចំពោះ មាតាដែលមានវ័យក្មេងភាគច្រើនមានអត្រាស្គមខ្ពស់ ២១.៣ ភាគរយ ។ ស្ត្រីស្គមចំនួន ១៧.១ ភាគរយរស់នៅតាមតំបន់ទីជនបទ និងទីប្រជុំជនមានចំនួន ១១.៤ ភាគរយ ។

យ៉ាងណាមិញ ដោយសារតែពេលវេលាមានកម្រិត និងធនធានមានកំណត់ អង្កេតមនុស្សមាត្រកម្ពុជា បានផ្តោតលើសូចនាករតែមួយប៉ុណ្ណោះ គឺបញ្ហាកង្វះមីក្រូសារជាតិ ។ ស្ត្រីទាំងឡាយដែលជាមាតា ត្រូវបានសាកសួរអំពីបញ្ហាមើលឃើញនាពេលយប់ (ជម្ងឺខ្វាក់មាន់) ដែលបណ្តាលមកពីកង្វះជីវជាតិអា ធ្ងន់ធ្ងរក្នុងអំឡុងពេលមានផ្ទៃពោះលើកចុងក្រោយ ។ មាតាចំនួន ៥.១ ភាគរយ បានរាយការណ៍ដោយខ្លួនឯងថាមានជម្ងឺខ្វាក់មាន់សម្រាប់អង្កេតឆ្នាំ២០០៨ (បានថយចុះពី ៨ ភាគរយ នៅឆ្នាំ២០០៥) ។ ប៉ុន្តែ ក្រោយពីការកែសម្រួលរួចមក (ដកចេញបញ្ហាស្រវាំងភ្នែកពេលថ្ងៃ) ចំនួនស្ត្រីខ្វាក់មាន់មានការថយចុះមកត្រឹម ១.៦ ភាគរយ ក្នុងឆ្នាំ២០០៨ ។

គួរបញ្ជាក់ថា នៅពេលបកស្រាយនូវនិន្នាការរបស់សូចនាករនិមួយៗ វាជាការសំខាន់នៅពេលដែលយើងពិចារណាអំពីកត្តាផ្សេងៗ បង្កជាផលប៉ះពាល់ដល់ស្ថានភាពអាហារូបត្ថម្ភរបស់ស្ត្រី ។ ចំពោះមាតា ផលប៉ះពាល់លើអាហារូបត្ថម្ភមានលក្ខណៈផ្សេងពីកុមារ ។ អាហារូបត្ថម្ភរបស់មនុស្សពេញវ័យមិនត្រូវបានវាយលុកធ្ងន់ធ្ងរខ្លាំងពីជម្ងឺនានាដូចកុមារនោះទេ ដោយសារតែមនុស្សពេញវ័យមានប្រព័ន្ធភាពស៊ាំនឹងជម្ងឺប្រភេទខ្លះរួចទៅហើយ ។ ដូចគ្នានេះផងដែរ ការអនុវត្តការមានកូនតាមប្រាថ្នា ក៏បានចូលរួមចំណែកមួយដែរសម្រាប់ការមានអាហារូបត្ថម្ភគ្រប់គ្រាន់របស់មាតាគ្រប់រូប ។

គួរពិចារណាថា និន្នាការប្រែប្រួលភាពស្គម និងជម្ងឺខ្វាក់មាន់របស់មាតា ទំនងបង្ហាញនូវកម្រិតប្រសើរឡើងផ្នែកអាហារូបត្ថម្ភរបស់មាតាក្នុងរយៈពេលវែងមួយ ទោះបីជាកម្រិតនៃការប្រែប្រួលនេះមិនបានកើនឡើងគួរឱ្យកត់សម្គាល់ក៏ដោយ ។ សូចនាកររបស់ស្ត្រីទាំងពីរខាងលើនេះ មិនបានវាស់វែងនូវនិន្នាការប្រែប្រួលរយៈពេលខ្លីនោះទេ ។ សរុបមក ការផ្តល់បន្ថែមគ្រាប់ថ្នាំជីវជាតិអា និងការអនុវត្តលទ្ធភាពបង្កើតកូន អាចចូលរួមចំណែកសំខាន់ក្នុងការកាត់បន្ថយបញ្ហាកង្វះមីក្រូសារជាតិរបស់មាតា ។

សន្ទស្សន៍មាឌរាងកាយ គឺជាសូចនាករតែមួយគត់នៃស្ថានភាពអាហារូបត្ថម្ភរបស់មាតា ដែលបង្ហាញអំពីការប្រែប្រួលក្នុងរយៈពេលខ្លី ។ លទ្ធផលភាពរីកចម្រើនក្នុងរង្វង់ឆ្នាំ២០០៥ និងឆ្នាំ២០០៨

ទំនងមកពីការថយចុះជាលំដាប់អំពីលទ្ធភាពនៃការចង់បានកូន ។ ប៉ុន្តែចំណុចនេះ មិនត្រូវបានវាស់វែងដោយ អ.ម.ក ២០០៨ នោះទេ ។ ប៉ុន្តែខុសប្លែកពី អ.ប្រ.ស.ក ២០០៥ ដែលបានរាយការណ៍ពីនិន្នាការថយចុះចំនួនកូនរបស់មាតាម្នាក់ៗ ។ ប្រសិនបើស្ថានភាពអាហារូបត្ថម្ភរបស់មាតាកំពុងស្ថិតនៅលើផ្លូវវិជ្ជមានមែននោះ ស្ថានភាពអាហារូបត្ថម្ភរបស់កុមារដែលមានអាយុតិចជាងគេបំផុត ក៏ឃើញមានភាពរីកចម្រើនផងដែរ ។

ដោយធ្វើការបំបែកមនុស្សមាត្រកុមារទៅតាមអាយុ នោះស្ថានភាពអាហារូបត្ថម្ភរបស់កុមារគ្រប់រូបមិនមែនសុទ្ធតែគ្មានភាពប្រសើរឡើងទេ ។ ចំពោះកុមារស្គម និងកង្វះទម្ងន់ដែលមានអាយុតិចជាងគេ (ក្រោម ១ ឆ្នាំ) ក៏ត្រូវបានរកឃើញថាមានលទ្ធផលវិជ្ជមានមួយចំនួនផងដែរ ។ ផ្ទុយទៅវិញអង្កេតបង្ហាញនូវលទ្ធផលអវិជ្ជមានចំពោះកុមារដែលមានអាយុច្រើន (ពី ១ ដល់ ៥ ឆ្នាំ) ។

## ជម្ងឺកុមារ

ការរៀបចំទិន្នន័យ អ.ប្រ.ស.ក ២០០៥ សំដៅប្រៀបធៀបនឹង អ.ម.ក ២០០៨ ជាគំហើញសំខាន់ពីរ ត្រូវបានយកមកប្រើប្រាស់ ។ ពីឆ្នាំ២០០០ ដល់ ឆ្នាំ២០០៥ ប្រេវ៉ាឡង់ជម្ងឺរាក ឬគ្រុនក្តៅពុំឃើញមានភាពប្រសើរឡើងទេ ។ បន្ទាប់ពីធ្វើការត្រួតពិនិត្យទៅតាមវដ្តកាលវិញ សូចនាករនៃជម្ងឺទាំងពីរនេះ មានភាពប្រសើរឡើងគួរឱ្យកត់សម្គាល់ក្នុងពេលនោះ ។ ការរកឃើញទីពីរ ទាក់ទងទៅនឹងកម្រងសំណួរ ដែលបានប្រើប្រាស់ដើម្បីរកប្រេវ៉ាឡង់ជម្ងឺរលាកផ្លូវដង្ហើមរបស់កុមារ ។ ជាទូទៅកម្រិតវិជ្ជមានពីឆ្នាំ២០០០ ដល់ឆ្នាំ២០០៥ នេះ ទំនងបណ្តាលមកពីការផ្លាស់ប្តូរកម្រងសំណួរអង្កេត ។

កុមារដែលចាត់ទុកថាមានជម្ងឺ លុះត្រាតែពួកគេឈឺក្នុងរយៈពេលពីរសប្តាហ៍មុនពេលអង្កេត ។ អ.ម.ក ២០០៨ បង្ហាញថាជម្ងឺទាំងបីរបស់កុមារមានប្រេវ៉ាឡង់ខ្ពស់ ។ ដូចជា : គ្រុនក្តៅមានប្រេវ៉ាឡង់ចំនួន ៥៨.៩ ភាគរយ ជម្ងឺរាកមានចំនួន ២៩.៧ ភាគរយ និងជម្ងឺរលាកផ្លូវដង្ហើមមានចំនួន ១៥.៥ ភាគរយ ។ នៅតំបន់ជនបទ និងគ្រួសារដែលមានកំរិតទ្រព្យសម្បត្តិខ្សត់ខ្សោយ បានប្រឈមនឹងអត្រាប្រេវ៉ាឡង់ជម្ងឺខ្ពស់បំផុត ។ ការកើនឡើងខ្ពស់នូវតួលេខទាំងអស់នេះ ប្រហែលជាពាក់ព័ន្ធទៅនឹងកង្វះអនាម័យ និងអាហារូត្ថម្ភខ្សត់ខ្សោយ ។ អាហារូបត្ថម្ភខ្សត់ខ្សោយ ជាបុព្វហេតុសំខាន់ដែលអាចធ្វើឱ្យប្រព័ន្ធស៊ាំនឹងជម្ងឺចុះខ្សោយ និងធ្វើឱ្យកុមារងាយឆ្លងជម្ងឺជាទីបំផុត ។

អង្កេតក្នុងឆ្នាំ២០០៥ បង្ហាញពីកម្រិតប្រសើរឡើងវិញនូវសូចនាករជម្ងឺកុមារទាំងអស់ ប៉ុន្តែស្ថានភាពដែលបានរកឃើញដោយរបាយការណ៍ អ.ម.ក ២០០៨ គឺមានភាពផ្ទុយគ្នាស្រឡះ ។ គ្រុនក្តៅបានកើនឡើង ២២ អត្រាភាគរយ ជម្ងឺរាកកើនឡើង ៨ អត្រាភាគរយ និងជម្ងឺរលាកផ្លូវដង្ហើមកើនឡើង ៧ អត្រាភាគរយ ។ គ្រុនក្តៅដែលបានកើនឡើងនេះ គឺជាករណីគួរឱ្យចាប់អារម្មណ៍ ។ ដូច្នេះ

ព័ត៌មានដែលទាក់ទងជាមួយជម្ងឺរបស់កុមារត្រូវធ្វើការពិនិត្យឡើងវិញឱ្យបានដិតដល់ ក្នុងនោះ មានករណីប្រេវ៉ាឡង់គ្រុនក្តៅជាដើម ។

ជម្ងឺកុមារ គឺជាសមាសភាពមួយផ្សេងទៀតនៃលក្ខណៈវិនិច្ឆ័យរបស់ IPC ហើយក៏ជាលក្ខណៈវិនិច្ឆ័យសម្រាប់ការសិក្សាពីផលប៉ះពាល់មកពីការរីករាលដាលវិបត្តិម្ហូបអាហារធ្ងន់ធ្ងរ និងវិបត្តិនៃការរស់នៅ ។ តាមរយៈលក្ខណៈវិនិច្ឆ័យទាំងពីរនេះ ជម្ងឺកុមារត្រូវបានរំពឹងថានឹងមានការកើនឡើង ។ ការរីករាលដាលជម្ងឺដែលបានរកឃើញ ជាទូទៅមានកម្រិតកើនឡើងខ្ពស់ជាងការរំពឹងទុក ។ តាមការរកឃើញរបស់ អ.ម.ក ២០០៨ បានបង្ហាញយ៉ាងច្បាស់ថា អត្រាប្រេវ៉ាឡង់ជម្ងឺកុមារមានការកើនឡើងខ្ពស់ជាងធម្មតា ធៀបទៅនឹងការរកឃើញរបស់ អ.ប្រ.ស.ក ២០០០ និង អ.ប្រ.ស.ក ២០០៥ ។

## យុទ្ធសាស្ត្រដោះស្រាយបន្ទាន់

ក្នុងបរិបទអង្កេតថ្លៃទំនិញ និងម្ហូបអាហារខ្ពស់ យុទ្ធសាស្ត្រដោះស្រាយបន្ទាន់របស់គ្រួសារនិមួយៗ គឺជាវិធីសាស្ត្រផ្ទាល់សំដៅកាត់បន្ថយនូវទំហំផលពិបាកផ្នែកហិរញ្ញវត្ថុរបស់គ្រួសារ ។ យុទ្ធសាស្ត្រដែលបានប្រើប្រាស់ច្រើនជាងគេនៅក្នុងអង្កេតមនុស្សមាត្រ ឆ្នាំ២០០៨ គឺទាក់ទងទៅនឹងយុទ្ធសាស្ត្រសម្រាប់ទប់ទល់នឹងការកើនឡើងថ្លៃម្ហូបអាហារ ។ ពីរភាគបីនៃចំនួនគ្រួសារដែលត្រូវបានសម្ភាសន៍ បានពឹងផ្អែកលើម្ហូបអាហារដែលមានតម្លៃថោកជាងមុន ឬក៏អាហារដែលមិនមែនជាចំណង់ចំណូលចិត្តរបស់ខ្លួនយ៉ាងតិចណាស់ក៏ម្តងដែរអំឡុងពេលមួយខែមុនអង្កេត ។ យុទ្ធសាស្ត្រផ្សេងទៀតដែលទាក់ទងទៅនឹងអាហាររួមមាន : ការទិញអាហារដោយជំពាក់ ការកាត់បន្ថយបរិមាណអាហារបរិភោគប្រចាំថ្ងៃ និងការកាត់បន្ថយបរិមាណបរិភោគរបស់មនុស្សពេញវ័យ ដោយលៃទុកសម្រាប់កុមារតូច ។ ***បន្ទាប់ពីយុទ្ធសាស្ត្រដែលទាក់ទងទៅនឹងអាហារ គឺយុទ្ធសាស្ត្រកាត់បន្ថយចំណាយលើការថែទាំសុខភាព ដែលមានគ្រួសារចំនួន ៤១.១ ភាគរយ ។***

វិបត្តិរបស់យុទ្ធសាស្ត្រដោះស្រាយបន្ទាន់ គឺមានផលប៉ះពាល់ទៅដល់ការចិញ្ចឹមជីវិតនៅពេលអនាគតមានដូចជា : ការលក់ដីធ្លី និងទ្រព្យសម្បត្តិផលិតកម្មជាដើម ។ ថ្វីត្បិតតែភាគរយគ្រួសារប្រើប្រាស់យុទ្ធសាស្ត្រដោះស្រាយវិបត្តិមានកម្រិតទាបមែន ប៉ុន្តែពួកគាត់បានចាប់ផ្តើមប្រើប្រាស់យុទ្ធសាស្ត្រទាំងអស់នេះ ក្នុងអំឡុងពេលអាហារឡើងថ្លៃសម្រាប់ការជួយសម្រាលថវិកាគ្រួសារ ។ ជាលទ្ធផល មានគ្រួសារចំនួន ៤ ភាគរយ បានលក់ដីធ្លី និងចំនួន ៣ ភាគរយ បានលក់ទ្រព្យសម្បត្តិផលិតកម្ម (ឧបករណ៍កសិកម្ម ម៉ាស៊ីនដេរ ។ល។) ។

កម្រិតខ្ពស់បំផុតនៃយុទ្ធសាស្ត្រដែលទាក់ទងទៅនឹងម្ហូបអាហារទីពីរ បន្ទាប់ពីពឹងផ្អែកលើម្ហូបអាហារដែលមានតម្លៃថោកជាងមុន ឬក៏អាហារដែលមិនមែនជាចំណង់ចំណូលចិត្តរបស់ខ្លួន គឺការកាត់បន្ថយបរិមាណបរិភោគរបស់មនុស្សពេញវ័យ និងការបង្កើនការទាញយកផលពីធនធានរួម

(ការនេសាទ ការស្វែងរកអាហារបន្ថែមជាដើម) ។ ការកើនឡើងខ្ពស់បំផុតនៃការប្រើប្រាស់យុទ្ធសាស្ត្រដែលមិនទាក់ទងទៅនឹងម្ហូបអាហារ គឺការកើនឡើងការលក់សត្វពាហនៈ និងការកាត់បន្ថយចំណាយលើការថែទាំសុខភាព ។ យុទ្ធសាស្ត្រដោះស្រាយបន្ទាន់ក៏ជាសមាសភាពមួយនៃលក្ខណៈវិនិច្ឆ័យរបស់ IPC ផងដែរ ។ ក្នុងពេលមានវត្តមានវិបត្តិថ្លៃអាហារខ្ពស់ កម្រិតការប្រើប្រាស់យុទ្ធសាស្ត្រដោះស្រាយបន្ទាន់មានភាពខ្ពស់ និងមានការកើនឡើងជាងពេលធម្មតា ។ លទ្ធផលមួយទៀតនោះ គឺការប្រើប្រាស់យុទ្ធសាស្ត្រដោះស្រាយវិបត្តិ ក៏ជាភស្តុតាងច្បាស់លាស់មួយដែរ ដែលក្រុមគ្រួសារមួយចំនួនបានអនុវត្តនាពេលអាហារឡើងថ្លៃ ។ ពីខែឧសភា ដល់ ខែវិច្ឆិកា ឆ្នាំ២០០៨ ការប្រើប្រាស់យុទ្ធសាស្ត្រដោះស្រាយបន្ទាន់ ឃើញថាមានការកើនឡើង ប៉ុន្តែបញ្ហានេះអាចទទួលឥទ្ធិពលមកពីអង្កេតត្រូវបានធ្វើឡើង នារដូវខ្វះខាត (មុនរដូវប្រមូលផល) ។

## ការប្រើប្រាស់អាហារ

សម្រាប់ការវាស់វែងការប្រើប្រាស់អាហារ គឺមានមធ្យោបាយផ្សេងពីគ្នា ហើយមធ្យោបាយនិមួយៗតែងតែមានវិធីសាស្ត្រខុសគ្នាដែរ ។ ការវាស់វែងការប្រើប្រាស់អាហារ គឺមិនមែនមានលក្ខណៈងាយស្រួលនោះទេ ។ ហេតុដូចនេះហើយ វាសំខាន់ណាស់ដែលអង្កេតនិមួយៗ អាចត្រូវបានយកមកធ្វើការប្រៀបធៀបគ្នាបានពីពេលមួយទៅពេលមួយទៀត ។ អ.ម.ក ២០០៨ និង អ.ប្រ.ស.ក ២០០៥ បានវាស់វែងនូវរបបអាហារចំរុះ ឬក៏ប្រភេទអាហារណាខ្លះដែលគ្រួសារបានបរិភោគ ។ អង្កេតនេះមិនបានធ្វើការវាស់វែងលើបរិមាណនៃអាហារដែលបានបរិភោគទេ ពីព្រោះតែចំនុចនេះនឹងត្រូវបានវាស់វែងដោយ អង្កេតសេដ្ឋកិច្ច-សង្គមកិច្ច ឆ្នាំ២០០៩ (CSES) ។

អាហារចម្បងនៅក្នុងរបបអាហាររបស់កុមារគឺ បាយ និងត្រី ។ អាហារសាមញ្ញបំផុតទីបីសម្រាប់កុមារដែលកំពុងតែប្រើប្រាស់សព្វថ្ងៃគឺ អាហារមានជាតិស្ករ ។ លើសពីនេះ ការមានជាតិស្ករខ្ពស់ក្នុងខ្លួនបណ្តាលឱ្យមានបញ្ហាដល់សុខភាព ។ មុខងាររបស់ជាតិស្ករនៅក្នុងរបបអាហារ គឺជាបញ្ហាដែលជាការគួរឱ្យព្រួយបារម្ភ ដោយសារតែ កុមារមួយចំនួនតូចប៉ុណ្ណោះបានបរិភោគអាហារដែលមានប្រភពពីសារជាតិប្រូតេអ៊ីន និងថាមពល ដូចជា : អាហារប្រភេទបន្លែ និងគ្រាប់ធុញ្ញជាតិ (១០ភាគរយ) អាហារជាតិប្រេង និងខ្លាញ់ (២៣.១ភាគរយ) និងផលិតផលទឹកដោះគោ (១៣.៩ ភាគរយ) ។ ការប្រើប្រាស់ក្រុមអាហារចម្បងជាមធ្យមរបស់កុមារដែលមានអាយុពី ៦ ទៅ ៣៥ខែ មានចំនួន ៤.៧ ក្នុងចំណោមអាហារទាំង ១៤ ក្រុម ។ អត្រាប្រែប្រួលមានភាពខុសគ្នាទៅតាមអាយុ ។ ចំពោះកុមារដែលមានអាយុច្រើន (២៤ ទៅ ៣៥ខែ) សមាមាត្របរិភោគក្រុមអាហារជាមធ្យម ២.៦ ច្រើនជាងកុមារដែលមានអាយុតិច (៦ ខែ ទៅ ១១ ខែ) ។ យ៉ាងណាមិញ ពុំមានភាពខុសគ្នារវាងតំបន់ប្រជុំជន និងជនបទក្នុងការប្រើប្រាស់ក្រុមអាហារចម្បងនោះទេ ប៉ុន្តែមានភាពខុសគ្នានៅក្នុងការជ្រើសរើស

ប្រភេទអាហារទៅវិញ ។ កុមារនៅតំបន់ទីប្រជុំជនចូលចិត្តបរិភោគអាហារប្រភេទសាច់ ចំណែកឯកុមារនៅតាមតំបន់ជនបទចូលចិត្តបរិភោគត្រីជាង ។ ការប្រើប្រាស់ផលិតផលទឹកដោះគោនៅតំបន់ទីប្រជុំជន មានចំនួន ៣៥ ភាគរយ ។ ចំនួននេះខ្ពស់ជាងជិត ៤ដង ច្រើនជាងអត្រានៃការប្រើប្រាស់នៅតាមតំបន់ទីជនបទ ។

ក៏ដូចជាកុមារដែរ បាយ និងត្រី គឺជាអាហារចម្បងនៅក្នុងរបបអាហារប្រចាំថ្ងៃរបស់ម្ដាយ ។ មានភាពខុសគ្នាយ៉ាងខ្លាំងរវាងរបបអាហាររបស់កុមារ និងម្ដាយ គឺការប្រើប្រាស់អាហារមានជាតិស្កររបស់ម្ដាយមានចំនួន ២០ អត្រាភាគរយ ទាបជាងការប្រើប្រាស់របស់កុមារ ។ ការប្រើប្រាស់អាហារដែលមានជាតិប្រេង និងខ្លាញ់របស់ម្ដាយ (៣២.៧ ភាគរយ) ខ្ពស់ជាងការប្រើប្រាស់របស់កុមារ ។ ដូច្នេះ ការផ្ដល់អាហារប្រភេទប្រេង និងខ្លាញ់ទាំងអស់នេះ មិនគួរត្រូវដាក់បញ្ចូលទៅក្នុងរបបអាហាររបស់កុមារនោះទេ ។

យ៉ាងណាមិញ ការប្រើប្រាស់អាហាររបស់កុមារត្រូវបានប្រៀបធៀបទៅនឹងទិន្នន័យដែលបានរកឃើញដោយអង្កេតប្រជាសាស្ត្រ និងសុខភាព ឆ្នាំ២០០៥ ។ នៅពេលធ្វើការប្រៀបធៀបអង្កេតទាំងពីរនេះ រដូវកាលជាកត្តាដែលអាចមានឥទ្ធិពលខ្លាំងដល់ការប៉ាន់ស្មាននៅក្នុងអង្កេតនេះ ជាពិសេសទៅលើរដូវកាលផ្លែឈើ និងបន្លែលើទីផ្សារ ។ ការប្រើប្រាស់ក្រុមអាហារចម្បងកំរិតថ្នាក់ជាតិក្នុងឆ្នាំ២០០៨ គឺប្រហាក់ប្រហែលគ្នាទៅនឹងឆ្នាំ២០០៥ ។ ប៉ុន្តែគេសង្កេតឃើញថាមានការថយចុះនៅតំបន់ទីប្រជុំជន ពី ៥.៤ ទៅ ៤.៨ ភាគរយ ។ ការប្រើប្រាស់ស្ទើរតែគ្រប់ក្រុមអាហារទាំងអស់ (១២/១៤) នៅតំបន់ទីប្រជុំជនមានការថយចុះ ។ ការប្រែប្រួលនេះ ពុំបានផ្ដល់នូវអត្ថន័យគ្រប់គ្រាន់ក្នុងន័យស្ថិតិនោះទេ ។ ការប្រែប្រួលខ្លាំងបំផុតនោះ គឺការថយចុះក្នុងការប្រើប្រាស់ប្រភេទអាហារដែលមានតម្លៃខ្ពស់នៅតំបន់ទីប្រជុំជន ។ ការប្រើប្រាស់អាហារប្រភេទត្រី និងសាច់ មានការថយចុះចំនួន ១៤ អត្រាភាគរយ។ រីឯការប្រើប្រាស់ស៊ុត និងសារជាតិប្រេង/ខ្លាញ់មានការថយចុះចំនួន ៨ និង ៧ អត្រាភាគរយ។

មានសមាសភាគពីរនៃលក្ខណៈវិនិច្ឆ័យរបស់ IPC ដែលទាក់ទងទៅនឹងការប្រើប្រាស់អាហារ ។ សមាសភាគទីមួយ ផ្អែកទៅលើការប្រើប្រាស់អាហារគិតជាកាឡូរី ដែលមិនបានធ្វើការវាស់វែងដោយអង្កេតមនុស្សមាត្រ ឆ្នាំ២០០៨ ទេ ។ សមាសភាគផ្សេងទៀត គឺរបបអាហារចំរុះដែលតំណាងឱ្យកម្រិតមានវិបត្តិខ្វះខាតរបបអាហារចំរុះធ្ងន់ធ្ងរ ។ ដោយឡែកនៅក្នុងប្រទេសកម្ពុជា អត្រាខ្ពស់របស់ភាពក្រិន ទំនងមកពីការខ្វះខាតរបបអាហារចំរុះរ៉ាំរ៉ៃ ។ នៅក្នុងបរិបទនេះ ការប្រែប្រួលជាអវិជ្ជមានណាមួយនៅក្នុងរបបអាហារចំរុះ គឺជាមូលហេតុដែលគួរឱ្យព្រួយបារម្ភ ។ នៅថ្នាក់ជាតិគេសង្កេតឃើញថា ការរីករាលដាលនូវការខ្វះខាតរបបអាហារចំរុះពុំមានលក្ខណៈធ្ងន់ធ្ងរនោះទេ ។ ប៉ុន្តែចំនុចអវិជ្ជមាន

ឃើញមាននៅតំបន់ទីប្រជុំជន ដោយសារភាគច្រើនអាហារដែលផ្ទុកនូវមីក្រូសារជាតិគ្រប់គ្រាន់នោះ បានឡើងថ្លៃ ។ ដូច្នេះ របបអាហារចំរុះខ្សត់ខ្សោយធ្ងន់ធ្ងរ គឺប្រហែលជាកើតមានឡើងនៅតំបន់ទាំងនោះ ។

## របៀបផ្តល់អាហារបន្ថែមដល់ទារក និងកុមារតូច

វិធីសាស្ត្រមួយដែលសំខាន់បំផុតក្នុងការចិញ្ចឹមទារក និងកុមារតូច គឺការបំបៅដោយទឹកដោះម្តាយតែមួយមុខគត់ ។ ការផ្តល់ឱ្យទារកនូវទឹកដោះម្តាយតែមួយមុខគត់ក្នុងរយៈពេល ៦ខែ ដំបូងនៃជីវិតអាចផ្តល់នូវអាហារូបត្ថម្ភគ្រប់គ្រាន់ ធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធស៊ាំនឹងជម្ងឺ និងមានហានិភ័យទាបប្រឈមទៅនឹងជម្ងឺឆ្លងផ្សេងៗ ។ អត្រាចិញ្ចឹមកូន ដោយទឹកដោះម្តាយតែមួយមុខគត់ក្នុងចំណោមទារកឬកុមារតូចអាយុពី ០_៥ខែ មានចំនួន ៦៥.៩ ភាគរយ ។ មានមូលហេតុសំខាន់ពីរដែលធ្វើឱ្យអត្រានៃការបំបៅដោះម្តាយតែមួយមុខគត់នោះមិនខ្ពស់ ដោយសារ : ម្តាយជាច្រើនចាប់ផ្តើមផ្តល់ទឹកដល់ទារកនៅក្នុងខែដំបូង និងចាប់ផ្តើមផ្តល់អាហារបន្ថែម ដល់ទារក ឬកុមារតូចនៅពេលដែលមានអាយុពី ៤ ទៅ ៥ ខែ ។ នៅតំបន់ទីជនបទ អត្រាចិញ្ចឹមកូន ដោយទឹកដោះម្តាយតែមួយមុខគត់ មានចំនួន ៧០.៨ ភាគរយ រីឯនៅតំបន់ប្រជុំជនមានអត្រាទាបជាង តំបន់ទីជនបទ គឺមានចំនួនតែ ៤០.៣ ភាគរយប៉ុណ្ណោះ ។ អង្កេតមនុស្សមាត្រ ឆ្នាំ២០០៨ បង្ហាញថា នៅទូទាំងប្រទេស កុមារស្ទើរតែទាំងអស់ ៩១.៥ ភាគរយ បានបៅដោះម្តាយតែមួយមុខគត់ នៅក្នុងខែ ដំបូងនៃជីវិត ។

ចាប់តាំងពីឆ្នាំ២០០០ មក អត្រាចិញ្ចឹមកូនដោយទឹកដោះម្តាយតែមួយមុខគត់ មានការរីកចម្រើនយ៉ាងឆាប់រហ័ស ដោយសារតែកម្មវិធីរបស់រដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល ។ ការផ្លាស់ប្តូរសំណួរខ្លះក្នុង អ.ប្រ.ស.ក ២០០៥ មានន័យថាការប៉ាន់ស្មាននៅឆ្នាំ២០០០ ត្រូវបានធ្វើការគណនាឡើងវិញ ។ អត្រាចិញ្ចឹមកូនដោយទឹកដោះម្តាយតែមួយមុខគត់នៅឆ្នាំ២០០០ មានចំនួន ៤៧ ភាគរយ នៅឆ្នាំ២០០៥ កើនដល់ ៦០ភាគរយ ហើយនៅឆ្នាំ២០០៨ បានកើនដល់ ៦៦ភាគរយ ។ ការប្រែប្រួលខ្លាំងបំផុតនេះ គឺដោយសារនៅមានម្តាយចំនួនតិចតួចប៉ុណ្ណោះ ដែលបានផ្តល់ទឹកដល់កូនរបស់គាត់ ។ ស្ថានភាពនៅតំបន់ទីប្រជុំជនបង្ហាញឱ្យឃើញថាមានភាពខុសគ្នា ។ អត្រាចិញ្ចឹមកូនដោយទឹកដោះម្តាយតែមួយមុខគត់នៅតំបន់ទីប្រជុំជន ពីឆ្នាំ២០០៥ ដល់ឆ្នាំ២០០៨ មានការថយចុះពី ៤៨.៥ ទៅ ៤០.៣ ភាគរយ។

ការផ្តល់អាហារបន្ថែម គឺសំដៅទៅលើអាហារចម្រុះ ក្រៅពីការបៅដោះម្តាយតែមួយមុខគត់បន្ទាប់ពីកុមារមានអាយុលើសពី ៦ ខែ ។ កុមារដែលទទួលអាហារបន្ថែមនៅអាយុក្មេងពេក ក៏ជាបញ្ហាដែរ ។ ការរកឃើញបានបង្ហាញថា កុមារដែលមានអាយុ ៥ ខែ ស្ទើរតែមួយភាគបីបានទទួលអាហារបន្ថែម ។ ចំនុចដែលសំខាន់បំផុតនោះគឺថា កុមារដែលមានអាយុ ៦ ខែ ចំនួន ២៥ ភាគរយ និងកុមារ

ដែលមានអាយុ ៧ ខែ ប្រហែល ១៥ ភាគរយ មិនត្រូវបានផ្តល់អាហារបន្ថែមទាន់ពេលវេលាទេ ។ ភាពយឺតយ៉ាវក្នុងការផ្តល់អាហារបន្ថែមត្រឹមត្រូវ បង្ហាញនូវរបបអាហារចំរុះខ្សត់ខ្សោយរបស់កុមារដែលមានអាយុពី ៦ ទៅ ១១ ខែ ។

### សេវាសុខភាពកុមារ

សម្រាប់កុមារ គ្រាប់ថ្នាំជីវជាតិអា និងគ្រាប់ថ្នាំទម្លាក់ព្រូន ត្រូវបានផ្តល់ឱ្យដោយមណ្ឌលសុខភាព មន្ទីរពេទ្យ និងតាមសេវាចុះដល់មូលដ្ឋាន ។ ហេតុផលចម្បងរបស់យុទ្ធសាស្ត្រផ្តល់បន្ថែមគ្រាប់ថ្នាំជីវជាតិអា សម្រាប់កុមារដែលមានអាយុពី ៦ ទៅ ៥៩ ខែ គឺជាសេវាពិសេសចុះដល់មូលដ្ឋានដោយផ្តោតលើការផ្តល់ ២ ដងក្នុងមួយឆ្នាំ (គឺខែ ឧសភា និងខែវិច្ឆិកា) ហើយជាងនេះទៅទៀត កុមារក៏បានទទួលគ្រាប់ថ្នាំទម្លាក់ព្រូនតាមរយៈសេវាចុះដល់មូលដ្ឋាននេះផងដែរ ។

កុមារដែលមានអាយុពី ៦ ទៅ ៥៩ ខែ ហើយបានទទួលបន្ថែមគ្រាប់ថ្នាំជីវជាតិអា ក្នុងរយៈពេល ៦ ខែ ចុងក្រោយនេះ មានចំនួន ៥៩.៤ ភាគរយ ។ ចំពោះអ្នកដែលបានឆ្លើយថា ***មិនដឹង*** សម្រាប់សំណួរអំពីគ្រាប់ថ្នាំជីវជាតិអា មានចំនួន ១២.៧ ភាគរយ មានន័យថានៅមានកម្រិតទាបជាង អ.ប្រ.ស.ក ២០០៥ ។ អ្នកផ្តល់ចម្លើយ និងអ្នកដែលរស់នៅតាមតំបន់ទីប្រជុំជននានា ភាគច្រើនជ្រើសរើសយកចម្លើយ ***មិនដឹង*** ។ ចំពោះការប្រៀបធៀបទៅលើលក្ខណៈប្រវត្តិ គឺមិនមានអ្វីសំខាន់ទេ ពីព្រោះភាពខុសគ្នាទាំងនេះ និងការព្យាករទាំងអស់អាចទាបជាងតំលៃពិតប្រាកដ ។

កាលបរិច្ឆេទសម្រាប់ការផ្តល់គ្រាប់ថ្នាំទម្លាក់ព្រូន និងការផ្តល់បន្ថែមគ្រាប់ថ្នាំជីវជាតិអា គឺត្រូវបានផ្តល់ក្នុងពេលតែមួយ ប៉ុន្តែគ្រាន់តែអ្នកផ្តល់ចំលើយមិនត្រូវបានសួរនាំឱ្យបានច្បាស់អំពីខែណាមួយពិតប្រាកដដែលកុមារបានទទួលទានគ្រាប់ថ្នាំ ។ ដូច្នេះ បានជាលទ្ធផលនៃអត្រាទទួលបន្ថែមគ្រាប់ថ្នាំជីវជាតិអា និងថ្នាំទម្លាក់ព្រូនមិនអាចប្រៀបធៀបគ្នាបាន ។ អ.ម.ក ២០០៨ បានផ្តល់របាយការណ៍ថាកុមារដែលមានអាយុពី ១២ ទៅ ៥៩ ខែ បានទទួលគ្រាប់ថ្នាំទម្លាក់ព្រូនមានចំនួន ៣៩.៩ ភាគរយនៅក្នុងរយៈពេល ៦ ខែ ចុងក្រោយ ។ យើងឃើញមានភាគរយខ្ពស់នៅក្នុងតំបន់ទីជនបទ (៤២.៧ ភាគរយ) នៅពេលធ្វើការប្រៀបធៀបជាមួយតំបន់ទីប្រជុំជន (២៦.៩ ភាគរយ) ។

### សេវាសុខភាពមាតា

សម្រាប់សេវាសុខរបស់មាតា (ការផ្តល់បន្ថែមគ្រាប់ថ្នាំជាតិដែកហ្វូលិក ថ្នាំទម្លាក់ព្រូនកំឡុងពេលមានផ្ទៃពោះ និងគ្រាប់ថ្នាំជីវជាតិអាក្រោយពេលសម្រាលកូនរួច) ដែលបានវាស់វែងដោយអង្កេតមនុស្សមាត្រ ឆ្នាំ២០០៨ គឺត្រូវបានផ្តល់ឱ្យតាមរយៈការពិនិត្យថែទាំផ្ទៃពោះមុនសម្រាល និងការថែទាំទារកក្រោយសម្រាលនៅឯមណ្ឌលសុខភាព និងតាមរយៈការផ្តល់សេវាចុះដល់មូលដ្ឋាន។

ជាលទ្ធផលក្រោយពីអង្កេត មានស្ត្រីជាម្តាយចំនួន ៤៧ ភាគរយ បានទទួលនូវ ការពិនិត្យថែទាំផ្ទៃពោះចំនួន ៤ដង សម្រាប់ការមានផ្ទៃពោះចុងក្រោយគេបង្អស់ដោយបានកើនឡើងពី ២៧ ភាគរយ ពីឆ្នាំ ២០០៥ ។ នៅក្នុងឆ្នាំ២០០៨ មានមាតា ៩ នាក់ ក្នុងចំណោមមាតា ១០ នាក់ បានទៅពិនិត្យផ្ទៃពោះយ៉ាងហោចណាស់ក៏ម្តងដែរ ផ្ទុយពីឆ្នាំ២០០៥ មានមាតាចំនួន ៧ នាក់ ប៉ុណ្ណោះក្នុងចំណោម ១០ នាក់ បានទៅពិនិត្យផ្ទៃពោះមុនពេលសម្រាល ។

តាមលទ្ធផល អ.ម.ក ២០០៨ បានបង្ហាញថាស្ត្រីទាំងអស់ទូទាំងប្រទេស បានទទួលគ្រាប់ថ្នាំជាតិដែក ចំនួន ៩០ ឬច្រើនជាងនេះក្នុងកំឡុងពេលមានផ្ទៃពោះចុងក្រោយមានចំនួន ៣៩.៥ ភាគរយ ហើយមាន ៣១.៤ ភាគរយ បានទទួលគ្រាប់ថ្នាំទម្លាក់ព្រូន ។ មានមាតាចំនួន ៤៣.៧ ភាគរយ បានទទួលបន្ថែមគ្រាប់ថ្នាំជីវជាតិអា ក្នុងអំឡុងពេល ៦ សប្តាហ៍ នៃការសម្រាលកូន និងមានចំនួន ៣៣.២ ភាគរយ បានទទួលគ្រាប់ថ្នាំជាតិដែកក្រោយពេលសម្រាលកូនហើយ ។

បើធ្វើការប្រៀបធៀប អ.ប្រ.ស.ក ២០០៥ យើងឃើញថាមានការរីកចម្រើនស្ទើរតែគ្រប់ផ្នែកនៃសេវាសុខភាពមាតា ។ ចំនួននៃការផ្តល់គ្រាប់ថ្នាំជាតិដែកគ្រាប់គ្រាន់ (+៩០) បានកើនឡើងជិត ២២ អត្រាភាគរយ ការផ្តល់គ្រាប់ថ្នាំទម្លាក់ព្រូនបាន ២១ អត្រាភាគរយ ការផ្តល់គ្រាប់ថ្នាំជីវជាតិអា ១៦ អត្រាភាគរយ និងការផ្តល់គ្រាប់ថ្នាំជាតិដែកហ្វូលិកក្រោយពេលសម្រាលកូនបាន ២២ អត្រាភាគរយ ។ ជាលទ្ធផល ការរីកចម្រើននៃអត្រាគ្របដណ្តប់លើសេវាថែទាំសុខភាពមាតា (ការកើនឡើងសេវាថែទាំផ្ទៃពោះមុនសម្រាល និងសេវាថែទាំក្រោយសម្រាល) ដោយសារតែកិច្ចខិតខំប្រឹងប្រែងរបស់កម្មវិធីរដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាល ក្នុងការលើកកម្ពស់សុខភាពមាតាដែលមានចែងនៅក្នុងគោលដៅអភិវឌ្ឍន៍ សហស្សវត្សរ៍កម្ពុជា ។

# សេចក្តីផ្តើម និងគោលបំណងនៃការធ្វើអង្កេតមនុស្សសាស្ត្រកម្ពុជា ២០០៨

បន្ទាប់ពីបានឆ្លងកាត់ការវិវត្តជាច្រើនដំណាក់កាល នៅក្នុងរយៈពេលទសវស្សចុងក្រោយនេះ ប្រទេសកម្ពុជាទទួលបាននូវសន្តិភាពទាំងស្រុងនៅក្នុងផ្ទៃប្រទេស និងមានការរីកចម្រើនស្ទើរតែគ្រប់វិស័យនៃការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមកិច្ច ដែលជាកត្តាសំខាន់សម្រាប់ធានាបាននូវកំណើនសេដ្ឋកិច្ចមួយប្រកបដោយចីរភាព ។ រវាងឆ្នាំ២០០៥ ទៅ ឆ្នាំ២០០៧ កំណើនផលិតផលក្នុងស្រុកសរុប (ផ.ផ.ស) ជាមធ្យមមានចំនួន ១១ ភាគរយ ។

តាមរយៈរបាយការណ៍ថ្មីរបស់ក្រសួងផែនការ (ក្រ.ផ.ក) នៅចុងឆ្នាំ២០០៨ បានបង្ហាញថា ទោះបីជាប្រជាជនកម្ពុជាប្រមាណ ៣០ ភាគរយ កំពុងរស់នៅក្រោមបន្ទាត់នៃភាពក្រីក្រក៏ដោយ ក៏ប៉ុន្តែជាមួយនឹងនិន្នាការកាត់បន្ថយជាមធ្យមចំនួន ១ ភាគរយ យ៉ាងតិចជារៀងរាល់ឆ្នាំចាប់តាំងពីឆ្នាំ២០០៤ មក កម្ពុជាសង្ឃឹមថានឹងសម្រេចបាននូវគោលដៅកាត់បន្ថយភាពក្រីក្រ ដូចដែលបានរំពឹងទុកក្នុងចំនុចដៅនៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ។

ក្នុងទិសដៅរក្សាបាននូវស្ថេរភាពនៃការរីកចម្រើនផ្នែកម៉ាក្រូសេដ្ឋកិច្ច និងការសម្រេចបាននូវការអភិវឌ្ឍប្រកបដោយចីរភាព ផែនការសកម្មភាពអភិវឌ្ឍន៍នានា ប្រកបដោយការគិតគូរគ្រប់ជ្រុងជ្រោយទូទាំងវិស័យត្រូវបានលើកឡើង ដើម្បីសម្រួលនូវគោលនយោបាយរវាងរាជរដ្ឋាភិបាលកម្ពុជា សង្គមស៊ីវិល ដៃគូអភិវឌ្ឍន៍ និងអង្គការពាក់ព័ន្ធនានា ។ ប៉ុន្តែនៅមានកត្តាជាច្រើនទៀតដែលទាមទារនូវពេលវេលា សមត្ថភាព និងធនធានសម្រាប់ដោះស្រាយមួយជំហ៊ានម្តងៗ ពីព្រោះថាបញ្ហាខ្លះ គឺជារឿងប្រឈមស្មុគស្មាញទាក់ទងគ្នា ដែលជូនកាលរារាំងដល់សមត្ថភាពផលិតរបស់ក្រុមគ្រួសារងាយរងគ្រោះ និងការបង្កើនប្រាក់ចំណូលគ្រួសាររបស់ពួកគាត់ ។

ការអាហារូបត្ថម្ភគ្រប់គ្រាន់ គឺជាតម្រូវការមូលដ្ឋានមួយរបស់មនុស្ស ដើម្បីបង្កើតនូវគុណភាពជីវិតដ៏ល្អប្រសើរ ដែលរួមមាន : ការចាកផុតពីជម្ងឺឆ្លងរបស់កុមារ អត្រាមរណៈ ភាពមិនប្រក្រតីនៃការអភិវឌ្ឍសារៈពាង្គកាយ និងពីភាពក្រីក្រ។ សូចនាករតាមវិស័យសុខភាព និងអាហារូបត្ថម្ភជាមូលដ្ឋានរបស់អង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា (អ.ប្រ.ស.ក) ២០០៥ បានបង្ហាញថាប្រទេសកម្ពុជាមានអត្រាខ្ពស់ផ្នែកអត្រាមរណភាពមាតា និងទារក និងកង្វះអាហារូបត្ថម្ភ ដែលក្នុងនោះកុមារដែលមានអាយុក្រោម ៥ ឆ្នាំ ចំនួន ៣៧ ភាគរយ[១] មានភាពក្រិន ។ ជារឿយៗសកម្មភាពសហគមន៍ដើម្បីអភិវឌ្ឍន៍សង្គម តែងតែផ្តោតលើការផ្តល់ជំនួយផ្នែកហិរញ្ញវត្ថុ ប៉ុន្តែតាមប្រវត្តិសាស្ត្រនៃការអភិវឌ្ឍបានបង្ហាញថា គំនិត ចំណេះដឹង និងការអប់រំអាចជាកាតាលីករជម្រុញឱ្យមានការផ្លាស់ប្តូរដើម្បីជួយលើកកំពស់ សុខមាលភាព និងអាហារូបត្ថម្ភរបស់មនុស្សជាតិផងដែរ ។

[១] តាមរូបមន្តគណនាថ្មីរបស់អង្គការសុខភាពពិភពលោក (អ.ស.ព) កុមារក្រិនក្រោមអាយុ ៥ ឆ្នាំ មានចំនួន ៤៣ ភាគរយ

ដោយសារតែវិបត្តិទីផ្សារប្រេងឥន្ធនៈពិភពលោក ប្រទេសកម្ពុជាក៏បានទទួលរងនូវឥទ្ធិពលនេះដែរ ។ ការកើនឡើងថ្លៃប្រេងឥន្ធនៈហួសប្រមាណ និងការកើនឡើងថ្លៃម្ហូបអាហារដែលពុំធ្លាប់មានពីមុនមក បានធ្វើឱ្យប៉ះពាល់ជាអវិជ្ជមានដល់ការផលិត និងកម្លាំងទិញរបស់គ្រួសារដែលមានជីវភាពមធ្យម និងក្រីក្រ ។ ជារួម ប្រការនេះអាចបង្កឱ្យគ្រួសារនិមួយៗ ខ្វះនូវឱកាសសម្រាប់ការផលិត និងទិញអាហារឱ្យបានគ្រប់គ្រាន់ ។ ជាក់ស្តែងតម្លៃអាហារនៅក្នុងប្រទេសកម្ពុជាមានកំណើនខ្ពស់បំផុតក្នុងអំឡុងពេល ៦ ខែ ដំបូងនាឆ្នាំ២០០៨ ។ សកម្មភាព និងនិន្នាការទាំងអស់នេះ បានកើតឡើងព្រមគ្នាក្នុងពេលវិបត្តិប្រេង និងហិរញ្ញវត្ថុពិភពលោកកំពុងបានរាលដាល ។

តាមការរកឃើញរបស់វិទ្យាស្ថានជាតិស្ថិតិ (វ.ជ.ស) តម្លៃអាហារ បានចាប់ផ្តើមឡើងថ្លៃក្នុងរង្វង់ខែ ឧសភា ឆ្នាំ២០០៧ ដល់ ខែឧសភា ឆ្នាំ២០០៨ រីឯសន្ទស្សន៍នៃការប្រែប្រួលគឺ ៤៩ ភាគរយ ។ សន្ទស្សន៍ថ្លៃគ្រប់មុខទំនិញប្រើប្រាស់ បានចាប់កើនឡើងខ្លាំងសម្រាប់ខែមករា ឆ្នាំ២០០៨ ។ ជាមួយគ្នានេះដែរ ***តម្លៃអាហារ*** ភេសជ្ជៈ និងថ្នាំជក់ បានហក់ឡើងយ៉ាងគំហុកធៀបនឹងទំនិញប្រើប្រាស់ផ្សេងៗទៀត (សៀវភៅសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ ឆ្នាំ២០០៨) ។

យ៉ាងណាមិញ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ប្រចាំខែដែលខ្ពស់ជាងគេបំផុតនាឆ្នាំ២០០៨ គឺក្នុងខែឧសភា ក្នុងអត្រាប្រមាណ ២៦ ភាគរយ ប៉ុន្តែសន្ទស្សន៍ខ្ពស់ បានធ្លាក់ចុះមកត្រឹមកម្រិត ១៦ ភាគរយនាខែវិច្ឆិកា ឆ្នាំ២០០៨ ធៀបនឹងឆ្នាំ២០០៧ និងបានបន្តធ្លាក់ចុះមកនៅត្រឹមកម្រិតអវិជ្ជមាន (-០.៧ ភាគរយ) សម្រាប់ខែមីនា ឆ្នាំ២០០៩ (សៀវភៅសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ ខែមីនា ឆ្នាំ២០០៩) ។ និន្នាការធ្លាក់ចុះក្នុងខែមីនា ឆ្នាំ២០០៩នេះ មួយផ្នែកធំដោយសារតែតម្លៃសន្ទស្សន៍ថ្លៃប្រើប្រាស់របស់ទំនិញចម្បងមួយចំនួន បានបន្តធ្លាក់ចុះចាប់តាំងពីចុងឆ្នាំ២០០៨មក ។ តម្លៃប្រេងឥន្ធនៈបន្តចុះថោក (អគ្គិសនី ហ្គាស និងឥន្ធនៈផ្សេងៗមាន -១១.៦ ភាគរយ ក្នុងនោះតម្លៃប្រេងសាំងធម្មតាមាន -៣៤.៣ ភាគរយ និងការដឹកជញ្ជូនក្នុងចំនួន -១៦.៧ ភាគរយ) ។ ការកើនទិន្នផលកសិកម្ម (រដូវប្រមូលកាត់ និងនេសាទ) មានដូចជា : សន្ទស្សន៍ថ្លៃអង្ករបានធ្លាក់ចុះដល់ -៩.៦ ភាគរយ ។ និងកត្តាកើនឡើងនូវការផ្គត់ផ្គង់ម្ហូបអាហារលើទីផ្សារ (សាច់ -៧.៨ ភាគរយ សាច់ជ្រូក -១៦ ភាគរយ និងត្រី -៤.៦ ភាគរយ ។

ការវិវត្តិនៃការឡើងចុះយ៉ាងលឿននៃតម្លៃប្រេងឆៅ ការប្រែប្រួលតម្លៃម្ហូបអាហារ កង្វះខាតស្បៀងអាហារ និងការផ្ទុះឡើងនូវវិបត្តិទីផ្សារហិរញ្ញវត្ថុរបស់ពិភពលោកថ្មីៗនេះ មិនមែនគ្រាន់តែជាបញ្ហាចម្បងធំៗ ដែលកម្ពុជាត្រូវប្រឈមមុខនោះទេ ប៉ុន្តែកត្តាទាំងអស់នេះអាចទំនងនឹងប្រែក្លាយទៅជាផលប៉ះពាល់ដែលអាចធ្វើឱ្យគ្រួសារក្រីក្រខ្លះ ក្លាយទៅជាជនងាយរងគ្រោះខ្លាំង និងខ្វះខាតបរិមាណអាហារ ដែលជាធម្មតាគ្រួសារទាំងនោះបានចំណាយប្រហែលជា ៧០ ភាគរយ ពីចំណូលរបស់ពួកគាត់ទៅលើម្ហូបអាហារ ។

ដើម្បីឆ្លើយតបទៅនឹងកំណើនខ្ពស់នៃថ្លៃម្ហូបអាហារ ក្រុមគ្រួសារខ្លះបានស្វែងរកការងារធ្វើបន្ថែម ដើម្បីទទួលបានចំណូលល្មមទប់ទល់នឹងការចំណាយច្រើនជាងមុន ។ ក្រុមគ្រួសារមួយចំនួនអាចជ្រើសរើសទិញអាហារណាដែលមានតម្លៃថោក ដែលទំនងមិនមានជីវជាតិគ្រប់គ្រាន់ និងមានកម្រិតអាហារូបត្ថម្ភតិចជាងមុន ។ បន្ទាប់មកមានគ្រួសារខ្លះ បានបន្ថយនូវបរិមាណម្ហូបអាហារបរិភោគ ដែលជាហេតុបង្កឱ្យមានផលប៉ះពាល់ដល់សុខភាព និងអាចធ្វើឱ្យសមាជិកគ្រួសារ ជាពិសេសកុមារតូចៗទទួលរងនូវអាហារូបត្ថម្ភខ្សត់ខ្សោយ ។ តាមរយៈសម្មតិកម្មដែលបានពោលខាងលើនេះ យើងអាចកំណត់បានថា យុទ្ធសាស្ត្រដែលក្រុមគ្រួសារមួយចំនួន បានដោះស្រាយទប់ទល់នឹងការកើនឡើងថ្លៃចំណីអាហារ ទំនងផ្តល់នូវចំណុចជាអវិជ្ជមាន ដូចជា : កង្វះជីវជាតិអា ជាតិដែក សារជាតិស័ង្កសី ជាតិអ៊ីយ៉ូដ ប្រូតេអ៊ីន និងថាមពល និងការកើនឡើងប្រភេទជម្ងឺនានា ។ ហើយអ្វីដែលជាបន្ទុកធ្ងន់ធ្ងរដល់គ្រួសារ និងប្រទេសជាតិនោះ គឺការធ្លាក់ចុះផលិតភាពផលិតរបស់គ្រួសារ និងការបាត់បង់ផ្នែកសេដ្ឋកិច្ចដ៏ធំមួយ ។

និន្នាការនៃវិបត្តិស្បៀងអាហារ ទំនងជាធ្វើឱ្យយឺតយ៉ាវដល់វឌ្ឍនភាពសកលលោកឆ្ពោះទៅរកការសម្រេចគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ក្នុងនោះគោលដៅទី៤ គឺការកាត់បន្ថយអត្រាមរណភាពកុមារ ។ នៅក្នុងប្រទេសកម្ពុជា ត្រូវបានប៉ាន់ស្មានថាប្រហែលជា ៣០ ភាគរយ នៃអត្រាមរណៈភាពរបស់កុមារ គឺបណ្តាលមកពីបញ្ហាកង្វះអាហារូបត្ថម្ភ ។ ហើយគោលដៅទី៥ គឺលើកកម្ពស់សុខភាពមាតា ។

ឆ្លើយតបនឹងវិបត្តិកើនឡើងថ្លៃម្ហូបអាហារ រាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍ សហគមន៍អឺរ៉ុប ក៏ដូចជាអង្គការក្រៅរដ្ឋាភិបាលនានា បានស្វះស្វែងរកវិធានការជាច្រើន ជាពិសេសការផ្តល់ប្រាក់កម្ចី និងជំនួយឥតសំណងដែលទាក់ទងជាមួយការងារសង្គ្រោះបន្ទាន់ ក្នុងន័យជួយសម្រាលបន្ទុកប្រជាជនក្រីក្រកម្ពុជាដែលកំពុងត្រូវការស្បៀង និងដើម្បីជៀសវាងនូវបញ្ហាកង្វះមីក្រូសារជាតិសម្រាប់ក្រុមគ្រួសារក្រីក្រ ពីព្រោះថាអសន្តិសុខស្បៀងគ្រួសារយូរអង្វែង បង្កជាកង្វះអាហារូបត្ថម្ភដែលអាចរួមចំណែកបំផ្លាញនូវកោសិកាលូតលាស់របស់កុមារជាដើម ។

សកម្មភាពទិសដៅរយៈពេលខ្លីសំខាន់ៗ របស់រាជរដ្ឋាភិបាលក្នុងខែឧសភា ឆ្នាំ២០០៨ មានដូចជា : ការអនុញ្ញាតឱ្យនាំចូលមកវិញនូវសត្វជ្រូកពីប្រទេសជិតខាង ការហាមនាំស្រូវចេញទៅក្រៅប្រទេស លើកលែងតែតាមបណ្តាខេត្តចំនួន ៣ គឺខេត្តកណ្តាល ព្រៃវែង និងតាកែវ ដែលស្ថិតនៅជាប់ព្រំដែនវៀតណាម ការបង្កើនប្រាក់បន្ថែមដល់មន្ត្រីរាជការ និងការលក់អង្ករជូនដល់ប្រជាជន (ឧបត្ថម្ភធន) តាមរយៈកិច្ចពីធនាគារអភិវឌ្ឍន៍ជនបទ (ធ.អ.ជ) ក្នុងតំលៃថោកជាងទីផ្សារ ។

ការឆ្លើយតបទៅនឹងការឡើងថ្លៃនៃម្ហូបអាហារតាមរយៈគម្រោងសុវត្ថិភាពស្បៀង ដែលជាជំនួយឥតសំណងចំនួន ៤លាន អឺរ៉ូ របស់សហគមន៍អឺរ៉ុប (ស.អ) ការចែកអង្ករដល់គ្រួសារក្រីក្រ និងគ្រួសារងាយរងគ្រោះនៅតាមខេត្តជុំវិញបឹងទន្លេសាប ដែលបានមកពីថវិកាបដិភាគរវាងរាជរដ្ឋាភិបាលកម្ពុជា ចំនួន ៥លាន ដុល្លារ និងធនាគារអភិវឌ្ឍន៍អាស៊ី (ធ.អ.អ) ក្នុងនោះកម្ចីមាន ១៧.៥លាន ដុល្លារ និង ជំនួយឥតសំណងចំនួន ១៧.៥លាន ដុល្លារ គឺជាវិធានការដែលត្រូវបានគិតថាជាជោគជ័យសម្រាប់សម្រាលនូវបន្ទុកកង្វះម្ហូបអាហារ ក៏ដូចជាអាហារូបត្ថម្ភខ្សត់ខ្សោយ ។

ផ្ទុយទៅវិញ យោងតាមទិដ្ឋភាពជាក់ស្តែងដែលថាប្រជាជនកម្ពុជាភាគច្រើនពឹងផ្អែកលើផលិតផលរបស់ខ្លួនជាពិសេសអាហារបរិភោគ នោះយើងអាចទាញនូវសម្មតិកម្មខ្លះថា បើទោះបីជាអតិផរណាមានកំណើនខ្ពស់ ក៏វានឹងមិនមែនជាបញ្ហាប៉ះពាល់ខ្លាំងដល់ប្រជាជនកម្ពុជាទាំងមូលដែរក្នុងស្ថានភាពអាហារូបត្ថម្ភ ។ កង្វះអាហារូបត្ថម្ភពុំមែនគ្រាន់តែបណ្តាលមកពីកង្វះចំណីអាហារប៉ុណ្ណោះទេ ប៉ុន្តែក៏អាចបណ្តាលមកពីខ្វះការថែទាំគ្រប់គ្រងពីមាតាបិតា ការផ្តល់អាហារមិនសមស្របទៅឱ្យកុមារតូច ជម្ងឺកុមារកើតឡើងភ្លាមៗ ខ្វះលទ្ធភាពទទួលបានសេវាសុខភាព កង្វះខាតនូវអនាម័យ និងពុំមានការប្រើប្រាស់ទឹកស្អាតផងដែរ ។

របាយការណ៍លទ្ធផលនេះ ត្រូវបានរៀបចំជារចនាសម្ព័ន្ធដូចតទៅ : សូចនាករ និងការពន្យល់ទូទៅអំពីលទ្ធផលអង្កេតរបស់មនុស្សមាត្រកុមារ និងស្ត្រីជម្ងឺខ្វាក់មាន់របស់ស្ត្រីមានផ្ទៃពោះ ក៏ដូចជាជម្ងឺរបស់កុមារដែលមានអាយុក្រោម ៥ ឆ្នាំ និងអំពីយុទ្ធសាស្ត្រដោះស្រាយបន្ទាន់ និងការប្រើប្រាស់អាហាររបស់គ្រួសាររងគ្រោះ ក្នុងអំឡុងពេលវត្តមានម្ហូបអាហារឡើងថ្លៃ នឹងត្រូវបានលើកយកមកពិភាក្សាក្នុងជំពូកទី ១ ។ ជំពូកទី ២ ផ្តោតលើសូចនាករបន្ថែមលើមនុស្សមាត្រកុមារ ស្ត្រី និងជម្ងឺឆ្លងកុមារនៅថ្នាក់ក្រោមជាតិ ។ ជំពូកទី ៣ ធ្វើការណែនាំ ក៏ដូចជាការបង្ហាញនូវរបៀបផ្តល់អាហារបន្ថែមដល់ទារក និងកុមារតូច ។ ជំពូកបន្ទាប់នោះ គឺសេវាសុខភាពអាហារូបត្ថម្ភដល់កុមារ និងស្ត្រីដែលជាមាតា ។ រីឯសេចក្តីសន្និដ្ឋាន និងអនុសាសន៍ ស្ថិតនៅក្នុងជំពូកទី ៥ ។ វិធីសាស្ត្រនៃការធ្វើអង្កេតមនុស្សមាត្រ ត្រូវបានបកស្រាយក្នុងជំពូកទី ៦ ។ និងបន្ទាប់មក គឺឧបសម្ព័ន្ធនានា ។

# ស្ថានភាពទូទៅរបស់អង្គការ

## របៀបជ្រើសរើសប៉ាន់គំរូ

ការជ្រើសរើសប៉ាន់គំរូរបស់អង្កេតមនុស្សមាត្រ ឈរលើមូលដ្ឋានដ៏ត្រឹមត្រូវបំផុតសម្រាប់គោលបំណងនានារបស់អង្កេត ។ ក្នុងន័យនេះដែរ គោលបំណងនិមួយៗ ផ្ដើមចេញពីសកម្មភាពដែលជាតម្រូវការចាំបាច់ ហើយសកម្មទាំងអស់នោះ ត្រូវបានកំណត់ទុកយ៉ាងច្បាស់លាស់ទៅតាមប្រភេទទិន្នន័យរបស់សូចនាករ ។ យ៉ាងណាមិញ បន្ទាប់ពីសកម្មភាពនៃការចុះបញ្ជីគ្រួសារនិមួយៗទៅតាមប្រភេទអង្កេតបែបម៉ាទ្រីសត្រូវបានបញ្ចប់សព្វគ្រប់រួចមក សំណួរខ្លះនៅក្នុងតារាងម៉ាទ្រីសខាងក្រោម ត្រូវបានជ្រើសរើស ដើម្បីជាផ្លូវទៅរកភាពជោគជ័យរបស់សកម្មភាព ហើយជ្រើសរើសទិន្នន័យណាដែលជាតម្រូវការសម្រាប់ឆ្លើយតបនឹងសំណួររបស់គោលបំណងប៉ុណ្ណោះ ។

**តារាង១៣ : ម៉ាទ្រីសនៃការធ្វើផែនការសម្រាប់អង្កេត**

| សកម្មភាព | ពត៌មាន<br>តាមរយៈសំណួរស្រាវជ្រាវ | ទិន្នន័យ |
|---|---|---|
| | **គោលបំណងសំខាន់ៗ** | |
| **ណែនាំពីប្រភេទចាំបាច់សម្រាប់ការអន្តរាគមន៍** | • គឺជាស្ថានការបន្ទាន់ ឬក៏គួរតែសង្កត់ធ្ងន់ទៅលើគោលដៅរយៈពេលមធ្យម/វែង?<br><br>តើកំណើនថ្លៃម្ហូបអាហារ ធ្វើឱ្យកើនឡើងចំនួនកុមារកង្វះអាហារូបត្ថម្ភ ឬក៏បន្ថយល្បឿនការសម្រេចបានតាមគោលដៅគ្រោងទុកដែរឬទេ? | • មនុស្សមាត្រស្ត្រី និងកុមារ<br>• អាហារចម្រុះ និងការប្រើប្រាស់ម្ហូបអាហាររបស់ម្ដាយ និងកុមារ<br>• យុទ្ធសាស្ត្រដោះស្រាយបន្ទាន់<br>• បញ្ហាកង្វះខាតមីក្រូសារជាតិ<br>• ជម្ងឺឆ្លងនានារបស់ក្មេង |
| **ណែនាំពីកន្លែងចាំបាច់សម្រាប់អន្តរាគមន៍** | • តើមានខេត្តណាខ្លះដែលកើនឡើងនូវអត្រាកង្វះខាតអាហារូបត្ថម្ភជាទ្រង់ទ្រាយធំដែរឬទេ?<br>• តើខេត្តមួយណា ដែលមាននូវកម្រិតកង្វះខាតអាហារូបត្ថម្ភខ្ពស់បំផុត?<br>• តើខេត្តមួយណាដែលមានចំនួនខ្វះខាតអាហារូបត្ថម្ភច្រើនជាងគេ?<br>• តើស្ថានការណ៍បច្ចុប្បនបានធ្វើឱ្យប៉ះពាល់ជាអវិជ្ជមានដល់តំបន់ប្រជុំជនក្រីក្រដែរឬទេ? | • ថ្នាក់ខេត្ត និងតំបន់ទីប្រជុំជន និងទីជនបទ<br>• ការជ្រើសរើសចំនួនលើស តំណាងតំបន់ប្រជុំជនក្រីក្រ |
| **ណែនាំពីជនប្រភេទណាដែលជាក្រុមគោលដៅសម្រាប់ទទួលបានការអន្តរាគមន៍** | • តើការកើនឡើងថ្លៃម្ហូបអាហារ បង្កផលប៉ះពាល់ខុសគ្នាដែរឬទេ ដល់ក្រុមសេដ្ឋកិច្ច-សង្គមកិច្ច?<br>• តើការកើនឡើងថ្លៃម្ហូបអាហារ បង្កផលប៉ះពាល់ខុសគ្នាដែរឬទេ ដល់កសិករ និងអ្នកប្រកបការងារដើម្បីប្រាក់ខែ? | • អង្កេតសេដ្ឋកិច្ច-សង្គមកិច្ច<br>• មុខរបរ<br>• ការទិញអង្ករ/បំណុល |

| | | |
|---|---|---|
| | • តើការកើនឡើងថ្លៃម្ហូបអាហារ បង្កផលប៉ះពាល់ខុសគ្នាដែរឬទេ ដល់ក្រុមដោះដូរទាំងអ្នកផលិត និងអ្នកប្រើប្រាស់អង្ករ?<br>• តើក្រុមកុមារដែលមានអាយុផ្សេងៗគ្នា ទទួលផលប៉ះពាល់ខុសគ្នាដែរឬទេ? | |
| **ណែនាំអំពីអន្តរាគមន៍អាហារូបត្ថម្ភផ្នែកណាដែលគួរតែត្រូវបន្ថែម** | • តើការផ្តល់គ្រាប់ថ្នាំវីតាមីនអាបន្ថែម មានគ្រប់គ្រាន់ដែរឬទេ?<br>• តើការផ្តល់គ្រាប់ថ្នាំទម្លាក់ព្រូន មានការគ្របដណ្តប់ទូទាំងប្រទេសគ្រប់គ្រាន់ដែរឬទេ?<br>• តើការផ្តល់បន្ថែមគ្រាប់ថ្នាំជាតិដែកហ្វូលិកអាស៊ីដ មានការគ្រប់ដណ្តប់ទូទាំងប្រទេសគ្រប់គ្រាន់ដែរឺទេ?<br>• តើអំបិលជាតិអ៊ីយ៉ូដ មានការគ្រប់ដណ្តប់ទូទាំងប្រទេសគ្រប់គ្រាន់ដែរឬទេ? | • ការឧបត្ថម្ភបន្ថែម មីក្រូសារជាតិសម្រាប់មាតា និងទារក<br>• អំបិលជាតិអ៊ីយ៉ូដតាមគ្រួសារ |

ដើម្បីធ្វើការប៉ាន់ស្មានភាពក្រីក្រ ឬខ្សត់ខ្សោយនៅតាមតំបន់ទីប្រជុំជននានារបស់ប្រទេសកម្ពុជា អង្កេតមនុស្សមាត្រមានវិធីសាស្ត្រជ្រើសរើសគំរូចំនួនពីរដាច់ដោយឡែកពីគ្នា ។ ការធ្វើដូច្នេះបានផ្តល់នូវសារៈសំខាន់ ពីព្រោះតែតារាងបញ្ជីមានភាពខុសគ្នាពីមួយទៅមួយ ។ គោលបំណងសម្រាប់ជ្រើសរើសគំរូតំណាងសម្រាប់ថ្នាក់ជាតិ គឺជាការជ្រើសរើស "គំរូបឋម" ។ ខណៈពេលដែលការជ្រើសរើសគំរូតំណាងសម្រាប់ភាពក្រីក្រ ឬខ្សត់ខ្សោយនៅតាមតំបន់ទីប្រជុំជន គឺត្រូវបានហៅថា "គំរូទី២"។

របៀបជ្រើសរើសគំរូបឋម គឺជាក្រុមអង្កេតដែលរៀបចំជាលំដាប់ថ្នាក់ជាក់ស្តែងតាមខេត្ត (តំបន់) និងម្យ៉ាងទៀត គឺជាការរៀបចំតាមស្រុក និងឃុំ ។ គោលបំណងចំនួនពីរសំខាន់របស់អង្កេត : (១)- ធ្វើការប៉ាន់ស្មានកុមារកង្វះអាហារូបត្ថម្ភនៅតាមបណ្តាខេត្តក្នុងការកំណត់គោលដៅអន្តរាគមន៍ ។ (២)- ចង្អុលបង្ហាញខេត្តណាមួយ ដែលមានចំនួនកុមារកង្វះអាហារូបត្ថម្ភកើនឡើងខ្ពស់ធៀបនឹងឆ្នាំ ២០០៥ កន្លងមក ។ ការប្រៀបធៀបអង្កេតមនុស្សមាត្រកម្ពុជាមួយនឹងអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ឆ្នាំ២០០៥ ទៅតាមតំបន់ដូចគ្នា មានដូចជា :

- ខេត្ត/ក្រុងចំនួន ១៤ មាន បន្ទាយមានជ័យ កំពង់ចាម កំពង់ឆ្នាំង កំពង់ស្ពឺ កំពង់ធំ កណ្តាល ក្រចេះ ភ្នំពេញ ព្រៃវែង ពោធិសាត់ សៀមរាប ស្វាយរៀង តាកែវ និងឧត្តរមានជ័យ

- ខេត្តផ្សេងៗដែលរួមបញ្ចូលគ្នាមានចំនួន ៥ ដូចជា : បាត់ដំបង/ប៉ៃលិន កំពត/កែប សីហនុ/កោះកុង ព្រះវិហារ/ស្ទឹងត្រែង និងមណ្ឌលគិរី/រតនៈគិរី

របៀបជ្រើសរើសគ្រួសារពី ១៩ខេត្ត-ក្រុងតាមតំបន់សម្រាប់សម្ភាសន៍ចែកចេញជា ២ ដំណាក់កាល ។

១. ដំណាក់កាលទី១ : តំបន់សម្ភាសន៍ ដោយយកលំនាំតាមជំរឿនទូទៅនៃប្រជាជនកម្ពុជា ឆ្នាំ ២០០៨ ត្រូវបានជ្រើសរើសដោយផ្អែកលើសមាមាត្រនៃប្រូបាបីលីតេទៅនឹងទំហំ ។

២. ដំណាក់កាលទី២ : គ្រប់គ្រួសារដែលនៅតំបន់សម្ភាសន៍យ៉ាងតិចមាន ២០០ គ្រួសារត្រូវបាន ចុះបញ្ជីគ្រួសារ ។ គ្រួសារដែលមានកុមារអាយុក្រោម ៥ឆ្នាំ ត្រូវបានរាប់បញ្ចូលសម្រាប់ការ យក១០គ្រួសារមកសម្ភាសន៍ដោយវិធីសាស្ត្រព្រាវ ។ ចំពោះកម្រងសំណួរកុមារដែលមានម្ដាយ ឬអ្នកថែទាំមានលក្ខណៈដាច់ដោយឡែកពីគ្នា ។

ទំហំជ្រើសរើសគំរូ ត្រូវបានកំណត់ដោយការប្រើប្រាស់របៀបគណនាយ៉ាងត្រឹមត្រូវទៅតាម គោលបំណងរបស់អង្កេតមនុស្សមាត្រ ពីព្រោះថាអង្កេតនេះ សង្កត់ធ្ងន់លើថ្លៃខ្ពស់នៃអាហារបង្កជា ផលប៉ះពាល់ដល់និន្នាការប្រែប្រួលកង្វះអាហារូបត្ថម្ភរបស់កុមារចាប់តាំងពីឆ្នាំ២០០០ មកដល់ពេល បច្ចុប្បន្នកាល ។ ទំនាក់ទំនងនានា ត្រូវបានគណនាដោយការទាញយកទិន្នន័យចេញពី អ.ប្រ.ស.ក ២០០៥ និងត្រូវបានព្យាករណ៍ថាផ្តល់មកវិញនូវផលប៉ះពាល់ប្រហែល ១.៣១ ។ ជារួមទំហំជ្រើសរើស គំរូ បង្ហាញនូវអត្រាភាគរយរបស់ភាពស្គមមានការប្រែប្រួលចំនួន ២ ចាប់តាំងពីឆ្នាំ២០០៥ មក ។

$$Power = \varphi\lfloor\Delta\rfloor \Big/ \sqrt{C(p_1q_1/M_1 + p_2q_2/M_2)} - z_{1-\alpha}\frac{\sqrt{\bar{p}\bar{q}(1/M_1 + 1/M_2)}}{\sqrt{p_1q_1/M_1 + p_2q_2/M_2}}$$

Where:

$C$=design effect or 1 + (n- 1)ϱ, where n=sample size per cluster and ϱ=intra-class correlation

$M$=sample size

$p$=proportion wasted

ការកំណត់យក ១០ គ្រួសារក្នុងមួយមណ្ឌលអង្កេត ហើយចំនួនទំហំជ្រើសរើសគំរូទាំងអស់ មាន ៧៦០០ មណ្ឌល និងបានជ្រើសរើសមណ្ឌលចំនួន ៤០ ក្នុងមួយខេត្ត ហើយទាមទារសម្រេចឱ្យបាន ចំនួន ៩០ ភាគរយ ។ ការជ្រើសរើសគំរូលើកទី២ បង្ហាញពីការជ្រើសរើសគំរូភាពខ្សត់ខ្សោយ ឬ

ភាពក្រីក្រតាមតំបន់ទីប្រជុំជន ដោយផ្អែកលើមូលដ្ឋានតំបន់មួយ សម្រាប់ការជ្រើសរើសគំរូបឋម ។ គំរូទាំងមូលមាន ៤០០គ្រួសារ ដោយជ្រើសរើសពី ៤០មណ្ឌល ។ ដើម្បីរកនូវចំណុចខុសគ្នារវាងគំរូទី ២ និងគំរូបឋម គឺផ្អែកលើរូបមន្តតែមួយដូចគ្នាចេញពី ROSNER ហើយរបៀបដូចគ្នាក៏ត្រូវបានប្រើប្រាស់ក្នុងការជ្រើសរើសគំរូបឋមដែរ ។ ជាមួយនឹងគំរូគ្រួសារចំនួន ៤០០ ពី ៤០មណ្ឌលអង្កេត ហើយបានរកឃើញអត្រាភាគរយខុសគ្នារបស់ភាពស្គមចំនួន ៥ របស់គំរូបឋម និងការជ្រើសរើសគំរូទី ២ មានអត្រាភាគរយចំនួន ០.៨៦ ។

## តារាងសំណួរអង្កេត

តារាងសំណួរអង្កេតត្រូវបានធ្វើឡើងដើម្បីតាមដាន និងសិក្សាវិភាគលើនិន្នការប្រែប្រួលដែលកើតមានឡើងរបស់សូចនាករនិមួយៗ ។ សំណួរអង្កេតខ្លះផ្អែកទាំងស្រុងតាមសំណួររបស់អង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ឆ្នាំ២០០៥ ។ សំណួរជាច្រើនត្រូវបានប្រើប្រាស់សម្រាប់គណនាសូចនាករទាំងឡាយដែលមាននៅក្នុងអង្កេតមនុស្សមាត្រ និងអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ឆ្នាំ២០០៥ ។

ការប្រមូលទិន្នន័យតាមរយៈសំណួរអង្កេតក្នុងអំឡុងពេលសម្ភាសន៍មានរយៈពេលចំនួន ១ខែ ។ សំណួររបស់ អ.ម.ក ២០០៨ ចែកចេញជា ៣ ផ្នែក ដែលមានដូចជា : គ្រួសារ កុមារ និងមាតា ។ ផ្នែកគ្រួសាររួមបញ្ចូលនូវការចុះបញ្ជីគ្រួសាររបស់ស្ត្រី រង្វាស់មនុស្សមាត្ររបស់ស្ត្រី សំណួរទាក់ទងនឹងលក្ខណៈ ប្រវត្តិសង្គមកិច្ច-សេដ្ឋកិច្ច និងយុទ្ធសាស្ត្រដោះស្រាយបន្ទាន់នឹងបញ្ហាចំពោះមុខ ។ ផ្នែកកុមារមានដូចជា : កុមារដែលបានជ្រើសរើសត្រូវតែមានវត្តមាននៅក្នុងបញ្ជីគ្រួសារ និងរង្វាស់មនុស្សមាត្រកុមារ ។ ផ្នែកផ្សេងៗរបស់កុមារ គឺបំបែកទៅតាមអាយុរបស់មាតាដែលមានអាយុចន្លោះពី ១៥-៤៩ឆ្នាំ នៅ ក្នុងរង្វង់គ្រួសារ ។ ផ្នែកចុងក្រោយបង្អស់ ខុសគ្នាទៅតាមលក្ខណៈប្រវត្តិ (ក្រុមអាយុ ភេទ កម្រិតធនធានទ្រព្យសម្បត្តិ ។ល។) ជម្ងឺកុមារ សេវាថែទាំសុខភាព និងការប្រើប្រាស់អាហារ ។

ផ្ទុយទៅវិញ សម្រាប់សូចនាករខ្លះរបស់ អ.ម.ក ២០០៨ មានភាពខុសគ្នាបន្តិចពីអង្កេតមុនៗ ដូចជា អ.ប្រ.ស.ក ២០០៥ ពីព្រោះតែប្រជាជនគោលនៃសូចនាករមួយចំនួនខុសគ្នា ។ សរុបមក រាល់ការប្រៀបធៀបដែលបានធ្វើឡើងនៅក្នុងរបាយការណ៍នេះ គឺជារបាយការណ៍ព្យាករណ៍បែបប្រៀបធៀប ។ ពត៌មានលម្អិតអំពីរបៀបវិភាគ មាននៅក្នុងជំពូក ***វិធីសាស្ត្រនៃការវិភាគ*** ។

ការចុះសម្ភាសន៍សាកល្បងចាប់ប្រព្រឹត្តពីថ្ងៃទី២៧ ដល់ ២៩ ខែតុលា ឆ្នាំ២០០៨ ។ មន្ត្រីសម្ភាសន៍សុទ្ធតែមានបទពិសោធន៍ពីអង្កេតមុនៗ ដូចជា អង្កេតសង្គមកិច្ច-សេដ្ឋកិច្ចកម្ពុជា ជាដើម ។ ម៉្យាងទៀតមន្ត្រីទាំងអស់បានឆ្លងកាត់វគ្គបណ្តុះបណ្តាលរយៈពេលចំនួន ៣ថ្ងៃ គឺចាប់ពីថ្ងៃទី៣ ដល់ ៥ ខែវិច្ឆិកា ឆ្នាំ២០០៨ ។ វគ្គបណ្តុះបណ្តាលផ្តោតលើការជ្រើសរើសប៉ាន់គំរូ ការឱ្យមន្ត្រីសម្ភាសន៍យល់ច្បាស់ពីតារាងសំណួរ និងរបៀបនៃការវាស់វែងមនុស្សមាត្រ ។ ការប្រមូលទិន្នន័យចាប់ផ្តើមពីថ្ងៃទី៦ខែវិច្ឆិកា ដល់ បំណាច់ខែវិច្ឆិកា ឆ្នាំ២០០៨ ។ ប៉ុន្តែដោយសាររដូវវស្សាអូសបន្លាយពេលយូរ អង្កេតមិនបានចប់សព្វគ្រប់តាមការកំណត់ទុក ដោយនៅសល់ភូមិចំនួន ២ ទៅ ៣ ដែលមិនបានសម្ភាសន៍ ។ ការសម្ភាសន៍សម្រាប់ភូមិដែលនៅសល់ត្រូវបានបន្តនាពាក់កណ្តាលខែធ្នូ និងត្រូវបានបញ្ចប់ជាស្ថាពរចុងខែដដែល ។

មន្ត្រីបញ្ចូលទិន្នន័យ មានការយល់ច្បាស់ពីតារាងសំណួរអង្កេតនេះ ក៏ព្រោះតែមន្ត្រីទាំងអស់បានចូលរួមក្នុងវគ្គបណ្តុះបណ្តាលនាពេលកន្លងមក ។ ការសរសេរកម្មវិធីបញ្ចូលទិន្នន័យបានប្រើប្រាស់នូវកម្មវិធី SQL សម្រាប់បង្រួមនូវកំហុសឆ្គងក្នុងពេលបញ្ចូលទិន្នន័យ ។ មន្ត្រីបញ្ចូលទិន្នន័យមានចំនួន ២០ នាក់ ដោយចាប់ដំណើរការបញ្ចូលទិន្នន័យពីដើមខែធ្នូ ឆ្នាំ២០០៨ និងបានបញ្ចប់នូវពេលពាក់កណ្តាលខែកុម្ភៈ ឆ្នាំ២០០៩ ។

# ជំពូកទី១

# បណ្ដាសូចនាករសម្រាប់ចាត់ថ្នាក់បន្ទាន់

ជំពូកនេះ ផ្តោតទៅលើសូចនាករសំខាន់ៗ ដែលទាក់ទងនឹងស្ថានភាពអាហារូបត្ថម្ភរបស់កុមារ និងស្ត្រីក្នុងអំឡុងពេលមុនអង្កេត និងទំនាក់ទំនងនៃបញ្ហាទំនិញ និងអាហារឡើងថ្លៃជាមួយយុទ្ធសាស្ត្រឆ្លើយតបបន្ទាន់ ។ កង្វះអាហារូបត្ថម្ភរបស់កុមារ និងស្ត្រីនឹងបង្ហាញនៅក្នុងសូចនាករមនុស្សមាត្រ ក៏ដូចជា ទំនាក់ទំនងរវាងសុខភាព និងកង្វះអាហារូបត្ថម្ភ ។

ចំនុចនេះក៏ផ្តោតផងដែរ លើការសិក្សានូវទំនាក់ទំនងរវាងមាតា និងកុមារក្នុងស្ថានភាពអាហារូបត្ថម្ភល្អដោយសំអាងលើសូចនាករមនុស្សមាត្រ និងសន្ទស្សន៍សមាសភាពរាង្គកាយ ។ ការមានអាហារូបត្ថម្ភគ្រប់គ្រាន់បរិបូរណ៍ គឺជាកត្តាល្អសម្រាប់ការរួចផុតពីភាពក្រិន កង្វះទម្ងន់ ស្គម និងជម្ងឺនានា និងអាចធ្វើឱ្យគ្រួសាររួចផុតពីការចំណាយធនធានខ្ពស់សម្រាប់គាំពារសុខភាពក្នុងពេលដែលថ្លៃទំនិញ និងអាហារកើនឡើងខ្ពស់ ។

ទំនិញ និងម្ហូបអាហារឡើងថ្លៃខ្ពស់ ក៏ដូចជាអសន្តិសុខស្បៀងដោយអន្លើ បានធ្វើឱ្យក្រុមគ្រួសារខ្លះរិះរកមធ្យោបាយមួយចំនួនដែលមានលក្ខណៈងាយស្រួល និងអាចបត់បែនបាន ដើម្បីឆ្លើយតបបន្ទាន់ និងសម្រួលដល់ការរស់នៅ និងការរស់រានមានជីវិត ។ ផ្ទុយទៅវិញទោះបីជាមិនមានបំណងក្តីមធ្យោបាយនោះ អាចធ្វើឱ្យសមាជិកខ្លះក្នុងគ្រួសារជួបប្រទះនូវផលប៉ះពាល់ពីកង្វះអាហារូបត្ថម្ភ និងបញ្ហាកង្វះមីក្រូសារជាតិ ។ យ៉ាងណាមិញ សន្ទស្សន៍យុទ្ធសាស្ត្រឆ្លើយតបបន្ទាន់ដែលបានយកមកប្រើប្រាស់ គឺជាសូចនាករសំខាន់សម្រាប់តាមដាន និងវិភាគលើស្ថានភាពអាហារូបត្ថម្ភ និងសន្តិសុខស្បៀងរបស់គ្រួសារ ។

## ១. មនុស្សមាត្រ និងកង្វះមីក្រូសារជាតិ

ដើម្បីកំណត់បាននូវរូបរាងខុសគ្នារបស់កុមារដែលមានអាយុក្រោម ៥ ឆ្នាំ និងគ្រប់ស្ត្រីដែលមានអាយុចន្លោះពី ១៥ ទៅ ៤៩ ឆ្នាំ រង្វាស់មនុស្សមាត្រនានាត្រូវបានយកមកប្រើប្រាស់ និងធ្វើការបកស្រាយបន្ថែមទៅតាមសាវតាររបស់អង្កេត ។ ជាធម្មតា ការកំណត់អត្ថន័យ និងនិយមន័យនៃកង្វះអាហារូបត្ថម្ភ គឺជារឿងពិបាកនៅពេលដែលគ្មានវិធីសាស្ត្រត្រឹមត្រូវសម្រាប់វាស់លើខ្លួនមនុស្ស ។ វិធីសាស្ត្រមនុស្សមាត្រកុមារដែលមានអាយុក្រោម ៥ ឆ្នាំ គឺសំដៅលើកម្ពស់ធៀបនឹងអាយុ (ទាប/ខ្ពស់) ទម្ងន់ធៀបនឹងកម្ពស់ (ធាត់/ស្គម) និងទម្ងន់ធៀបនឹងអាយុ (លើស/ខ្វះទម្ងន់) ពិន្ទុក្រោម២ នៃតម្លៃអវិជ្ជមានតាមគម្លាតស្តង់ដា ។ កង្វះទម្ងន់អាចមានន័យថា អត្រាស្គមរួមជាមួយនឹងអត្រាទាប (ដោយអង្គការ Helen Keller International, 2002) ។ រីឯសន្ទស្សន៍មាឌរាងកាយ (BMI) របស់ស្ត្រី ដែលមានអាយុចន្លោះពី ១៥ ទៅ ៤៩ ឆ្នាំ ជាសន្ទស្សន៍នៃទម្ងន់ធៀបនឹងកម្ពស់លើកជាម៉ែត្រការេ ($Kg/m^2$)។ សន្ទស្សន៍ទាំងអស់នេះ ផ្តល់នូវព័ត៌មានខុសគ្នាអំពីការលូតលាស់រាងកាយ ក៏ដូចជាទំនាក់ទំនងស្ថានភាពអាហារូបត្ថម្ភរបស់កុមារ និងមាតា ។

ជាទូទៅសម្រាប់ប្រទេសកម្ពុជា និងប្រទេសកំពុងអភិវឌ្ឍន៍ដទៃទៀត កម្ពស់ធៀបនឹងអាយុ សម្គាល់លើភាពក្រិន ទម្ងន់ធៀបនឹងកម្ពស់ គឺជាអត្រាស្គមហើយទម្ងន់ធៀបនឹងអាយុ បង្ហាញពីអាការៈកង្វះទម្ងន់របស់កុមារដែលមានអាយុក្រោម ៥ ឆ្នាំ ។ ប្រព័ន្ធការពារសរីរាង្គសម្រាប់ទប់ទល់ជាមួយនឹងជម្ងឺចាប់ផ្តើមចុះខ្សោយនៅពេលដែលកុមារជួបកង្វះខាតអាហារូបត្ថម្ភហើយដំណាលគ្នានោះ បង្កជាជម្ងឺឆ្លងនានា ។ ក្នុងន័យនេះ កុមារក្នុងស្ថានភាពអាហាររូបត្ថម្ភខ្សត់ខ្សោយនឹងជួបនូវហានិភ័យខ្ពស់ផ្នែកជម្ងឺកុមារ (រាក រោគសញ្ញាជម្ងឺរលាកផ្លូវដង្ហើម និងគ្រុនក្តៅ) ។ ផ្ទុយទៅវិញ ទោះបីជាអាហារូបត្ថម្ភខ្សត់ខ្សោយត្រូវបានកាត់បន្ថយ ក៏កង្វះអាហារូបត្ថម្ភនៅតែជាបញ្ហាចម្បង (ដោយលោក Peter Hess & Clark Ross, 1997) ។

កង្វះអាហារូបត្ថម្ភ និងបញ្ហាកង្វះមីក្រូសារជាតិ គឺជាកត្តាចម្បងដែលត្រូវយល់ដឹង ។ សម្រាប់រយៈពេលខ្លី មូលហេតុទាំងពីរនេះបង្កឱ្យមានជម្ងឺឆ្លង អត្រាមរណៈ និងបាត់បង់លទ្ធភាពផ្នែកសារពាង្គកាយ ។ ចំណែកឯរយៈពេលវែង បង្កជាផលអវិជ្ជមានដូចជា : ទំហំរីកលូតលាស់ បញ្ញាសារពាង្គកាយ សមត្ថភាព មុខងារស៊ាំនឹងមេរោគ សុខភាពបន្តពូជ ផលិតភាពសេដ្ឋកិច្ចរបស់គ្រួសារ ក៏ដូចជាសេដ្ឋកិច្ចរបស់ប្រទេសជាតិទាំងមូល ។

## ១.១. មនុស្សមាត្រកុមារ

តាមលទ្ធផលរបស់អង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា បង្ហាញថាកង្វះអាហារូបត្ថម្ភក្នុងចំណោមកុមារដែលមានអាយុក្រោម ៥ ឆ្នាំ នៅតែបន្តជាបញ្ហាចម្បងក្នុងប្រទេសកម្ពុជា ។ សូចនាករសំខាន់ៗសម្រាប់សិក្សាលើនិន្នាការប្រែប្រួលនៃស្ថានភាពអាហារូបត្ថម្ភរបស់កុមារដែលមានអាយុក្រោម ៥ ឆ្នាំ ដូចជា : ស្គមស្គាំង ភាពក្រិន និងខ្វះទម្ងន់ ដែលមានអត្រាប្រេវ៉ាឡង់ចំនួន ១៥ ភាគរយ ៤៥ ភាគរយ និង ៤៥ ភាគរយ នៅឆ្នាំ២០០០ ថយចុះមកត្រឹម ៧ ភាគរយ ៣៧ ភាគរយ និង ៣៦ ភាគរយ សម្រាប់ ឆ្នាំ២០០៥[២] ។

ភាពក្រិនត្រូវបានរកឃើញមានការផ្លាស់ប្តូរខ្លាំងក្នុងន័យស្ថិតិ ។ ជារួមការធ្លាក់ចុះនេះ មានប្រហែលជាពាក់កណ្តាលក្នុងរយៈពេល ៥ ឆ្នាំ ចាប់តាំងពីឆ្នាំ២០០០ មក ។ ផ្ទុយទៅវិញ ទោះបីជាមានការរីកចម្រើនក្តីនូវស្ថានភាពអាហារូបត្ថម្ភរបស់កុមារដែលមានអាយុក្រោម ៥ ឆ្នាំ ក៏កុមារកម្ពុជាជាមធ្យមមានភាពក្រិនប្រហែល ៣ ដង ច្រើនជាងកុមារដែលមានសុខភាពល្អបរិបូណ៍ ។

យ៉ាងណាមិញ ការគណនាថ្មីតាមរូបមន្តរបស់អង្គការសុខភាពពិភពលោក បានបង្ហាញនូវអត្រាថ្មីនាឆ្នាំ២០០០ និងឆ្នាំ២០០៥ នៃសូចនាករមនុស្សមាត្រទាំង៣របស់កុមារ ។ (រាល់ព័ត៌មានថ្មីផ្តើម

[២] តាមរូបមន្តចាស់ដែលបានប្រើប្រាស់ដោយ អ.ប្រ.ស.ក

ចេញពីការគណនាតាមរូបមន្តរបស់អង្គការ WHO សម្រាប់អង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ឆ្នាំ ២០០០ និងឆ្នាំ២០០៥ សូមមើលក្នុងឧបសម្ព័ន្ធទី២ ស្តីពីមនុស្សមាត្រកុមារឆ្នាំ២០០០ និងឆ្នាំ២០០៥) ។

ការបែងចែកសូចនាករនានារបស់មនុស្សមាត្រកុមារនៃអង្កេតឆ្នាំ២០០៨ បានបង្ហាញពីគម្លាតខុសគ្នាខ្លាំងរវាងស្ថានភាពអាហារូបត្ថម្ភនៃក្រុមគ្រួសារអ្នកមាន និងក្រុមគ្រួសារអ្នកក្រដែលមានកុមារអាយុក្រោម ៥ ឆ្នាំ ដូចដែលបង្ហាញក្នុងតារាងខាងក្រោម ។

តារាងលេខ ១ : សូចនាករស្ថានភាពអាហារូបត្ថម្ភតាមរយៈកម្រិតធនធានទ្រព្យសម្បត្តិ

| លក្ខណៈប្រវត្តិ | កុមារស្គម <-2 SD | កុមារក្រិន <-2 SD | កុមារខ្វះទម្ងន់ <-2 SD |
|---|---|---|---|
| **ធនធានទ្រព្យសម្បត្តិ** | | | |
| ក្របំផុត | ៨.៦ | ៤៨.១ | ៣៤.៥ |
| ក្រ | ១១.៧ | ៤២.៦ | ៣៣.៥ |
| មធ្យម | ៧.៧ | ៤១.១ | ២៩.៩ |
| មាន | ៨.០ | ៣៨.៣ | ២៧.៨ |
| មានបំផុត | ៨.៩ | ២៨.៦ | ១៩.៣ |
| សរុប | ៨.៩ | ៣៩.៥ | ២៨.៨ |

ទោះបីជាសូចនាករកុមារស្គម នៅមានអត្រាប្រេវ៉ាឡង់ទាបជាងបណ្តាសូចនាករអាហារូបត្ថម្ភផ្សេងៗក៏ដោយ ក៏កម្រិតទ្រព្យសម្បត្តិមិនបានរារាំងកុមារដែលមានអាយុក្រោម ៥ ឆ្នាំ ឱ្យផុតពីបញ្ហាកង្វះអាហារូបត្ថម្ភទេ ។

### គ. ទម្ងន់ធៀបនឹងកម្ពស់

ភាពស្គម បង្ហាញនូវទម្រង់ឱនភាពសមាសភាពធាត់ ដែលអាចបណ្តាលមកពីកត្តារារាំងដល់ការកើនឡើងទម្ងន់ ឬក៏ការធ្លាក់ចុះនូវទម្ងន់ ។ អត្រាប្រេវ៉ាឡង់ខ្ពស់នៃកុមារស្គម មានទំនាក់ទំនងជាមួយស្ថានភាពអាហារូបត្ថម្ភខ្សត់ខ្សោយក្នុងរយៈពេលខ្លី ការទទួលទានអាហារមិនគ្រប់គ្រាន់ ស្បៀងគ្រួសារខ្សត់ខ្សោយដោយអន្លើ និងជម្ងឺថ្មីៗ ។ អសន្តិសុខស្បៀងអាហារបង្កឱ្យគ្រួសារខ្វះ ខ្វះលទ្ធភាពក្នុងការបរិភោគគ្រប់គ្រាន់ ។ ការបរិភោគគ្រប់គ្រាន់ គឺជាប្រភពសំខាន់បង្កើតជាថាមពល និងសារជាតិសម្រាប់ទ្រទ្រង់ និងលូតលាស់សារពាង្គកាយ ។

អត្រាស្គមខ្ពស់របស់កុមារដែលមានអាយុក្រោម ៥ ឆ្នាំ (តារាងលេខ ២) គឺឃើញមាននៅក្នុងចំណោមកុមារដែលមានអាយុចាប់ពី ៦ ទៅ ១១ ខែ ជាមួយនឹងអត្រាប្រេវ៉ាឡង់ ១១.៨ ភាគរយ ។

អត្រាខ្ពស់នេះ ទំនងបណ្តាលមកពីទារកចាប់ផ្តើមមានតម្រូវការខ្ពស់ផ្នែកមីក្រូសារជាតិដែលមាននៅក្នុងប្រភេទអាហារ និងទឹកដោះម្តាយ ។

**តារាងលេខ ២ : ទម្ងន់ធៀបនឹងកម្ពស់របស់កុមារដែលមានអាយុចាប់ពី 0 ទៅ ៥៩ ខែ**

| ភាគរយទម្ងន់ធៀបនឹងកម្ពស់ (ស្គម) របស់កុមារដែលមានអាយុក្រោម ៥ ឆ្នាំ តាមបទដ្ឋានវាស់វែងការលូតលាស់របស់អង្គការសុខភាពពិភពលោក ដោយអង្កេតមនុស្សមាត្រកម្ពុជា ឆ្នាំ២០០៨ | | | | |
|---|---|---|---|---|
| លក្ខណៈប្រវត្តិ | **ទម្ងន់ធៀបនឹងកម្ពស់** | | | |
| **អាយុជាខែ** | < - 3 SD | < - 2 SD | មធ្យម | ចំនួនកុមារ |
| 0 - 5 | 2.0 | 9.8 | -0.14 | 618 |
| 6 - 11 | 2.8 | 11.8 | -0.60 | 824 |
| 12 - 23 | 1.8 | 9.8 | -0.71 | 1706 |
| 24 - 35 | 2.2 | 10.1 | -0.69 | 1434 |
| 36 - 47 | 1.5 | 7.1 | -0.68 | 1343 |
| 48 - 59 | 0.9 | 5.5 | -0.68 | 1094 |
| **ភេទ** | | | | |
| ប្រុស | 2.1 | 9.7 | -0.64 | 3585 |
| ស្រី | 1.6 | 8.0 | -0.62 | 3434 |
| **តំបន់រស់នៅ** | | | | |
| ទីប្រជុំជន | 1.6 | 8.5 | -0.44 | 1217 |
| ទីជនបទ | 1.9 | 9.0 | -0.67 | 5801 |
| **កម្រិតទ្រព្យសម្បត្តិ** | | | | |
| ក្របំផុត | 1.6 | 8.6 | -0.65 | 1344 |
| ក្រ | 3.2 | 11.7 | -0.71 | 1261 |
| មធ្យម | 1.5 | 7.7 | -0.66 | 1469 |
| មាន | 1.5 | 8.0 | -0.64 | 1452 |
| មានបំផុត | 1.6 | 8.9 | -0.51 | 1481 |
| **សរុប** | **1.8** | **8.9** | **-0.63** | **7019** |

ទោះបីជាទិន្នន័យបង្ហាញនូវគម្លាតខុសគ្នាខ្លាំងរវាងកង្វះអាហារូបត្ថម្ភ តាមកម្រិតទ្រព្យសម្បត្តិក៏ដោយ ក៏មានការខុសគ្នាតែបន្តិចបន្តួចប៉ុណ្ណោះរវាងតំបន់ទីប្រជុំជន និងតំបន់ទីជនបទ ។ តាមរយៈតារាងនេះ កុមារកង្វះអាហារូបត្ថម្ភមានគ្រប់ទីកន្លែងក្នុងផ្ទៃប្រទេស មិនថាតែក្នុងសហគមន៍ ឬគ្រួសារក្រីក្របំផុតនោះទេ ។ ក្នុងកាលៈទេសៈនេះ កត្តាសេដ្ឋកិច្ចរបស់គ្រួសារ ទំនងមិនមែនជាភ្នាក់ងារសំខាន់ដែលជួយលើកកម្ពស់ស្ថានភាពអាហារូបត្ថម្ភរបស់កុមារនោះទេ ។ គឺនៅមានភ្នាក់ងារផ្សេងៗ ដូចជា :

អាយុ និងទំហំរបស់ទារកនៅពេលកើត កម្រិតនៃការអប់រំរបស់មាតាអំពីអាហារូបត្ថម្ភ និងវិធីសាស្ត្រនៃការចិញ្ចឹមកូន (ការបំបៅកូនដោយទឹកដោះម្ដាយ និងការផ្ដល់អាហារបន្ថែមត្រឹមត្រូវ) ។

យ៉ាងណាមិញក្នុងកម្រិតប្រទេស យើងឃើញថាអត្រាប្រេវ៉ាឡង់ស្គមរបស់កុមារ គឺមិនមានប្រែប្រួលសំខាន់នោះទេធៀបនឹងឆ្នាំ២០០៥ របស់ អ.ប្រ.ស.ក (រូបភាពលេខ ១) ។

រូបភាពលេខ ១ : និន្នាការប្រែប្រួលកង្វះអាហារូបត្ថម្ភនៃភាពស្គមរបស់កុមារ




### ខ. កម្ពស់ធៀបនឹងអាយុ

គឺជាសូចនាករខ្សែបន្ទាត់នៃភាពរីកលូតលាស់យឺតយ៉ាវ (ឆ្អឹងជងខ្លួន) ឬក៏ការឈប់រីកចម្រើននៃកម្ពស់របស់ទារក និងកុមារធៀបនឹងអាយុ ។ មានន័យថា ភាពក្រិនជានិច្ចកាលត្រូវបានកត់សម្គាល់លើអាយុលូតលាស់របស់ក្មេង ហើយលទ្ធផលបង្ហាញនូវកម្ពស់មិនបានឆ្លើយតបទៅនឹងទម្ងន់ ។ តាមការរកឃើញបង្ហាញថា ប្រសិនកុមារមានភាពក្រិនធ្ងន់ធ្ងរក្នុងវ័យកំពុងលូតលាស់ នោះភាពក្រិននឹងស្ថិតនៅលើកុមារ នោះជារៀងរហូត ។ កម្រិតភាពក្រិនធ្ងន់ធ្ងរអាចបណ្ដាលមកពីការទទួលអាហារូបត្ថម្ភមិនគ្រប់គ្រាន់ក្នុងអំឡុងពេលយូរ ជម្ងឺរ៉ាំរ៉ៃ និងធនធានគ្រួសារខ្សត់ខ្សោយ ។ ដូច្នេះការប្រែប្រួលអត្រាប្រេវ៉ាឡង់ មិនមែនដោយសារតែការទទួលអាហារប្រចាំថ្ងៃក្នុងរយៈពេលខ្លីមិនបានគ្រប់គ្រាន់នោះទេ ។

ប្រេវ៉ាឡង់ភាពក្រិន ពិន្ទុក្រោម២ នៃតម្លៃអវិជ្ជមានតាមគម្លាតស្តង់ដា (<-2SD) តំណាងឱ្យក្រុមកុមារដែលមានអាយុតិចជាងគេក្នុងចំណោមកុមារដែលមានអាយុក្រោម ៥ ឆ្នាំ មានកម្រិតខុសគ្នាយ៉ាងខ្លាំងទៅតាមអាយុ និងកម្រិតធនធានទ្រព្យសម្បត្តិក្នុងន័យស្ថិតិ (តារាងលេខ ៣) ។

តារាងលេខ ៣ : កម្ពស់ធៀបនឹងអាយុរបស់កុមារដែលមានអាយុចាប់ពី 0 ទៅ ៥៩ ខែ

| ភាគរយកម្ពស់ធៀបនឹងអាយុ (ក្រិន) របស់កុមារដែលមានអាយុក្រោម ៥ ឆ្នាំ តាមបទដ្ឋានវាស់វែង ការលូតលាស់របស់អង្គការសុខភាពពិភពលោក ដោយអង្កេតមនុស្សសាស្ត្រកម្ពុជា ឆ្នាំ២០០៨ | | | | |
|---|---|---|---|---|
| លក្ខណៈប្រវត្តិ | **កម្ពស់ធៀបនឹងអាយុ** | | | |
| **អាយុជាខែ** | **< - 3 SD** | **< - 2 SD** | **មធ្យម** | **ចំនួនកុមារ** |
| 0 - 5 | 5.6 | 14.5 | -0.34 | 618 |
| 6 - 11 | 4.3 | 14.5 | -0.48 | 824 |
| 12 - 23 | 13.7 | 35.2 | -1.32 | 1706 |
| 24 - 35 | 22.1 | 49.1 | -1.49 | 1434 |
| 36 - 47 | 23.4 | 50.7 | -2.13 | 1343 |
| 48 - 59 | 25.7 | 53.1 | -2.29 | 1094 |
| **ភេទ** | | | | |
| ប្រុស | 18.1 | 40.9 | -1.62 | 3585 |
| ស្រី | 16.5 | 38.1 | -1.52 | 3434 |
| **តំបន់រស់នៅ** | | | | |
| ទីប្រជុំជន | 14.7 | 31.9 | -1.25 | 1217 |
| ទីជនបទ | 17.9 | 41.1 | -1.64 | 5801 |
| **កម្រិតទ្រព្យសម្បត្តិ** | | | | |
| ក្របំផុត | 21.5 | 48.1 | -1.9 | 1344 |
| ក្រ | 20.1 | 42.6 | -1.7 | 1261 |
| មធ្យម | 18.4 | 41.1 | -1.6 | 1469 |
| មាន | 17.0 | 38.3 | -1.5 | 1452 |
| មានបំផុត | 10.3 | 28.6 | -1.2 | 1481 |
| **សរុប** | **17.3** | **39.5** | **-1.6** | **7019** |

ដូចដែលបានបង្ហាញក្នុងតារាងលេខ ៣ កុមារកម្ពុជាដែលមានអាយុត្រឹមតែ ៣ឆ្នាំ មានភាពក្រិនប្រហែលជិតពាក់កណ្ដាល ក្នុងនោះភាពក្រិន មានខ្ពស់នៅក្នុងតំបន់ជនបទ (៤១.១ ភាគរយ) និងប្រមាណជា ៣១.៩ ភាគរយ នៅតំបន់ទីប្រជុំជន ។ ប៉ុន្តែមិនមានភាពខុសគ្នាគួរឱ្យកត់សម្គាល់តាមភេទរបស់កុមារនោះទេ ។ ផ្ទុយទៅវិញ កម្រិតទ្រព្យសម្បត្តិរបស់គ្រួសារកាន់តែច្រើន ប្រេវ៉ាឡង់ភាពក្រិនរបស់កុមារ គឺកាន់តែទាប ។ តារាងខាងលើ បង្ហាញនូវអត្រាភាគរយខុសគ្នាប្រមាណជា ២០ ពី ៤៨.១ ភាគរយ សម្រាប់កុមារដែលមានគ្រួសារក្របំផុត និង ២៨.៦ ភាគរយ សម្រាប់កុមារដែលគ្រួសារមានជីវភាពធូរធារបំផុត ។

សម្រាប់កម្រិតជាតិ ភាពក្រិនរបស់កុមារដែលមានអាយុក្រោម ៥ ឆ្នាំ បានធ្លាក់ចុះពី ៤៣.២ ភាគរយ នៅឆ្នាំ២០០៥ មកនៅត្រឹម ៣៩.៥ ភាគរយសម្រាប់ឆ្នាំ២០០៨ (ធ្លាក់ចុះអត្រាភាគរយបានចំនួន ៣ ដូចដែលឃើញមានពីឆ្នាំ២០០០ ទៅឆ្នាំ២០០៥) ។ ប៉ុន្តែនៅពេលយើងមើលនៅលើអាយុរបស់កុមារ ទៅតាមក្រុមអាយុនិមួយៗ នោះយើងសង្កេតឃើញថានៅមានគម្លាតខុសគ្នាច្រើន ។ អត្រាប្រេវ៉ាឡង់ មានចំនួន ៥.៦ ភាគរយ ចំពោះកុមារដែលមានអាយុតិចជាង ៦ខែ និង ៥៣.១ ភាគរយ សម្រាប់ក្រុម អាយុចាប់ពី ៤៨ ដល់ ៥៩ខែ ។

ដូច្នេះ ទោះបីជាមានផលវិជ្ជមាននៃការធ្លាក់ចុះអត្រាប្រេវ៉ាឡង់ភាពក្រិនរបស់កុមារនៅឆ្នាំ ២០០៨ មែន ក៏កម្រិតភាពក្រិន គឺនៅតែខ្ពស់ហើយចាំបាច់ត្រូវធ្វើការពិចារណា ដើម្បីកាត់បន្ថយនូវ កម្រិតខ្ពស់នេះបន្តទៀត ពីព្រោះថាកុមារកម្ពុជាដែលមានអាយុក្រោម ៥ ឆ្នាំ ប្រហែលស្មើរតែ ៤០ ភាគរយ នៅមានបញ្ហាជាមួយកង្វះអាហារូបត្ថម្ភ ។

រូបភាពលេខ ២ : និន្នាការប្រែប្រួលកង្វះអាហារូបត្ថម្ភនៃភាពក្រិនរបស់កុមារ




យើងអាចសន្និដ្ឋានបានថា ក្រៅពីតំបន់រស់នៅ និងជីវភាពសេដ្ឋកិច្ចគ្រួសារ កម្ពស់ធៀបនឹង អាយុរបស់កុមារដែលមានអាយុក្រោម ៥ ឆ្នាំ មានទំនាក់ទំនងសំខាន់ជាមួយនឹងអាយុរបស់កុមារ ទម្ងន់ និងកម្ពស់របស់ម្តាយ ក៏ដូចជាកម្រិតនៃការអប់រំរបស់ឪពុកម្តាយ (ដោយលោក Haughton, 1997) ។ ដូចគ្នានេះដែរ បញ្ហាកង្វះមីក្រូសារជាតិស័ង្កសីនៅពេលដែលអត្រាប្រើប្រាស់អាហារប្រភេទសាច់បាន ធ្លាក់ចុះ ក៏អាចជាមូលហេតុមួយបណ្តាលឱ្យកុមារក្លាយទៅជាក្រិន និងមានជម្ងឺរាក ។

### គ. ទម្ងន់ធៀបនឹងអាយុ

គឺជាការបូកបញ្ចូលគ្នានៃសន្ទស្សន៍កម្ពស់ធៀបនឹងអាយុ និងទម្ងន់ធៀបនឹងកម្ពស់ ។ ដូចគ្នានេះដែរ កង្វះទម្ងន់ឆ្លើយតបទៅនឹងការប្រែប្រួលរយៈពេលខ្លី និងវែងនៃការមានអាហារូបត្ថម្ភគ្រប់គ្រាន់ ។ ក៏ប៉ុន្តែកុមារដែលមានសុខភាពបរិបូណ៌ ក៏មិនប្រាកដថាមានទម្ងន់គ្រប់គ្រាន់ទេ ។ ក្រៅពីកត្តាកង្វះអាហារូបត្ថម្ភ ជាពិសេសជម្ងឺកុមារ (បណ្តាលមកពីប្រព័ន្ធការពាររាងកាយចុះខ្សោយ) ក៏នៅមានកត្តាផ្សេងទៀតដូចជា : ទម្ងន់នាពេលកើតរបស់ទារក ក៏ជាបុព្វហេតុសំខាន់ផងដែរដែលមានទំនាក់ទំនងយ៉ាងជិតដិតជាមួយបញ្ហាកង្វះទម្ងន់ (ដោយអង្គការ WFP, 2006) ។

កង្វះទម្ងន់ដូចដែលបានពន្យល់ដោយទិន្នន័យនៅក្នុងឆ្នាំ២០០៨ កន្លងទៅថ្មីៗនេះ (តារាងលេខ ៤) មាន អត្រាប្រេវ៉ាឡង់ចំនួនប្រមាណ ២៨.៨ ភាគរយ ។ អត្រាខ្ពស់នេះ គឺអាចបណ្តាលមកពីការទាក់ទងគ្នារវាងអត្រាប្រេវ៉ាឡង់ខ្ពស់របស់ភាពក្រិន (៣៩.៥ ភាគរយ) ។

តារាងលេខ ៤ : ទម្ងន់ធៀបនឹងអាយុរបស់កុមារដែលមានអាយុចាប់ពី 0 ទៅ ៥៩ ខែ

| ភាគរយទម្ងន់ធៀបនឹងអាយុ (កង្វះទម្ងន់) របស់កុមារដែលមានអាយុក្រោម ៥ ឆ្នាំ តាមបទដ្ឋានវាស់វែងការលូតលាស់របស់អង្គការសុខភាពពិភពលោក ដោយអង្កេតមនុស្សសាស្ត្រកម្ពុជា ឆ្នាំ២០០៨ | | | | |
|---|---|---|---|---|
| លក្ខណៈប្រវត្តិ | **ទម្ងន់ធៀបនឹងអាយុ** | | | |
| **អាយុជាខែ** | < - 3 SD | < - 2 SD | មធ្យម | ចំនួនកុមារ |
| 0 – 5 | 1.5 | 7.5 | -0.44 | 618 |
| 6 - 11 | 2.8 | 15.6 | -0.79 | 824 |
| 12 - 23 | 6.5 | 25.4 | -1.18 | 1706 |
| 24 - 35 | 11.2 | 33.5 | -1.56 | 1434 |
| 36 - 47 | 13.1 | 36.2 | -1.72 | 1343 |
| 48 - 59 | 14.3 | 40.5 | -1.85 | 1094 |
| **ភេទ** | | | | |
| ប្រុស | 9.2 | 28.4 | -1.36 | 3585 |
| ស្រី | 9.0 | 29.2 | -1.35 | 3434 |
| **តំបន់រស់នៅ** | | | | |
| ទីប្រជុំជន | 6.9 | 21.1 | -1.02 | 1217 |
| ទីជនបទ | 9.5 | 30.4 | -1.43 | 5801 |
| **កម្រិតទ្រព្យសម្បត្តិ** | | | | |
| ក្របំផុត | 12.2 | 34.5 | -1.5 | 1344 |
| ក្រ | 11.4 | 33.5 | -1.5 | 1261 |
| មធ្យម | 9.3 | 29.9 | -1.4 | 1469 |
| មាន | 8.1 | 27.8 | -1.3 | 1452 |
| មានបំផុត | 5.0 | 19.3 | -1.4 | 1481 |
| **សរុប** | **9.1** | **28.8** | **-1.35** | **7019** |

អត្រាខ្វះទម្ងន់មិនមានជាបញ្ហាចោទ និងខុសគ្នាប៉ុន្មានទេកំឡុងពេល ៦ ខែ ដំបូង ទំនងដោយសារការចិញ្ចឹមដោយទឹកដោះម្ដាយតែមួយមុខ និងមូលហេតុទម្ងន់នៅពេលកើត ។ ប៉ុន្តែអត្រាបានចាប់ផ្ដើមប្រែប្រួលយ៉ាងឆាប់រហ័សចាប់ពីអាយុ ៦ ខែ ឡើងទៅ ពីព្រោះទឹកដោះម្ដាយតែមួយមុខពុំមែនជាតម្រូវការគ្រប់គ្រាន់សម្រាប់វ័យលូតលាស់របស់កុមារ ។ មានបុព្វហេតុពីរយ៉ាង (ការវិលចុះវិលឡើងស្ថានភាពកង្វះទម្ងន់ និងរបៀបចិញ្ចឹម) អាចបណ្ដាលឱ្យកុមារដែលមានអាយុចាប់ពី ៦ ខែ ឡើងទៅជួបនឹងបញ្ហាកង្វះទម្ងន់ ឬអាហាររូបត្ថម្ភខ្សត់ខ្សោយ ។

- ប្រសិនទារកជួបនូវបញ្ហាកង្វះទម្ងន់នៅពេលកើត នោះកង្វះទម្ងន់នៅតែបន្តរហូតមក ទោះបីជាអាយុកុមារកាន់តែច្រើនក្តី ។
- នៅពេលដែលកុមារគួរតែត្រូវបានផ្តល់អាហារបន្ថែមដែលមានជីវជាតិ និងបន្តនូវការចិញ្ចឹមដោយទឹកដោះម្តាយ ប៉ុន្តែការផ្តល់អាហារបន្ថែមស្ថិតនៅក្នុងលក្ខណៈ យឺតពេល មិនគ្រប់គ្រាន់ និងមិនសមរម្យ ស្របពេលចំនួននៃការបៅទឹកដោះម្តាយត្រូវបានកាត់បន្ថយ ។

ជាលទ្ធផល ពីរនាក់ក្នុងចំណោម៥នាក់នៃកុមារដែលមានអាយុចាប់ពី ៤៨ ទៅ ៥៩ ខែ មានបញ្ហាកង្វះទម្ងន់ខ្ពស់គួរឱ្យបារម្ភ ។ ផ្ទុយទៅវិញទិន្នន័យរបស់អង្កេតបង្ហាញថា នៅពេលដែលជីវភាពគ្រួសារមានការរីកចម្រើន (មានបំផុត) នោះកម្រិតនៃអាហារូបត្ថម្ភមានភាពប្រសើរជាងមុន ហើយបញ្ហាកង្វះទម្ងន់ ក៏នៅក្នុងកម្រិតទាបជាងមុនដែរក្នុងសមាមាត្រ ១៩.៣ ភាគរយ សម្រាប់គ្រួសារ ដែលមានចំណូលខ្ពស់ ទល់នឹង ៣៤.៥ ភាគរយ នៃគ្រួសារក្រីក្របំផុត ។

បញ្ហាកង្វះទម្ងន់របស់កុមារដែលមានអាយុក្រោម ៥ ឆ្នាំ បាននឹងកំពុងប្រសើរឡើងចាប់ពីឆ្នាំ ២០០៥ ទៅឆ្នាំ២០០៨ ក្នុងអត្រាខុសគ្នាទៅតាមសូចនាករផ្សេងៗ ជាពិសេស គឺទារកអាយុចាប់ពី ០ ទៅ ៦ ខែ បានថយចុះប្រហែល ៥០ ភាគរយ ដោយមានប្រេវ៉ាឡង់ ៧.៥ ភាគរយនៅឆ្នាំ២០០៨ ចុះពី ១២ ភាគរយនៅឆ្នាំ ២០០៥ ។ ប៉ុន្តែសម្រាប់ថ្នាក់ជាតិក្នុងឆ្នាំ២០០៨ ភាពរីកចម្រើននៃកុមារកង្វះទម្ងន់ស្ថិតនៅស្ថានភាពនឹងថ្កល់ មានន័យថាអត្រាប្រេវ៉ាឡង់កង្វះទម្ងន់របស់កុមារដែលមានអាយុក្រោម ៥ ឆ្នាំ មិនមាននិន្នាការប្រែប្រួលគួរឱ្យកត់សម្គាល់ទេចាប់តាំងពីឆ្នាំ២០០៥ មក (រូបភាពលេខ ១.៣) ។

រូបភាពលេខ ៣ : និន្នាការប្រែប្រួលកង្វះអាហារូបត្ថម្ភរបស់កុមារកង្វះទម្ងន់



អង្កេតមនុស្សមាត្រកម្ពុជា ឆ្នាំ២០០៨ ត្រូវបានធ្វើក្នុងខែវិច្ឆិកា (រដូវខ្វះមុខខ្វះក្រោយ) គឺជារដូវដែលក្រុមគ្រួសារកសិករភាគច្រើន ចាប់ផ្តើមធ្វើការច្រូតកាត់ផលិតផលកសិកម្មជាពិសេសស្រូវ និងស្របពេលដែលមានបញ្ហាតម្លៃអាហារកើនឡើងខ្ពស់ ។ ដូច្នេះ កម្រិតកង្វះអាហារូបត្ថម្ភត្រូវបានគិតថានឹងកើនឡើងខ្ពស់ជាងខែធម្មតា ក៏ដូចជាខែនៃការប៉ាន់ស្មាន ។ ជាលទ្ធផល រដូវនេះអាចធ្វើឱ្យប៉ះពាល់ដល់វឌ្ឍនភាពនៃសូចនាករទាក់ទងនឹងមនុស្សមាត្រកុមារ (អត្រាកង្វះទម្ងន់) នៅក្នុងកម្រិតណាមួយនោះ ។ (សូមមើលនៅក្នុងឧបសម្ព័ន្ធទី១ : មនុស្សមាត្រកុមារតាមខែនិមួយៗ) ។

ដោយប្រៀបធៀបជាមួយនឹងទិន្នន័យដែលទទួលបានបន្ទាប់ពីអង្កេត អត្រាប្រេវ៉ាឡង់កុមារស្គមនិងអត្រាប្រេវ៉ាឡង់កុមារកង្វះទម្ងន់ មានការប្រែប្រួលបន្តិចបន្តួចប៉ុណ្ណោះ (រូបភាពលេខ ៤) ។

រូបភាពលេខ ៤ : និន្នាការប្រែប្រួលកង្វះអាហារូបត្ថម្ភរបស់កុមារក្នុងខែដូចគ្នា




អង្កេតមនុស្សមាត្រ ឆ្នាំ២០០៨ ត្រូវបានធ្វើនៅក្នុងអំឡុងខែវិច្ឆិកា ។ រីឯកម្រិតរំពឹងទុក
គឺជាការគណនាដោយយកលទ្ធផលភាគរយអង្កេតឆ្នាំ២០០០ ដកនឹងអង្កេតឆ្នាំ២០០៥
ហើយបំលែងចូលទៅក្នុងកម្រិតលទ្ធផលដែលមានស្រាប់នៅក្នុងខែវិច្ឆិកា ឆ្នាំ២០០៥

## រូបភាពលេខ ៥ : និន្នាការប្រែប្រួលកង្វះអាហាររូបត្ថម្ភរបស់កុមារតាមតំបន់រស់នៅ




រូបភាពលេខ ៥ បង្ហាញនូវកម្រិតវិជ្ជមាននៃភាពស្គម និងកង្វះទម្ងន់នៅតាមទីជនបទ ពីឆ្នាំ ២០០០ ទៅឆ្នាំ២០០៥ ប៉ុន្តែភាពរីកចម្រើនទាំងអស់នេះ បានឈប់បន្ទាប់ពីឆ្នាំ២០០៥មក ។ ក៏ប៉ុន្តែ ភាពវិជ្ជមាន នៅឃើញមាននៅក្នុងតំបន់ទីប្រជុំជន ជាពិសេសអត្រាកង្វះទម្ងន់ដែលអាចជាលទ្ធផល ទំនាក់ទំនងមកពីមានការរីកចម្រើនក្នុងអត្រាប្រេវ៉ាឡង់ភាពគ្រិនរបស់កុមារ ។ ផ្ទុយទៅវិញ ដោយធ្វើ ការបែងចែកទៅតាមតំបន់ និងកម្រិតធនធានគ្រួសារ នោះរូបភាពដដែលបង្ហាញថា កុមារស្គមរបស់ ក្រុមគ្រួសារដែល មានជីវភាពខ្សត់ខ្សោយនៅតាមតំបន់ទីប្រជុំជនមានចំនួនខ្ពស់ជាង ២ ដង ធៀបនឹង កុមារដែលមានគ្រួសារមានជីវភាពល្អប្រសើរ ។

**រូបភាពលេខ ៦ ៖ និន្នាការប្រែប្រួលកង្វះអាហារូបត្ថម្ភរបស់កុមារតាមតំបន់រស់នៅ និងធនធានគ្រួសារ**

ភាគរយភាពស្គមរបស់កុមារដែលមានអាយុក្រោម ៥ ឆ្នាំ ទៅតាមតំបន់រស់នៅ និងកម្រិតធនធានទ្រព្យសម្បត្តិ ដោយអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ឆ្នាំ២០០៥ និងអង្កេតមនុស្សមាត្រកម្ពុជា ឆ្នាំ២០០៨




កម្រិតធនធានទ្រព្យសម្បត្តិបានប្រើប្រាស់វិធីសាស្ត្រអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ឆ្នាំ២០០៥ អ្នកក្របែកចែកជាពីរក្រុម ខណៈដែលអ្នកមានក៏ត្រូវបានបែងចែកជាពីរក្រុមដែរ

និន្នាការអត្រាកង្វះទម្ងន់ បានចាប់ផ្តើមប្រែប្រួលសម្រាប់ក្រុមកុមារនៅពេលដែលត្រូវបានទទួលអាហារបន្ថែម និងស្របពេលដែលសារជាតិពីទឹកដោះម្តាយតែមួយមុខគត់ មិនអាចមានលទ្ធភាពគ្រប់គ្រាន់សម្រាប់ការរីកលូតលាស់របស់កុមារ ។ កង្វះទម្ងន់បានធ្លាក់ចុះចំនួន ៣ អត្រាភាគរយ ពីឆ្នាំ ២០០៥ (១៨.៦ ភាគរយ) មកនៅត្រឹម ១៥.៦ ភាគរយ នាឆ្នាំ២០០៨ សម្រាប់ក្រុមកុមារដែលមានអាយុពី ៦ ទៅ ១១ ខែ ។

នៅពេលដែលអត្រាប្រេវ៉ាឡង់ត្រូវបានបែងចែកទៅតាមក្រុមអាយុរបស់កុមារវិញ នោះអត្រាប្រេវ៉ាឡង់កង្វះទម្ងន់របស់ក្រុមកុមារដែលមានអាយុចាប់ពី ៦ ទៅ ១១ ខែ បានកើនឡើងប្រហែល ៥០ ភាគរយ ខ្ពស់ជាងធៀបនឹងក្រុមកុមារដែលមានអាយុពី ០ ទៅ ៦ ខែ ។ អត្រាបានបន្តកើនឡើងចំពោះកុមារដែលមានអាយុចាប់ពីមួយឆ្នាំឡើងទៅ ។ រីឯក្រុមកុមារដែលមានអាយុចាប់ពី ៤៨ ទៅ ៥៩ ខែ ទាំងអស់ ស្ទើរតែ ២ភាគ៥ មានបញ្ហាជាមួយនឹងភាពកង្វះទម្ងន់ (រូបភាពលេខ ៧) ។

## រូបភាពលេខ ៧ : និន្នាការប្រែប្រួលកង្វះអាហារូបត្ថម្ភរបស់កុមារកង្វះទម្ងន់តាមអាយុ




យ៉ាងណាមិញ ចាប់តាំងពីឆ្នាំ២០០០ មកដល់ ឆ្នាំ២០០៨ អត្រាកង្វះទម្ងន់មានការថយចុះគួរឱ្យកត់សម្គាល់ចំពោះក្រុមកុមារដែលមានអាយុពី ០ ទៅ ៥ ខែ ។ នេះមានន័យថាកុមារតូចៗមានលក្ខណៈប្រសើរជាមួយស្ថានភាពអាហារូបត្ថម្ភ ។ ដូចគ្នានេះដែរ នៅពេលដែលអាហារូបត្ថម្ភរបស់មាតាមានការរីកចម្រើន នោះក៏អាចជាកត្តាសំខាន់រួមចំណែកការកាត់បន្ថយអត្រាកង្វះអាហារូបត្ថម្ភរបស់កុមារអាយុក្រោម ៥ ឆ្នាំ ផងដែរ ។

## រូបភាពលេខ ៨ : កុមារកង្វះទម្ងន់តាមអាយុ




អ្វីដែលគួរឱ្យចាប់អារម្មណ៍នោះគឺ អត្រាភាពក្រិន និងកង្វះទម្ងន់កាន់តែខ្ពស់ នៅពេលអាយុកុមារកាន់តែច្រើន ។ ផ្ទុយទៅវិញ អត្រាភាគរយនៃភាពស្គមរបស់កុមារអាយុពី ៤៨ ទៅ ៥៩ ខែ (៥.៥ ភាគរយ) ស្ថិតនៅកម្រិតទាបជាងគេ ដោយបានធ្លាក់ចុះប្រមាណ ៤ អត្រាភាគរយ ពី ៩.៨ ភាគរយសម្រាប់កុមារតូច និងទារកដែលមានអាយុពី ០ ទៅ ៥ ខែ ទៅវិញ (រូបភាពលេខ៩) ។ ប៉ុន្តែមិនមានការបកស្រាយណាមួយដែលអាចចាត់ទុកថាល្អ និងសមស្របច្បាស់លាស់នៅក្នុងចំនុចនេះទេ ក្រៅពីការធ្លាក់ចុះនេះបង្ហាញនូវសញ្ញាល្អចំពោះស្ថានភាព អាហាររូបត្ថម្ភរបស់កុមារដែលមានអាយុកាន់តែច្រើនប៉ុណ្ណោះ ។

ដើម្បីតាមដាននូវសូចនាករនិន្នាការប្រែប្រួលអាហាររូបត្ថម្ភរបស់កុមារ ការធ្វើអង្កេតថ្មីមួយគួរតែមាន ពីព្រោះថាប្រេវ៉ាឡង់អត្រាស្គមរបស់កុមារអាចកើនឡើង ឬថយចុះនឹងអាស្រ័យលើសុខភាពរបស់កុមារអំឡុងពេលធ្វើអង្កេត ។

រូបភាពលេខ ៩ : និន្នាការប្រែប្រួលកង្វះអាហារូបត្ថម្ភរបស់កុមារស្គមតាមអាយុ




## ១.២. មនុស្សមាត្រស្ត្រី

សូចនាករសំខាន់ពីរសម្រាប់មនុស្សមាត្រស្ត្រី គឺរង្វាស់កម្ពស់ និងសន្ទស្សន៍សមាសភាពរាងកាយ ។ សូចនាករទាំងពីរនេះ ត្រូវបានយកមកប្រើប្រាស់ដើម្បីតាមដានស្ថានភាពអាហារូបត្ថម្ភរបស់ស្ត្រី ។ ស្ត្រីកង្វះអាហារូបត្ថម្ភក្នុងអំឡុងពេលមានផ្ទៃពោះ បង្ហាញនូវអត្រាហានិភ័យខ្ពស់ផ្នែកសុខភាពទារកក្នុងផ្ទៃ ។ ស្ត្រីគ្រប់រូបដែលមានកម្ពស់ទាបជាង ១៤៥ សង់ទីម៉ែត្រ មានចំនួន ៧.២ ភាគរយ ទល់នឹង ៦.៣ ភាគរយ ត្រូវបានរកឃើញដោយ អ.ប្រ.ស.ក ឆ្នាំ២០០៥ និង អ.ម.ក ឆ្នាំ ២០០៨ ។ ទោះបីជា បានធ្លាក់ចុះចំនួន ១ អត្រាភាគរយ ក៏ពិតមែន ប៉ុន្តែក្នុងន័យស្ថិតិចំនុចនេះ មិនត្រូវបានចាត់ទុកថាមានការប្រែប្រួលគួរឱ្យកត់សម្គាល់នោះទេ ។

ស្ត្រីគ្រប់រូបដែលត្រូវបានគិតថាប្រឈមនឹងភាពលំបាកក្នុងការផ្តល់កំនើតដល់កូននោះ គឺស្ត្រីគ្រប់រូបដែលមានកម្ពស់ទាបជាង ១៤៥ សង់ទីម៉ែត្រ ដោយភាគច្រើនស្ថិតនៅក្នុងវ័យបន្តពូជដែលមានអាយុចន្លោះពី ១៥ ទៅ ១៩ ឆ្នាំ មានចំនួនជិត ១០ ភាគរយ ។ កម្ពស់ទាបរបស់ស្ត្រីគ្រប់រូបដែលមានអាយុចន្លោះពី ១៥ ទៅ ៤៩ ឆ្នាំ ក្នុងស្ថានភាពអាហារូបត្ថម្ភខ្សត់ខ្សោយខ្លាំង ក៏ជាមូលហេតុផងដែលធ្វើឱ្យទារកពិបាកកើត និងស្លាប់នៅពេលសម្រាល ។

តារាងលេខ ៥ : សូចនាករមនុស្សមាត្រមាតា

| ស្ត្រីគ្រប់រូបមានអាយុចន្លោះពី ១៥ ទៅ ៤៩ ឆ្នាំ ដែលមានកូនអាយុក្រោម ៥ឆ្នាំ រួមមាន ភាគរយរបស់ស្ត្រីដែលមានកម្ពស់ក្រោម ១៤៥ សង់ទីម៉ែត្រ សន្ទស្សន៍មាឌរាងកាយជាមធ្យម និងកម្រិតភាគរយសន្ទស្សន៍មាឌរាងកាយនិមួយៗ ទៅតាមលក្ខណៈប្រវត្តិ ដោយអង្កេតមនុស្សមាត្រកម្ពុជា ឆ្នាំ២០០៨ | | | | | | | |
|---|---|---|---|---|---|---|---|
| | **កម្ពស់** | | **សន្ទស្សន៍** | **ភាពស្គម** | | **ភាពធាត់** | **ចំនួន** |
| | ភាគរយ កម្ពស់ក្រោម ១៤៥ សង់ទីម៉ែត្រ | ចំនួន ស្ត្រី | សមាសភាព រាងកាយ ជាមធ្យម | ភាពស្គម សរុប <18.5 | ស្គមល្មម ស្គមខ្លាំង ≤17.0 | ≥ 30.0 | **ស្ត្រី សរុប** |
| **អាយុម្តាយ** | | | | | | | |
| 15-19 | 9.8 | 183 | 20.2 | 21.3 | 3.2 | 0.0 | 145 |
| 20-29 | 5.9 | 4015 | 20.9 | 16.8 | 3.9 | 0.7 | 3477 |
| 30-39 | 6.6 | 2045 | 21.8 | 14.0 | 3.2 | 2.5 | 1860 |
| 40-49 | 7.1 | 644 | 21.8 | 17.5 | 4.4 | 3.0 | 618 |
| **តំបន់រស់នៅ** | | | | | | | |
| ទីប្រជុំជន | 5.3 | 1144 | 22.1 | 11.4 | 3 | 2.6 | 1048 |
| ទីជនបទ | 6.5 | 5744 | 21.1 | 17.1 | 3.9 | 1.2 | 5051 |
| **សរុប** | **6.3** | **6888** | **21.2** | **16.1** | **3.7** | **1.5** | **6099** |

អត្រាភាគរយខ្ពស់ជាងគេបំផុតនៃភាពស្គមរបស់ស្ត្រីដែលមានកូនអាយុក្រោម ៥ ឆ្នាំ ក្នុងបន្ទុកគ្រួសារ គឺស្ថិតនៅក្នុងក្រុមអាយុចន្លោះពី ១៥ ទៅ ១៩ ឆ្នាំ ។ មានន័យថា មួយក្នុងចំណោមស្ត្រី ៥នាក់ដែលតំណាងឱ្យស្ត្រីកម្ពុជាទាំងមូល មានបញ្ហាជាមួយនឹងភាពស្គម ខណៈដែលភាពធាត់ គឺមិនមានសោះ ។ ម្យ៉ាងវិញទៀត ក្នុងចំណោមស្ត្រីស្គមទូទាំងប្រទេស (១៦.១ ភាគរយ) មានស្ត្រីស្គមចំនួន ១៧.១ ភាគរយ រស់នៅតាមតំបន់ទីជនបទ និងមានចំនួន ១១.៤ ភាគរយ រស់នៅតំបន់ទីប្រជុំជន។ ដូចគ្នានេះដែរ ស្ត្រីមានកម្ពស់ទាប គឺរកឃើញថាមានអត្រាខ្ពស់នៅតំបន់ជនបទ ។

យ៉ាងណាមិញ តាមការវាស់វែងដោយសន្ទស្សន៍មាឌរាងកាយ (BMI) របស់ស្ត្រីក្នុងវ័យបន្តពូជជាមធ្យមមានចំនួន ២០.៩ ភាគរយ (ឧបសម្ព័ន្ធទី២ ស្តីអំពីមនុស្សមាត្រស្ត្រីឆ្នាំ២០០៥) ។ ប៉ុន្តែចាប់តាំងពីឆ្នាំ២០០៥ មក BMI របស់ស្ត្រីក្នុងចន្លោះអាយុពី ១៥ ទៅ ៤៩ ឆ្នាំ ស្ទើរតែពុំមានការផ្លាស់ប្តូរទេ ពោលគឺអត្រាមានត្រឹមតែ ២១.២ ភាគរយ ប៉ុណ្ណោះសម្រាប់ឆ្នាំ២០០៨ ។

រូបភាពលេខ ១០ បកស្រាយនូវការរីកចម្រើននៃភាពស្គម និងកង្វះទម្ងន់ក្នុងចំណោមស្ត្រី ។ ការធ្លាក់ចុះប្រមាណ ៣ អត្រាភាគរយ របស់ស្ត្រីស្គមពីឆ្នាំ២០០៥ (១៩.១ ភាគរយ) មកនៅត្រឹម ១៦.១ ភាគរយ នាឆ្នាំ២០០៨ មានអត្ថន័យសំខាន់ក្នុងន័យស្ថិតិ ។ អាការៈស្គមរបស់ស្ត្រី អាចមកពីកត្តាបរិភោគដែលស្ត្រីភាគច្រើនតែងតែបរិភោគតិចជាងគេក្នុងរង្វង់គ្រួសារបន្ទាប់ពីកុមារតូច ។ ជាទូទៅ ការកាត់បន្ថយចំនួនកូនក្នុងគ្រួសារ ឬការមានកូនតាមប្រាថ្នា និងចន្លោះពេលយូរនៃការផ្តល់កំណើតកូន ដែលបានរកឃើញដោយ អ.ប្រ.ស.ក ឆ្នាំ២០០៥ អាចរួមចំណែកក្នុងការលើកម្ពស់ស្ថានភាពអាហារូបត្ថម្ភឱ្យបានប្រសើរជាងមុន និងសមស្របសម្រាប់ស្ត្រី ។

**រូបភាពលេខ ១០ : និន្នាការប្រែប្រួលមនុស្សមាត្ររបស់មាតា**



## ១.៣. មាតា និងជម្ងឺខ្វាក់មាន់

ជីវជាតិអា គឺជាមីក្រូសារជាតិម្យ៉ាងសំខាន់សម្រាប់ប្រព័ន្ធការពារពីភាពពិការភ្នែក និងការចម្លងជម្ងឺ ។ បញ្ហាកង្វះជីវជាតិអាធ្ងន់ធ្ងររបស់មាតាអាចបណ្តាលឱ្យខ្វាក់ ឬពិការភ្នែក ។

**តារាងលេខ ៦ : ជម្ងឺខ្វាក់មាន់របស់មាតា**

| ភាគរយស្ត្រីជាម្តាយ ដែលមានទម្ងន់កូនក្រោយគេបង្អស់ ក្នុងអំឡុងពេល៥ឆ្នាំមុនអង្កេត មានបញ្ហាជាមួយជម្ងឺខ្វាក់មាន់ ដោយអង្កេតមនុស្សមាត្រកម្ពុជា ឆ្នាំ២០០៨ | | | |
|---|---|---|---|
| | ភាគរយស្ត្រីដែលមានបញ្ហាជាមួយជម្ងឺខ្វាក់មាន់ | | ចំនួនស្ត្រីសរុប |
| | ប្រាប់ដោយផ្ទាល់ | ក្រោយកែតម្រូវ | |
| **អាយុម្តាយ** | | | |
| 15-19 | 4.5 | 1.6 | 179 |
| 20-29 | 4.5 | 1.5 | 3984 |
| 30-39 | 5.9 | 1.7 | 2034 |
| 40-49 | 7 | 1.9 | 639 |
| **តំបន់រស់នៅ** | | | |
| ទីប្រជុំជន | 2.3 | 0.5 | 1136 |
| ទីជនបទ | 5.7 | 1.8 | 5700 |
| **សរុប** | 5.1 | 1.6 | 6836 |

តាមលទ្ធផលរបស់ អ.ប្រ.ស.ក ឆ្នាំ២០០៥ បានបង្ហាញថា ជម្ងឺខ្វាក់មាន់ក្នុងចំណោមស្ត្រីមានផ្ទៃពោះមានរហូតដល់ ៨ ភាគរយ មុនធ្វើការកែតម្រូវ ។ ស្ត្រីមានផ្ទៃពោះ (មុនកែតម្រូវ) ដែលប្រាប់ថាមានបញ្ហាជាមួយនឹងជម្ងឺខ្វាក់មាន់ក្នុងឆ្នាំ២០០៨ ភាគច្រើនគឺក្នុងវ័យ ៤០ ទៅ ៤៩ ឆ្នាំ មានចំនួន ៧ ភាគរយ និងនៅតាមទីជនបទមានប្រមាណ ៥.៧ ភាគរយ ។

### រូបភាពលេខ ១១ : និន្នាការប្រែប្រួលប្រេវ៉ាឡង់ជម្ងឺខ្វាក់មាន់របស់មាតា




ជាទូទៅបើអត្រាប្រេវ៉ាឡង់ខ្វាក់មាន់របស់ស្ត្រីមានផ្ទៃពោះ ធំជាងឬស្មើ ៥ ភាគរយ នោះគេសន្មតថាជាបញ្ហាសុខភាពសាធារណៈ ឬក៏មានកំហុសឆ្គងសំណួរសម្ភាសន៍នៅក្នុងអំឡុងពេលអង្កេត ។ មូលហេតុចម្បងមួយដែលធ្វើឱ្យកុមារអាយុក្រោម ២ ឆ្នាំ មានទំនាក់ទំនងជាមួយបញ្ហាកង្វះជីវជាតិអា និងបញ្ហាកង្វះមីក្រូសារជាតិដ៏ទៃទៀត គឺអាស្រ័យលើស្ត្រីគ្រប់រូបដែលជាម្តាយដែលមានអាយុចន្លោះពី ១៥ ទៅ ៤៩ ឆ្នាំ មានលទ្ធភាពទទួលបានបរិមាណអាហារដែលមានជីវជាតិគ្រប់គ្រាន់ដែរឺទេ ។ ប្រសិនបើម្តាយមិនបានទទួលទានអាហារដែលមានមីក្រូសារជាតិគ្រប់គ្រាន់នោះទេ ទារក និងកុមារក្នុងវ័យកំពុងលូតលាស់ ក៏ជួបនូវបញ្ហាកង្វះខាតមីក្រូសារជាតិទាំងអស់នេះដែរ ។ ដូច្នេះកំឡុងពេលអាយុកុមារកើនឡើង ជាពិសេស (៦ ទៅ ២៣ ខែ) អត្រាប្រេវ៉ាឡង់ជម្ងឺឆ្លងទំនងនឹងកើនឡើងដែរ មូលហេតុដោយសារតម្រូវការអាហារូបត្ថម្ភរបស់កុមារដែលមានអាយុក្រោម ៥ ឆ្នាំ កើនឡើងខ្លាំងខ្ពស់ជាងមុនដើម្បីឆ្លើយតបទៅនឹងកម្រិតនៃការលូតលាស់ ។

## ២. ជម្ងឺកុមារ

មូលហេតុភ្លាមៗនៃកង្វះមីក្រូសារជាតិ បណ្តាលមកពីការបរិភោគអាហារមិនគ្រប់គ្រាន់ក្នុងអំឡុងពេលអសន្តិសុខស្បៀងគ្រួសារ ឬក៏ការទទួលទានអាហារមិនសមស្របពីម្តាយទៅកូន ។ ជាធម្មតាមូលហេតុទាំងពីរខាងលើនេះ មិនបានធ្វើឱ្យកុមារអាយុក្រោម ៥ ឆ្នាំ ទទួលនូវជម្ងឺឆ្លងដោយផ្ទាល់នោះទេ

ក៏ប៉ុន្តែ កង្វះអាហារូបត្ថម្ភ កង្វះអនាម័យក្នុងចំណីអាហារ និងការហូបចុក អាចធ្វើឱ្យប្រព័ន្ធការពាររាងកាយដែលជាមុខងារសំខាន់សម្រាប់ទ្រទ្រង់រាងកាយ និងទប់ទល់នឹងជម្ងឺរបស់កុមារចុះខ្សោយ ហើយបង្កជាផលប៉ះពាល់ធ្ងន់ធ្ងរ លើស្ថានភាពសុខភាពរបស់កុមារ ។ ជាលទ្ធផល ជម្ងឺឆ្លងនឹងកើតមានឡើង ទោះបីក្នុងកម្រិតមួយតិច ឬច្រើន ។ នៅកម្ពុជា ជាទូទៅជម្ងឺកុមារដែលបានអង្កេតដោយ អ.ប្រ.ស.ក ២០០៥ មានដូចជា : ជម្ងឺរលាកផ្លូវដង្ហើម ជម្ងឺរាក និងគ្រុនក្តៅ ។ ជម្ងឺកុមារទាំងអស់នេះ ប្រែក្លាយជាមូលហេតុធ្ងន់ធ្ងរនៃអត្រាមរណៈភាពខ្ពស់របស់កុមារកម្ពុជា ក៏ដូចជាកុមារនៃប្រទេសកំពុងអភិវឌ្ឍន៍ដ៏ទៃទៀតដែរ ។

លទ្ធផលរបស់ អ.ម.ក ២០០៨ បង្ហាញថាអត្រាប្រេវ៉ាឡង់កុមារកើតជម្ងឺ មានកម្រិតខ្ពស់ជាងធម្មតា និងខ្ពស់ជាងការរំពឹងទុកធៀបនឹង អ.ប្រ.ស.ក ២០០០ និង២០០៥ ។ ផ្ទុយទៅវិញ លទ្ធផលខ្លះដែលបានដកស្រង់ចេញពីអង្កេតតាមគ្រួសារ អាចនឹងផ្តល់នូវទិន្នន័យដែលមិនអាចយកជាការបាន ក៏ដូចជាទិន្នន័យ ដែលបានកើតឡើងដោយហេតុការណ៍ចៃដន្យប៉ុណ្ណោះ ជាពិសេសទាក់ទងទៅនឹងការយល់ដឹងពីប្រភេទរោគសញ្ញានៃជម្ងឺនានា ។ ដូច្នេះ រាល់ព័ត៌មានទាក់ទងជាមួយជម្ងឺ ជាពិសេសអត្រាប្រេវ៉ាឡង់គ្រុនក្តៅ និងរាក ចាំបាច់ត្រូវធ្វើការពិនិត្យ និងវិភាគឱ្យបានដិតដល់ ។ ប្រភពទំនាក់ទំនងជាមួយនឹងជម្ងឺរបស់កុមារអាយុក្រោម ៥ ឆ្នាំ មានដូចជា : ក្រុមកុមារដែលមានអាយុទាបជាងគេ តំបន់ទីជនបទ គ្រួសារក្រីក្រនៅតាមតំបន់ទីជនបទ និងទីប្រជុំជន កាលានុវត្តភាពការងារ ក៏ដូចជាកម្រិតអប់រំរបស់ឪពុកម្តាយ និងរបៀបរស់នៅក្នុងហូបចុកផងដែរ ។

## ២.១. ជម្ងឺរលាកផ្លូវដង្ហើម

ជម្ងឺរលាកផ្លូវដង្ហើម គឺជាជម្ងឺឆ្លងរាលដាលមេរោគដែលមួយផ្នែកទំនងបណ្តាលមកពីវីរុសគ្រុនផ្តាសាយធំដែលជានិច្ចកាលនាំឱ្យមានអត្រាឆ្លងជម្ងឺខ្ពស់បំផុតនោះ គឺនៅក្នុងពេលអាកាសធាតុផ្លាស់ប្តូរ (រដូវរំហើយ ឬពេលភ្លៀងធ្លាក់) ។ វិធីសាស្ត្រសម្រាប់វិភាគជម្ងឺរលាកផ្លូវដង្ហើម ត្រូវបានកំណត់មុខសញ្ញា ដោយផ្អែកតាមការវិភាគរាងកាយ និងតាមការឆ្លុះកម្មរស្មីលើទ្រូងរបស់អ្នកជម្ងឺ ។ ដោយឡែកប្រទេសកម្ពុជា វិធីសាស្ត្រនៃការកំណត់មុខសញ្ញានៃជម្ងឺនៅក្នុង អ.ប្រ.ស.ក គឺធ្វើឡើងតាមការយល់ឃើញពីម្តាយ ឬអាណាព្យាបាលរបស់កុមារតែប៉ុណ្ណោះ ។

### រូបភាពលេខ ១២ : សំណួរកំណត់រោគសញ្ញាជម្ងឺរលាកផ្លូវដង្ហើមរបស់កុមារតាមអង្កេតប្រជាសាស្ត្រ និងសុខភាព កម្ពុជា ឆ្នាំ២០០៥

| | | | |
|---|---|---|---|
| ៥៣១ | តើ (ឈ្មោះ) មានក្អកនាពេលណាមួយ ក្នុងអំឡុងពេល ២សប្តាហ៍ក្រោយនេះទេ? | មាន .................................... | ១ |
| | | មិនមាន ................................<br>បើសិនមិនមាន តទៅលេខ ៥៣៤ | ២ |
| | | មិនដឹង .................................. | ៣ |
| ៥៣២ | នៅពេល (ឈ្មោះ) ក្អក តើមានដកដង្ហើមលឿនជាងមុន ខ្លី ឬពិបាកដកដង្ហើមដែរឬទេ? | មាន .................................... | ១ |
| | | មិនមាន ................................<br>បើសិនមិនមាន តទៅលេខ ៥៣៤ | ២ |
| | | មិនដឹង .................................. | ៣ |
| ៥៣៣ | នៅពេល (ឈ្មោះ) ឈឺ តើមានបញ្ហាជាមួយឈឺទ្រូង ឬតឹងច្រមុះ ឬហៀរសំបោរដែរឬទេ? | មានតែឈឺទ្រូង .......................... | ១ |
| | | មានតែហៀរសំបោរ ..................... | ២ |
| | | ទាំងពីរខាងលើ .......................... | ៣ |
| | | ផ្សេងៗ<br>បញ្ជាក់ ________ | ៦ |
| | | មិនដឹង ..................................<br>តទៅលេខ ៥៣៤ | ៨ |

យោងតាមវិធីសាស្ត្រគណនារបស់ អ.ប្រ.ស.ក នាឆ្នាំ២០០០ (ក្អក ដកដង្ហើមខ្លីៗហើយញាប់) របស់តារាងលេខ ១៣ បង្ហាញថាប្រេវ៉ាឡង់រោគសញ្ញាមាន ២១.៤ ភាគរយ ។ ប៉ុន្តែ សមាមាត្រ បានធ្លាក់មក នៅកម្រិតត្រឹមតែ ១៥.៨ ភាគរយ នាឆ្នាំ២០០៥ ។ ប្រេវ៉ាឡង់ថយចុះនេះ អាចអាស្រ័យ លើវិធីសាស្ត្រថ្មី (ឈឺទ្រូង នៅពេលក្អក និងពិបាកដកដង្ហើម) ត្រូវបានបន្ថែម ។

### រូបភាពលេខ ១៣ : និន្នាការប្រែប្រួលរោគសញ្ញាជម្ងឺរលាកផ្លូវដង្ហើមរបស់កុមារតាមរូបមន្តគណនា ឆ្នាំ២000

អត្រាប្រេវ៉ាឡង់កុមារអាយុតិចជាងគេ ក្នុងចំណោមកុមារអាយុពី ០_៤ ឆ្នាំ
មានរោគសញ្ញាជម្ងឺផ្លូវដង្ហើម ដោយអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា
ឆ្នាំ២០០០_២០០៥ និងអង្កេតមនុស្សមាត្រកម្ពុជា ឆ្នាំ២០០៨




ការរកឃើញនូវអត្រាប្រេវ៉ាឡង គឺតាមរយៈការប្រើប្រាស់វិធីសាស្ត្ររបស់ អ.ប្រ.ស.ក ២០០០ ដោយក្នុងនោះ ក្អក និងពិបាកដកដង្ហើម ត្រូវបានរាប់បញ្ចូល

ដើម្បីកំណត់បាននូវលទ្ធផលដែលសុក្រឹត និងអាចប្រៀបធៀបគ្នាបាន ចាំបាច់ត្រូវមានសំណួរបន្ថែមទៀត (កុមារដែលមានអាយុតិចជាងគេក្នុងចំណោមកុមារអាយុក្រោម ៥ ឆ្នាំ) សម្រាប់ អ.ប្រ.ស.ក ២០០៥ និង អ.ម.ក ២០០៨ ។ ចំណែកឯ ក្អក ដកដង្ហើមខ្លីៗហើយញាប់ ឈឺទ្រូងនៅពេលក្អក និងពិបាកដកដង្ហើម នឹងនៅតែជាលក្ខណៈវិនិច្ឆ័យដ៏ប្រសើរ សំដៅកំណត់រករោគសញ្ញាជម្ងឺរលាកផ្លូវដង្ហើម ។ យ៉ាងណាមិញ ដោយសារតែការប្រើប្រាស់នូវវិធីសាស្ត្រថ្មីសម្រាប់គណនារកភាគរយពិតនោះប្រេវ៉ាឡង់ជម្ងឺរលាកផ្លូវដង្ហើមតាម អ.ម.ក ឆ្នាំ២០០៨ មានចំនួន ១៥.៦ ភាគរយ ដោយបានកើនឡើងទ្វេដងធៀបនឹងឆ្នាំ២០០៥ ដែលមានភាគរយត្រឹមតែ ៨.៩ ប៉ុណ្ណោះ (តារាងលេខ ១៤) ។ យើងសង្កេតឃើញថា ទោះបីជាវិធីសាស្ត្រទាំងពីរនេះផលិតនូវភាគរយខុសគ្នាក៏ពិតមែន ក៏ប៉ុន្តែវាផ្តល់នូវលទ្ធផលរួមមួយថា ចំនួនកុមារមានរោគសញ្ញាជម្ងឺរលាកផ្លូវដង្ហើមបានកើនឡើងពីរដងពីឆ្នាំ ២០០៥ ទៅឆ្នាំ២០០៨ ។

**រូបភាពលេខ ១៨ : និន្នាការប្រែប្រួលរោគសញ្ញាជម្ងឺរលាកផ្លូវដង្ហើមរបស់កុមារតាមរូបមន្តគណនា ឆ្នាំ២០០៥**

ចំនុចប្រេវ៉ាឡង់កុមារអាយុតិចជាងគេ ក្នុងចំណោមកុមារអាយុពី ០_៤ ឆ្នាំ មានរោគ សញ្ញាជម្ងឺរលាកផ្លូវដង្ហើមដោយអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ឆ្នាំ២០០៥ និងអង្កេតមនុស្សមាត្រកម្ពុជា ឆ្នាំ២០០៨




ការរកឃើញនូវចំនុចប្រេវ៉ាឡង់ គឺតាមរយៈការប្រើប្រាស់វិធីសាស្ត្ររបស់ អ.ប្រ.ស.ក ២០០៥ ដោយក្នុងនោះ ក្អក ពិបាកដកដង្ហើម និងឈឺទ្រូងនៅពេលក្អក ត្រូវបានរាប់បញ្ចូល

កំណត់សំគាល់ : ការធ្វើគណនាឡើងវិញនូវប្រេវ៉ាឡង់របស់អ.ប្រ.ស.ក ២០០៥ នៃរោគសញ្ញាជម្ងឺរលាកផ្លូវដង្ហើម ដើម្បីប្រៀបធៀប ជាមួយនឹងប្រេវ៉ាឡង់ថ្មី នៃអង្កេតមនុស្សមាត្រកម្ពុជា ២០០៨

ក្មេងដែលមានអាយុក្រោម ២ ឆ្នាំ ងាយប្រឈមមុខនឹងជម្ងឺរលាកផ្លូវដង្ហើម ជាមួយប្រេវ៉ាឡង់ប្រហែល ១១.៥ ភាគរយ (០ ទៅ ៥ ខែ) ១៧.១ ភាគរយ (៦ ទៅ ១១ ខែ) និង ១៧ ភាគរយ (១២ ទៅ ២៣ ខែ) ខ្ពស់ជាងបណ្តាក្រុមក្មេងផ្សេងៗ ។ យ៉ាងណាមិញ កម្រិតខុសគ្នាខ្លាំង គឺត្រូវបានឃើញទៅតាមតំបន់រស់នៅរបស់កុមារ ។ អត្រានៃការមានរោគសញ្ញាជម្ងឺរលាកផ្លូវដង្ហើមនៅទីប្រជុំជន គឺ ៩.១ ភាគរយ ។ ភាគរយនេះ នៅតិចជាង ៥០ ភាគរយ ធៀបនឹងទីជនបទ ដែលមានអត្រាប្រមាណ ១៦.៧ ភាគរយ ។ គម្លាតខុសគ្នាមួយផ្សេងទៀត គឺត្រូវបានរកឃើញពាក់ព័ន្ធនឹងកម្រិតជីវភាពរស់នៅរបស់គ្រួសារដោយឡែកពីគ្នា ។ ការព្យាបាលដោយថ្នាំអង់ទីប៊ីយូទិកឱ្យបានទាន់ពេលវេលា និងការវិនិច្ឆ័យរោគឱ្យបានត្រឹមត្រូវអាចជួយទប់ស្កាត់នូវអត្រាមរណៈភាព ដោយសារជម្ងឺរលាកផ្លូវដង្ហើមក្នុងចំណោមកុមារដែលមានអាយុ ក្រោម ៥ ឆ្នាំ ។

តារាងលេខ ៧ : រោគសញ្ញាជម្ងឺរលាកផ្លូវដង្ហើមរបស់កុមារតាមរូបមន្ត ឆ្នាំ២០០៥

| ភាគរយកុមារអាយុតិចជាងគេក្នុងចំណោមកុមារដែលមានអាយុក្រោម ៥ ឆ្នាំ មានរោគសញ្ញាជម្ងឺរលាកផ្លូវដង្ហើម ក្នុងអំឡុងពីរសប្តាហ៍មុនអង្កេត តាមលក្ខណៈប្រវត្តិ ដោយអង្កេតមនុស្សមាត្រកម្ពុជា ឆ្នាំ២០០៨ | | |
|---|---|---|
| លក្ខណៈប្រវត្តិ | **រោគសញ្ញាជម្ងឺរលាកផ្លូវដង្ហើម** | **ចំនួនកុមារ** |
| **អាយុជាខែ** | | |
| ០ - ៥ | 11.5 | 550 |
| ៦ - ១១ | 17.1 | 736 |
| ១២ - ២៣ | 17.0 | 1520 |
| ២៤ - ៣៥ | 14.8 | 1364 |
| ៣៦ - ៤៧ | 16.2 | 1440 |
| ៤៨ - ៥៩ | 14.3 | 1200 |
| **ភេទ** | | |
| ប្រុស | 15.6 | 3481 |
| ស្រី | 15.3 | 3330 |
| **តំបន់** | | |
| ប្រជុំជន | 9.1 | 1135 |
| ជនបទ | 16.7 | 5676 |
| **ធនធានទ្រព្យសម្បត្តិ** | | |
| ក្របំផុត | 20.4 | 1316 |
| ក្រ | 17.9 | 1228 |
| មធ្យម | 16.0 | 1392 |
| មាន | 16.2 | 1407 |
| មានបំផុត | 8.0 | 1473 |
| **សរុប** | **15.5** | **6811** |

រូបភាពខាងក្រោមនេះ បង្ហាញអំពីការប្រៀបធៀបនិន្នាការនូវចំនុចប្រេវ៉ាឡង់នៃរោគសញ្ញាជម្ងឺរលាក ផ្លូវដង្ហើមក្នុងចំណោមកុមារអាយុតិចជាងគេ ចាប់ពី ០ ទៅ ៤ ឆ្នាំ របស់ អ.ប្រ.ស.ក ឆ្នាំ២០០៥ និង អ.ប្រ.ស.ក ក្នុងខែវិច្ឆិកា ឆ្នាំ២០០៥ និង អ.ម.ក ឆ្នាំ២០០៨ ។ ដោយប្រើវិធីសាស្ត្រឆ្នាំ២០០០

នោះប្រេវ៉ាឡង់រោគសញ្ញាជម្ងឺរលាកផ្លូវដង្ហើមសម្រាប់ឆ្នាំ២០០៨ មាន ២៨.៩ ភាគរយ គឺខ្ពស់ជាងប្រហែលពាក់កណ្តាលធៀបនឹងវិធីសាស្ត្រឆ្នាំ២០០៥ ដែលមានប្រេវ៉ាឡង់ចំនួន ១៥.៦ ភាគរយ ។

**រូបភាពលេខ ១៥ : និន្នាការប្រែប្រួលរោគសញ្ញាជម្ងឺរលាកផ្លូវដង្ហើមរបស់កុមារក្នុងខែតែមួយ**

ពិន្ទុប្រេវ៉ាឡង់រោគសញ្ញាជម្ងឺរលាកផ្លូវដង្ហើមក្នុងចំណោមកុមារក្មេងជាងគេបង្អស់ដែលមានអាយុពី 0 ទៅ ៤ ឆ្នាំ ដោយអង្កេតប្រជាសាស្ត្រនិងសុខភាពកម្ពុជា ឆ្នាំ២០០៥ និងអង្កេតមនុស្សមាត្រកម្ពុជា ឆ្នាំ២០០៨




វិធីសាស្ត្រសម្រាប់គណនារកប្រេវ៉ាឡង់ឆ្នាំ២០០០ មានភាពខុសគ្នាពីឆ្នាំ២០០៥ ដោយសារការកំណត់រោគសញ្ញាចំនួនពីរ (ក្អក និងពិបាកដកដង្ហើម) ត្រូវបានបន្ថែមទៅក្នុងអង្កេតឆ្នាំ២០០០ រីឯបញ្ហាឈឺទ្រូងត្រូវបានបន្ថែមសម្រាប់ឆ្នាំ២០០៥

## ២.២. ជម្ងឺរាគ

រាគ គឺជាការបន្ទោរបង់ដែលមានលាមករាវមកជាមួយទឹក ។ សម្រាប់ អ.ម.ក ២០០៨ បានកំណត់ថា កុមារកើតជម្ងឺរាគ លុះត្រាតែការបន្ទោរបង់ដែលមានលាមករាវមកជាមួយទឹកលើសពីចំនួន ៣ ដងក្នុងមួយថ្ងៃ នាថ្ងៃណាមួយក្នុងរយៈពេល ២ សប្តាហ៍កន្លងមកមុនអង្កេត ។ វីរុស បាក់តេរី និងប៉ារ៉ាស៊ិតដែលឆ្លងតាមការបរិភោគដោយគ្មានអានាម័យ ផឹកទឹកមិនស្អាត និងទាក់ទងជាមួយនឹងកាកសំណល់ផ្សេងប្រមូលផ្តុំលាក់ខ្លួននៅក្នុងពោះវៀន ហើយចុងក្រោយបង្កើតបានជាភ្នាក់ងារចម្លងរោគ ។ ជាទូទៅកង្វះអនាម័យ ជាពិសេសផ្នែកកាកសំណល់តាមបណ្តាគ្រួសារដែលនៅតែជាបញ្ហាបង្កឱ្យកើតមានជម្ងឺរាគក្នុងអត្រាប្រេវ៉ាឡង់មួយខ្ពស់ ។ ដូចគ្នានេះដែរ កង្វះខាតមីក្រូសារជាតិស័ង្កសី (អាហារប្រភេទសាច់ក្រហមខ្សត់ខ្សោយ) ក៏ជាមូលហេតុមួយសំខាន់ផងដែរ ចំពោះក្មេងដែលមានអាយុច្រើន

ជាង ៦ ខែ ។ ជម្ងឺរាក ជាភ្នាក់ងារសំខាន់នៃការមានអាហារូបត្ថម្ភខ្សត់ខ្សោយ ពីព្រោះតែតម្រូវការសារជាតិខ្ពស់ក្នុងអំឡុងពេលមានជម្ងឺរាក ។

អង្កេតឆ្នាំ២០០៥ តាមវិធីសាស្ត្រគណនាថ្មី បានបង្ហាញថាប្រេវ៉ាឡង់នៃជម្ងឺរាករបស់កុមារអាយុក្រោម ៥ ឆ្នាំ គឺស្ថិតក្នុងកម្រិត ២១.៦ ភាគរយ ។ អត្រាជម្ងឺរាកនៃកុមារអាយុចាប់ពី ០ ទៅ ៤ ឆ្នាំ សម្រាប់ក្នុងខែ វិច្ឆិកា ឆ្នាំ២០០៥ របស់ អ.ប្រ.ស.ក ២០០៥ (ដោយសារតែ អ.ម.ក ២០០៨ បានធ្វើនៅក្នុងខែវិច្ឆិកា) មានសមាមាត្រប្រហាក់ប្រហែលនឹង ២២.១ ភាគរយ ។ លទ្ធផលអង្កេតបង្ហាញថា អាយុតាមខែ និងកម្រិត ទ្រព្យសម្បត្តិ ក៏ទំនងជាកត្តារួមចំណែកសំខាន់ផងដែររបស់អត្រាប្រេវ៉ាឡង់ជម្ងឺរាកកុមារ ។ តួយ៉ាងក្រុមទារកអាយុចាប់ពី ០ ទៅ ៥ ខែ និងកុមារដែលមានអាយុពី ៦ ទៅ ១១ ខែ មានអត្រាប្រេវ៉ាឡង់ខ្ពស់ជាងកុមារដែលមានអាយុច្រើនជាង ។ ដូចគ្នានេះដែរ ក្រុមកុមារដែលមានអាយុចាប់ពី ៤៨ ទៅ ៥៩ ខែ មានអត្រាដូចគ្នានឹងកុមារដែលមានជីវភាពគ្រួសារធូរធា (ប្រមាណ ១៩ ភាគរយ) ។ ការមានអត្រាប្រេវ៉ាឡង់ខ្ពស់ចំពោះក្រុមទារក និងកុមារដែលមានអាយុ ០ ទៅ ៥ ខែ ទំនងដោយសារការផ្តល់នូវអាហារបន្ថែមលឿនពេក ក៏ដូចជាការបន្ថែម និងផ្លាស់ប្តូរនូវអាហារប្រភេទថ្មី ។

ជម្ងឺរាករបស់កុមារនៅតែជាកង្វល់ធំ ទោះបីវាជាជម្ងឺសាមញ្ញក្នុងស្រទាប់កុមារអាយុក្រោម ៥ឆ្នាំក្តី ។ ប៉ុន្តែ ចាំបាច់ទាមទារនូវការឆ្លើយតប និងបកស្រាយច្រើនពីលក្ខណៈទំនាក់ទំនងរវាងមូលហេតុជម្ងឺ និងកង្វះអាហារូបត្ថម្ភនៅពេលដែលក្មេងចាប់ផ្តើមទទួលទានអាហារបន្ថែមក្នុងអំឡុងពេលបំបៅដោះម្តាយតែមួយមុខត្រូវបានកាត់បន្ថយសម្រាប់ក្មេងអាយុលើសពី ៦ ខែឡើងទៅ ។

រូបភាពលេខ ១៦ : និន្នាការប្រែប្រួលជម្ងឺរាគរបស់កុមារ




តារាងលេខ ៨ បង្ហាញពីប្រេវ៉ាឡង់នៃជម្ងឺរាគរបស់កុមារអាយុតិចជាងគេក្នុងចំណោមកុមារដែលមានអាយុក្រោម ៥ ឆ្នាំ កំឡុងពេល ២ សប្តាហ៍មុនអង្កេត ។ ជាក់ស្តែង មានកុមារប្រហែលជា ២៩.៧ ភាគរយ ឬ ១ភាគ៣ ក្នុងចំណោមកុមារកម្ពុជាដែលមានអាយុក្រោម ៥ ឆ្នាំ បានកើតជម្ងឺរាគ ។ ហើយក្នុងនោះមាន ២.៩ ភាគរយ រាគលាយឈាម ឬរាគមូល ។ ដំណាលគ្នានេះដែរ កុមារដែលមានអាយុតិចជាង ២៤ ខែ ទូទាំងប្រទេសមានចំនួនប្រមាណ ៣០ ភាគរយបានកើតជម្ងឺរាគ ។ ក្រុមកុមារដែលប្រឈមនឹងកើតជម្ងឺរាគ ភាគច្រើនជាក្រុមកុមារដែលរស់នៅក្នុងតំបន់ទីជនបទដោយមានចំនួន ៣១.៦ ភាគរយ ធៀបនឹង (២០.១ ភាគរយ) ដែលជាក្រុមកុមាររស់នៅក្នុងតំបន់ទីប្រជុំជន ដែលយើងគិតថា ជាទីកន្លែងមានលក្ខណៈប្រសើរ សម្រាប់ប្រជាពលរដ្ឋអាចមានលទ្ធភាពប្រើប្រាស់ជំនួយពីសេវាគាំពារសុខភាព ។

ដូចគ្នានេះដែរ សមាមាត្រជម្ងឺរាគរបស់កុមារដែលមានជីវភាពគ្រួសារក្រីក្រ មានចំនួនខ្ពស់ជាងក្រុមកុមារដែលរស់នៅជាមួយគ្រួសារមានជីវភាពធូរធា ។

តារាងលេខ ៨ : ស្ថានភាពជម្ងឺរាគរបស់កុមារ

| ភាគរយនៃកុមារអាយុតិចជាងគេក្នុងចំណោមក្មេងអាយុក្រោម ៥ ឆ្នាំ មានជម្ងឺរាគក្នុងរយៈពេលពីរសប្តាហ៍មុនអង្កេតតាមលក្ខណៈផ្សេងៗ ដោយអង្កេតមនុស្សមាត្រកម្ពុជា ឆ្នាំ២០០៨ | | | |
|---|---|---|---|
| លក្ខណៈប្រវត្តិ | **រាគសរុប** | **រាគមូល** | **ចំនួនកុមារ** |
| **អាយុជាខែ** | | | |
| ០ - ៥ | 33.4 | 1.6 | 919 |
| ៦ - ១១ | 38.3 | 4.4 | 1006 |
| ១២ - ២៣ | 32.9 | 2.4 | 1892 |
| ២៤ - ៣៥ | 28.2 | 3.6 | 1287 |
| ៣៦ - ៤៧ | 21.0 | 2.8 | 980 |
| ៤៨ - ៥៩ | 19.2 | 2.5 | 742 |
| **ភេទ** | | | |
| ប្រុស | 31.5 | 3.1 | 3525 |
| ស្រី | 27.7 | 2.7 | 3301 |
| **តំបន់** | | | |
| ប្រជុំជន | 20.1 | 1.6 | 1149 |
| ជនបទ | 31.6 | 3.1 | 5677 |
| **កម្រិតទ្រព្យសម្បត្តិ** | | | |
| ក្របំផុត | 37.7 | 4.5 | 1316 |
| ក្រ | 32.2 | 2.7 | 1228 |
| មធ្យម | 32.2 | 2.6 | 1392 |
| មាន | 28.6 | 3.8 | 1407 |
| មានបំផុត | 19.0 | 0.9 | 1473 |
| **សរុប** | **29.7** | **2.9** | **6826** |

ទោះបីជាវិធីសាស្ត្រព្យាបាលជម្ងឺរាគរបស់កុមារ មិនត្រូវបានសួរនាំពេលអង្កេតក៏ដោយ ក៏ការងារសំខាន់ៗមួយចំនួន អាចផ្តល់នូវអត្ថប្រយោជន៍យ៉ាងសំខាន់សម្រាប់ជួយទប់ស្កាត់ និងជួយសង្គ្រោះបឋមសម្រាប់ការរស់រានមានជីវិតរបស់កុមារ ។ វិធីសាស្ត្រសាមញ្ញនៃការព្យាបាល ដូចជាការបំពេញនូវការបាត់បង់ជាតិទឹកតាមរយៈអំបិលអូរ៉ាលីត ការព្យាបាលតាមមធ្យោបាយបង្កើនបរិមាណអាហាររាវ និងការបញ្ជូនទៅកាន់មណ្ឌលសុខភាពទាន់ពេលវេលា ដើម្បីស្វែងរកជំនួយពីបុគ្គលិក

សុខាភិបាល ។ ការបំបៅកូនដោយទឹកដោះម្ដាយតែមួយមុខក្នុងរយៈពេល ៦ ខែ ដំបូងនៃជីវិត អាចជួយកាត់បន្ថយអត្រាមរណៈភាពរបស់កុមារដែលបណ្ដាលមកពីជម្ងឺរាកបាន ព្រោះថាទឹកដោះម្ដាយផ្ទុកមីក្រូសារជាតិសំខាន់ៗសម្រាប់កុមារ (ក្រុមស្រ្ដីជាម្ដាយដែលមានអាហារបរិភោគគ្រប់គ្រាន់) ។

## ២.៣. គ្រុនក្ដៅ

ជាការកើនឡើងនូវសីតុណ្ហភាពក្នុងខ្លួនហួសពីកម្រិតធម្មតាដែលជាទូទៅមានត្រឹមតែ ៣៧ អង្សាសេ ប៉ុណ្ណោះ ។ កម្ដៅក្នុងខ្លួនខ្លាំងធ្វើឱ្យកុមារទទួលទានអាហារមិនបានគ្រប់គ្រាន់ ខ្វះជាតិទឹកដែលជាកត្តាជំរុញឱ្យកុមារកើតគ្រុនក្ដៅខ្លាំងជាងមុន កាន់តែអស់កម្លាំង និងមានសភាពធ្ងន់ធ្ងរ ។ គ្រុនក្ដៅបង្កឡើងដោយជម្ងឺឆ្លងនានា ដូចជា : ផ្ដាសាយ គ្រុនចាញ់ ។ល។ ហើយទាមទារនូវវិធីព្យាបាលដោយឡែកពីគ្នា ។ ជាទូទៅ អ.ប្រ.ស.ក ដោយយោងតាមរូបមន្តថ្មីបានបង្ហាញថា មិនមានការប្រែប្រួលនូវអត្រាប្រេវ៉ាឡង់នៃគ្រុនក្ដៅរបស់កុមារអាយុក្រោម ៥ ឆ្នាំ នោះទេ រវាងឆ្នាំ២០០០ និងឆ្នាំ២០០៥ ក្នុងសមាមាត្រ ៣៧.១ ភាគរយ ។ គ្រុនក្ដៅធម្មតាអាចព្យាបាលបានដោយការប្រើប្រាស់ថ្នាំបញ្ចុះកម្ដៅ និងការបញ្ជូនកុមារទៅកាន់មណ្ឌលសុខភាព ។

រូបភាពលេខ ១៧ : និន្នាការប្រែប្រួលរបស់កុមារកើតគ្រុនក្ដៅ




រូបភាពទី ១៧ បង្ហាញថាអត្រាប្រេវ៉ាឡង់នៃកុមារអាយុតិចជាងគេក្នុងចំណោមកុមារដែលមានអាយុក្រោម ៥ ឆ្នាំ ដែលកើតគ្រុនក្ដៅ បានកើនឡើងជិតទ្វេដងចាប់ពី ៣៧.១ ភាគរយ នាឆ្នាំ២០០៥ ឬ ៣៩.៦ ភាគរយ សម្រាប់ខែវិច្ឆិកា នាឆ្នាំ២០០៥ មក ៥៨.៩ ភាគរយ នាឆ្នាំ២០០៨ ។

តារាងលេខ ៩ : ស្ថានភាពគ្រុនក្តៅរបស់កុមារ

| ភាគរយកុមារអាយុតិចជាងគេក្នុងចំណោមកុមារដែលមានអាយុក្រោម ៥ ឆ្នាំ កើតជម្ងឺគ្រុនក្តៅ ក្នុងអំឡុងពេល ពីរសប្តាហ៍មុនអង្កេតតាមលក្ខណៈផ្សេងៗ ដោយអង្កេតមនុស្សមាត្រកម្ពុជា ឆ្នាំ២០០៨ | | |
|---|---|---|
| លក្ខណៈប្រវត្តិ | **គ្រុនក្តៅសរុប** | **ចំនួនកុមារ** |
| **អាយុជាខែ** | | |
| ០  ៥ | 53.5 | 550 |
| ៦  ១១ | 64.5 | 736 |
| ១២  ២៣ | 62.6 | 1520 |
| ២៤  ៣៥ | 58.0 | 1364 |
| ៣៦  ៤៧ | 48.4 | 104 |
| ៤៨  ៥៩ | 53.5 | 131 |
| **ភេទ** | | |
| ប្រុស | 58.8 | 3525 |
| ស្រី | 58.9 | 3301 |
| **តំបន់** | | |
| ប្រជុំជន | 45.6 | 1138 |
| ជនបទ | 61.5 | 5698 |
| **កម្រិតទ្រព្យសម្បត្តិ** | | |
| ក្របំផុត | 66.7 | 1316 |
| ក្រ | 60.3 | 1228 |
| មធ្យម | 60.5 | 1392 |
| មាន | 59.3 | 1407 |
| មានបំផុត | 48.7 | 1473 |
| **សរុប** | **58.9** | **6836** |

ប្រេវ៉ាឡង់គ្រុនក្តៅមានកម្រិតទាបក្នុងចំណោមក្រុមកុមារដែលមានអាយុតិចជាង ៦ខែ (៥៣.៥ ភាគរយ) និង (៤៨.៤ ភាគរយ) សម្រាប់កុមារតូចដែលមានអាយុចន្លោះ ៣៦ ទៅ ៤៧ ខែ ។ ជារួម សមាមាត្រនៃជម្ងឺមានភាពខុសគ្នាទៅតាមក្រុមប្រភេទអាយុរបស់កុមារ ។ កុមារដែលមានអាយុកាន់តែច្រើន អត្រាប្រឈមនឹងជម្ងឺកាន់តែតិច ។ តាមតារាងរបស់សូចនាករទាំង ៣ ខាងលើ យើងឃើញថា

បន្ទាប់ពីខែដំបូងនៃជីវិតមក អត្រាប្រេវ៉ាឡង់នៃជម្ងឺរបស់កុមារដែលមានអាយុពី ៦ ទៅ ២៤ ខែ បានចាប់ផ្តើមកើនឡើងរហូតបដល់ចំនុចកំពូល ។ បន្ទាប់មកអត្រាប្រេវ៉ាឡង់បានចាប់ផ្តើមធ្លាក់ចុះបន្តិចម្តងៗ ទៅតាមអាយុកាលរបស់កុមារ ។ ប៉ុន្តែលើកលែងតែគ្រុនក្តៅមួយប៉ុណ្ណោះ ដែលមានអត្រាប្រេវ៉ាឡង់ខ្ពស់បំផុតប្រហាក់ប្រហែលគ្នា ។ កុមារដែលមានអាយុក្រោម ៥ ឆ្នាំ ដែលបានរកឃើញក្នុងអង្កេតតាមគ្រួសារ ច្រើនជាង ៥០ ភាគរយ មានគ្រុនក្តៅ ។

ជាលទ្ធផល អត្រាប្រេវ៉ាឡង់នៃជម្ងឺរបស់កុមារដែលមានអាយុក្រោម ៥ ឆ្នាំ ត្រូវបានរកឃើញថាមានចំនួនកើនឡើងនាឆ្នាំ២០០៨ ។ ជាមួយនឹងអត្រាកំណើននេះ អាចធ្វើឱ្យប៉ះពាល់ដល់សកម្មភាពដំណើរការខិតខំប្រឹងប្រែងនៃគោលនយោបាយរដ្ឋាភិបាល ក៏ដូចជាអង្គការពាក់ព័ន្ធនានាក្នុងវិស័យសុខាភិបាល ។ បញ្ហាប្រឈមនេះចាំបាច់ទាមទារនូវការកំណត់មូលហេតុ និងកំណត់គោលដៅឱ្យបានច្បាស់ដែលមានលក្ខណៈងាយស្រួល និងអាចធ្វើបាន និងការងារអន្តរាគមន៍បន្ទាន់ដែលប្រជាពលរដ្ឋអាចមានលទ្ធភាពទទួលបាននូវការប្រើប្រាស់ ដើម្បីលើកកម្ពស់សុខភាពកុមារជាពិសេសកុមារនៅតាមទីជនបទ និងតំបន់ទីប្រជុំជនក្រីក្រ ។

## ៣. យុទ្ធសាស្ត្រដោះស្រាយបន្ទាន់ និងការប្រើប្រាស់អាហារ

សន្ទស្សន៍ខ្ពស់នៃថ្លៃទំនិញប្រើប្រាស់ បានបន្សល់នូវគោលនយោបាយជំនួយសង្គ្រោះបន្ទាន់ភ្លាមៗ ក៏ដូចជាទិន្នន័យសំខាន់ៗខ្លះដែលមិនទាន់បានបកស្រាយបំភ្លឺ ។ គោលនយោបាយត្រឹមត្រូវក្នុងរយៈពេលវែង មធ្យម និងខ្លី ។ ហើយក្នុងពេលដំណាលគ្នានោះ យុទ្ធសាស្ត្រដោះស្រាយបន្ទាន់ចាំបាច់ត្រូវបានលើកឡើង ដើម្បីជួយសម្រួលស្ថានការណ៍អសន្តិសុខស្បៀងរបស់គ្រួសារ ការជួយពង្រឹងឡើងវិញនូវស្ថានភាពអាហារូបត្ថម្ភរបស់កុមារ និងស្ត្រីងាយរងគ្រោះដោយបញ្ហាថ្លៃទំនិញ និងម្ហូបអាហារកើនខ្ពស់ជាងមុនខ្លាំង ហើយជាពិសេសនោះ គឺការខំប្រឹងប្រែងដើម្បីសម្រេចបាននូវការលុបបំបាត់ភាពក្រីក្រធ្ងន់ធ្ងរ និងភាពអត់ឃ្លានដែលជាគោលដៅទី១របស់គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា។

ក្នុងបរិបទអង្កេតថ្លៃទំនិញ និងម្ហូបអាហារខ្ពស់ យុទ្ធសាស្ត្រដោះស្រាយបន្ទាន់របស់គ្រួសារនិមួយៗ គឺជាវិធីសាស្ត្រផ្ទាល់សំដៅកាត់បន្ថយនូវទំហំផលពិបាកផ្នែកហិរញ្ញវត្ថុរបស់គ្រួសារ ត្រូវបានយកមកប្រើប្រាស់ជាមួយអង្កេតមនុស្សមាត្រកម្ពុជា ២០០៨ ។

### ៣.១. ទំនាក់ទំនងការប្រើប្រាស់អាហារ និងយុទ្ធសាស្ត្រដោះស្រាយបន្ទាន់

ទំនាក់ទំនងនៃការកើនឡើងថ្លៃម្ហូបអាហារក្នុងប្រទេសកម្ពុជា អាចបណ្តាលមកពីតម្លៃអាហារទីផ្សារអន្តរជាតិបានហក់ឡើងក្នុងកម្រិតខ្ពស់ជាងមុន បានជម្រុញទឹកចិត្តឱ្យកសិករក្នុងស្រុកផលិតនូវផលិតផលម្ហូបអាហារបន្ថែមសម្រាប់ការផ្គត់ផ្គង់លើទីផ្សារក្នុងតម្លៃមួយដែលតែងតែខ្ពស់ ឬថ្លៃជាងមុន។

ប្រការនេះ បានធ្វើឱ្យមានផលពិបាកដល់អ្នកប្រើប្រាស់ទំនិញដុល ឬក៏អ្នកទិញអាហារដែលមិនមានលទ្ធភាពគ្រប់គ្រាន់ក្នុងការទទួលបាននូវអាហារដែលបានឡើងថ្លៃទាំងអស់នោះ ។ ជាលទ្ធផលចំណូល និងជីវភាពរបស់គ្រួសារជាពិសេសគ្រួសារក្រីក្រទំនងទទួលផលប៉ះពាល់ពីករណីទាំងពីរនេះ ។

យុទ្ធសាស្ត្រដែលគ្រួសារខ្លះនៅក្នុងប្រទេសកម្ពុជា បានយកមកប្រើប្រាស់សម្រាប់ទប់ទល់នឹងការកើនឡើងថ្លៃចំណីអាហារ គឺអាចផ្តល់នូវចំណុចអវិជ្ជមានមកវិញដូចជា : កង្វះជីវជាតិអា ជាតិដែក ស័ង្កសី អ៊ីយ៉ូដ ប្រូតេអ៊ីន និងថាមពល ។ល។ ភាពប្រឈមមុខនឹងអត្រាខ្ពស់នៃកង្វះអាហារូបត្ថម្ភ និងការកើនឡើងនូវប្រភេទជម្ងឺនានា ។ ហើយអ្វីដែលជាបន្ទុកធ្ងន់ធ្ងរដល់គ្រួសារ និងប្រទេសជាតិនោះ គឺការធ្លាក់ចុះនូវផលិតភាពផលិត និងការបាត់បង់យ៉ាងសំខាន់ផ្នែកសក្តានុពលកំណើនសេដ្ឋកិច្ច ។

សន្ទស្សន៍យុទ្ធសាស្ត្រឆ្លើយតបបន្ទាន់ គឺជាសូចនាករសុវត្ថិភាពស្បៀងគ្រួសារដែលងាយយល់ និងសាមញ្ញសម្រាប់វាស់វែងនូវសុវត្ថិភាពស្បៀង និងអាហារូបត្ថម្ភរបស់ស្ត្រី និងកុមារ អំឡុងពេលថ្លៃទំនិញអាហារកើនឡើងខ្ពស់ ។ តើសមាជិកគ្រួសារបានធ្វើអ្វីខ្លះ នៅពេលដែលកំពុងខ្វះខាតម្ហូបអាហារដោយសារថ្លៃខ្ពស់ និងគ្មានប្រាក់កាសគ្រប់គ្រាន់ដើម្បីទិញអាហារប្រចាំថ្ងៃ ?

អត្ថន័យសុវត្ថិភាពស្បៀង តាមសៀវភៅផែនទីសុវត្ថិភាពស្បៀងកម្ពុជា គឺជាលទ្ធភាពប្រើប្រាស់រូបវ័ន្តសេដ្ឋកិច្ច និងអេកូឡូស៊ីសម្រាប់ការមានអាហារគ្រប់គ្រាន់ អាហារដែលមានសុវត្ថិភាព និងអាហារដែលផ្ទុកទៅដោយសារជាតិអាហារូបត្ថម្ភ ក្នុងផ្នែកតម្រូវការបរិភោគប្រចាំថ្ងៃ និងផ្នែកអាហារដែលជាចំណង់ចំណូលចិត្តសម្រាប់ជីវិតប្រកបដោយភាពរស់រវើក សុខភាពល្អ និងផលិតភាព ។

ដូច្នេះដើម្បីឆ្លើយតបទៅនឹងការកើនឡើងខ្ពស់នៃថ្លៃអាហារ អង្កេតក្នុងបរិបថអាហារូបត្ថម្ភបង្ហាញឱ្យឃើញថា ទោះបីជាថ្លៃខ្ពស់នៃម្ហូបអាហារ និងទំនិញបានធ្លាក់ចុះក៏ពិតមែននាពេលថ្មីៗនេះក៏ប៉ុន្តែការធ្លាក់ចុះនេះ គឺមិនទាន់ដល់ចំនុចមុនពេលបានកើនឡើង ។ តាមការរកឃើញនៅត្រឹមខែវិច្ឆិកា ឆ្នាំ២០០៨ បង្ហាញថា ក្នុងចំណោមពីរភាគបីនៃគ្រួសារដែលត្រូវបានសម្ភាសន៍ បានពឹងផ្អែកលើម្ហូបអាហារណាដែលមានតម្លៃថោកជាងមុន ឬក៏អាហារដែលមិនមែនជាចំណង់ចំណូលចិត្តរបស់ខ្លួនយ៉ាងតិចណាស់ ក៏ម្តងដែរអំឡុងពេលមួយខែមុនអង្កេត ។ ម្ហូបអាហារទាំងអស់នោះ ជួនកាលមានជីវជាតិតិចជាងមុន ឬក៏មានកម្រិតមីក្រូសារជាតិមិនគ្រប់គ្រាន់ ។

បន្ទាប់មកប្រហែលជា ៦០ ភាគរយ នៃគ្រួសារទាំងនោះ បានបន្ថយនូវបរិមាណអាហារដែលគ្រួសារបានបរិភោគ ។ ក្នុងរយៈពេលមួយយូរ ការកាត់បន្ថយនូវបរិមាណអាហារនេះ ប្រហែលជានឹងផ្តល់ផលប៉ះពាល់ដល់សុខភាព និងកង្វះមីក្រូសារជាតិក្នុងកម្រិតមួយដែលទាមទារនូវការបកស្រាយបន្ថែម ។ យុទ្ធសាស្ត្រឆ្លើយតបផ្សេងទៀត សម្រាប់រយៈពេលខ្លីដែលគ្រួសារមួយចំនួននិយមប្រើយ៉ាងតិចណាស់ក៏ម្តងដែរ មានដូចជា : ស្ត្រីដែលជាមេគ្រួសារចាប់ផ្តើមបន្ថយបរិមាណនៃការហូបចុកមាន

ចំនួន ៤៤ ភាគរយ ។ ហើយដំណាលគ្នានោះ ការបន្ថយបរិមាណអាហារបរិភោគរបស់មនុស្សធំ ឥទុកសម្រាប់កុមារ មានចំនួន ៥៦ ភាគរយ ។ គ្រួសារចំនួន ៥២ ភាគរយ បានអនុវត្តន៍ជម្រើសបង្កើនរបបអាហារ តាមរយៈការខ្ចីម្ហូបអាហារពីសាច់ញាតិ និងអ្នកជិតខាង ។

រូបភាពលេខ ១៨ បកស្រាយពីយុទ្ធសាស្ត្រប្រើប្រាស់ទប់ទល់ជាមួយថ្លៃអាហាររបស់គ្រួសារ ដែលបានរកឃើញដោយ អ.ម.ក (អង្កេតចាប់ផ្តើមក្នុងខែវិច្ឆិកា) ឆ្នាំ២០០៨ ។ ស្ថានភាពសេដ្ឋកិច្ចរបស់គ្រួសារចាប់ផ្តើមលំបាក ហើយក្នុងពេលដំណាលគ្នានោះ កម្រិតភាគរយទាំងឡាយក្នុងពេលថ្លៃអាហារបានកើនឡើងខុសគ្នាទៅតាមប្រភេទនៃការប្រើប្រាស់យុទ្ធសាស្ត្រ ។ ក៏ប៉ុន្តែហេតុផលមួយផ្សេងទៀត ដែលជម្រុញឱ្យស្ថានភាពសេដ្ឋកិច្ច និងអាហារូបត្ថម្ភរបស់គ្រួសារខ្លះជួបប្រទះនឹងការលំបាកនោះ គឺទំនងជាចំពេលរដូវខ្វះខាត (មុនរដូវប្រមូលផល) ដោយសារទិន្នផលពីរដូវកាលមុនមិនគ្រប់គ្រាន់ក្នុងការដោះដូរសម្រាប់សម្រាល សេដ្ឋកិច្ចគ្រួសារនាពេលកន្លងមក ។ល។

**រូបភាពទី ១៨ : និន្នាការប្រែប្រួលក្នុងការប្រើប្រាស់យុទ្ធសាស្ត្រដោះស្រាយបញ្ហាបន្ទាន់ចំពោះមុខទាក់ទងនឹងអាហារ**



## ៣.២. ការបរិភោគម្ហូបអាហារ

គ្រួសារក្នុងប្រទេសកម្ពុជា ជាពិសេសគ្រួសារនៅតាមទីជនបទ បានចំណាយច្រើនទៅលើម្ហូបអាហារ ប្រហែលជា ៧០ ភាគរយ នៃកម្រៃចំណូលប្រចាំថ្ងៃ ។ អាហារប្រចាំថ្ងៃជាទូទៅ គឺបាយតែមួយមុខ មិនអាចធានាដល់ការមានជីវជាតិគ្រប់គ្រាន់បានទេ ។ កំឡុងពេលនៃវិបត្តិម្ហូបអាហារឡើងថ្លៃ គ្រួសារ មួយចំនួនបានកាត់បន្ថយផងដែរនូវពេលវេលានៃការបរិភោគអាហារដែលមានអត្រាប្រហែលជា ៦០ ភាគរយ ។

ការប្រើប្រាស់អាហារ គឺជាក្រុមអាហារដែលគ្រួសារបានទទួលទានយ៉ាងតិចបំផុតក្នុងកម្រិតគីឡូកាឡូរីមួយគ្រប់គ្រាន់ក្នុងមួយថ្ងៃ សម្រាប់ទ្រទ្រង់ដល់តម្រូវការរបស់រាងកាយ ។ ចំនួនសមាជិកគ្រួសារ បរិមាណអាហារ និងចំនួនពេលវេលានៃការហូបចុក មានទំនាក់ទំនងនឹងការប្រើប្រាស់អាហារ និងការទទួលបាននូវអាហារូបត្ថម្ភរបស់បុគ្គល និងក្រុមគ្រួសារទាំងមូលក្នុងពេលទំនិញឡើងថ្លៃ ។ យ៉ាងណាមិញ វិធីសាស្ត្រកំណត់ការប្រើប្រាស់អាហារនៅតែជាការងារពិបាកសម្រាប់វាស់វែង ដើម្បីឱ្យបាននូវលទ្ធផលត្រឹមត្រូវមួយ ពីព្រោះតែវិធីសាស្ត្រសម្រាប់អង្កេតតែងតែមិនមានភាពសុក្រឹតល្អ ។ ប៉ុន្តែការងារនេះ នៅតែសំខាន់សម្រាប់តាមដាននូវបម្រែបម្រួលក្នុងអំឡុងពេលហេតុការណ៍ណាមួយកើតឡើង ។

### *ការគណនាកម្រិតនៃការប្រើប្រាស់អាហាររបស់អង្កេតសេដ្ឋកិច្ច-សង្គមកិច្ច កម្ពុជា ២០០៤*

ជាទូទៅការចំណាយប្រាក់ ដើម្បីទទួលទានអាហារឱ្យបានគ្រប់គីឡូកាឡូរីក្នុងមួយថ្ងៃសម្រាប់មនុស្សម្នាក់ ត្រូវបានប្រើប្រាស់សម្រាប់វិភាគកម្រិតអាហាររបស់គ្រួសារទាំងមូល ។ គុណភាពម្ហូបអាហារគ្រប់គ្រាន់អាចដើរតួនាទីសំខាន់សម្រាប់បង្កើតថាមពលទ្រទ្រង់រាងកាយ ។ អង្កេតសង្គមកិច្ច-សេដ្ឋកិច្ចកម្ពុជា ឆ្នាំ២០០៤ បានបង្ហាញនូវសារៈសំខាន់ពីប្រភេទអាហារប្រើប្រាស់ និងវិធីសាស្ត្ររៀបចំទុកដាក់អាហារក្នុងពេលមានកង្វះខាតអាហារសម្រាប់បរិភោគ ។

ក្នុងចំណោមប្រជាជនកម្ពុជាទាំងមូល ជាមធ្យមមនុស្សម្នាក់ត្រូវការថាមពលពីអាហារ យ៉ាងហោចណាស់ក៏ប្រហែលជា ១៧១៥ គីឡូកាឡូរីក្នុងមួយថ្ងៃ ។ កម្រិតគីឡូកាឡូរីខ្វះ ឬក៏គ្រប់គ្រាន់អាស្រ័យលើទំហំនៃសមាជិកក្រុមគ្រួសារ ។ ជាក់ស្តែងអត្រាកង្វះខាតម្ហូបអាហារខ្ពស់នឹងថយចុះនៅពេលដែលសមាជិកគ្រួសារលើសពី ៦នាក់ ក្នុងកម្រិតប្រមាណ ៣៤ ភាគរយ មកនៅត្រឹម ៥ ភាគរយ នាឆ្នាំ២០០៤ ចំពោះគ្រួសារដែលមានសមាជិកមួយ ឬពីរនាក់ ។ កម្រិតនៃការប្រើប្រាស់ថាមពលអាហារនឹងកើនឡើងនៅពេលដែលចំណូលគ្រួសារប្រសើរជាងមុន ។ ជាក់ស្តែងចំណាយពិតលើម្ហូបអាហាររបស់គ្រួសារតាមទីជនបទមានកម្រិត ៧០ ភាគរយ នៃប្រាក់ចំណូល ។ ការចំណាយ

ទាំងអស់នេះ គឺដើម្បីឱ្យបានថាមពលជាមធ្យម ជាតិកាបូនអ៊ីដ្រាត មានកម្រិតខ្ពស់ក្នុងអត្រា ៧៥ ភាគរយ ដោយសារតែប្រជាជនកម្ពុជាបរិភោគបាយ និងមានតែ ១១ ភាគរយ ជាប្រូតេអ៊ីនបានមកពីសាច់ គ្រាប់ធញ្ញជាតិ និងផលិតផលផ្សេងៗ ។

***ការគណនាកម្រិតនៃការប្រើប្រាស់អាហាររបស់អង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ២០០០-២០០៥ និងអង្កេតមនុស្សមាត្រកម្ពុជា ២០០៨***

សំដៅលើការប្រើប្រាស់អាហារចម្រុះ ក៏ដូចជាប្រភេទអាហារដែលបានទទួលក្នុងរយៈពេល ២៤ម៉ោង គឺជាវិធីសាស្ត្រត្រឹមត្រូវ ទោះបីជាការគណនានេះ មិនទាន់មានភាពសុក្រឹតល្អសម្រាប់ការកំណត់នូវស្ថានភាពអាហារូបត្ថម្ភរបស់បុគ្គល (កុមារនិងស្ត្រី) ក៏ដោយ ។ ការប្រើប្រាស់ប្រភេទអាហារសម្រាប់កុមាររបស់អង្កេតមនុស្សមាត្រកម្ពុជា ឆ្នាំ២០០៨ គឺអាចប្រៀបធៀបបានជាមួយនឹងទិន្នន័យពីអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ២០០៥ ទោះបីជាមានបញ្ហាបច្ចេកទេសមួយចំនួន ។

អាហារចម្បងសម្រាប់បរិភោគរបស់កុមារ គឺបាយ ត្រី និងអាហារមានជាតិស្ករ ។ ការមានជាតិស្ករក្នុងខ្លួនខ្ពស់ពេក បណ្តាលឱ្យមានបញ្ហាដល់សុខភាព ។ អ្វីដែលជាការព្រួយបារម្ភនោះ គឺមីក្រូសារជាតិ ដូចជា : ប្រូតេអ៊ីន និងថាមពល ក្នុងអាហារប្រភេទបន្លែ (១០ ភាគរយ) អាហារជាតិប្រេង (២៣.១ ភាគរយ) ផលិតផលទឹកដោះគោ (១៣.៩ ភាគរយ) ត្រូវបានបរិភោគដោយ ក្រុមកុមារដែលមានអាយុក្រោម ៣៥ ខែ ក្នុងចំនួនមួយទាបបំផុត ដោយសារតែមានតម្លៃថ្លៃ និងរបៀបចិញ្ចឹមមិនបានសមស្រប ។ ចំនួនកុមារដែលទទួលទានបានច្រើន គឺស្ថិតនៅក្នុងក្រុមកុមារដែលមានអាយុ ២៤ ទៅ ៣៥ ខែ ដោយសារនៅក្នុងវ័យនេះ ជាទូទៅកុមារត្រូវការអាហារបន្ថែមសម្រាប់ការលូតលាស់ក៏ដូចជាបំពេញនូវកង្វះខាតអាហារូបត្ថម្ភ ។

ភាពមិនខ្វះមិនលើសគ្នានៃមធ្យមភាគ ក្រុមអាហារប្រើប្រាស់ដោយកុមាររវាងតំបន់ទីប្រជុំជន និងតំបន់ទីជនបទនៅតែបន្ត ក៏ប៉ុន្តែការជ្រើសរើសប្រភេទអាហារបរិភោគ មានភាពខុសគ្នាគួរឱ្យកត់សម្គាល់ ជាពិសេសផលិតផលទឹកដោះគោដែលមាននៅតាមតំបន់ទីប្រជុំជន (៣៥ ភាគរយ) ច្រើនជាងនៅតាមតំបន់ជនបទ (៩.៨ ភាគរយ) ប្រហែលបួនដង ។

ទំនាក់ទំនងអាហាររវាងម្តាយ និងកូនមិនជាខុសគ្នាទេក្នុងមធ្យមភាគនៃក្រុមអាហារ ។ ប៉ុន្តែអត្រាភាគរយរបស់មាតា គឺខ្ពស់ជាងកូន ចំពោះអាហារប្រភេទសាច់ និងអាហារប្រភេទមើម ដូចជាការ៉ុត ។ល។ យ៉ាងណាមិញ កម្រិតជាតិស្កររបស់មាតា គឺទាបជាងកូនក្នុងសមាមាត្រ ៣១.៤ ភាគរយ នឹង ៥៤.៩ ភាគរយ ។

ទិន្នន័យប្រៀបធៀបរវាង អ.ប្រ.ស.ក ២០០៥ និង អ.ម.ក ២០០៨ បង្ហាញនូវទំហំនៃការប្រែប្រួលអំពីការប្រើប្រាស់អាហារ ។ ការប្រែប្រួលខ្លាំងបំផុតនោះ គឺកុមារ ក៏ដូចជាមាតានៅតាមតំបន់ទីប្រជុំជន បានកាត់បន្ថយនូវបរិមាណអាហារដែលមានតម្លៃខ្ពស់ ដូចជាអត្រាភាគរយប្រភេទសាច់ និងត្រី បានធ្លាក់ចុះប្រមាណ ១៤ ។

រូបភាពលេខ ១៩ : និន្នាការប្រែប្រួលក្នុងការប្រើប្រាស់អាហាររបស់កុមារ




នៅក្នុងបរិបទប្រទេសកម្ពុជា ការធ្លាក់ចុះជាអវិជ្ជមានណាមួយនៃកម្រិតការប្រើប្រាស់អាហារចម្រុះ អាចជាមូលហេតុគួរឱ្យបារម្ភដ៏ចម្បងដែលត្រូវយកចិត្តទុកដាក់ ក៏ដូចជាការត្រៀមរកនូវវិធីដោះស្រាយសម្រាប់បញ្ចៀសនូវផលប៉ះពាល់ធ្ងន់ធ្ងរដល់ស្ថានភាពអាហារូបត្ថម្ភរបស់កុមារ ។ អត្រាប្រេវ៉ាឡង់ខ្ពស់ (៣៩.៥ ភាគរយ) នៃភាពក្រិនក្នុងចំណោមកុមារដែលមានអាយុក្រោម ៥ ឆ្នាំ បង្ហាញថាកម្រិតធ្លាក់ចុះជាអវិជ្ជមានរបស់អាហារគ្រប់មុខ ទំនងជាមូលហេតុមួយដែលបណ្តាលឱ្យភាពក្រិនកើនឡើងនៅក្នុងឆ្នាំ២០០៨ ជាពិសេសនៅតាមតំបន់ទីប្រជុំជន ដែលមធ្យមភាគនៃក្រុមអាហារបានកើនឡើងខ្ពស់ (៥.៤) ធៀបនឹងតំបន់ជនបទ (៤.៦) ក្នុងរូបភាពលេខ ២០ ។ ហើយគ្រួសារភាគច្រើនគឺជាអ្នកប្រើប្រាស់ទំនិញដុល មិនមែនជាអ្នកផលិតស្បៀង ក៏ដូចជាអ្នកដែលពឹងផ្អែកតែលើប្រាក់ឈ្នួលសម្រាប់ទំនិញ និងអាហារដែលមានតម្លៃខ្ពស់នេះដែរ ។

រូបភាពលេខ ២០ : និន្នាការប្រែប្រួលភ្លូខការប្រើប្រាស់អាហាររបស់កុមារ និងម្តាយ



## តារាងទី ១០ : ការប្រើប្រាស់អាហាររបស់កុមារដែលមានអាយុចាប់ពី ៦ ទៅ ៣៥ ខែ

**ភាគរយនៃកុមារដែលបានទទួលទានអាហារផ្សេងៗ ក្នុងអំឡុងពេល ២៤ ម៉ោង មុនអង្កេត និងចំនួនមធ្យមទៅតាមក្រុមម្ហូបផ្សេងៗ ដោយអង្កេតមនុស្សមាត្រកម្ពុជា ២០០៨**

| លក្ខណៈប្រវត្តិ | ប្រភេទសាច់គ្រឿងក្នុង | ផ្លែឈើសំបូរជីវជាតិអា | អាហារធញ្ញជាតិ | បន្លែសំបូរជីវជាតិអា | សាច់គោ ជ្រូក មាន់ ទា | ត្រី | បន្លែ | ផ្សេងៗ | ផលិតផលទឹកដោះគោ | អាហារមើម | ផ្លែឈើ បន្លែផ្សេងៗ | ស៊ុត | អាហារមានជាតិប្រេង | អាហារមានជាតិស្ករ | ចំនួនមធ្យមទៅតាមក្រុមម្ហូប | ចំនួនក្មេង |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| **អាយុជាខែ** | | | | | | | | | | | | | | | | |
| ៦-១១ | 3.6 | 5.7 | 88.2 | 25.4 | 21.7 | 38.3 | 3.6 | 23.5 | 12.6 | 8.6 | 13.7 | 14.5 | 10.9 | 30.2 | 3.0 | **1006** |
| ១២-២៣ | 6.3 | 11.5 | 97.6 | 51.1 | 40.8 | 73.2 | 10.1 | 40.0 | 15.4 | 15.0 | 31.8 | 25.7 | 24.4 | 60.0 | 5.0 | **4892** |
| ២៤-៣៥ | 6.9 | 14.7 | 97.9 | 62.0 | 41.8 | 81.3 | 14.8 | 46.7 | 12.6 | 19.2 | 38.3 | 24.8 | 30.7 | 66.7 | 5.6 | **1287** |
| **កន្លែងរស់នៅ** | | | | | | | | | | | | | | | | |
| ប្រជុំជន | 7.6 | 6.6 | 96.8 | 54.3 | 45.4 | 52.6 | 9.9 | 36.8 | 35.0 | 9.6 | 29.7 | 20.5 | 16.9 | 54.4 | 4.8 | **679** |
| ជនបទ | 5.5 | 12.0 | 95.2 | 47.1 | 34.8 | 70.2 | 10.0 | 38.4 | 9.8 | 15.7 | 29.4 | 23.1 | 24.3 | 55.0 | 4.7 | **3506** |
| **សរុប** | **5.8** | **11.1** | **95.4** | **48.2** | **36.5** | **67.3** | **10.0** | **38.1** | **13.9** | **14.7** | **29.5** | **22.7** | **23.1** | **54.9** | **4.7** | 4185 |

## តារាងទី ១១ : ការប្រើប្រាស់អាហាររបស់មាតាដែលមានអាយុចាប់ពី ១៥ ទៅ ៤៩ ឆ្នាំ

**ភាគរយនៃកុមារដែលបានទទួលទានអាហារផ្សេងៗ ក្នុងអំឡុងពេល ២៤ ម៉ោង មុនអង្កេត និងចំនួនមធ្យមនៅតាមក្រុមម្ហូបផ្សេងៗ ដោយអង្កេតមនុស្សមាត្រកម្ពុជា ២០០៨**

| លក្ខណៈប្រវត្តិ | ផលិតផលទឹកដោះគោ | ផ្សេងៗ | អាហារធញ្ញជាតិ | អាហារមើមពណ៌ស | ផ្លែឈើសំបូរវីតាមីនអា | សាច់គោ ជ្រូក មាន់ ទា | ប្រភេទសាច់គ្រឿងក្នុង | ត្រី | បន្លែ | អាហារមើម | ផ្លែឈើ បន្លែផ្សេងៗ | ស៊ុត | អាហារមានជាតិប្រេង | អាហារមានជាតិស្ករ | ចំនួនមធ្យមនៅតាមក្រុមម្ហូប | ចំនួនស្ត្រី |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| **អាយុជាឆ្នាំ** | | | | | | | | | | | | | | | | |
| ១៥-១៩ | 4.0 | 6.1 | 99.9 | 17.6 | 10.4 | 43.5 | 5.3 | 86.7 | 17.0 | 28.3 | 29.1 | 19.2 | 29.6 | 30.2 | 4.3 | **174** |
| ២០-២៩ | 6.6 | 6.2 | 98.2 | 20.0 | 13.5 | 47.5 | 8.2 | 83.3 | 17.9 | 30.2 | 47.2 | 25.1 | 33.0 | 32.3 | 4.7 | **2602** |
| ៣០-៣៩ | 7.8 | 6.5 | 98.3 | 22.1 | 12.4 | 44.4 | 6.3 | 85.9 | 14.5 | 29.8 | 44.5 | 19.4 | 32.7 | 31.3 | 4.6 | **1102** |
| ៤០-៤៩ | 3.7 | 7.0 | 98.8 | 21.9 | 12.4 | 41.2 | 5.0 | 80.4 | 15.7 | 36.2 | 48.4 | 20.6 | 31.4 | 25.4 | 4.5 | **311** |
| **កន្លែងរស់នៅ** | | | | | | | | | | | | | | | | |
| ប្រជុំជន | 9.8 | 2.9 | 99.1 | 20.4 | 14.2 | 65.6 | 9.9 | 76.7 | 17.6 | 42.7 | 53.0 | 25.4 | 37.0 | 41.1 | 5.2 | **665** |
| ជនបទ | 6.0 | 7.0 | 98.3 | 20.7 | 12.8 | 42.4 | 6.8 | 85.3 | 16.7 | 28.2 | 44.5 | 22.6 | 31.9 | 29.6 | 4.5 | **3525** |
| **សរុប** | **6.6** | **6.3** | **98.4** | **20.6** | **13.0** | **46.1** | **7.3** | **83.9** | **16.8** | **30.5** | **45.8** | **23.0** | **32.7** | **31.4** | **4.6** | **4190** |

### ៣.៣. យុទ្ធសាស្ត្រដោះស្រាយបន្ទាន់ផ្សេងៗ

ចាប់តាំងពីថ្លៃអាហារបានកើនឡើងយ៉ាងឆាប់រហ័សនាឆ្នាំ២០០៧ មក ប្រទេសកម្ពុជាបានចាប់អនុវត្តន៍នូវយុទ្ធសាស្ត្ររយៈពេលវែង មធ្យម និងខ្លីជាច្រើន ដើម្បីទប់ទល់នឹងវិបត្តិអាហារឡើងថ្លៃ ការធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធដោះស្រាយសន្តិសុខស្បៀងថ្នាក់ជាតិ បង្កើនស្បៀងដល់គ្រួសារដែលរងផលប៉ះពាល់ដោយសារវិបត្តិខ្វះស្បៀងនិងជម្រុញឱ្យប្រសើរឡើងនូវសុវត្ថិភាពស្បៀងអាហារគ្រួសារក្នុងស្ថានភាពអាហារូបត្ថម្ភគ្រប់គ្រាន់ ។ អង្គការក្រៅរដ្ឋាភិបាលនានា បានស្វះស្វែងរកវិធានការណ៍ជាច្រើនដើម្បីដោះស្រាយនូវបញ្ហានេះ ជាពិសេសកម្ចី និងជំនួយឥតសំណង ដែលទាក់ទងនឹងការងារសង្គ្រោះបន្ទាន់ក្នុងន័យជួយសម្រាលបន្ទុកប្រជាជនក្រីក្រកម្ពុជា ដែលប្រឈមមុខនឹងបញ្ហាសុវត្ថិភាពស្បៀង និងដើម្បីជៀសវាងនូវកង្វះមីក្រូសារជាតិសម្រាប់ក្រុមគ្រួសារ ជាពិសេសការបំផ្លាញនូវកោសិកាលូតលាស់របស់កុមារក្នុងរយៈពេលយូរ និងភាពងាយរងគ្រោះដោយជម្ងឺនានា ដែលបណ្តាលមកពីបញ្ហាកង្វះអាហារូបត្ថម្ភសម្រាប់រយៈពេលខ្លី ។

សកម្មភាពទិសដៅរយៈពេលខ្លីសំខាន់ៗរបស់រាជរដ្ឋាភិបាលក្នុងខែឧសភា ឆ្នាំ២០០៨ ដែលបង្ហាញដោយអង្គការសហប្រជាជាតិ មានដូចជា :

- ការអនុញ្ញាតឱ្យនាំចូលមកវិញនូវសត្វជ្រូកពីប្រទេសជិតខាង
- បម្រាមហាមនាំស្រូវចេញទៅក្រៅប្រទេស លើកលែងតែខេត្តចំនួន ៣ គឺខេត្តកណ្តាល ព្រៃវែង និងតាកែវ ដែលស្ថិតនៅក្បែរព្រំដែនវៀតណាម
- ការបង្កើនប្រាក់បន្ថែម ដែលមានចំនួនប្រហែលជា ៤០ពាន់លាន រៀលដល់មន្ត្រីរាជការ
- ការលក់អង្កររដ្ឋជូនប្រជាជនក្រីក្រ (ឧបត្ថម្ភធន) ក្នុងតំលៃថោកជាងទីផ្សារតាមរយៈកម្ចីពីធនាគារអភិវឌ្ឍន៍ជនបទ ចំនួន១០លាន ដុល្លារ ។
- ការកាត់បន្ថយពន្ធលើជីកសិកម្ម (ប្រភពជម្រុញឱ្យតម្លៃទិន្នផលកសិកម្មឡើងថ្លៃ) គឺជាយន្តការសំខាន់សម្រាប់កាត់បន្ថយនូវចំណាយរបស់គ្រួសារកសិករក្រីក្រ ។

វិធានការជោគជ័យក្នុងការឆ្លើយតបទៅនឹងការឡើងថ្លៃនៃម្ហូបអាហារនោះ គឺតាមរយៈគម្រោងសុវត្ថិភាពស្បៀងដែលជាជំនួយឥតសំណងរបស់សហគមន៍អឺរ៉ុប ។ រីឯកម្មវិធីចែកអង្ករជូនដល់គ្រួសារក្រីក្រ និងងាយរងគ្រោះ គឺសកម្មភាពទី១ដែលមានថវិការបដិភាគរវាងរដ្ឋាភិបាលកម្ពុជា និង ធនាគារអភិវឌ្ឍន៍អាស៊ី ។

រូបភាពលេខ ២១ ៖ យុទ្ធសាស្ត្រនានាដែលមិនទាក់ទងជាមួយនឹងអាហារ




ការមិនឱ្យកូនទៅរៀន និងការបង្កើនចំនួនបំលាស់ទីលំនៅរបស់សមាជិកគ្រួសារ ដើម្បីរកអាហារ និងការស្វែងរកការងារធ្វើបន្ថែម យ៉ាងហោចណាស់ម្តងក្នុងរយៈពេល ៣០ ថ្ងៃ មុនអង្កេត គឺជាផ្នែកមួយនៃយុទ្ធសាស្ត្រដែលគ្រួសារបានអនុវត្តន៍ក្នុងពេលអាហារឡើងថ្លៃ ។ ម្យ៉ាងវិញទៀត ការជ្រើសរើសការងារថ្មី ឬស្វែងរកការងារបន្ថែមដើម្បីបង្គ្រប់លើការចំណាយប្រចាំថ្ងៃក្នុងគ្រួសារ ។ អាចមានន័យថា សមាជិកក្នុងគ្រួសារ ជាពិសេសម្តាយមានពេលវេលាតិចជាងមុនសម្រាប់ថែទាំកូន ដូចជាការបង្ការពីជម្ងឺឆ្លង និងកង្វះអនាម័យ និងរបៀបចិញ្ចឹមកូនប្រកបដោយអាហារូបត្ថម្ភគ្រប់គ្រាន់ (ទារក ឬក្មេងដែលត្រូវការចិញ្ចឹមដោយទឹកដោះម្តាយ និងការបរិភោគឱ្យបានត្រឹមត្រូវ ក៏ដូចជាអាហារបន្ថែម) ។

ផ្ទុយទៅវិញចំណាយលើវិស័យថែទាំសុខភាព ដើម្បីបង្ការជម្ងឺឆ្លងនានារបស់គ្រួសារ ជាពិសេសជម្ងឺកុមារដែលមានអាយុក្រោម ៥ ឆ្នាំ ត្រូវបានកាត់បន្ថយដោយមានគ្រួសារចំនួនប្រហែលជា ៤១.១ ភាគរយ ។ ចំណាត់ការនេះ អាចផ្តល់នូវគុណវិបត្តិដល់ផ្នែកសុខភាពកុមារ ដែលជាទូទៅកុមារច្រើនតែជាជនងាយរងគ្រោះដោយសារជម្ងឺផ្សេងៗ ។

| តារាងលេខ ១២ : ភាគរយគ្រួសារប្រើប្រាស់យុទ្ធសាស្ត្រដោះស្រាយបញ្ហាបន្ទាន់ចំពោះមុខ អំឡុងពេល ៣០ ថ្ងៃមុនអង្កេត ដោយអង្កេតមនុស្សមាត្រកម្ពុជា ២០០៨ | | | | | |
|---|---|---|---|---|---|
| **យុទ្ធសាស្ត្រដោះស្រាយបន្ទាន់** | **យ៉ាងតិចម្តង** | **យ៉ាងតិចម្តង** | | **រាល់ថ្ងៃ** | **ចំនួនគ្រួសារ** |
| | | **ប្រជុំជន** | **ជនបទ** | | |
| ពឹងផ្អែកលើអាហារដែលមានតម្លៃថោកជាងមុន និងចំណង់ចំណូលចិត្តតិចជាងមុន | 71.5 | 68.7 | 72.0 | 6.5 | 7489 |
| ខ្ចីអាហារ ឬក៏ពឹងផ្អែកលើមិត្តភ័ក្ត្រ ឬសាច់ញាតិ | 51.8 | 39.1 | 54.3 | 0.2 | 7489 |
| ទិញអាហារដោយសាច់ប្រាក់សុទ្ធ ឬជំពាក់បំណុលគេ | 70.3 | 59.5 | 72.4 | 1.4 | 7489 |
| កាត់បន្ថយអាហារហូបប្រចាំថ្ងៃ | 59.5 | 63.3 | 58.8 | 1.5 | 7489 |
| បន្ថយការហូបចុករបស់មនុស្សធំ សម្រាប់ក្មេង | 56.3 | 52.9 | 99.6 | 2.6 | 7489 |
| ម្តាយ ឬក៏បងស្រីធំ បរិភោគតិចជាងសមាជិកគ្រួសារ | 43.7 | 33.0 | 45.8 | 1.3 | 7489 |
| បរិភោគគ្រាប់ពូជដែលទុកសម្រាប់រដូវក្រោយ | 13.0 | 2.2 | 15.1 | 0.3 | 7489 |
| កាត់បន្ថយចំណាយប្រើប្រាស់ជីគីមី ថ្នាំសម្លាប់សត្វល្អិត ការចិញ្ចឹមសត្វ ។ល។ | 16.0 | 2.4 | 18.7 | 0.0 | 7489 |
| លក់ទ្រព្យសម្បត្តិគ្រួសារ (វិទ្យុ គ្រឿងសង្ហារឹម) | 4.3 | 2.4 | 4.6 | 0.0 | 7489 |
| លក់ទ្រព្យសម្បត្តិរកស៊ី (ប្រដាប់ប្រដាកសិកម្ម គ្រឿងម៉ាស៊ីន ម៉ូតូ) | 3.4 | 2.0 | 3.6 | 0.1 | 7489 |
| លក់ដីធ្លី | 3.5 | 1.4 | 4.0 | 0.1 | 7489 |
| លក់គ្រឿងអលង្ការ | 10.3 | 11.1 | 10.2 | 0.4 | 7489 |
| លក់សត្វពាហនៈច្រើនជាងធម្មតា | 17.5 | 3.5 | 20.2 | 0.0 | 7489 |
| កាត់បន្ថយចំណាយសេវាថែទាំសុខភាព | 41.1 | 32.1 | 42.9 | 0.1 | 7489 |
| មិនឱ្យកូនទៅរៀន | 9.0 | 8.9 | 9.0 | 1.9 | 7489 |
| ជ្រើសរើសការងារថ្មី ឬស្វែងរកការងារបន្ថែម | 30.1 | 42.3 | 31.2 | 7.6 | 7489 |
| បង្កើនចំនួនសមាជិកគ្រួសារចំណាកស្រុក ដើម្បីរកម្ហូប និងរកការងារធ្វើបន្ថែម | 17.0 | 10.5 | 18.3 | 4.1 | 7489 |
| បង្កើននូវការទាញយកផលពីធនធានធម្មជាតិ (នេសាទ រុករានព្រៃ...) | 33.1 | 8.2 | 37.9 | 9.1 | 7489 |
| បង្កើនការដាំដំណាំ និងដាំដំណាំថ្មីៗបន្ថែមដើម្បីដោះស្រាយជាមួយតម្លៃម្ហូបអាហារ | 25.3 | 6.6 | 29.0 | 3.0 | 7489 |

# ជំពូកទី២

# ការជ្រើសរើសសូចនាករថ្នាក់ក្រោមជាតិ និង ការវិភាគបន្ថែមនៃការជ្រើសរើសសូចនាករ សម្រាប់ចាត់ថ្នាក់បន្ទាន់

## ១. មនុស្សមាត្រកុមារ

ក្រៅពីកត្តាសេដ្ឋកិច្ច-សង្គមកិច្ចដូចជា : កម្រិតអប់រំរបស់ឪពុកម្ដាយ ធនធានគ្រួសារ សេវាសុខភាពសាធារណៈ និងវិធីសាស្ត្រចិញ្ចឹមបីបាច់ថែរក្សាកូន នោះកត្តាភូមិសាស្ត្រ (ទីកន្លែងរស់នៅ) ក៏ជាសូចនាករសំខាន់ សម្រាប់បង្ហាញនូវវឌ្ឍនភាព ឬក៏ការថយចុះនៃស្ថានភាពអាហារូបត្ថម្ភកុមារ ។ ជាក់ស្ដែង នៅតាមតំបន់ដែលមានសុវត្ថិភាពស្បៀងគ្រប់គ្រាន់ដូចជាទីក្រុងភ្នំពេញ កម្រិតស្ថានភាពអាហារូបត្ថម្ភរបស់កុមារដែលមានអាយុក្រោម ៥ ឆ្នាំ (ក្រិន ស្គម និងកង្វះទម្ងន់) មានលក្ខណៈប្រសើរជាងនៅតាមបណ្ដាខេត្តផ្សេងៗ ។ ទោះបីជាមានសុទិដ្ឋិនិយមផ្នែកកង្វះអាហារូបត្ថម្ភនៅទីក្រុងភ្នំពេញក៏ពិតមែន មូលហេតុដោយសារតែមានកំណើន និងការអភិវឌ្ឍខ្ពស់គ្រប់ផ្នែកជាងខេត្តដ៏ទៃ ក៏មិនមានន័យថា កុមារនៅទីក្រុងភ្នំពេញស្ថិតនៅក្នុងចំនុចប្រៀបឡង់មួយល្អនោះទេ ពីព្រោះតែអង្កេតឆ្នាំ២០០៨ បានបង្ហាញថា សូចនាករភាពក្រិន និងកង្វះទម្ងន់របស់កុមារបានកើនឡើងគួរសមក្រោយឆ្នាំ២០០៥ មក (ឧបសម្ព័ន្ធទី២ ផ្នែកមនុស្សមាត្រកុមារឆ្នាំ២០០៥) បន្ទាប់ពីមានការកាត់បន្ថយខ្លាំងរវាងពីឆ្នាំ ២០០០ មកឆ្នាំ២០០៥ ។ ហេតុដូចនេះ ការងារជាច្រើនក្រៅពីសេវាសុខភាពសាធារណៈចាំបាច់ទាមទារនូវការឆ្លើយតប និងកិច្ចអន្តរាគមន៍បន្ថែម ។

### ១.១. ថ្នាក់ខេត្ត

កម្រិតខ្ពស់នៃភាពខ្សត់ខ្សោយអាហារូបត្ថម្ភរបស់កុមារ នៅតាមបណ្ដាខេត្តនានាជាពិសេសខេត្តនៅជុំវិញតំបន់បឹងទន្លេសាប បញ្ជាក់នូវការប្រឈមមុខខ្លាំងផ្នែកជម្ងឺកុមារ ក៏ដូចជាផលប៉ះពាល់ដល់ការលូតលាស់នៃសារពាង្គកាយរបស់កុមារដែរ ។ ផ្ទុយទៅវិញ នៅពេលដែលទិន្នន័យនៅតាមខេត្តមួយត្រូវបានបំបែក នោះភាពខុសគ្នា (ភាគរយ) នៃកង្វះអាហារូបត្ថម្ភរបស់ខេត្តនោះ ពុំមែនជាន័យសំខាន់ក្នុងន័យស្ថិតិនោះទេ ។ កង្វះអាហារូបត្ថម្ភបែរជាបង្ហាញនូវភាគរយខុសគ្នាច្រើន នៅពេលដែលទិន្នន័យត្រូវបានបំបែកទៅតាមតំបន់របស់ខេត្តផ្សេងៗ មានដូចជា : តំបន់ជុំវិញបឹងទន្លេសាប តំបន់ឆ្នេរសមុទ្រ តំបន់ខ្ពង់រាប និងទំនាប ។ ១ភាគ៣ នៃកុមារក្រិន ឬច្រើនជាង ៣០ ភាគរយ និងច្រើនជាង ២០ ភាគរយ ក្នុងចំណោមកុមារខ្វះទម្ងន់កំពុងរស់នៅក្នុងតំបន់ទាំងអស់នេះ លើកលែងតែទីក្រុងភ្នំពេញចេញប៉ុណ្ណោះ ។ ក្រៅពីនេះ មានខេត្តចំនួន ១៥ ក្នុងចំណោម ១៩ ខេត្ត ដែលមានខេត្តខ្លះត្រូវបានបញ្ចូលគ្នា បង្ហាញនូវភាពស្គមស្គាំងរបស់កុមារដែលមានអាយុក្រោម ៥ ឆ្នាំ ក្នុងអត្រា ១០ ភាគរយ ។

ដូចដែលបានបង្ហាញពីខាងលើ តំបន់កម្រិតទាបជាងគេនៃកង្វះអាហារូបត្ថម្ភ គឺទីក្រុងភ្នំពេញធៀបនឹងបណ្ដាខេត្តផ្សេងៗ ។ ប៉ុន្តែធៀបនឹងក្រុមកុមារដែលមានសុខភាពអាហារូបត្ថម្ភគ្រប់គ្រាន់ នោះ

អត្រាភាពក្រិននៅទីក្រុងភ្នំពេញច្រើនជាង ១៥ ដង កង្វះទម្ងន់ច្រើនជាង ៨ ដង និងអត្រាស្គមខ្ពស់ជាង ២ ដង ។

**តារាងលេខ ១៣ : មនុស្សមាត្រកុមារតាមខេត្ត-ក្រុង**

ភាគរយកុមារដែលមានអាយុក្រោម ៥ ឆ្នាំ មានបញ្ហាជាមួយកង្វះអាហារូបត្ថម្ភ តាមរយៈសន្ទស្សន៍សូចនាករទាំង៣នៃស្ថានភាពអាហារូបត្ថម្ភ : កម្ពស់ធៀបនឹងអាយុ ទម្ងន់ធៀបនឹងកម្ពស់ និងទម្ងន់ធៀបនឹងអាយុ នៅតាមខេត្ត ដោយអង្កេតមនុស្សមាត្រកម្ពុជា ឆ្នាំ២០០៨

| ឈ្មោះខេត្ត | កម្ពស់ធៀបនឹងអាយុ | | ទម្ងន់ធៀបនឹងកម្ពស់ | | ទម្ងន់ធៀបនឹងអាយុ | | ចំនួនកុមារ |
|---|---|---|---|---|---|---|---|
| | < -2 SD | < -3 SD | < -2 SD | < -3 SD | < -2 SD | < -3 SD | |
| បន្ទាយមានជ័យ | 38.4 | 18.0 | 11.7 | 2.8 | 29.7 | 10.4 | 317 |
| កំពង់ចាម | 38 | 15.5 | 10 | 2.9 | 30.1 | 9.6 | 888 |
| កំពង់ឆ្នាំង | 45.4 | 19.6 | 11.1 | 3.3 | 37.4 | 12.1 | 306 |
| កំពង់ស្ពឺ | 37.6 | 15.1 | 10.9 | 1.3 | 27.8 | 5.9 | 471 |
| កំពង់ធំ | 47.1 | 23.0 | 9.6 | 2.1 | 33.5 | 12.8 | 187 |
| កណ្ដាល | 35.8 | 15.8 | 10.8 | 1.9 | 29.6 | 9.9 | 627 |
| ក្រចេះ | 46.3 | 22.6 | 9.1 | 2.4 | 29.3 | 9.8 | 164 |
| ភ្នំពេញ | 33.6 | 16.7 | 5.6 | 1.4 | 18.7 | 6.8 | 658 |
| ព្រៃវែង | 42.2 | 16.1 | 5.5 | 0.8 | 29.7 | 8.3 | 528 |
| ពោធិសាត់ | 36.4 | 16.1 | 11.2 | 2.2 | 33.3 | 9.1 | 187 |
| សៀមរាប | 46 | 23.1 | 8.6 | 1.8 | 34.7 | 11.9 | 628 |
| ស្វាយរៀង | 36 | 13.6 | 11 | 1.1 | 30.9 | 9.2 | 272 |
| តាកែវ | 43.4 | 16.7 | 7.1 | 1.9 | 28.9 | 7.9 | 479 |
| ឧត្ដរមានជ័យ | 41 | 16.7 | 10.1 | 3.8 | 26.6 | 7.6 | 78 |
| បាត់ដំបង/ប៉ៃលិន | 37.3 | 15.3 | 9.3 | 1.3 | 25 | 8.3 | 557 |
| កំពត/កែប | 34.5 | 13.8 | 8.1 | 1.1 | 27.2 | 7.7 | 261 |
| ព្រះសីហនុ/កោះកុង | 40.1 | 19.9 | 7.1 | 0.5 | 26.4 | 10.5 | 182 |
| ព្រះវិហារ/ស្ទឹងត្រែង | 46.6 | 23.3 | 6.7 | 1.5 | 24.1 | 6.0 | 133 |
| មណ្ឌលគិរី/រតនគិរី | 41.7 | 22.9 | 6.3 | 2.1 | 27.1 | 9.4 | 96 |
| **សរុប** | 39.5 | 17.3 | 8.9 | 1.8 | 28.8 | 9.1 | 7019 |

អត្រាកុមារក្រិនខ្ពស់បំផុត គឺស្ថិតនៅក្នុងខេត្តកំពង់ធំ ក្នុងចំនួន ៤៧.១ ភាគរយ ។ រីឯកង្វះទម្ងន់ ឃើញមានអត្រាខ្ពស់ផងដែរ នៅក្នុងខេត្តសៀមរាប (៣៤.៧ ភាគរយ) ។ ក៏ប៉ុន្តែ អត្រាទាំងអស់នេះ មិនមានភាពខុសគ្នាច្រើនទេធៀបនឹងខេត្តដ៏ទៃផ្សេងទៀត ។ កង្វះអាហារូបត្ថម្ភរបស់កុមារដែលមានអត្រាប្រេវ៉ាឡង់ស្រដៀងគ្នានៅតាមបណ្តាខេត្តនានា មិនទំនងជាសំខាន់នោះទេ (ភាគរយដូចគ្នា ប៉ុន្តែចំនួនកុមារខុសគ្នា) ។ មានន័យថា ក្រុមគោលដៅដែលគួរឱ្យចាប់អារម្មណ៍នោះ គួរតែមើលនៅលើចំនួនពិតរបស់កុមារកំពុងខ្វះអាហារូបត្ថម្ភដែលរស់នៅតាមបណ្តាខេត្តទាំងអស់នោះ ជាជាងការមើលតែនៅលើអត្រាប្រេវ៉ាឡង់ ។

រូបភាពខាងក្រោមនេះ បង្ហាញនូវការប៉ាន់ស្មានអំពីចំនួនកុមារជួបប្រទះនូវកង្វះអាហារូបត្ថម្ភតាមរយៈសូចនាករទាំង៣ ទៅតាមខេត្តនិមួយៗ និងទីក្រុងភ្នំពេញ ។ តាមការប៉ាន់ស្មានរបស់អង្កេតមនុស្សមាត្រកម្ពុជា ដោយផ្តើមចេញពីការគណនារកចំនួនប្រជាជន ដែលបានធ្វើឡើងដោយជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជានាឆ្នាំ២០០៨ (ជ.ទ.ប្រ.ក) បង្ហាញថាខេត្តកំពង់ចាមសំបូរទៅដោយកុមារដែលមានបញ្ហាកង្វះអាហារូបត្ថម្ភច្រើនជាងគេបង្អស់ ។ ដោយក្នុងនោះ មានចំនួនប្រហែល ៥៤,០០០ នាក់ ជាកុមារកង្វះទម្ងន់ ភាពស្គមមានប្រហែលជា ១៨,០០០ នាក់ និងកុមារក្រិន គឺច្រើនជាង ៦៨,០០០ នាក់ ។ យើងឃើញថា កង្វះអាហារូបត្ថម្ភខ្ពស់ ភាគច្រើនកើតមាននៅក្នុងខេត្តណាដែលមានចំនួនប្រជាជនច្រើនជាងគេ ។

រូបភាពលេខ ២២ : ចំនួនកុមារកង្វះទម្ងន់ដែលមានអាយុក្រោម ៥ ឆ្នាំ តាមខេត្ត-ក្រុង



ការប៉ាន់ស្មានចំនួនកុមារ តាមរយៈការបញ្ចូលប្រេវ៉ាឡង់របស់មនុស្សមាត្រទៅក្នុងជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជា ឆ្នាំ២០០៨

### រូបភាពលេខ ២៣ : ចំនួនកុមារស្គមដែលមានអាយុក្រោម ៥ ឆ្នាំ តាមខេត្ត-ក្រុង




### រូបភាពលេខ ២៤ : ចំនួនកុមារក្រិនដែលមានអាយុក្រោម ៥ ឆ្នាំ តាមខេត្ត-ក្រុង



រូបភាពខាងក្រោមនេះ បង្ហាញនូវនិន្នាការប្រែប្រួលប្រេវ៉ាឡង់កុមារស្គម តាមខេត្ត និងតំបន់ ។ តំបន់និមួយៗ ផ្តល់នូវទិន្នន័យខុសគ្នា ក៏ដូចជាការបកស្រាយ ដោយសារតែភាគរយមានការខុសគ្នាច្រើនក្នុងន័យស្ថិតិ ។ ពីឆ្នាំ២០០០ មកឆ្នាំ២០០៥ អត្រាស្គមរបស់កុមារបានផ្តល់នូវសញ្ញាវិជ្ជមានគួរឱ្យកត់សម្គាល់សម្រាប់គ្រប់តំបន់ទាំងអស់ ។ ប៉ុន្តែវឌ្ឍនភាពនេះ បានឈប់នៅត្រឹមនាឆ្នាំ២០០៨ លើកលែង តែខេត្តព្រៃភ្នំដាច់ស្រយាលដូចជា : មណ្ឌលគីរី រតនគីរី ស្ទឹងត្រែង និងព្រះវិហារ ប៉ុណ្ណោះ ដែលមាន អត្រាប្រេវ៉ាឡង់បន្តថយចុះស្ទើរតែពាក់កណ្តាលបន្តរហូតចាប់តាំងពីឆ្នាំ២០០០មក ។

តំបន់ដែលផ្តល់នូវសញ្ញាអវិជ្ជមាននៃអត្រាកង្វះអាហារូបត្ថម្ភខ្ពស់នោះ គឺតំបន់បឹងទន្លេសាប ក្នុងនោះ ខេត្តបន្ទាយមានជ័យបានកើនឡើង ៧ អត្រាភាគរយ (ក្បែរ ៥០ ភាគរយ) ពី ៥ ភាគរយ ឆ្នាំ ២០០៥ ទៅ ១២ ភាគរយ នាឆ្នាំ២០០៨ ។ ជាងនេះទៅទៀតនោះ មានខេត្តចំនួន ៦ ក្នុងចំណោមខេត្តទាំង ៧ ក្នុងតំបន់ជុំវិញបឹងទន្លេសាប មានការកើនឡើងនូវអត្រាស្គមចាប់ពីឆ្នាំ២០០៥ មក ។ អត្ថន័យនេះ រំលេចនូវរឿងខ្លះគួរឱ្យភ្ញាក់ផ្អើលដែលថាតំបន់ដែលសំបូរទៅដោយផលិតផលកសិកម្ម តែផ្ទុយទៅវិញ អត្រាភាពស្គមរបស់កុមារបែរជាកើនឡើងលើសបណ្តាតំបន់ដ៏ទៃវិញ ។ ឬក៏តំបន់សំបូរទៅដោយអង្ករសម្រាប់បរិភោគក៏ពិតមែន ប៉ុន្តែសម្រាប់បរិបទសន្តិសុខស្បៀង ក្រុមគ្រួសារដែលរស់នៅតំបន់នេះ ទំនងជាមិនមានបរិមាណអាហារគ្រប់គ្រាន់ ឬក៏ជួបបញ្ហាអសន្តិសុខស្បៀងសម្រាប់សមាជិកគ្រួសារ ដូចដែលរដ្ឋាភិបាល និង ADB បានសហការណ៍គ្នាធ្វើអន្តរាគមន៍កន្លងមក ។

**រូបភាពលេខ ២៥ : និន្នាការប្រែប្រួលមនុស្សមាត្រកុមារតាមខេត្តរបស់តំបន់ឆ្នេរ និងបឹងទន្លេសាប**






## ១.២. លក្ខណៈប្រវត្តិបន្ថែមផ្សេងៗ

ប្រភេទការងាររបស់ឪពុកម្តាយ ក៏បានចូលរួមចំណែកយ៉ាងសំខាន់ ក្នុងការជួយជ្រោមជ្រែងនូវស្ថានភាពអាហារូបត្ថម្ភរបស់កុមារដែរ ដោយសារតែពេលវេលាត្រូវបានចែកក្រោយពីការងារសម្រាប់ការថែរក្សាកុមារតូច ប្រកបដោយសុខភាពខ្ពស់ និងការរីកលូតលាស់ល្អប្រសើរ ។ ជាទូទៅនៅក្នុងប្រទេសកម្ពុជា ប្រជាជនច្រើនជាង ៧០ ភាគរយ ប្រកបអាជីពជាកសិករ (ការងារទុនផ្ទាល់ខ្លួន និងការងារយកប្រាក់កំរៃ) ហើយមានកសិករខ្លះក្នុងចំណោមកសិករទាំងអស់នេះ មានជំនាញបន្ទាប់បន្សំក្រៅពីការងារកសិកម្ម ។ ក្នុងចំណោមការងារទាំងពីរក្នុងផ្នែកកសិកម្ម ប្រេវ៉ាឡង់កុមារក្រិន និងកង្វះទម្ងន់ មានខ្ពស់ជាងគេ បើសិនជាឪពុកម្តាយប្រកបការងារយកប្រាក់កំរៃ ធៀបនឹងប្រភេទការងារផ្សេងៗ លើកលែងតែប្រេវ៉ាឡង់កុមារស្គមប៉ុណ្ណោះ ដែលមិនមានភាពខុសគ្នាខ្លាំងក្នុងន័យស្ថិតិ ។ ជាទូទៅភាគរយអត្រាកង្វះអាហារូបត្ថម្ភរបស់កុមារ មានការខុសគ្នាបន្តិចបន្តួចទៅតាមលក្ខណៈប្រវត្តិ ។

បើប្រៀបជាមួយនឹងកុមារដែលមានសុខភាព និងស្ថានភាពអាហារូបត្ថម្ភល្អ ហើយមានឪពុកម្តាយប្រកបការងារយកប្រាក់កំរៃ នោះជាមធ្យមប្រេវ៉ាឡង់កុមារក្រិនមាន ២៦ ដង កុមារកង្វះទម្ងន់ជិតដល់ ២០ ដង និងកុមារស្គមក្នុងចំនួនក្បែរ ៥ ដង ។

## តារាងលេខ ១៤ ៖ មនុស្សមាត្រកុមារតាមប្រភេទការងាររបស់ឪពុក

| ភាគរយកុមារកង្វះអាហារូបត្ថម្ភដែលមានអាយុក្រោម ៥ ឆ្នាំ តាមរយៈសន្ទស្សន៍សូចនាករមនុស្សមាត្រទាំង ៣ នៃស្ថានភាពអាហារូបត្ថម្ភតាមមុខរបររបស់ឪពុក ដោយអង្កេតមនុស្សមាត្រកម្ពុជា ឆ្នាំ២០០៨ | | | | |
|---|---|---|---|---|
| **មុខរបរឪពុក** | **គម្លាតស្តង់ដារអវិជ្ជមានក្រោម ២** | | | **ចំនួនកុមារ** |
| | កម្ពស់ធៀបនឹងអាយុ | ទម្ងន់ធៀបនឹងអាយុ | ទម្ងន់ធៀបនឹងកម្ពស់ | |
| កម្លាំងប្រដាប់អាវុធ | 31.5 | 28.3 | 6.6 | 92 |
| ការងារជំនាញ | 28.2 | 19.9 | 6.2 | 337 |
| ស្មៀន | 13.4 | 10.3 | 7.1 | 126 |
| លក់ដូរ | 27.4 | 16.1 | 8.4 | 273 |
| ការងារកសិកម្មដោយទុនផ្ទាល់ខ្លួន | 41.6 | 30.9 | 9.2 | 3672 |
| ការងារកសិកម្មដោយយកកម្រៃ | 53.5 | 39.1 | 9.8 | 256 |
| ការងារពលកម្មមានជំនាញ | 36.9 | 25.8 | 9.8 | 1267 |
| ការងារពលកម្មគ្មានជំនាញ | 38.9 | 30.3 | 10.4 | 442 |
| **សរុប** | **39.0** | **28.6** | **9.1** | **6465** |

## តារាងលេខ ១៥ ៖ មនុស្សមាត្រកុមារតាមប្រភេទការងាររបស់ម្តាយ

| ភាគរយកុមារកង្វះអាហារូបត្ថម្ភដែលមានអាយុក្រោម ៥ ឆ្នាំ តាមរយៈសន្ទស្សន៍សូចនាករមនុស្សមាត្រទាំង ៣ នៃស្ថានភាពអាហារូបត្ថម្ភតាមមុខរបររបស់ម្តាយ ដោយអង្កេតមនុស្សមាត្រកម្ពុជា ឆ្នាំ២០០៨ | | | | |
|---|---|---|---|---|
| **មុខរបរម្តាយ** | **គម្លាតស្តង់ដារអវិជ្ជមានក្រោម ២** | | | **ចំនួនកុមារ** |
| | កម្ពស់ធៀបនឹងអាយុ | ទម្ងន់ធៀបនឹងអាយុ | ទម្ងន់ធៀបនឹងកម្ពស់ | |
| ការងារជំនាញ | 32.1 | 16.7 | 7.5 | 54 |
| លក់ដូរ | 34.5 | 27.4 | 9.1 | 591 |
| ការងារកសិកម្មដោយទុនផ្ទាល់ខ្លួន | 42.2 | 31.7 | 9.3 | 1490 |
| ការងារកសិកម្មដោយយកកម្រៃ | 55 | 41.6 | 7.9 | 190 |
| ការងារពលកម្មមានជំនាញ | 43.2 | 30.7 | 10.6 | 407 |
| ការងារពលកម្មគ្មានជំនាញ | 38.9 | 35.7 | 12 | 283 |
| **សរុប** | **41.2** | **31.4** | **9.6** | **3015** |

តារាងខាងក្រោមនេះ បង្ហាញនូវកង្វះអាហារូបត្ថម្ភរបស់កុមារទាក់ទងជាមួយនឹងប្រភេទកម្មសិទ្ធិកាន់កាប់ដីស្រែរបស់គ្រួសារដែលបានសម្ភាសន៍ ។ ម្តងទៀតប្រជាជនភាគច្រើនប្រកបរបរកសិកម្ម ប៉ុន្តែអត្រាកង្វះអាហារូបត្ថម្ភរបស់កុមារ មិនជាខុសគ្នាប៉ុន្មានទេទៅតាមប្រភេទដីកាន់កាប់ ។ តាមរយៈ

ប្រភេទកម្មសិទ្ធិដីស្រែរបស់ឪពុកម្តាយ អត្រាភាពក្រិននៅតែជាបញ្ហាប្រឈមរបស់កុមារក្នុងចំនួនសរុបទាំងអស់ក្នុងអត្រា ៤១.៨ ភាគរយ ។ អត្រាខ្ពស់ទំនងជាបណ្តាលមកពីគុណភាពដី (ជីជាតិ) ជាជាងទំហំដីកាន់កាប់។

តារាងលេខ ១៦ : មនុស្សមាត្រកុមារតាមប្រភេទកម្មសិទ្ធិកាន់កាប់ដីស្រែចម្ការ

ភាគរយកុមារកង្វះអាហារូបត្ថម្ភដែលមានអាយុក្រោម ៥ ឆ្នាំ តាមរយៈសន្ទស្សន៍សូចនាករមនុស្សមាត្រទាំង ៣ នៃស្ថានភាពអាហារូបត្ថម្ភតាមប្រភេទកម្មសិទ្ធិកាន់កាប់ដីស្រែចម្ការ ដោយអង្កេតមនុស្សមាត្រកម្ពុជា ឆ្នាំ២០០៨

| **ប្រភេទដីកាន់កាប់** | **គម្លាតស្តង់ដារអវិជ្ជមានក្រោម ២** | | | **ចំនួនកុមារ** |
|---|---|---|---|---|
| | កម្ពស់ធៀបនឹងអាយុ | ទម្ងន់ធៀបនឹងអាយុ | ទម្ងន់ធៀបនឹងកម្ពស់ | |
| ដីផ្ទាល់ខ្លួន | 41.8 | 31.2 | 9.0 | 3498 |
| ដីគ្រួសារ | 39.2 | 27.3 | 12.6 | 199 |
| ដីជួលពីគេ | 41.0 | 30.5 | 7.6 | 105 |
| ដីរបស់អ្នកដទៃ | 44.2 | 36.0 | 9.7 | 267 |
| **សរុប** | **41.8** | **31.3** | **9.2** | **4068** |

ក្នុងបរិបទខាងលើនេះ កុមារខ្វះអាហារូបត្ថម្ភ ដែលបែងចែកទៅតាមការងាររបស់ឪពុកម្តាយក៏ដូចជាប្រភេទកម្មសិទ្ធិកាន់កាប់ដីស្រែចំការ អាចជាបញ្ហាដែលត្រូវការយកចិត្តទុកដាក់ខ្ពស់ ។ ដូច្នេះគំនិតនៃការពង្រឹងបណ្តាញសុវត្ថិភាពសង្គមដែលមានលក្ខណៈជាប្រព័ន្ធ និងការសម្របសម្រួលរួមដោយការផ្តោតយកចិត្តទុកដាក់ទៅលើក្រុមគ្រួសារកសិករ និងគ្រួសារងាយរងគ្រោះបំផុត ។

យ៉ាងណាមិញ ទាក់ទងជាមួយនឹងការទិញអង្ករបរិភោគក្នុងអំឡុងពេល ១២ខែ កន្លងមកមុនអង្កេតត្រូវបានសាកសួរ សម្រាប់កំណត់រកនូវអត្រាប្រេវ៉ាឡង់ស្ថានភាពអាហារូបត្ថម្ភខ្សត់ខ្សោយពិតប្រាកដរវាងក្រុមកសិករធ្វើស្រែ (ផលិតអង្ករ) និងក្រុមប្រើប្រាស់ផលិតផលអង្ករ ។ ជាលទ្ធផលកង្វះអាហារូបត្ថម្ភនៃសូចនាករទាំង៣ គឺមិនសូវជាខុសគ្នាច្រើនទេក្នុងចំណោមក្រុមទាំងពីរ ។

## តារាងលេខ ១៧ : មនុស្សមាត្រកុមារតាមប្រភេទផលិតកម្មអង្ករ

| ភាគរយកុមារកង្វះអាហារូបត្ថម្ភដែលមានអាយុក្រោម ៥ ឆ្នាំ តាមរយៈសន្ទស្សន៍សូចនាករមនុស្សមាត្រទាំង ៣ នៃស្ថានភាពអាហារូបត្ថម្ភតាមប្រភេទកម្មសិទ្ធិកាន់កាប់ដីស្រែចម្ការ ដោយអង្កេតមនុស្សមាត្រកម្ពុជា ឆ្នាំ២០០៨ | | | | |
|---|---|---|---|---|
| **ប្រភេទដីកាន់កាប់** | **គម្លាតស្តង់ដារអវិជ្ជមានក្រោម ២** | | | **ចំនួនកុមារ** |
| | កម្ពស់ធៀបនឹងអាយុ | ទម្ងន់ធៀបនឹងអាយុ | ទម្ងន់ធៀបនឹងកម្ពស់ | |
| អ្នកផលិតស្រូវដុល | 39.2 | 27.2 | 7.5 | 1512 |
| អ្នកប្រើប្រាស់ផលិតផលស្រូវដុល | 41.9 | 31.5 | 9.5 | 4289 |

ហានិភ័យនៃកុមារកង្វះអាហារូបត្ថម្ភ មានស្មើរតែគ្រប់រូបភាព ទោះបីជាគ្រួសារទាំងនៅជនបទ និងទីប្រជុំជន ឬក៏បានជួប និងមិនជួបនូវបញ្ហាកង្វះខាតថវិកាក្តី ស្របពេលដែលការចំណាយរបស់គ្រួសារសម្រាប់ម្ហូបអាហារដែលមានតម្លៃថោកជាងមុនយ៉ាងហោចណាស់ក៏ម្តងដែរ ក្នុងអំឡុងពេល ៣០ ថ្ងៃ មុនអង្កេត ។ ស្មើរតែពាក់កណ្តាលនៃកុមារដែលមានអាយុក្រោម ៥ ឆ្នាំ ទាំងតំបន់ទីជនបទ និងទីប្រជុំជនដែលមានគ្រួសារបានជួបបញ្ហាកង្វះខាតថវិកា បានប្រឈមជាមួយភាពគ្រិន ។

## តារាងលេខ ១៨ : មនុស្សមាត្រកុមារតាមការបោះស្រាយពីបញ្ហាកង្វះថវិកា

| ភាគរយកុមារកង្វះអាហារូបត្ថម្ភដែលមានអាយុក្រោម ៥ ឆ្នាំ តាមរយៈសន្ទស្សន៍សូចនាករមនុស្សមាត្រទាំង ៣ នៃស្ថានភាពអាហារូបត្ថម្ភនៅពេលមានកង្វះថវិកា ដោយអង្កេតមនុស្សមាត្រកម្ពុជា ឆ្នាំ២០០៨ | | | | |
|---|---|---|---|---|
| **តំបន់រស់នៅ និងបញ្ហាថវិកា** | **គម្លាតស្តង់ដារអវិជ្ជមានក្រោម ២** | | | **ចំនួនកុមារ** |
| | កម្ពស់ធៀបនឹងអាយុ | ទម្ងន់ធៀបនឹងអាយុ | ទម្ងន់ធៀបនឹងកម្ពស់ | |
| តំបន់ទីប្រជុំជនមានបញ្ហាផ្នែក ថវិកា | 38.2 | 27.4 | 10.8 | 628 |
| តំបន់ទីជនបទមានបញ្ហាផ្នែក ថវិកា | 42.1 | 32.0 | 9.3 | 4603 |
| មានបញ្ហាផ្នែកថវិកាទាំងស្រុង | 41.6 | 31.5 | 9.5 | 5231 |
| តំបន់ទីប្រជុំជនគ្មានបញ្ហាផ្នែក ថវិកា | 25.1 | 14.4 | 6.1 | 589 |
| តំបន់ទីជនបទគ្មានបញ្ហាផ្នែក ថវិកា | 37.6 | 24.2 | 7.8 | 1198 |
| គ្មានបញ្ហាផ្នែកទាំងស្រុង | 33.4 | 21 | 7.2 | 1787 |
| **សរុប** | **38.2** | **27.4** | **10.8** | **628** |

## ២. មនុស្សមាត្រស្ត្រី

### ថ្នាក់ខេត្ត

អង្កេតក្នុងឆ្នាំ២០០៥ បានបង្ហាញថា កម្ពស់របស់ស្ត្រីមានទំនាក់ទំនងជាមួយស្ថានភាពសង្គម-សេដ្ឋកិច្ច ក្នុងរយៈកាលកន្លងមក និងស្ថានភាពអាហារូបត្ថម្ភអំឡុងវ័យកុមារភាព និងវ័យជំទង់ ។ ការឆាប់មានផ្ទៃពោះ និងចន្លោះពេលនៃការផ្តល់កំណើតទារក ចូលរួមចំណែកសំខាន់សម្រាប់អាហារូបត្ថម្ភខ្សត់ខ្សោយរបស់ស្ត្រី ។ ចំណែកឯ អ.ម.ក ឆ្នាំ២០០៨ បង្ហាញថា ខេត្តមណ្ឌលគិរី រតនគិរី ព្រះវិហារ និងស្ទឹងត្រែង មានស្ត្រីដែលមានកម្ពស់ទាបជាង ១៤៥ ស.ម ច្រើនជាងបណ្តាខេត្តផ្សេងៗ ។ រីឯស្ត្រីដែលបានវាយតំលៃថាស្គម នោះគឺសន្ទស្សន៍មាឌរាងកាយតិចជាង ១៨.៥ ឃើញមាននៅតាមខេត្តនៃតំបន់ខ្ពង់រាប ។ តំណាលគ្នានេះដែរ ស្ត្រីស្គមល្មម និងខ្លាំងមានអត្រាច្រើនជាង ៤ ភាគរយ នៅតាមខេត្តតំបន់វាលទំនាប ។

**តារាងលេខ ១៩ : មនុស្សមាត្រមាតាតាមខេត្ត-ក្រុងបែងតាមតំបន់**

ស្ត្រីគ្រប់រូបមានអាយុចន្លោះពី ១៥ ទៅ ៤៩ ឆ្នាំ ដែលមានកូនអាយុក្រោម ៥ ឆ្នាំ រួមមាន ភាគរយរបស់ស្ត្រីដែលមានកម្ពស់ក្រោម ១៤៥ សង់ទីម៉ែត្រ សន្ទស្សន៍មាឌរាងកាយជាមធ្យម និងកម្រិតភាគរយសន្ទស្សន៍មាឌរាងកាយនិមួយៗ ទៅតាមលក្ខណៈប្រវត្តិ ដោយអង្កេតមនុស្សមាត្រកម្ពុជា ឆ្នាំ២០០៨

| ឈ្មោះខេត្ត | កម្ពស់ | | សន្ទស្សន៍ | ភាពស្គម | | ភាពធាត់ | ចំនួន |
|---|---|---|---|---|---|---|---|
| | ភាគរយកម្ពស់ក្រោម ១៤៥ សង់ទីម៉ែត្រ | ចំនួន ស្ត្រី | សមាសភាព រាងកាយ | សរុប <18.5 | ស្គមល្មម/ស្គមខ្លាំង ≤17.0 | ≥ 30.0 | ស្ត្រី សរុប |
| បន្ទាយមានជ័យ | 5.0 | 318 | 22.1 | 10.7 | 1.1 | 2.8 | 292 |
| កំពង់ចាម | 5.2 | 918 | 21.3 | 16.1 | 4.4 | 1.6 | 810 |
| កំពង់ឆ្នាំង | 6.3 | 278 | 20.9 | 18.8 | 4.0 | 0.3 | 239 |
| កំពង់ស្ពឺ | 6.3 | 439 | 20.8 | 18.4 | 3.0 | 0.6 | 383 |
| កំពង់ធំ | 7.5 | 194 | 21.1 | 16.1 | 3.4 | 0.8 | 171 |
| កណ្តាល | 6.8 | 562 | 21.0 | 18.0 | 5.7 | 1.3 | 492 |
| ក្រចេះ | 5.6 | 164 | 21.1 | 17.4 | 2.4 | 1.3 | 144 |
| ភ្នំពេញ | 4.5 | 655 | 21.8 | 11.9 | 2.4 | 1.3 | 602 |
| ព្រៃវែង | 4.5 | 528 | 20.8 | 20.4 | 4.2 | 0.4 | 482 |
| ពោធិសាត់ | 7.4 | 186 | 21.1 | 13.1 | 3.9 | 0.5 | 167 |
| សៀមរាប | 6.9 | 572 | 21.4 | 15.7 | 3.1 | 1.5 | 465 |
| ស្វាយរៀង | 8.2 | 258 | 20.3 | 22.5 | 5.1 | 0.8 | 238 |
| តាកែវ | 7.6 | 488 | 20.7 | 20.6 | 6.9 | 2.6 | 439 |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ឧត្តរមានជ័យ | 6.0 | 85 | 21.1 | 12.3 | 2.4 | 0.7 | 75 |
| បាត់ដំបង/ប៉ៃលិន | 5.8 | 574 | 21.9 | 11.3 | 2.4 | 3.4 | 516 |
| កំពត/កែប | 6.9 | 251 | 21.2 | 17.6 | 2.8 | 2.1 | 220 |
| ព្រះសីហនុ/កោះកុង | 6.4 | 173 | 21.6 | 14.8 | 3.4 | 1.7 | 151 |
| ព្រះវិហារ/ស្ទឹងត្រែង | 11.4 | 143 | 21.0 | 11.8 | 3.3 | 0.2 | 126 |
| មណ្ឌលគិរី/រតនគិរី | 16.1 | 100 | 20.9 | 14.7 | 3.2 | 0.3 | 85 |

## ៣. ជម្ងឺរបស់កុមារ

### ថ្នាក់ខេត្ត

ខេត្តចំនួន ៦ ក្នុងចំណោម ១៩ ខេត្ត ដែលខេត្តខ្លះត្រូវបានរួមបញ្ចូលគ្នា អត្រារោគសញ្ញាជម្ងឺរលាកផ្លូវដង្ហើមមានច្រើនជាង ២០ ភាគរយ ក្នុងនោះខេត្តព្រះសីហនុ និងកោះកុងមានភាគរយច្រើនជាងគេ ២៣.៣ ។ ទីក្រុងភ្នំពេញ នៅតែជាកន្លែងដែលមានរោគសញ្ញាជម្ងឺរលាកផ្លូវដង្ហើមតិចជាងគេបង្អស់ ក្នុងកម្រិត ១ ខ្ទង់ (៣ ភាគរយ) ។ ជាមួយនឹងកម្រិត ១ ខ្ទង់នេះដែរ ខេត្តចែកតាមតំបន់២ទៀត បាត់ដំបង/ប៉ៃលិន និងកំពត/កែប មានអត្រាបន្តបន្ទាប់ គឺ ៦.៣ ភាគរយ និង ៨.៥ ភាគរយ ។ យើងឃើញថាទីក្រុង ឬខេត្តខ្លះដែលត្រូវបានរួមបញ្ចូលគ្នាដែលមានកុមារអាយុក្រោម ៥ ឆ្នាំ ចំនួនច្រើន មានអត្រារោគសញ្ញារលាកផ្លូវដង្ហើម តិចជាង ១០ ភាគរយ ។

**តារាងលេខ ២០ : រោគសញ្ញារលាកផ្លូវដង្ហើមរបស់កុមារតាមខេត្ត-ក្រុងចែកតាមតំបន់**

ភាគរយកុមារដែលមានអាយុតិចជាងគេបង្អស់ក្នុងចំណោមកុមារដែលមានអាយុក្រោម ៥ ឆ្នាំ មានរោគសញ្ញាជម្ងឺរលាកផ្លូវដង្ហើម តាមលក្ខណៈប្រវត្តិ ដោយអង្កេតមនុស្សមាត្រកម្ពុជា ឆ្នាំ២០០៨

| លក្ខណៈប្រវត្តិ | **រោគសញ្ញាជម្ងឺរលាកផ្លូវដង្ហើមក្នុងអំឡុងពេល ២សប្តាហ៍មុនអង្កេត** | |
|---|---|---|
| | រោគសញ្ញាជម្ងឺរលាកផ្លូវដង្ហើម | ចំនួនកុមារ |
| **ឈ្មោះខេត្ត** | | |
| បន្ទាយមានជ័យ | 22.9 | 318 |
| កំពង់ចាម | 20.7 | 897 |
| កំពង់ឆ្នាំង | 14.3 | 276 |
| កំពង់ស្ពឺ | 16.7 | 437 |
| កំពង់ធំ | 20.5 | 194 |
| កណ្តាល | 17.2 | 561 |
| ក្រចេះ | 14.9 | 162 |
| ភ្នំពេញ | 3.0 | 665 |

| | | |
|---|---|---|
| ព្រៃវែង | 13.8 | 520 |
| ពោធិសាត់ | 12.5 | 185 |
| សៀមរាប | 22.4 | 563 |
| ស្វាយរៀង | 14.6 | 256 |
| តាកែវ | 22.2 | 480 |
| ឧត្តរមានជ័យ | 18.2 | 84 |
| បាត់ដំបង/ប៉ៃលិន | 6.3 | 566 |
| កំពត/កែប | 8.5 | 250 |
| ព្រះសីហនុ/កោះកុង | 23.3 | 172 |
| ព្រះវិហារ/ស្ទឹងត្រែង | 11.3 | 142 |
| មណ្ឌលគីរី/រតនគីរី | 17.1 | 98 |
| **សរុប** | **15.6** | **6826** |

កុមារមានជម្ងឺរាក មានភាគរយទាបដូចគ្នានឹងរោគសញ្ញាជម្ងឺរលាកផ្លូវដង្ហើម នៅតាមខេត្ត ដែលត្រូវបានរួមបញ្ចូលគ្នា ដូចជា បាត់ដំបង/ប៉ៃលិន និងកំពត/កែប ក្នុងអត្រាប្រហែល ២០ ភាគរយ ។ ក្រុងភ្នំពេញបន្តនូវអត្រាទាបជាងគេ ថ្វីត្បិតតែចំនួនជម្ងឺរាករបស់កុមារ ច្រើនជាង ៤ ដងធៀបនឹងរោគសញ្ញាជម្ងឺរលាកផ្លូវដង្ហើមក្តី ។ ខេត្តចំនួន ១៣ ក្នុងចំណោម ១៩ ខេត្ត ដែលខេត្តខ្លះត្រូវបានរួមបញ្ចូលគ្នា មានប្រេវ៉ាឡង់ធំជាង ៣០ ភាគរយ ។

**តារាងលេខ ២១ : ជម្ងឺរាករបស់កុមារតាមខេត្ត-ក្រុងចែកតាមតំបន់**

| ភាគរយកុមារដែលមានអាយុតិចជាងគេបង្អស់ក្នុងចំណោមកុមារដែលមានអាយុក្រោម ៥ ឆ្នាំ បានកើតជម្ងឺរាក តាមលក្ខណៈប្រវត្តិ ដោយអង្កេតមនុស្សសាស្ត្រកម្ពុជា ឆ្នាំ២០០៨ | | | |
|---|---|---|---|
| លក្ខណៈប្រវត្តិ | **ជម្ងឺរាកក្នុងអំឡុងពេល ២សប្តាហ៍មុនអង្កេត** | | |
| | រាក | រាកមូល | ចំនួនកុមារ |
| **ឈ្មោះខេត្ត** | | | |
| បន្ទាយមានជ័យ | 33.9 | 1.6 | 318 |
| កំពង់ចាម | 33.7 | 2.8 | 897 |
| កំពង់ឆ្នាំង | 37.5 | 5.3 | 276 |
| កំពង់ស្ពឺ | 26.8 | 1.7 | 437 |
| កំពង់ធំ | 31.0 | 3.5 | 194 |
| កណ្តាល | 28.8 | 2.6 | 561 |

| | | | |
|---|---|---|---|
| ក្រចេះ | 38.1 | 6.6 | 162 |
| ភ្នំពេញ | 13.4 | 0.8 | 665 |
| ព្រៃវែង | 33.9 | 4.3 | 520 |
| ពោធិសាត់ | 32.3 | 2.6 | 185 |
| សៀមរាប | 36.8 | 2.0 | 563 |
| ស្វាយរៀង | 36.3 | 4.9 | 256 |
| តាកែវ | 29.4 | 2.7 | 480 |
| ឧត្តរមានជ័យ | 40.9 | 3.0 | 84 |
| បាត់ដំបង/ប៉ៃលិន | 20.8 | 3.0 | 566 |
| កំពត/កែប | 21.5 | 2.9 | 250 |
| ព្រះសីហនុ/កោះកុង | 31.6 | 3.8 | 172 |
| ព្រះវិហារ/ស្ទឹងត្រែង | 30.5 | 2.0 | 142 |
| មណ្ឌលគីរី/រតនគីរី | 41.1 | 6.5 | 98 |
| **សរុប** | 30.0 | 2.9 | 6826 |

យ៉ាងណាមិញ ប្រហែល ៤០ ភាគរយ នៃកុមាររស់នៅទីក្រុងភ្នំពេញបានកើតគ្រុនក្តៅ ទោះបីជាចំនួនភាគរយនេះទាបជាងបណ្តាខេត្តផ្សេងៗក្តី ។ ខេត្តចំនួន ១៦ ក្នុងចំណោម ១៩ ខេត្ត ដែលខេត្តខ្លះត្រូវបានរួមបញ្ចូលគ្នាចែកតាមតំបន់ បង្ហាញថាមានកុមារម្នាក់ក្នុងចំណោម ២ នាក់ កើតគ្រុនក្តៅ ។

**តារាងលេខ ២២ : គ្រុនក្តៅរបស់កុមារតាមខេត្ត-ក្រុងចែកតាមតំបន់**

| ភាគរយកុមារដែលមានអាយុតិចជាងគេបង្អស់ក្នុងចំណោមកុមារដែលមានអាយុក្រោម ៥ ឆ្នាំ កើតគ្រុនក្តៅ តាមលក្ខណៈប្រវត្តិ ដោយអង្កេតមនុស្សសាស្ត្រកម្ពុជា ឆ្នាំ២០០៨ | | |
|---|---|---|
| លក្ខណៈប្រវត្តិ | **គ្រុនក្តៅក្នុងអំឡុងពេល ២សប្តាហ៍មុនអង្កេត** | |
| | គ្រុនក្តៅ | ចំនួនកុមារ |
| **ឈ្មោះខេត្ត** | | |
| បន្ទាយមានជ័យ | 51.9 | 318 |
| កំពង់ចាម | 57.4 | 897 |
| កំពង់ឆ្នាំង | 68.4 | 276 |
| កំពង់ស្ពឺ | 66.7 | 437 |
| កំពង់ធំ | 65.9 | 194 |

| | | |
|---|---|---|
| កណ្ដាល | 61.7 | 561 |
| ក្រចេះ | 51.3 | 162 |
| ភ្នំពេញ | 39.9 | 665 |
| ព្រៃវែង | 68.6 | 520 |
| ពោធិសាត់ | 64.4 | 185 |
| សៀមរាប | 62.1 | 563 |
| ស្វាយរៀង | 68.8 | 256 |
| តាកែវ | 72.2 | 480 |
| ឧត្ដរមានជ័យ | 62.6 | 84 |
| បាត់ដំបង/ប៉ៃលិន | 48.0 | 566 |
| កំពត/កែប | 52.5 | 250 |
| ព្រះសីហនុ/កោះកុង | 57.6 | 172 |
| ព្រះវិហារ/ស្ទឹងត្រែង | 49.8 | 142 |
| មណ្ឌលគិរី/រតនគិរី | 66.7 | 98 |
| **សរុប** | 58.9 | 6826 |

សរុបមក មិនមានសញ្ញាបង្ហាញថា ស្ទួចនាករជម្ងឺទាំង៣របស់កុមារនៅក្នុងតំបន់មួយមានភាគរយ ច្រើនជាង ឬក៏តិចជាងតំបន់មួយផ្សេងទេ នៅពេលដែលខេត្តទាំងអស់នោះ (លើកលែងទីក្រុងភ្នំពេញ) ត្រូវបានបំបែកចែកទៅតាមតំបន់ ។

## ៤. មនុស្សមាត្រ និងជម្ងឺកុមារតាមលំនៅដ្ឋានមិនទាន់រៀបរយ នៅទីក្រុងភ្នំពេញ

លំនៅដ្ឋានមិនទាន់រៀបរយនានានៅភ្នំពេញ ត្រូវបានជ្រើសរើសយកជាគំរូដាច់ដោយឡែកពីគ្នា សំដៅធ្វើការប៉ាន់ស្មានទូវស្ថានភាពអាហារូបត្ថម្ភរបស់តំបន់ទាំងអស់នេះ ។ កម្រងសំណួរ និង វិធីសាស្ត្រប្រើប្រាស់សម្រាប់អង្កេត ដែលបានប្រើប្រាស់ជាមួយតំបន់មិនទាន់រៀបរយទាំងអស់នេះ គឺដូចគ្នាបេះបិទទៅនឹងអង្កេតមនុស្សមាត្រ ។ ចំពោះតំបន់តាំងទីលំនៅថ្មី មិនត្រូវបានរាប់បញ្ចូលក្នុងពេលធ្វើអង្កេតជាក់ស្ដែង ដោយសារតែតំបន់ថ្មីទាំងអស់នោះ មិនទាន់មានវត្តមាននៅពេលធ្វើសំណាកគំរូ ដោយវិទ្យាស្ថានជាតិស្ថិតិ ។

កម្រិតនៃកង្វះអាហារូបត្ថម្ភ (ស្គម) របស់កុមារនៅតាមតំបន់មិនទាន់រៀបរយនៅទីក្រុងភ្នំពេញ មាន ៨.៦ ភាគរយ អត្រានេះប្រហាក់ប្រហែលទៅនឹងកម្រិតជាមធ្យមរបស់ប្រទេស (៨.៩ ភាគរយ) ។

យ៉ាងណាមិញ ភាពក្រិនមានអត្រាភាគរយប្រហែល ១០ ទាបជាង កម្រិតជាមធ្យមរបស់ប្រទេស ។ អត្រាកង្វះអាហារូបត្ថម្ភរបស់កុមារនៅតាមលំនៅដ្ឋានមិនទាន់រៀបរយនានានៅ ទីក្រុងភ្នំពេញមានកម្រិតទាបជាងកម្រិតជាតិក៏ពិតមែន ប៉ុន្តែវាជារឿងសំខាន់មួយដែលគួរតែមានចំណាប់អារម្មណ៍ខ្លាំង ។ រូបភាពខាងក្រោមនេះ បង្ហាញនូវអត្រាកង្វះអាហារូបត្ថម្ភរបស់កុមារ តាមបទដ្ឋានវាស់វែងការលូតលាស់របស់អង្គេតសុខភាពពិភពលោក ដោយអង្កេតមនុស្សមាត្រឆ្នាំ២០០៨។

តារាងលេខ ២៣ : មនុស្សមាត្រកុមារតាមលំនៅដ្ឋានមិនទាន់រៀបរយនានានៅទីក្រុងភ្នំពេញ

| កុមារកង្វះអាហារូបត្ថម្ភដែលមានអាយុក្រោម ៥ ឆ្នាំ រស់នៅតាមតំបន់មិនទាន់រៀបរយនាទីក្រុងភ្នំពេញ តាមបទដ្ឋានវាស់វែងការលូតលាស់របស់ អង្កេតសុខភាពពិភពលោក ដោយអង្កេតមនុស្សមាត្រកម្ពុជា | | | | | |
|---|---|---|---|---|---|
| | < - 3 SD | < - 2 SD | មធ្យម | ចំនួន | កម្រិតលំអៀង |
| ទម្ងន់ធៀបនឹងអាយុ | 6.3 | 22.1 | -0.9 | 364 | 1.4 |
| ទម្ងន់ធៀបនឹងកម្ពស់ | 2.5 | 8.6 | -0.3 | 364 | 1.3 |
| កម្ពស់ធៀបនឹងអាយុ | 14.8 | 29.2 | -1.2 | 364 | 1.8 |

ស្ត្រីស្គមល្ងមដែលរស់នៅក្នុងតំបន់មិនទាន់រៀបរយនៅទីក្រុងភ្នំពេញ កើនឡើងប្រហែលជា ៣ អត្រាភាគរយ ធៀបនឹងអត្រាស្គមល្ងមរបស់ស្ត្រីនៅទីក្រុងភ្នំពេញទាំងមូល ។ ជាមួយនឹងអត្រាកំណើននេះ មិនជាបញ្ហាចោទទេសម្រាប់ន័យស្ថិតិ ។ ដំណាលគ្នាផងដែរ អត្រាខុសគ្នានូវភាពស្គមនេះ ក៏ដូចជាអត្រាខុសគ្នារបស់សូចនាករដ៏ទៃទៀត ក៏មិនបានបង្កើតនូវអត្ថន័យគ្រប់គ្រាន់សម្រាប់បកស្រាយ និងវិភាគឡើយ ពីព្រោះតែទិន្នន័យរបស់សូចនាករ មិនសំខាន់ក្នុងអត្ថន័យស្ថិតិ (តារាងលេខ ២៤) ។

សរុបមកយើងឃើញថា កង្វះខាតម្ហូបតែមួយក្នុងចំណោមកត្តាសំខាន់ផ្សេងទៀត មិនមែនជាមូលហេតុចម្បងនៃទំនាក់ទំនងកង្វះអាហារូបត្ថម្ភ និងជម្ងឺនោះទេ ។ នៅមានកត្តាគួបផ្សំជាច្រើនទៀតដែលធ្វើ ឱ្យកុមារ និងស្ត្រីដែលជាជនងាយរងគ្រោះជួបនូវបញ្ហាទាំងអស់ខាងលើ ។

តារាងលេខ ២៤ : មនុស្សមាត្រមាតាតាមលំនៅដ្ឋានមិនទាន់រៀបរយនានានៅទីក្រុងភ្នំពេញ

| ស្ត្រីគ្រប់រូបមានអាយុចន្លោះពី ១៥ ទៅ ៤៩ឆ្នាំ ដែលមានកូនអាយុក្រោម ៥ឆ្នាំ រួមមានភាគរយរបស់ស្ត្រី ដែលមានកម្ពស់ក្រោម ១៤៥ សង់ទីម៉ែត្រ សន្ទស្សន៍មាឌរាងកាយជាមធ្យម និងកម្រិតភាគរយសន្ទស្សន៍មាឌរាងកាយនិមួយៗ របស់ស្ត្រីដែលរស់នៅតំបន់មិនទាន់រៀបរយនាទីក្រុងភ្នំពេញ ដោយអង្កេត មនុស្សមាត្រកម្ពុជា ឆ្នាំ២០០៨ | | | | | | |
|---|---|---|---|---|---|---|
| **កម្ពស់** | | **សន្ទស្សន៍** | **ភាពស្គម** | | **ភាពធាត់** | **ចំនួន** |
| ភាគរយ កម្ពស់ក្រោម ១៤៥ សង់ទីម៉ែត្រ | ចំនួន ស្ត្រី | សមាសភាព រាងកាយ ជាមធ្យម | សរុប ភាពស្គម <18.5 | ស្គមល្មម ស្គមខ្លាំង ≤17.0 | ≥ 30.0 | **ស្ត្រី សរុប** |
| **5.0** | **326** | **21.9** | **14.1** | **5.3** | **2.9** | **289** |

របាយការណ៍អត្រាប្រេវ៉ាឡង់នៃប្រភេទជម្ងឺ ទំនងជាថយចុះ ឬក៏កើនឡើងអាស្រ័យលើចំណេះដឹង ការអប់រំរបស់មាតា ដែលជាកត្តាសំខាន់មិនអាចរំលងបាន ទោះបីកុមាររស់នៅតំបន់ណាក៏ដោយ ។ តាមរយៈតារាងខាងក្រោម កុមារមានរោគសញ្ញាជម្ងឺរលាកផ្លូវដង្ហើម នៅតាមលំនៅដ្ឋានមិនទាន់រៀបរយ មានភាគរយតិចជាងកម្រិតប្រទេស ។ ប៉ុន្តែមានចំនួន ៣ ដងធំជាង ទីក្រុងភ្នំពេញ ដោយគិតតាម វិធីសាស្ត្រគណនាឆ្នាំ២០០៥ ។ ជម្ងឺរាក មានអត្រាប្រហែលនឹងកម្រិតប្រទេស (៣០ ភាគរយ) តែនៅតែខ្ពស់ជាង (ប្រហែល ៣ ដង) ធៀបជាមួយអត្រារបស់ទីក្រុងភ្នំពេញ ។ ចំណែកឯអត្រាប្រេវ៉ាឡង់របស់កុមារគ្រុនក្តៅ មានភាគរយទាបជាងកម្រិតប្រទេស និងទីក្រុងភ្នំពេញ ។

តារាងលេខ ២៥ : ជម្ងឺរបស់កុមារតាមលំនៅដ្ឋានមិនទាន់រៀបរយនានានៅទីក្រុងភ្នំពេញ

| ភាគរយកុមារដែលមានអាយុតិចជាងគេក្នុងចំណោមកុមារដែលមានអាយុក្រោម ៥ ឆ្នាំ បានកើតជម្ងឺ ក្នុងអំឡុងពេល ២សប្តាហ៍ មុនអង្កេត រស់នៅក្នុងតំបន់មិនទាន់រៀបរយ នាទីក្រុងភ្នំពេញ ដោយអង្កេត មនុស្សមាត្រកម្ពុជា ឆ្នាំ២០០៨ | | |
|---|---|---|
| **ប្រភេទជម្ងឺ** | **%** | **ចំនួន** |
| រោគសញ្ញារលាកផ្លូវដង្ហើម (តាមរូបមន្តឆ្នាំ២០០៥) | 10.3 | 335 |
| រោគសញ្ញារលាកផ្លូវដង្ហើម (តាមរូបមន្តឆ្នាំ២០០០) | 15.5 | 335 |
| រាក | 32.9 | 335 |
| រាកលាយឈាម | 4.2 | 335 |
| គ្រុនក្តៅ | 33.4 | 335 |

ដូច្នេះអត្រាប្រេវ៉ាឡង់ជម្ងឺកុមារ នៅតាមលំនៅដ្ឋានមិនទាន់រៀបរយនាទីក្រុងភ្នំពេញ គឺជាហេតុផលដ៏សំខាន់ បង្ហាញនូវកត្តាចម្បងផ្នែកសុខភាពរបស់តំបន់ទាំងអស់នេះ ជាជាងទីក្រុងភ្នំពេញទាំងមូល ។ ទាក់ទងនឹងបញ្ហានេះ កម្រិតខ្ពស់នៃជម្ងឺឆ្លងនានា ទំនងជាភ្នាក់ងារសំខាន់បង្កឱ្យកុមារនៅក្នុងតំបន់ទាំងនេះ ទៅជាកុមារកង្វះអាហារូបត្ថម្ភ ។

អាហារចម្រុះរបស់លំនៅដ្ឋានមិនទាន់រៀបរយនានាជាមធ្យម (៤.៣ភាគរយ) មានចំនួនតិចជាងធៀបនឹងចំនួនមធ្យមរបស់ប្រទេស (៤.៧ ភាគរយ) ។ ខណៈពេលដែលការបរិភោគអាហារសាច់ (៤៩.៥ ភាគរយ) បែរជាមានកម្រិតខ្ពស់ជាងកម្រិតប្រទេស (៣៦.៥ ភាគរយ) ទៅវិញ ។ យ៉ាងណាមិញ ការបរិភោគសាច់ត្រី (៤៩.១ ភាគរយ) គឺមានចំនួនទាបជាងច្រើន ធៀបនឹងកម្រិតប្រទេស (៦៧.៣ ភាគរយ) ក្នុងតារាងលេខ ២៦។

## តារាងលេខ ២៦ : ការប្រើប្រាស់អាហាររបស់កុមារតាមលំនៅដ្ឋានមិនទាន់រៀបរយនានានៅទីក្រុងភ្នំពេញ

| ភាគរយកុមារដែលមានអាយុពី ៦ ទៅ ៣៥ ខែ រស់នៅតាមតំបន់មិនទាន់រៀបរយ នាទីក្រុងភ្នំពេញ ដែលបានប្រើប្រាស់ក្រុមអាហារក្នុងអំឡុងពេលថ្ងៃ ឬយប់មុនពេលអង្កេត និងចំនួនមធ្យមនៃក្រុមអាហារដែលបានប្រើប្រាស់ ដោយអង្កេតមនុស្សសាស្ត្រកម្ពុជា ឆ្នាំ២០០៨ | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| សាច់គ្រឿងក្នុង | វីតាមីនអាក្នុងផ្លែឈើ | គ្រាប់ធុញ្ញជាតិ | វីតាមីនអាក្នុងបន្លែ | សាច់ក្រហម | សាច់ត្រី | បន្លែ | ផ្សេងៗ | ផលិតផលទឹកដោះគោ | អាហារមើម | បន្លែនិងផ្លែឈើផ្សេងៗ | ស៊ុត | ប្រេងនិងជាធាត់ | បង្អែម | | ក្រុមម្ហូបជាមធ្យម | ចំនួនកុមារ |
| 5.3 | 8.5 | 84 | 42.2 | 49.5 | 49.1 | 8.3 | 17.7 | 33.4 | 9.5 | 46.5 | 26.1 | 9.5 | 36.7 | | 4.26 | 335 |

# ជំពូកទី៧

# របៀបផ្តល់អាហារបន្ថែមដល់ទារក និងកុមារតូច

## ១. ទំហំទារកនៅពេលកើត

ទំហំពេលកើត គឺជាកត្តាចម្បងនៃសុខភាព និងភាពរស់រានមានជីវិតរបស់ទារក (អ.ប្រ.ស.ក ២០០៥)។ ទារកដែលមានទម្ងន់ស្រាលជាង ២.៥ គ.ក ត្រូវបានរំពឹងថាប្រឈមនឹងការស្លាប់ និងជភាពស្លេកស្លាំងបណ្តាលមកពីកង្វះជាតិដែក ច្រើនជាងទារកដែលមានទម្ងន់គ្រប់គីឡូ ។ ទិន្នន័យរបស់ទារកទទួលបានតាមរយៈការ ប៉ាន់ស្មានរបស់ម្តាយ និងឯកសារកត់ត្រាពីមន្ទីរពេទ្យ ។ ចំពោះទម្ងន់តំណាង (Proxy) ត្រូវបាន ប្រើប្រាស់នៅពេលដែល គ្មានអំណះអំណាងទាំងពីរខាងលើ ។

អង្កេតធ្វើការប៉ាន់ស្មានថា មានទារកប្រហែលជា ៩ ក្នុងចំណោម ១០០ នាក់ទូទាំងប្រទេសកើតមកមានទំហំតូច ឬទម្ងន់ក្រោម ២.៥ គ.ក ។ ប្រសិនណាបើទារកមានទម្ងន់តិចជាង ឬស្មើ ២.៥ គ.ក នេះមានន័យថា ទូទាំងប្រទេសកម្ពុជាមានទារកមិនគ្រប់ទម្ងន់ច្រើនជាង ១៦ ភាគរយ ។ មាតាចំនួន ៦២ ភាគរយ បានប្រាប់ថាទារកត្រូវបានថ្លឹងក្រោយពេលកើត ។ ចំពោះទារកដែលមិនបានថ្លឹងភាគច្រើន ទំនងចេញមកពីគ្រួសារក្រីក្រ ។ គ្រួសារកាន់តែក្រីក្រ ការប្រឈមនឹងអត្រាទារកមានទំហំតូច ឬទំហំស្រាលពេលកើតកាន់តែខ្ពស់ (តារាងលេខ ២៧) ។ យ៉ាងណាមិញ ទិន្នន័យដែលបានផ្តល់តាមរយៈការប៉ាន់ស្មានទម្ងន់តំណាងភាគច្រើន គឺជាចំនួនកើននៅក្នុងប្រភេទកន្លះគីឡូក្រាម ដូចជា : ២, ២.៥, ៣, ៣.៥ គ.ក ។ល។ ដែលជាកត្តាពិបាកក្នុងការស្វែងរក ទម្ងន់ពិតប្រាកដ ។

តំបន់ជនបទសំបូរទៅដោយទារកមានទំហំតូច ឬទម្ងន់ស្រាលពេលកើត ជាជាងតំបន់ទីប្រជុំជនជាមួយនឹងអត្រា ៦ ភាគរយ ទល់នឹង ៩.៩ ភាគរយ ។ ខេត្តដាច់ស្រយាលជាពិសេស មណ្ឌលគីរី និងរតនគីរី មានអត្រាខ្ពស់ជាងគេក្នុងចំណោមខេត្តដ៏ទៃទៀតនៅទូទាំងប្រទេស ។ ការខុសគ្នានៅតាមខេត្តនេះ អាចបណ្តាលមកពីកត្តាលទ្ធភាពបង្កកំណើត និង*កម្ពស់របស់ម្តាយ* (តារាងលេខ ១៩ : មនុស្សមាត្រមាតាតាមខេត្ត-ក្រុងចែកតាមតំបន់) ។

រីឯការវិភាគលើទម្ងន់របស់ទារកទៅតាមឆ្នាំនៃការអង្កេតវិញមិនអាចធ្វើទៅបាន ដោយសារតែពីមួយឆ្នាំទៅមួយឆ្នាំ មានការកើនឡើងនូវភាគរយមាតាប្រាប់នូវព័ត៌មានពីទម្ងន់របស់ទារកដែលបានថ្លឹង ដូចជា : ឆ្នាំ២០០០ (១៧ ភាគរយ) ឆ្នាំ២០០៥ (៤០ ភាគរយ) និង ឆ្នាំ២០០៨ (៦២ ភាគរយ) ។ ម្យ៉ាងវិញទៀត អង្កេតឆ្នាំ២០០៨ គឺសង្កត់ធ្ងន់ទៅលើតែស្ត្រីណាដែលមានកូនអាយុតិចជាងគេក្នុងរង្វង់គ្រួសារតែប៉ុណ្ណោះ ។ តារាងខាងក្រោមបង្ហាញនូវការប្រែប្រួលខុសគ្នាគួរឱ្យកត់សម្គាល់រវាងភាគរយរបស់ទំហំទារកនៅតាមតំបន់ ខេត្ត ទីកន្លែងរស់នៅ និងធនធានរបស់គ្រួសារ ។

## តារាងលេខ ២៧ : ទំហំរបស់ទារកតាមលក្ខណៈជីវប្រវត្តិផ្សេងៗ

| ភាគរយកុមារដែលមានអាយុតិចជាងគេបង្អស់ មានបញ្ហានឹងទំហំតូច ឬទម្ងន់ស្រាលជាង ២.៥ គីឡូក្រាម តាមលក្ខណៈប្រវត្តិ ដោយអង្កេតមនុស្សមាត្រកម្ពុជា ឆ្នាំ២០០៨ | | |
|---|---|---|
| | ទម្ងន់ស្រាល | ចំនួនកុមារ |
| **ថ្នាក់ជាតិ** | 8.9% | 4227 |
| **តំបន់រស់នៅ** | | |
| ទីប្រជុំជន | 6.0% | 1070 |
| ទីជនបទ | 9.9% | 3168 |
| **ខេត្តតាមតំបន់** | | |
| បន្ទាយមានជ័យ | 10.0% | 208 |
| កំពង់ចាម | 9.6% | 585 |
| កំពង់ឆ្នាំង | 7.4% | 166 |
| កំពង់ស្ពឺ | 11.9% | 213 |
| កំពង់ធំ | 9.8% | 100 |
| កណ្ដាល | 7.9% | 398 |
| ក្រចេះ | 13.3% | 115 |
| ភ្នំពេញ | 4.7% | 648 |
| ព្រៃវែង | 11.3% | 294 |
| ពោធិសាត់ | 8.3% | 116 |
| សៀមរាប | 10.3% | 334 |
| ស្វាយរៀង | 6.6% | 113 |
| តាកែវ | 7.9% | 276 |
| ឧត្ដរមានជ័យ | 12.6% | 43 |
| បាត់ដំបង/ប៉ៃលិន | 9.9% | 278 |
| កំពត/កែប | 6.9% | 105 |
| ព្រះសីហនុ/កោះកុង | 8.7% | 123 |
| ព្រះវិហារ/ស្ទឹងត្រែង | 13.2% | 78 |
| មណ្ឌលគិរី/រតនគិរី | 15.5% | 45 |
| **សន្ទស្សន៍ធនធានទ្រព្យសម្បត្តិ** | | |
| ក្របំផុត | 11.9% | 553 |
| ក្រ | 12.3% | 612 |
| មធ្យម | 8.9% | 810 |
| មាន | 8.3% | 929 |
| មានបំផុត | 6.3% | 1324 |

## ២. ស្ថានភាពបំបៅកូនដោយទឹកដោះម្តាយ និងការផ្តល់អាហារបន្ថែម

មធ្យោបាយមួយដែលសំខាន់ដែលអាចធានាដល់ការមានអាហារូបត្ថម្ភគ្រប់គ្រាន់ សម្រាប់ទារក គឺតាមការបំបៅកូនដោយទឹកដោះម្តាយតែមួយមុខ ។ ទឹកដោះម្តាយមិនគ្រាន់តែផ្ទុកទៅដោយសារជាតិសំខាន់ប៉ុណ្ណោះទេ ប៉ុន្តែផ្តល់នូវអត្ថប្រយោជន៍ប្រព័ន្ធការពារនឹងជម្ងឺកុមារ ។ ទឹកដោះម្តាយមិនទាមទារនូវការចំណាយ ដែលផ្ទុយពីការចិញ្ចឹមទារកដោយផលិតផលម្សៅទឹកដោះគោដែលលាយនឹងទឹក ។ ហើយក្នុងពេលជំណាលគ្នានោះ អត្រានៃការផ្តល់ទឹកដល់ទារក ឃើញមានខ្ពស់នៅក្នុងដំណាក់កាល ៦ ខែ ដំបូងនៃជីវិត ។

ជាទូទៅ ទារកគួរតែត្រូវបានចិញ្ចឹមដោយទឹកដោះម្តាយ សម្រាប់រយៈពេល ១២ ខែ ឬ ១៨ ខែ ដំបូងជាមួយនឹងអាហាររឹង និងទន់បន្ថែមក្រោយពី ៦ ខែ នៃការចិញ្ចឹមដោយទឹកដោះម្តាយតែមួយមុខគត់ ។ លើកលែងតែទឹកដោះដែលបានមកពីម្តាយផ្ទុកនូវជម្ងឺអេដស៍ និងម្តាយដែលមិនមានលទ្ធភាពគ្រប់គ្រាន់ ក្នុងការផលិតនូវសារជាតិទឹកដោះទៅឱ្យទារក ។

របៀបផ្តល់ចំណីអាហារដល់ទារក និងកុមារតូចឱ្យបានត្រឹមត្រូវ និងទាន់ពេលវេលា រួមមានការចាប់ផ្តើមផ្តល់បន្ថែមនូវអាហាររឹង និងទន់ដល់ទារកដែលមានអាយុចាប់ពី ៦ ខែ ឡើងទៅ ។ ក្នុងពេលជំណាលគ្នានោះ ការបង្កើនបរិមាណអាហារ និងក្រុមប្រភេទចំណីអាហារចម្រុះ ជាតម្រូវការចាំបាច់ហើយការផ្តល់ចំណីអាហារនេះ ត្រូវតែធ្វើឱ្យបានញឹកញាប់ ។ ប៉ុន្តែ ការបំបៅកូនដោយទឹកដោះម្តាយ នៅតែជាការអនុវត្តសំខាន់ និងចាំបាច់សម្រាប់ការទ្រទ្រង់ទារក និងកុមារតូចក្នុងការពង្រឹងនូវប្រព័ន្ធស៊ាំការពារសារពាង្គកាយ ក៏ដូចជាក្នុងការកាត់បន្ថយហានិភ័យនៃជម្ងឺឆ្លងនានាដែរ ។

ផ្ទុយទៅវិញ ការផ្តល់អាហាររឹងបន្ថែម គួរតែចាប់ផ្តើមនៅពេលដែលទារក និងកុមារតូចមានអាយុចាប់ពី ៦ ខែ ឡើងទៅ ដោយសារពេលនោះទឹកដោះម្តាយតែមួយមុខគត់ លែងគ្រប់គ្រាន់សម្រាប់ការលូតលាស់ធំធាត់របស់ទារក និងកុមារតូចទៀតហើយ ។ អាហារូបត្ថម្ភគ្រប់គ្រាន់ (ប្រភពបានមកពីចំណីអាហារបន្ថែមឱ្យបានត្រឹមត្រូវ ក៏ដូចជាបន្តនូវការបំបៅកូនដោយទឹកដោះម្តាយ) អាចជួយបំពេញនូវតម្រូវការខ្វះខាតអាហារូបត្ថម្ភរបស់កុមារ ដែលមានអាយុក្រោម ៥ ឆ្នាំ (៦ ទៅ ៥៩ ខែ) ។ ជាក់ស្តែង ប្រេវ៉ាឡង់នៃកង្វះអាហារូបត្ថម្ភ (ទម្ងន់ធៀបនឹងអាយុ និងកម្ពស់ធៀបនឹងអាយុ) បានកើនឡើងខ្ពស់គួរឱ្យកត់សម្គាល់ក្នុងអង្កេតមនុស្សមាត្រនេះ ។

តារាងខាងក្រោម បង្ហាញនូវភាគរយរបស់ទារក ឬកុមារតូចអាយុតិចជាងគេ ដែលកំពុងរស់នៅជាមួយម្តាយទៅតាមស្ថានភាពបៅដោះម្តាយ និងភាគរយនៃការបំបៅកូនដោយទឹកដោះម្តាយ ទៅតាមអាយុជាខែ ។ ទិន្នន័យក្នុងតារាងនេះផងដែរ បង្ហាញថាក្នុងចំណោមទារកអាយុចាប់ពី ០ ទៅ ៥ខែ

មាន ៦៥.៩ ភាគរយ ដែលបៅដោះម្ដាយតែមួយមុខ ។ ក្នុងពេលដំណាលគ្នានេះដែរ ការផ្ដល់អាហារបន្ថែមដល់ទារក មានលក្ខណៈឆាប់រហ័សពេកសម្រាប់ទារកអាយុចាប់ពី ០ ទៅ ៥ ខែ ក្នុងអត្រា ១២.២ ភាគរយ ។

ប្រហែល ១ភាគ២ ក្នុងចំណោមកុមារទាំងអស់អាយុចាប់ពី ២០ ទៅ ២៣ ខែ ត្រូវបានឈប់ចិញ្ចឹមដោយការបៅដោះម្ដាយ ប៉ុន្តែបានទទួលនូវការផ្ដល់អាហារបន្ថែម ។ មានន័យថាអាយុកុមារកាន់តែច្រើន ការបំបៅដោយទឹកដោះម្ដាយតែមួយមុខនឹងលែងជាប្រភពផ្ដល់នូវអាហារូបត្ថម្ភគ្រប់គ្រាន់ទៀតហើយ ។ ដូច្នេះការផ្ដល់អាហាររឹង ឬទន់បន្ថែម ការបង្កើនប្រភេទចំណីអាហារចម្រុះ ក៏ដូចជាការបង្កើនការផ្ដល់ចំណីអាហារឱ្យបានញឹកញាប់ក្រៅពីទឹកដោះម្ដាយ គឺជាការសំខាន់សម្រាប់កុមារដែលមានអាយុចាប់ពី ៦ ទៅ ២៣ ខែ ។

**តារាងលេខ ២៨ : ស្ថានភាពនៃការចិញ្ចឹមកូនដោយទឹកដោះម្ដាយ និងអាហារ**

**ភាគរយទារក ឬកុមារតូចអាយុតិចជាងគេដែលកំពុងរស់នៅជាមួយម្ដាយទៅតាមស្ថានភាពបៅដោះម្ដាយ និង ភាគរយនៃការបំបៅកូនដោយទឹកដោះម្ដាយទៅតាមអាយុជាខែ ដោយអង្កេតមនុស្សសាស្ត្រកម្ពុជា ឆ្នាំ២០០៨**

**ការចិញ្ចឹមកូនដោយទឹកដោះម្ដាយ និងអាហារ**

| អាយុជាខែ | មិនបំបៅដោះ | បៅដោះតែមួយមុខ | ទឹក | ទឹកផ្លែឈើ | ទឹកដោះគោ | អាហារបន្ថែម | សរុប | បន្តចិញ្ចឹមកូនដោយទឹកដោះម្ដាយ | ចំនួនសរុប |
|---|---|---|---|---|---|---|---|---|---|
| 0 - 3 | 5.4 | 74.3 | 11.3 | 0.3 | 4.0 | 4.9 | 100.0 | 94.6 | 616 |
| 0 - 5 | 5.8 | 65.9 | 12.1 | 0.7 | 3.3 | 12.2 | 100.0 | 94.3 | 929 |
| 6 - 9 | 10.7 | 3.5 | 8.7 | 1.2 | 0.2 | 75.7 | 100.0 | 89.3 | 673 |
| 12 - 15 | 19.0 | 0.3 | 1.0 | 0.0 | 0.0 | 79.6 | 100.0 | 81.0 | 783 |
| 12 - 23 | 35.5 | 0.2 | 0.9 | 0.0 | 0.1 | 63.3 | 100.0 | 64.5 | 2058 |
| 20 - 23 | 53.0 | 0.0 | 0.9 | 0.0 | 0.2 | 45.9 | 100.0 | 47.0 | 590 |

អត្រានៃការចិញ្ចឹមកូនដោយទឹកដោះម្ដាយតែមួយមុខគត់របស់ទារក ឬកុមារតូចអាយុពី ០ ទៅ ៥ ខែ នៅក្នុងប្រទេសកម្ពុជាទាំងមូល មានចំនួន ៦៥.៩ ភាគរយ ។ មូលហេតុសំខាន់ចំនួនពីរដែលធ្វើឱ្យអត្រានៃការបំបៅកូនដោយទឹកដោះម្ដាយតែមួយមុខមិនខ្ពស់នោះ គឺដោយសារតែម្ដាយបានចាប់ផ្ដើមផ្ដល់ទឹកដល់ទារកក្នុងអំឡុងពេលខែដំបូងនៃកំណើត និងការផ្ដល់នូវអាហារបន្ថែមឆាប់ពេកដល់ទារក ឬកុមារតូចក្នុងចន្លោះអាយុពី ៣ ទៅ ៥ ខែ ។ សម្រាប់ប្រទេសកម្ពុជាទាំងមូល អង្កេតបានបង្ហាញថា ស្ទើរតែ

កុមារទាំងអស់ (៩១.៥ ភាគរយ) ត្រូវបានចិញ្ចឹមដោយវិធីសាស្ត្រការបំបៅកូនដោយទឹកដោះតែមួយមុខ សម្រាប់ខែដំបូងនៃជីវិត ។

ក្នុងចំណោមកុមារតូចអាយុតិចជាងគេចាប់ពី ០ ទៅ ៥ ខែ ក្នុងកម្រិតប្រទេសមានស្ទើរតែ ៣ភាគ៤ រស់នៅតំបន់ទីជនបទ និងមាន ២ភាគ៥ រស់នៅតំបន់ទីប្រជុំជន (អត្រានេះមានការថយចុះពី ៤៨.៥ ភាគរយ នៅឆ្នាំ២០០៥ មកនៅត្រឹមតែ ៤០.៣ ភាគរយក្នុងឆ្នាំ២០០៨) ។ ការធ្លាក់ចុះនូវអត្រានៃការចិញ្ចឹមកូនដោយទឹកដោះម្តាយតែមួយមុខគត់ក្នុងតំបន់ទីប្រជុំជន គឺទំនងទំនោរទៅរកការប្រើប្រាស់ផលិតផលម្សៅទឹកដោះគោ និងការធ្វើនគរូបនីយកម្មជាមួយកំណើននៃការចូលរួមរបស់ស្ត្រីក្នុងការងារពលកម្ម ។

**រូបភាពលេខ ២៧ : ស្ថានភាពបំបៅកូនដោយទឹកដោះម្តាយនាពេលបច្ចុប្បន្នសម្រាប់កុមារអាយុតិចជាងគេគិតជាអាយុតាមខែដោយអង្កេតមនុស្សសាស្ត្រកម្ពុជា ឆ្នាំ២០០៨**




ចាប់តាំងពីឆ្នាំ២០០០មក ការចិញ្ចឹមកូនដោយទឹកដោះម្តាយតែមួយមុខគត់ មានការរីកចម្រើនយ៉ាងឆាប់រហ័ស ។ យ៉ាងណាមិញ ដោយសារតែមានការផ្លាស់ប្តូរនូវសំណួរខ្លះៗក្នុង អ.ប្រ.ស.ក ២០០៥ ដើម្បីឱ្យស៊ីគ្នានឹងសំណួរក្នុង អ.ម.ក ឆ្នាំ២០០៨ នោះតួលេខនៃការចិញ្ចឹមកូនដោយទឹកដោះម្តាយតែមួយមុខគត់របស់ អ.ប្រ.ស.ក ឆ្នាំ២០០០ មាន ៤៧ ភាគរយ ហើយតួលេខនេះបន្តរីកចម្រើនក្នុងឆ្នាំ២០០៥ (៦០ភាគរយ) និងឆ្នាំ២០០៨បានកើនឡើងចំនួន ៦ អត្រាភាគរយ បន្ថែមទៀត (៦៦ភាគរយ) ធៀបនឹងឆ្នាំ២០០៥ ។ ការកើនឡើងនេះ មួយផ្នែកគឺដោយសារតែម្តាយបានកាត់បន្ថយនូវ

ការផ្តល់ទឹកដល់ទារក និងមួយផ្នែកធំទៀត គឺដោយសារតែកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ក៏ដូចជា អង្គការពាក់ព័ន្ធនឹងកម្មវិធីជម្រុញការចិញ្ចឹមកូនដោយទឹកដោះម្តាយតែមួយមុខគត់ក្នុងអំឡុងពេលនៃកំណើត និងក្នុង ៦ ខែ ដំបូងនៃជីវិត ។

តារាងលេខ ២៩ : ស្ថានភាពនៃការចិញ្ចឹមកូនដោយទឹកដោះម្តាយ និងអាហារតាមទីកន្លែងរស់នៅ

**ភាគរយទារក ឬកុមារតូចអាយុតិចជាងគេ (០ ទៅ ៥ ខែ) ដែលកំពុងរស់នៅជាមួយម្តាយទៅតាមស្ថានភាពបៅដោះម្តាយ និងភាគរយនៃការបំបៅកូនដោយទឹកដោះដោយម្តាយទៅតាមកន្លែងរស់នៅ ដោយអង្កេតមនុស្សសាស្ត្រកម្ពុជា ឆ្នាំ២០០៨**

**ការចិញ្ចឹមកូនដោយទឹកដោះម្តាយ និងអាហារ**

| កន្លែងរស់នៅ | មិនបំបៅដោះម្តាយ | បៅដោះម្តាយតែមួយមុខ | ទឹក | ទឹកក្រូចច្របាច់ | ទឹកដោះគោ | អាហារបន្ថែម | សរុប | បន្តចិញ្ចឹមកូនដោយទឹកដោះម្តាយ | ចំនួនសរុប |
|---|---|---|---|---|---|---|---|---|---|
| ប្រជុំជន | 18.2 | 40.3 | 17.3 | 0.4 | 5.3 | 18.6 | 100.0 | 81.8 | 149 |
| ជនបទ | 3.3 | 70.8 | 11.2 | 0.8 | 3.9 | 10.9 | 100.0 | 96.7 | 780 |
| សរុប | 5.8 | 65.9 | 12.1 | 0.7 | 3.3 | 12.2 | 100.0 | 94.3 | 929 |

ស្ថានភាពការបំបៅកូនដោយទឹកដោះម្តាយ នៅតាមបណ្តាលំនៅដ្ឋានពុំទាន់រៀបរយនាទីក្រុងភ្នំពេញមានកម្រិតភាគរយប្រហាក់ប្រហែលគ្នា ទៅនឹងបណ្តាទីប្រជុំជនផ្សេងៗក្នុងកម្រិតប្រទេសទាំងមូល ។ ដូច្នេះ គោលនយោបាយអាទិភាពដំបូងបំផុតនោះ គឺលើកកម្ពស់អត្រាបំបៅកូនដោយទឹកដោះម្តាយតែមួយមុខឱ្យបានលើសលុប និងត្រឹមត្រូវ ។

## តារាងលេខ ៣០ : ស្ថានភាពចិញ្ចឹមកូនដោយទឹកដោះម្តាយ និងអាហារតាមបណ្តាលំនៅដ្ឋានមិនទាន់រៀបរយនានានៅទីក្រុងភ្នំពេញ

ភាគរយរបស់កុមារដែលមានអាយុតិចជាងគេបង្អស់គិតតាមខែដែលកំពុងរស់នៅជាមួយម្តាយក្នុងលំនៅដ្ឋាន មិនទាន់រៀបរយនាទីក្រុងភ្នំពេញ តាមស្ថានភាពចិញ្ចឹមកូនដោយទឹកដោះម្តាយ និងភាគរយបំបៅកូនដោយទឹកដោះម្តាយនាពេលបច្ចុប្បន្ន ដោយអង្កេតមនុស្សមាត្រកម្ពុជា ឆ្នាំ២០០៨

| **អាយុគិតជាខែ** | មិនចិញ្ចឹមដោយទឹកដោះម្តាយ | បៅទឹកដោះម្តាយតែមួយមុខ | ទឹកសុទ្ធ | ទឹកក្រូចច្របាច់ | ទឹកដោះគោ | អាហារបន្ថែម | សរុប | ចិញ្ចឹមកូនដោយទឹកដោះម្តាយនាពេលបច្ចុប្បន្ន | ចំនួនកុមារដែលមានអាយុតិចជាងគេបង្អស់ |
|---|---|---|---|---|---|---|---|---|---|
| 0 - 5 | 18.7 | 37.6 | 19.2 | 0.0 | 7.9 | 16.7 | 100.0 | 81.3 | 42 |
| 12 - 23 | 53.1 | 2.5 | 0.0 | 0.0 | 0.0 | 44.4 | 100.0 | 46.9 | 93 |

# ជំពូកទី៨

# សេវាសុខភាពអាហារូបត្ថម្ភ

## ១. ការផ្តល់បន្ថែមគ្រាប់ថ្នាំវីតាមីនអា ដល់កុមារ និងការទម្លាក់ព្រូនសម្រាប់កុមារ

មូលហេតុចម្បងដែលនាំឱ្យមានជម្ងឺ និងការស្លាប់ក្នុងវ័យកុមារភាព គឺបណ្តាលមកពីកង្វះមីក្រូសារជាតិធ្ងន់ធ្ងរ ។ កុមារអាចទទួលបានមីក្រូសារជាតិគ្រប់គ្រាន់ពីអាហារផ្សេងៗ ទាំងអាហារដែលមានបញ្ចូលជីវជាតិ និងអាហារដែលផ្តល់ដោយផ្ទាល់ ។ ជាទូទៅជីវជាតិអា គឺជាមីក្រូសារជាតិសំខាន់សម្រាប់ភាពស៊ាំទប់ទល់នឹងជម្ងឺ និងដើរតួនាទីសំខាន់ក្នុងការថែរក្សាស្រទាប់ជាលិកាវាងកាយ ។ បញ្ហាកង្វះជីវជាតិអាធ្ងន់ធ្ងរ អាចបង្កឱ្យកុមារមានជម្ងឺខ្វាក់មាន់ក្នុងអត្រាមួយខ្ពស់ ។

សម្រាប់កុមារ ការផ្តល់នូវគ្រាប់ថ្នាំជីវជាតិអា និងគ្រាប់ថ្នាំទម្លាក់ព្រូនមានធ្វើនៅតាមមណ្ឌលសុខភាព តាមការធ្វើសកម្មភាពចុះផ្តល់សេវាដល់មូលដ្ឋាន និងតាមសាលារៀន ។ សកម្មភាពផ្តល់បន្ថែមគ្រាប់ថ្នាំជីវជាតិអា និងគ្រាប់ថ្នាំទម្លាក់ព្រូនត្រូវបានអនុវត្តជារៀងរាល់ ៦ ខែ ម្តង ដើម្បីធានាកាត់បន្ថយនូវហានិភ័យ ក៏ដូចជាភាពងាយរងគ្រោះរបស់កុមារ ។ តារាងលេខ ៣១ បង្ហាញពីភាគរយនៃកុមារ អាយុតិចជាងគេក្នុងចំណោមកុមារដែលមានអាយុចាប់ពី ៦ ទៅ ៥៩ ខែ កំពុងរស់នៅជាមួយម្តាយ ហើយបានទទួលការផ្តល់គ្រាប់ថ្នាំជីវជាតិអាបន្ថែម និងថ្នាំទម្លាក់ព្រូនក្នុងកំឡុងពេល ៦ ខែ មុនអង្កេត ។

រាល់ព័ត៌មាន និងទិន្នន័យ គឺបានមកពីការសម្ភាសន៍ជាមួយម្តាយរបស់កុមារ ។ ដូច្នេះ ការទទួលបាននូវគ្រាប់ថ្នាំជីវជាតិអារបស់កុមារដែលមានអាយុពី ៦ ទៅ ៥៩ ខែ មានចំនួន ៥៩.៤ ភាគរយ ។ មានតែម្នាក់ប៉ុណ្ណោះក្នុងចំណោមកុមារ ៨ នាក់ (ឆ្លើយដោយម្តាយ) មិនបានដឹងលឺពីគ្រាប់ថ្នាំជីវជាតិអានេះទេ ។ ចំនួននេះ គឺទាបជាងការរកឃើញក្នុងឆ្នាំ២០០៥ ដោយ អ.ប្រ.ស.ក ប៉ុន្តែបង្កនូវផលប៉ះពាល់ខ្លាំង សម្រាប់ព្យាករណ៍នូវចំនួនពិត ។

ថ្វីត្បិតតែទីក្រុងភ្នំពេញ ក៏ដូចជាតំបន់ទីប្រជុំជនដ៏ទៃទៀត សំបូរទៅដោយមណ្ឌលសុខភាព ការផ្សព្វផ្សាយចំណេះដឹងផ្នែកសុខភាព ។ល។ ក៏ប៉ុន្តែចំនួននៃការទទួលបានគ្រាប់ថ្នាំជីវជាតិអា នៅមានអត្រាទាបត្រឹមតែ ២២.២ ភាគរយ ប៉ុណ្ណោះ ហើយដំណាលគ្នានោះមាន ៦៨.៩ ភាគរយ មិនបានដឹងលឺពី គ្រាប់ថ្នាំជីវជាតិអាទេ ។ អត្រានេះមានន័យថា ក្រុមគ្រួសាររបស់កុមារដែលមានជីវភាពខ្សត់ខ្សោយ និងរស់នៅតាមតំបន់ជនបទច្រើនជាង ៦០ ភាគរយ មានភាពប្រសើរជាងប្រជាជនដែលមានកម្រិតជីវភាពសមរម្យ និងគ្រប់គ្រាន់ និងរស់នៅក្នុងតំបន់ប្រជុំជនក្នុងការទទួលបាននូវសេវាផ្តល់បន្ថែមគ្រាប់ថ្នាំជីវជាតិអាទេវិញ ។

## តារាងលេខ ៣១ : សេវាសុខភាពសម្រាប់កុមារតាមលក្ខណៈប្រវត្តិផ្សេងៗ

ភាគរយកុមារដែលមានអាយុតិចជាងគេបង្អស់ក្នុងចំណោមក្មេងអាយុចាប់ពី ៦ ទៅ ៥៩ ខែ កំពុងរស់នៅជាមួយម្តាយ ដែលបានទទួលបន្ថែមគ្រាប់ថ្នាំជីវជាតិអា និងទទួលថ្នាំទម្លាក់ព្រូន ក្នុងអំឡុងពេល ៦ ខែ មុនអង្កេត តាមលក្ខណៈប្រវត្តិផ្សេងៗ ដោយអង្កេតមនុស្សសាស្ត្រកម្ពុជា ឆ្នាំ២០០៨

| លក្ខណៈប្រវត្តិផ្សេងៗ | **គ្រាប់ថ្នាំជីវជាតិ** | | | **ថ្នាំទម្លាក់ព្រូន** | | |
|---|---|---|---|---|---|---|
| | ភាគរយ ទទួលបាន គ្រាប់ថ្នាំ ជីវជាតិអា | ភាគរយ មិនដឹង | ចំនួនកុមារ | ភាគរយ ទទួលបាន ថ្នាំទម្លាក់ព្រូន | ភាគរយ មិនដឹង | ចំនួនកុមារ |
| **អាយុគិតជាខែ** | | | | | | |
| 6 - 11 | 59.3 | 7.2 | 1006 | n/a | n/a | n/a |
| 12 - 23 | 65.4 | 10.5 | 1891 | 32.9 | 0.4 | 1891 |
| 24 - 35 | 59.2 | 15.5 | 1286 | 41.7 | 1.3 | 1286 |
| 36 - 47 | 54.0 | 16.4 | 980 | 47.3 | 0.5 | 980 |
| 48 - 59 | 51.6 | 16.3 | 741 | 44.8 | 2.4 | 741 |
| **តំបន់រស់នៅ** | | | | | | |
| ទីប្រជុំជន | 43.4 | 36.5 | 1000 | 26.9 | 0.4 | 849 |
| ទីជនបទ | 62.6 | 7.9 | 4906 | 42.7 | 1.1 | 4051 |
| **ឈ្មោះខេត្ត** | | | | | | |
| បន្ទាយមានជ័យ | 81.8 | 4.0 | 271 | 38.2 | 0.0 | 218 |
| កំពង់ចាម | 70.7 | 0.8 | 781 | 32.4 | 0.0 | 633 |
| កំពង់ឆ្នាំង | 73.6 | 0.9 | 234 | 27.9 | 0.6 | 188 |
| កំពង់ស្ពឺ | 72.7 | 1.1 | 370 | 42.1 | 6.0 | 310 |
| កំពង់ធំ | 60.9 | 13.3 | 171 | 54.2 | 0.0 | 135 |
| កណ្តាល | 67.3 | 4.2 | 487 | 42.1 | 0.4 | 418 |
| ក្រចេះ | 49.4 | 6.0 | 133 | 28.1 | 1.5 | 110 |
| ភ្នំពេញ | 22.2 | 68.9 | 575 | 14.7 | 0.9 | 499 |
| ព្រៃវែង | 74.3 | 0.6 | 451 | 63.8 | 0.5 | 375 |
| ពោធិសាត់ | 57.6 | 17.6 | 158 | 50.3 | 0.0 | 127 |
| សៀមរាប | 41 | 26 | 474 | 33.6 | 1.2 | 402 |
| ស្វាយរៀង | 67.6 | 1.9 | 223 | 58.2 | 0.0 | 170 |
| តាកែវ | 62.1 | 12 | 441 | 41.4 | 1.1 | 385 |
| ឧត្តរមានជ័យ | 50.4 | 5.7 | 66 | 33.2 | 0.1 | 52 |
| បាត់ដំបង/ប៉ៃលិន | 49.7 | 1.6 | 498 | 54.5 | 1.3 | 403 |

| | | | | | | |
|---|---|---|---|---|---|---|
| កំពត/កែប | 64.1 | 13.5 | 219 | 37.9 | 0.9 | 176 |
| ព្រះសីហនុ/កោះកុង | 71.7 | 2.0 | 142 | 47.8 | 0.2 | 116 |
| ព្រះវិហារ/ស្ទឹងត្រែង | 51.8 | 19.5 | 124 | 55.9 | 1.7 | 110 |
| មណ្ឌលគិរី/រតនគិរី | 36.2 | 0.4 | 80 | 17.1 | 0.0 | 65 |
| **កម្រិតជនបទ** | | | | | | |
| ក្របំផុត | 58.9 | 6.6 | 1100 | 38.7 | 0.3 | 893 |
| ក្រ | 63.6 | 7.2 | 1061 | 42.1 | 0.3 | 872 |
| មធ្យម | 62.7 | 7.3 | 1216 | 40.6 | 1.2 | 1011 |
| មាន | 61.3 | 10.2 | 1220 | 42.4 | 1.9 | 1022 |
| មានបំផុត | 51.4 | 29.9 | 1301 | 36.2 | 1.1 | 1094 |

យ៉ាងណាមិញ ម្តាយរបស់កុមារមិនត្រូវបានសួរនាំអំពីខែណាមួយ ដែលកុមារបានទទួលគ្រាប់ថ្នាំទម្លាក់ព្រូននោះទេ ទោះបីជាសូចនាករនៃការផ្តល់ថ្នាំទម្លាក់ព្រូនរបស់កុមារត្រូវបានបញ្ចូលក្នុងតារាងជាមួយការផ្តលបន្ថែម់គ្រាប់ថ្នាំជីវជាតិអា ក៏ដោយ ។ ហេតុដូច្នេះហើយ បានជាលទ្ធផលនៃអត្រាទទួលគ្រាប់ថ្នាំជីវជាតិអា និងថ្នាំទម្លាក់ព្រូនមិនអាចប្រៀបធៀបគ្នាបាន ។ ក្នុងតារាងខាងក្រោមនេះ បង្ហាញថា ក្នុងរយៈពេល ៦ ខែ កន្លងមកមានតែ ៣៩.៩ ភាគរយ ប៉ុណ្ណោះក្នុងចំណោមកុមារដែលមានអាយុចាប់ពី ៦ ទៅ ៥៩ ខែ បានទទួលគ្រាប់ថ្នាំទម្លាក់ព្រូន ។ អត្រានៅតំបន់ជនបទ គឺនៅតែខ្ពស់ជាងតំបន់ទីប្រជុំជនក្នុងសមាមាត្រ ៤២.៧ ភាគរយ ទល់នឹង ២៦.៩ ភាគរយ ។ ក៏ប៉ុន្តែកម្មវិធីអន្តរាគមន៍ផ្នែកសុខភាព គឺច្រើនតែផ្តោតលើកុមារដែលមានអាយុច្រើនជាង ១២ ខែ ។ ជាលទ្ធផល អ.ម.ក ឆ្នាំ២០០៨ មិនបានរកឃើញនូវលទ្ធផលរបស់ក្រុមទារកអាយុពី ៦ ទៅ ១១ ខែ នោះទេ ។

## ២. ការផ្តល់បន្ថែមគ្រាប់ថ្នាំជាតិដែក ដល់មាតា ការទម្លាក់ព្រូនសម្រាប់ស្ត្រីគំឡុងពេលមានផ្ទៃពោះ និង ការផ្តល់បន្ថែមគ្រាប់ថ្នាំជីវជាតិអា ក្រោយពេលសម្រាល

ការទទួលទានមីក្រូសារជាតិគ្រប់គ្រាន់ អាចផ្តល់អត្ថប្រយោជន៍ជាច្រើនដល់ស្ត្រី ។ ដូចគ្នានេះដែរការផ្តល់គ្រាប់ថ្នាំជាតិដែកដល់ស្ត្រីមានផ្ទៃពោះ បានជួយការពារមាតា និងទារកប្រឆាំងនឹងភាពស្លេកស្លាំងបណ្តាលមកពីកង្វះជាតិដែក ។ ដូច្នេះ អ.ប្រ.ស.ក ២០០៥ បានបង្ហាញឱ្យឃើញថា ការពិនិត្យផ្ទៃពោះមុនពេលសម្រាលឱ្យបាន ៤ ដង ជាមួយនឹងការទទួលគ្រាប់ថ្នាំជាតិដែកហ្វូលិកចំនួន

៩០ គ្រាប់ (សម្រាប់រយៈពេល ៩០ថ្ងៃ) ជាមធ្យោបាយប្រសើរសម្រាប់កាត់បន្ថយនូវអត្រាកើនឡើងនៃភាពស្លេកស្លាំង បណ្ដាលមកពីកង្វះជាតិដែក ។ ក្នុងនោះ ៣១ ភាគរយ នៃស្ត្រីមានផ្ទៃពោះបានទទួលទានគ្រាប់ថ្នាំជាតិដែកតិចជាង ៦០ ថ្ងៃ ។

អង្កេតមនុស្សមាត្របានបង្ហាញថា ស្ត្រីជាម្ដាយប្រហែល ៣៩.៥ ភាគរយ បានទទួលគ្រាប់ថ្នាំជាតិដកហ្វូលិក ចំនួន ៩០ គ្រាប់ ឬលើសពីចំនួននេះ និងមាន ៣១.៤ ភាគរយ បានទទួលគ្រាប់ថ្នាំទម្លាក់ព្រូនក្នុងកំឡុងពេលមានផ្ទៃពោះលើកចុងក្រោយ ។ ដូចគ្នានោះដែរ គ្រប់ស្ត្រីទាំងអស់ដែលបានទទួលបន្ថែមគ្រាប់ថ្នាំជីវជាតិអាអំឡុងពេល ៦ សប្ដាហ៍ ក្រោយពេលសម្រាលកូន មានចំនួនប្រមាណ ៤៣.៧ ភាគរយ ហើយ ៣៣.២ ភាគរយ បានទទួលផងដែរនូវគ្រាប់ថ្នាំជាតិដែកហ្វូលិកក្រោយពេលសម្រាល ។ សំណួរសម្រាប់ការផ្ដល់គ្រាប់ថ្នាំជីវជាតិអាបន្ថែម ក្រោយពេលសម្រាលកូនរបស់អង្កេតឆ្នាំ ២០០៨ គឺមានលក្ខណៈខុសគ្នាបន្តិចត្រង់ថា គោលនយោបាយត្រូវបានផ្លាស់ប្ដូរ ។ ពេលវេលាផ្ដល់គ្រាប់ថ្នាំជាតិដែកហ្វូលិក បានកាត់បន្ថយពីរយៈពេល ២ ខែ មកនៅត្រឹម ៦ សប្ដាហ៍ ។ ប៉ុន្តែទោះបីជាមានការកាត់បន្ថយពេលវាលាក៏ដោយ ក៏មិនបានធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរលើសូចនាករផ្សេងៗដែរ ។

ដោយប្រៀបធៀបជាមួយនឹង អ.ប្រ.ស.ក ឆ្នាំ២០០៥ នោះអង្កេតឆ្នាំ២០០៨ បង្ហាញនូវការរីកចម្រើនគួរឱ្យកត់សម្គាល់គ្រប់ផ្នែកនៃសូចនាកររបស់សេវាសុខភាពរបស់មាតា ។ ការផ្ដល់គ្រាប់ថ្នាំជាតិដែកហ្វូលិកបន្ថែមមុនពេលសម្រាលចំនួនលើសពី ៩០ គ្រាប់ កើនឡើងអត្រាភាគរយជិត ២២ និងការទម្លាក់ព្រូនបានកើនឡើង ២១ ។ ដូចគ្នានោះដែរ អត្រាភាគរយនៃការផ្ដល់បន្ថែមគ្រាប់ថ្នាំជីវជាតិអាកើនចំនួន ១៦ ហើយអត្រាភាគរយជាតិដែកហ្វូលិកក្រោយពេលសម្រាល គឺបានកើនចំនួន ២២ ។ វឌ្ឍនភាពរីក ចម្រើនទៅមុខនេះ គឺដោយសារការរួមចំណែកពីរដ្ឋាភិបាល និងអង្គការពាក់ព័ន្ធនានាបានបន្តជួយជ្រោមជ្រែងទាំងការផ្សព្វផ្សាយ ក៏ដូចជាផ្ដល់នូវសេវាថែទាំសុខភាពដល់ស្ត្រីមានផ្ទៃពោះសំដៅជួយលើកកម្ពស់កម្រិតការពិនិត្យថែទាំផ្ទៃពោះមុនសម្រាល និងការថែទាំក្រោយពេលសម្រាល ។

## តារាងលេខ ៧២ : សេវាសុខភាពសម្រាប់មាតាតាមលក្ខណៈប្រវត្តិផ្សេងៗ

ភាគរយស្ត្រីគ្រប់រូបដែលមានអាយុចន្លោះពី ១៥ ទៅ ៤៩ ឆ្នាំ ដែលបានទទួលគ្រាប់ថ្នាំជីវជាតិ ៦ សប្តាហ៍ ដំបូងក្រោយពេលផ្តល់កំណើតកូនលើកចុងក្រោយបង្អស់ក្នុងរយៈពេល៥ឆ្នាំកន្លងមក ភាគរយដែលទទួលបានថ្នាំទម្លាក់ព្រូន និងភាគរយទទួលទានជាតិដែកជាគ្រាប់ថ្នាំ ឬស៊ីរ៉ូម តាមលក្ខណៈប្រវត្តិផ្សេងៗ ដោយអង្កេតមនុស្សមាត្រកម្ពុជា ឆ្នាំ២០០៨

| លក្ខណៈប្រវត្តិផ្សេងៗ | **ជីវជាតិអា** | **ទម្លាក់ព្រូន** | | | **ចំនួនថ្ងៃដែលស្ត្រីទទួលទានថ្នាំជាតិដែក ជាគ្រាប់ ឬស៊ីរ៉ូមក្នុងអំឡុងពេលមានផ្ទៃពោះ** | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | ភាគរយទទួលបានគ្រាប់ថ្នាំជីវជាតិអា | ភាគរយទទួលបានថ្នាំទម្លាក់ព្រូន | ភាគរយមិនដឹង | ចំនួនកុមារ | មិនមាន | <60 | 60-89 | >90 | មិនដឹង | ចំនួនកុមារ |
| **អាយុរបស់ស្ត្រី** | | | | | | | | | | |
| 15 - 19 | 36.8 | 31.7 | 0.0 | 179 | 17.9 | 25.9 | 19.0 | 37.1 | 0.0 | 179 |
| 20 - 29 | 45.3 | 33.7 | 1.0 | 3970 | 11.7 | 24.0 | 20.4 | 42.7 | 1.3 | 3970 |
| 30 - 39 | 42.3 | 29.0 | 1.4 | 2023 | 17.6 | 27.6 | 18.6 | 35.0 | 1.3 | 2023 |
| 40 - 49 | 40.7 | 25.0 | 1.3 | 636 | 23.6 | 22.3 | 18.0 | 34.8 | 1.3 | 636 |
| **តំបន់រស់នៅ** | | | | | | | | | | |
| ទីប្រជុំជន | 60.0 | 20.8 | 1.1 | 1141 | 8.7 | 25.1 | 34.2 | 31.5 | 0.5 | 4148 |
| ទីជនបទ | 40.4 | 33.6 | 1.1 | 5667 | 16.0 | 24.9 | 16.6 | 41.1 | 1.4 | 5677 |
| **ឈ្មោះខេត្ត** | | | | | | | | | | |
| បន្ទាយមានជ័យ | 44.2 | 51.7 | 0.9 | 317 | 7.0 | 9.6 | 7.4 | 76.0 | 0.0 | 318 |
| កំពង់ចាម | 42.0 | 17.4 | 0.2 | 897 | 17.9 | 41.7 | 11.6 | 28.8 | 0.0 | 897 |
| កំពង់ឆ្នាំង | 34.1 | 36.9 | 1.6 | 275 | 12.1 | 36.7 | 19.4 | 29.5 | 2.4 | 276 |
| កំពង់ស្ពឺ | 28.5 | 38.0 | 5.1 | 434 | 11.0 | 18.9 | 21.8 | 48.3 | 0.0 | 437 |
| កំពង់ធំ | 25.3 | 37.6 | 0.0 | 193 | 24.1 | 16.0 | 14.7 | 44.1 | 1.1 | 194 |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| កណ្ដាល | 30.6 | 17.4 | 1.3 | 560 | 15.4 | 30.4 | 21.3 | 29.7 | 3.2 | 561 |
| ក្រចេះ | 50.6 | 33.5 | 0.4 | 161 | 23.8 | 29.1 | 15.0 | 31.7 | 0.5 | 162 |
| ភ្នំពេញ | 85.9 | 8.3 | 1.7 | 660 | 4.9 | 26.0 | 52.8 | 15.9 | 0.3 | 665 |
| ព្រៃវែង | 56.5 | 56.2 | 0.0 | 518 | 8.8 | 13.5 | 14.6 | 63.0 | 0.0 | 520 |
| ពោធិសាត់ | 47.1 | 65.1 | 1.5 | 184 | 7.9 | 10.7 | 15.3 | 65.6 | 0.6 | 185 |
| សៀមរាប | 30.5 | 21.5 | 0.2 | 562 | 27.5 | 19.7 | 15.3 | 34.0 | 3.5 | 563 |
| ស្វាយរៀង | 38.5 | 36.0 | 0.7 | 255 | 5.8 | 17.2 | 24.9 | 50.9 | 1.1 | 256 |
| តាកែវ | 44.8 | 28.9 | 2.0 | 479 | 5.5 | 29.8 | 18.2 | 45.4 | 1.1 | 480 |
| ឧត្តរមានជ័យ | 38.8 | 41.4 | 0.8 | 84 | 25.4 | 18.0 | 13.5 | 42.9 | 0.3 | 84 |
| បាត់ដំបង/ប៉ៃលិន | 44.3 | 41.8 | 0.5 | 564 | 17.2 | 24.8 | 14.8 | 41.9 | 1.3 | 566 |
| កំពត/កែប | 32.0 | 35.2 | 1.5 | 246 | 18.7 | 20.8 | 11.6 | 42.0 | 7.0 | 250 |
| ព្រះសីហនុ/កោះកុង | 30.0 | 30.2 | 0.9 | 171 | 26.8 | 20.8 | 12.9 | 38.9 | 0.6 | 172 |
| ព្រះវិហារ/ស្ទឹងត្រែង | 55.0 | 59.0 | 0.7 | 141 | 21.4 | 22.8 | 25.2 | 28.8 | 1.8 | 142 |
| មណ្ឌលគិរី/រតនគិរី | 16.6 | 17.8 | 0.6 | 98 | 40.8 | 28.0 | 13.4 | 17.4 | 0.3 | 98 |
| **កម្រិតធនធាន** | | | | | | | | | | |
| ក្របំផុត | 39.5 | 32.0 | 0.4 | 1315 | 23.4 | 25.2 | 15.4 | 34.5 | 1.5 | 1316 |
| ក្រ | 37.9 | 33.6 | 0.5 | 1224 | 19.8 | 25.2 | 15.0 | 38.6 | 1.3 | 1228 |
| មធ្យម | 41.1 | 33.1 | 1.0 | 1389 | 15.8 | 27.0 | 15.5 | 41.0 | 0.6 | 1392 |
| មាន | 42.1 | 32.3 | 1.6 | 1401 | 11.1 | 25.3 | 20.1 | 41.7 | 1.8 | 1407 |
| មានបំផុត | 56.5 | 26.7 | 1.9 | 1467 | 5.5 | 22.3 | 30.4 | 40.6 | 1.2 | 1473 |
| **សរុប** | **43.7** | **31.4** | **1.1** | **6809** | **14.7** | **24.9** | **19.6** | **39.5** | **1.3** | **6809** |

## ៣.	ការពិនិត្យថែទាំផ្ទៃពោះមុនពេលសម្រាល

សម្រាប់សេវាសុខភាពអាហារូបត្ថម្ភរបស់ស្ត្រី (ការផ្តល់គ្រាប់ថ្នាំជាតិដែកហ្វូលិកបន្ថែម ការផ្តល់ថ្នាំទម្លាក់ព្រូនកំឡុងពេលមានផ្ទៃពោះ និងការផ្តល់គ្រាប់ថ្នាំជីវជាតិអាបន្ថែម) ដែលបានវាស់វែងដោយអង្កេតមនុស្សមាត្រ គឺត្រូវបានផ្តល់ឱ្យតាមរយៈការពិនិត្យថែទាំផ្ទៃពោះមុនសម្រាល និងការថែទាំទារកក្រោយសម្រាលនៅឯមណ្ឌលសុខភាព ។ ជាលទ្ធផលក្រោយពីអង្កេត ស្ត្រីជាម្តាយមានចំនួន ៤៧ ភាគរយ បានទទួលនូវការពិនិត្យថែទាំផ្ទៃពោះបានចំនួន ៤ ដង និងសម្រាប់ការមានផ្ទៃពោះលើកចុងក្រោយបានកើនឡើងពី ២៧ ភាគរយ ពីឆ្នាំ២០០៥ ។

**តារាងលេខ ៣៣ : ចំនួនស្ត្រីដែលបាននៅពិនិត្យថែទាំផ្ទៃពោះមុនពេលសម្រាល**

ភាគរយស្ត្រីគ្រប់រូបដែលបានផ្តល់កំណើតកូនក្នុងរយៈពេល ៥ ឆ្នាំ ចុងក្រោយ មុនពេលអង្កេតតាមចំនួនទៅមណ្ឌលសុខភាពសម្រាប់ការពិនិត្យផ្ទៃពោះមុនពេលសម្រាល ដោយអង្កេតមនុស្សមាត្រកម្ពុជា ឆ្នាំ២០០៨

| លក្ខណៈប្រវត្តិផ្សេងៗ | គ្មាន | ១ដង | ២-៣ដង | លើសពី៤ដង | មិនដឹង | ចំនួនស្ត្រី |
|---|---|---|---|---|---|---|
| **អាយុរបស់មាតា** | | | | | | |
| 15 - 19 | 7.20 | 13.20 | 36.10 | 43.50 | - | 179 |
| 20 - 29 | 8.20 | 5.90 | 34.20 | 51.20 | 0.50 | 3970 |
| 30 - 39 | 14.20 | 7.00 | 35.90 | 42.60 | 0.30 | - |
| 40 - 49 | 18.90 | 6.10 | 36.30 | 37.80 | 1.00 | 636 |
| **តំបន់រស់នៅ** | | | | | | |
| ទីប្រជុំជន | 3.2 | 2.4 | 21.0 | 73.0 | 0.4 | 1148 |
| ទីជនបទ | 12.6 | 7.2 | 37.8 | 41.9 | 0.5 | 5677 |
| **ឈ្មោះខេត្ត** | | | | | | |
| បន្ទាយមានជ័យ | 6.6 | 3.7 | 33.9 | 55.8 | - | 317 |
| កំពង់ចាម | 11.2 | 7.6 | 42.4 | 38.4 | 0.3 | 897 |
| កំពង់ឆ្នាំង | 9.0 | 6.8 | 30.8 | 53.4 | - | 276 |
| កំពង់ស្ពឺ | 10.4 | 5.2 | 39.5 | 44.2 | 0.7 | 436 |
| កំពង់ធំ | 20.0 | 8.9 | 35.0 | 35.6 | 0.5 | 193 |
| កណ្តាល | 9.4 | 4.6 | 36.3 | 48.7 | 1.0 | 560 |
| ក្រចេះ | 23.3 | 12.0 | 44.2 | 20.5 | - | 162 |
| ភ្នំពេញ | 2.6 | 2.7 | 17.5 | 76.9 | 0.2 | 665 |
| ព្រៃវែង | 12.7 | 13.0 | 47.6 | 26.7 | - | 519 |
| ពោធិសាត់ | 5.9 | 3.0 | 32.4 | 58.1 | 0.6 | 185 |
| សៀមរាប | 12.2 | 5.7 | 31.2 | 50.3 | 0.6 | 562 |

| | | | | | | |
|---|---|---|---|---|---|---|
| ស្វាយរៀង | 5.3 | 5.2 | 32.6 | 56.4 | 0.6 | 255 |
| តាកែវ | 6.3 | 3.9 | 43.4 | 45.9 | 0.5 | 479 |
| ឧត្តរមានជ័យ | 20.2 | 11.1 | 32.1 | 35.2 | 1.4 | 84 |
| បាត់ដំបង/ប៉ៃលិន | 15.6 | 6.2 | 22.0 | 55.8 | 0.3 | 566 |
| កំពត/កែប | 18.1 | 7.3 | 38.6 | 35.2 | 0.7 | 249 |
| ព្រះសីហនុ/កោះកុង | 17.7 | 8.6 | 24.5 | 47.2 | 2.0 | 172 |
| ព្រះវិហារ/ស្ទឹងត្រែង | 4.4 | 10.4 | 56.8 | 28.0 | 0.4 | 142 |
| មណ្ឌលគីរី/រតនគីរី | 39.2 | 5.4 | 33.6 | 21.7 | - | 98 |
| **កម្រិតធនធាន** | | | | | | |
| ក្របំផុត | 20.4 | 9.3 | 40.7 | 29.1 | 0.5 | 1316 |
| ក្រ | 17.3 | 7.3 | 38.2 | 36.7 | 0.6 | 1227 |
| មធ្យម | 11.2 | 7.6 | 38.2 | 42.8 | 0.3 | 1391 |
| មាន | 6.8 | 5.4 | 34.2 | 53.1 | 0.5 | 1406 |
| មានបំផុត | 1.4 | 3.0 | 24.9 | 70.3 | 0.4 | 1472 |
| **សរុប** | **11.0** | **6.4** | **34.9** | **47.2** | **0.4** | **6826** |

## ៤. ការប្រើប្រាស់អំបិលអ៊ីយ៉ូដគ្រួសារ

ជាតិអ៊ីយ៉ូដ គឺជារ៉ែធម្មជាតិ និងជាមីក្រូសារជាតិសំខាន់មួយក្នុងចំណោមសារជាតិទាំងអស់ ។ ការទទួលទានជាតិអ៊ីយ៉ូដមិនគ្រប់គ្រាន់នៅក្នុងបរិបទនៃបញ្ហាកង្វះមីក្រូសារជាតិ បង្កើតជាហានិភ័យខ្ពស់នៃជម្ងឺពកក និងកុមាររលូតលាស់មិនប្រក្រតីទាំងរាងកាយ និងប្រាជ្ញា ។ល។ ការធ្វើតេស្តកំណត់រកជាតិអ៊ីយ៉ូដក្នុងអំបិលត្រូវបានធ្វើទាំងនៅក្នុង អ.ប្រ.ស.ក ឆ្នាំ២០០៥ និង អ.ម.ក ឆ្នាំ២០០៨ ។ យោងតាមលទ្ធផល អ.ប្រ.ស.ក ឆ្នាំ២០០៥ បានបង្ហាញឱ្យឃើញថា អត្រាប្រើប្រាស់អំបិលអ៊ីយ៉ូដមាន ៧២.៥ ភាគរយ បានកើនឡើងចំនួន ៥ ដង ចាប់តាំងពីឆ្នាំ២០០០ ដែលមានអត្រាត្រឹមតែ ១៤ ភាគរយប៉ុណ្ណោះ ។

ទោះបីជាអំបិលជាតិអ៊ីយ៉ូដគ្របដណ្តប់លើផ្ទៃប្រទេសក្នុងកម្រិតខ្ពស់ក៏ដោយ ក៏យើងឃើញនៅមានខេត្តមួយចំនួនមានបរិមាណ ឬអត្រានៃការប្រើប្រាស់អំបិលអ៊ីយ៉ូដនៅមានកម្រិតទាបជាងគេ ។ ការប្រើប្រាស់អំបិលអ៊ីយ៉ូដសរុបរបស់គ្រួសារ មានចំនួន ៧១.៥ ភាគរយ គឺទាបជាងការរកឃើញនៅក្នុងឆ្នាំ២០០៥ ។

## តារាងលេខ ៣៤ : ការប្រើប្រាស់អំបិលអ៊ីយ៉ូដតាមលក្ខណៈគ្រួសារ

| ភាគរយគ្រួសារដែលត្រូវបានធ្វើការវិភាគរកអំបិលជាតិអ៊ីយ៉ូដ តាមលក្ខណៈប្រវត្តិ ដោយអង្កេតមនុស្សសាស្ត្រកម្ពុជា ឆ្នាំ២០០៨ | | | | |
|---|---|---|---|---|
| លក្ខណៈប្រវត្តិផ្សេងៗ | គ្រួសារប្រើប្រាស់អំបិលជាតិអ៊ីយ៉ូដ | | | |
| | ភាគរយគ្មានជាតិអ៊ីយ៉ូដ | ភាគរយមានជាតិអ៊ីយ៉ូដ | ចំនួនសរុបជាភាគរយ | ចំនួនគ្រួសារ |
| **តំបន់រស់នៅ** | | | | |
| ទីប្រជុំជន | 13.8 | 86.2 | 100.0 | 1220 |
| ទីជនបទ | 31.4 | 68.6 | 100.0 | 6208 |
| **ឈ្មោះខេត្ត** | | | | |
| បន្ទាយមានជ័យ | 22.6 | 77.4 | 100.0 | 368 |
| កំពង់ចាម | 24 | 76 | 100.0 | 1047 |
| កំពង់ឆ្នាំង | 20.5 | 79.5 | 100.0 | 281 |
| កំពង់ស្ពឺ | 21.5 | 78.5 | 100.0 | 471 |
| កំពង់ធំ | 22.7 | 77.3 | 100.0 | 202 |
| កណ្តាល | 34.6 | 65.4 | 100.0 | 655 |
| ក្រចេះ | 16.1 | 83.9 | 100.0 | 170 |
| ភ្នំពេញ | 5.9 | 94.1 | 100.0 | 656 |
| ព្រៃវែង | 34.6 | 65.4 | 100.0 | 580 |
| ពោធិសាត់ | 27.4 | 72.6 | 100.0 | 190 |
| សៀមរាប | 28.3 | 71.7 | 100.0 | 595 |
| ស្វាយរៀង | 77.5 | 22.5 | 100.0 | 288 |
| តាកែវ | 38.2 | 61.8 | 100.0 | 522 |
| ឧត្តរមានជ័យ | 35.7 | 64.3 | 100.0 | 90 |
| បាត់ដំបង/ប៉ៃលិន | 32 | 68 | 100.0 | 591 |
| កំពត/កែប | 53.2 | 46.8 | 100.0 | 278 |
| ព្រះសីហនុ/កោះកុង | 12.3 | 87.7 | 100.0 | 190 |
| ព្រះវិហារ/ស្ទឹងត្រែង | 13.3 | 86.9 | 100.0 | 145 |
| មណ្ឌលគីរី/រតនគីរី | 26.3 | 73.7 | 100.0 | 109 |
| **កម្រិតធនធាន** | | | | |
| ក្របំផុត | 31.4 | 68.6 | 100.0 | 1412 |
| ក្រ | 33.7 | 66.3 | 100.0 | 1347 |
| មធ្យម | 33.4 | 66.6 | 100.0 | 1531 |
| មាន | 28.4 | 71.6 | 100.0 | 1564 |
| មានបំផុត | 16.6 | 83.4 | 100.0 | 1571 |
| **សរុប** | **28.5** | **71.5** | **100.0** | **7428** |

# ជំពូកទី៩

# សេចក្ដីសន្និដ្ឋាន និងអនុសាសន៍

គោលបំណងរបស់ជំពូកនេះ ផ្តល់ការណែនាំអំពីសកម្មភាពសំខាន់ៗ របស់អង្កេតមនុស្សមាត្រកម្ពុជា ឆ្នាំ២០០៨ ។

សកម្មភាពទាំងអស់រួមមាន :

- ណែនាំពីការឆ្លើយតបឱ្យបានសមស្របចំពោះការឡើងថ្លៃទំនិញ
- ណែនាំពីទីកន្លែងណា និងក្រុមណាគួរតែជាគោលដៅសម្រាប់ធ្វើកិច្ចអន្តរាគមន៍ដែលទាក់ទងនឹងផ្នែកអាហារូបត្ថម្ភ
- ណែនាំពីសកម្មភាពអន្តរាគមន៍ដែលទាក់ទងនឹងផ្នែកអាហារូបត្ថម្ភដែលចាំបាច់ត្រូវអនុវត្តន៍

សេចក្តីសន្និដ្ឋាន និងអនុសាសន៍ ផ្អែកលើភស្តុតាងដែលបានមកពី : ការវាស់វែងផ្នែកមនុស្សមាត្រ បញ្ហាកង្វះមីក្រូសារជាតិ ការប្រើប្រាស់អាហារ ជម្ងឺកុមារ យុទ្ធសាស្ត្រដោះស្រាយបន្ទាន់ ការបំបៅដោះ ទារក/កុមារតូច និងសេវាថែទាំសុខភាព ។

## តើមានមធ្យោបាយអ្វី ដើម្បីឆ្លើយតបឱ្យបានសមស្របនៅនឹងការកើនឡើងថ្លៃម្ហូបអាហារ ?

ដោយសារមានបុព្វហេតុផ្សេងៗជាពិសេសតម្រូវការស្បៀងអាហារ ថ្លៃអាហារខ្ពស់ និងទំនិញផ្សេងៗ បានបន្តកើនឡើងគួរឱ្យកត់សម្គាល់ក្នុងឆ្នាំ២០០៨ ។ ក្នុងកាលៈទេសៈនេះ ក្រុមដែលធ្វើការពាក់ពន្ធ័ជាមួយនឹងការងារអាហារូបត្ថម្ភ និងការងារអភិវឌ្ឍន៍អន្តរជាតិ បានសំដែងនូវកង្វល់ស្តីអំពីថ្លៃទំនិញខ្ពស់ អាចជះឥទ្ធិពលអវិជ្ជមាន ដល់ស្ថានភាពអាហារូបត្ថម្ភរបស់កុមារ ។ ជាពិសេសកត្តាអវិជ្ជមាននេះ អាចផ្តល់ផលកាន់តែអាក្រក់នៅក្នុងតំបន់ដែលមានប្រជាជនរស់នៅច្រើន ហើយកំពុងរស់នៅក្រោមបន្ទាត់ភាពក្រីក្រ ។ យ៉ាងណាមិញ រាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍នានាកំពុងបន្តបោះនូវជំហានទៅមុខ សំដៅសម្រាលឥទ្ធិពលនៃតំលៃទំនិញខ្ពស់នេះ ។ ក្នុងពេលដំណាលគ្នានេះ កិច្ចអន្តរាគមន៍ជាច្រើនត្រូវបានបង្កើត និងអនុវត្តន៍ឡើងដោយប្រើប្រាស់នូវព័ត៌មានដែលមានស្រាប់ និងច្បាស់លាស់ ដើម្បីជួយរួមចំណែកក្នុងការកាត់បន្ថយនូវភាពងាយរងគ្រោះរបស់ក្រុមគ្រួសារក្រីក្រឱ្យចំគោលដៅ និងមានប្រសិទ្ធភាព ។

ប៉ុន្តែអង្កេតមនុស្សមាត្រកម្ពុជានេះ គឺជាការអង្កេតថ្នាក់ជាតិលើកទី ១ ដែលបានសិក្សាពីផលប៉ះពាល់ដោយសារតម្លៃទំនិញខ្ពស់ទៅលើស្ថានភាពអាហារូបត្ថម្ភរបស់កុមារ ។ ដូច្នេះ អង្កេតនេះគឺជាគោលដៅមួយក្នុងចំណោមគោលដៅជាច្រើនទៀតរបស់អង្កេតដែលបានបង្កើតឡើង និងធានា

យ៉ាងពិតប្រាដកថា កិច្ចអន្តរាគមន៍ទាំងពេលបច្ចុប្បន្ន និងទាំងពេលអនាគតមានលក្ខណៈសមស្រប សម្រាប់គ្រប់ស្ថានភាព ។

ដើម្បីសម្រេចចិត្តថាតើការឆ្លើយតបប្រភេទអ្វីដែលជាតម្រូវការចាំបាច់ យើងចាំបាច់ត្រូវកំណត់ថាអ្វីជាស្ថានភាពនាពេលបច្ចុប្បន្នជាមុនសិន ។ អង្កេតសាកល្បងរបស់ Integrated Food Security and Humanitarian Phase Classification (IPC) ត្រូវបានធ្វើឡើងក្នុងប្រទេសកម្ពុជា នាឆ្នាំ២០០៧ ហើយអង្កេតនេះទៀតបានកំណត់ថា គ្រប់ខេត្តក្រុងទាំងអស់ទូទាំងប្រទេស មានបញ្ហាអសន្តិសុខស្បៀងរ៉ាំរ៉ៃ លើកលែងតែទីក្រុងភ្នំពេញ និងខេត្តបាត់ដំបងប៉ុណ្ណោះដែលមិនមានជាបញ្ហាចោទ ។ នេះជាមូលហេតុមួយរារាំងដល់កំណើនសេដ្ឋកិច្ចក្នុងតំបន់ជនបទ ។

ផ្ទុយទៅវិញ អង្កេតមនុស្សមាត្រកម្ពុជា ឆ្នាំ២០០៨ ពុំបានប្រើប្រាស់នូវលក្ខណៈវិនិច្ឆ័យរបស់ IPC ទាំងស្រុងនោះទេ ។ ប៉ុន្តែមានសូចនាករខ្លះ (៤ក្នុងចំណោមសូចនាករទាំង១០របស់ IPC) ត្រូវបានរួមបញ្ចូលក្នុងកត្តាសំខាន់៧សម្រាប់សិក្សា និងសង្កត់ធ្ងន់លើការវិភាគនិន្នាការប្រែប្រួលរបស់សូចនាករទាំងឡាយ ។

សូចនាករទាំង ៤ ដែលមាននៅក្នុង IPC ដែលត្រូវបានជ្រើសរើសដាក់បញ្ចូលក្នុង អ.ម.ក ឆ្នាំ២០០៨ មានដូចជា : កង្វះអាហារូបត្ថម្ភខ្សត់ខ្សោយ ជម្ងឺ ប្រភេទអាហារចំរុះ និងយុទ្ធសាស្ត្រដោះស្រាយបន្ទាន់ ។ តារាងលេខ ៣៥ របស់ អ.ម.ក ឆ្នាំ២០០៨ និងការប្រៀបធៀបជាមួយការរកឃើញរបស់ IPC បង្ហាញនូវលក្ខណៈវិន្និច្ឆ័យចំនួន ៣ គឺវិបត្តិអសន្តិសុខស្បៀងអាហារ ស្បៀងអាហារខ្សត់ខ្សោយ និងវិបត្តិរស់នៅ និងជំនួយមនុស្សធម៌បន្ទាន់ ។

តារាងលេខ ៣៥ : និតិវិធីនៃការចាត់ចំណាត់ថ្នាក់ចូលទៅក្នុងកង្វះអាហារូបត្ថម្ភតាមដំណាក់កាលនិមួយៗ និងរបកគំហើញរបស់អង្កេតមនុស្សមាត្រកម្ពុជា ឆ្នាំ២០០៨

| លទ្ធផលសូចនាករ | អសន្តិសុខស្បៀង | វិបត្តិស្បៀងអាហារ និងកម្រិតប៉ះពាល់ដល់ជីវភាពរស់រនៅ | គ្រោះមហន្តរាយ/គ្រោះធម៌ | អង្កេតមនុស្សមាត្រកម្ពុជា ឆ្នាំ២០០៨ |
|---|---|---|---|---|
| កង្វះអាហារូបត្ថម្ភ (ភាពស្គម) | >3% ប៉ុន្តែ <10% ធម្មតា និងស្ថេរភាព | >10% ប៉ុន្តែ <15%> ធម្មតា និងភាគត្បាត | >15%> ធម្មតា និងភាគត្បាត | ភាពស្គមមានចំនួន ៨.៩ ភាគរយ ។ មានន័យថា មិនមានការប្រែប្រួលគួរឱ្យកត់សម្គាល់ក្នុងន័យស្ថិតិចាប់តាំងពីឆ្នាំ២០០៥មក |
| ជម្ងឺកុមារ | - | ជំងឺឆ្លង និងរាតត្បាត | រោគឆ្លងពេញបន្ទុក | កម្រិតជម្ងឺរាក រោគសញ្ញាជម្ងឺរលាកផ្លូវដង្ហើម និងគ្រុនក្តៅ របស់ អ.ម.ក ខ្ពស់ជាងលទ្ធផលរបស់អង្កេត អ.ប្រ.ស.ក ២០០០ និង២០០៥ |
| របបអាហារចំរុះ | បញ្ហាកង្វះខាតរបបអាហារចំរុះធ្ងន់ធ្ងរ | បញ្ហាកង្វះខាតរបបអាហារចំរុះ | ប្រើប្រាស់ក្រុមអាហារសំខាន់ៗក្នុងរយៈពេលទៀងទាត់ ២-៣ ឬក៏តិចជាង | ភាពក្រិនមាន ៣៩.៥ ភាគរយ ។ មូលហេតុថយចុះ : ប្រើប្រាស់អាហារប្រភេទសាច់ និងត្រី ។ ការប្រើប្រាស់ក្រុមអាហារជាមធ្យមមាន ៤.៧ ក្នុងចំណោមអាហារទាំង ១៤ ក្រុម |
| យុទ្ធសាស្រ្តដោះស្រាយបន្ទាន់ | យុទ្ធសាស្រ្តធានារ៉ាប់រង | យុទ្ធសាស្រ្តដោះស្រាយបន្ទាន់ខ្ពស់ជាងការធានា និងការកើនឡើងនៃវិបត្តិយុទ្ធសាស្រ្ត | យុទ្ធសាស្រ្តដោះស្រាយបន្ទាន់មានសារៈសំខាន់ខ្ពស់ជាង និងការកើនឡើងនៃយុទ្ធសាស្រ្តបរាជ័យ | ការកើនឡើងនៃការប្រើប្រាស់យុទ្ធសាស្រ្តដោះស្រាយបន្ទាន់ ប៉ុន្តែមិនបានទូលំទូលាយ |

ទិន្នន័យដែលបានរកឃើញដោយ អ.ម.ក ឆ្នាំ២០០៨ បានបង្ហាញថាប្រជាជនក្រីក្រដែលរស់នៅតាមទីតំបន់ប្រជុំជន បានទទួលរងនូវផលប៉ះពាល់ពីថ្លៃម្ហូបអាហារខ្ពស់ជាងប្រជាជនដែលរស់នៅតំបន់ផ្សេងៗទៀត ។ ជាក់ស្តែង នៅតំបន់ទីប្រជុំជន អត្រាប្រើប្រាស់គ្រប់ក្រុមអាហារស្ទើរតែទាំងអស់ ( ១២ ភាគ ១៤ ) មានការថយចុះ ហើយការប្រើប្រាស់ក្រុមម្ហូបអាហារជាមធ្យម ក៏បានធ្លាក់ចុះដែរ ពី ៥.៤ ទៅ ៤.៨ ។ ការប្រើប្រាស់អាហារប្រភេទសាច់ និងត្រី បានថយចុះចំនួន ១៤ អត្រាភាគរយ ។ ផ្ទុយទៅវិញ អត្រាភាពស្គមរបស់កុមារដែលមានអាយុក្រោម ៥ ឆ្នាំ ហើយកំពុងរស់នៅក្នុងតំបន់ទីប្រជុំជនក្រីក្រ បានកើនឡើងពី ៩.៦ ភាគរយ នាឆ្នាំ២០០៥ ដល់ ១៦ ភាគរយ សម្រាប់ឆ្នាំ២០០៨ ។

***មន្ទីរពេទ្យនាពេលបច្ចុប្បន្ន ដែលកំពុងអនុវត្តនូវកម្មវិធីផ្តល់អាហារបំប៉នបន្ថែម គួរតែកែប្រែដើម្បីជួយលើកកម្ពស់ក្នុងការផ្តល់នូវអនុសាសន៍ និងរបាយការណ៍នានា ដោយរួមបញ្ចូលទាំងការគ្រប់គ្រងសហគមន៍ និងការងារតាមដានកង្វះអាហារូបត្ថម្ភ*** ។ កិច្ចខិតប្រឹងប្រែងរបស់រាជរដ្ឋាភិបាល និងដៃគូទាំងអស់បានកំណត់គោលដៅតំបន់បឹងទន្លេសាបសម្រាប់ការទទួលបាននូវជំនួយឧបត្ថម្ភស្បៀងអាហារ ។ ដៃគូរាជរដ្ឋាភិបាលក្នុងពេលបច្ចុប្បន្ន ក៏កំពុងធ្វើអន្តរាគមន៍ដល់ខេត្តនៅដាច់ស្រយាលនៅភូមិភាគឥសាន ។ ***ជាក់ស្តែងការអង្កេតបានបង្ហាញថា ខេត្តដាច់ស្រយាលភាគច្រើនរបស់ប្រទេសកម្ពុជាប្រហែលបានទទួលរងនូវផលប៉ះពាល់ពីថ្លៃស្បៀងអាហារខ្ពស់*** ។ ខេត្តទាំងនោះមានដូចជា : ខេត្តមណ្ឌលគិរី រតនៈគិរី ស្ទឹងត្រែង និងព្រះវិហារ បានបង្ហាញពីការកើនឡើងនៃការកង្វះអាហារូបត្ថម្ភចំពោះកុមារ ។ អ.ម.ក ឆ្នាំ២០០៨ បានបង្ហាញ ៥ ខេត្ត ក្នុងចំណោម ខេត្តទាំង ៧ ជុំវិញបឹងទន្លេសាប មានកម្រិតភាពស្គមខ្សត់ខ្សោយរបស់កុមារដែលមានអាយុក្រោម ៥ ឆ្នាំ ច្រើនជាង ១០ ភាគរយ ។ យើងឃើញហើយថា ការធ្វើអន្តរាគមន៍ដល់ខេត្តទាំងឡាយជុំវិញតំបន់បឹងទន្លេសាប គឺជាការកំណត់ក្រុមគោលដៅដ៏ល្អប្រពៃ ក្នុងអត្ថន័យជួយជនរងគ្រោះពិតប្រាកដ ហើយអាចបានជួយបន្ធូរបន្ថយ និងធ្វើឱ្យកាន់តែប្រសើឡើង ចំពោះផលប៉ះពាល់ដល់ប្រជាពលរដ្ឋពីការឡើងថ្លៃខ្ពស់នៃស្បៀងអាហារនៅក្នុងតំបន់ ។ ប៉ុន្តែតាមរបកគំហើញរបស់អង្កេត ***ក្រុមដែលងាយរងគ្រោះបំផុត និងត្រូវការជំនួយបន្ទាន់នោះ គួរតែជាក្រុមប្រជាជនក្រីក្រដែលកំពុងរស់នៅក្នុងតំបន់ទីប្រជុំជនក្រីក្រ*** ។ ទោះបីជាយ៉ាងណាក៏ដោយសរុបមកវិញ ***ក្នុងស្ថានភាពបច្ចុប្បន្ននេះ កង្វះអាហារូបត្ថម្ភមាននៅទូទាំងប្រទេសកម្ពុជា ដែលជាការឧបត្ថម្ភអង្ករតែមួយមុខ មិនអាចជួយកាត់បន្ថយនូវអត្រាកង្វះអាហារូបត្ថម្ភទាំងស្រុងនោះទេ ។ នៅមានកិច្ចការជាច្រើនទៀតដែលជាជំហានបន្តបន្ទាប់សម្រាប់លើកកម្ពស់ផ្នែកអាហារូបត្ថម្ភដល់ប្រជាជនកម្ពុជាគ្រប់រូប*** ។

ជាមួយនឹងស្បៀងអាហារមានតម្លៃខ្ពស់នាឆ្នាំ២០០៨ បើប្រៀបទៅឆ្នាំមុនៗ កត្តានេះហាក់ដូចជានៅបន្តផ្តល់ផលប៉ះពាល់ចំពោះស្ថានភាពអាហារូបត្ថម្ភ ហើយវាកាន់តែធ្ងន់ធ្ងរជាងនេះទៅទៀតនៅពេល ដែលវិបត្តិសេដ្ឋកិច្ចពិភពលោក មានឥទ្ធិពលអវិជ្ជមានដល់ប្រទេសកម្ពុជា ទោះបីជាក្នុងកម្រិតតិចឬច្រើនក៏ដោយ ។ លទ្ធភាពប្រើប្រាស់អាហារបានបន្តចោទជាបញ្ហាសម្រាប់គ្រួសារក្រីក្រ ហើយប្រហែល នៅតែបន្តជាបញ្ហាបន្តទៀតពីព្រោះតែតម្លៃស្បៀងអាហារ និងការបាត់បង់ប្រាក់ចំណូលគ្រួសារ ។

***ការកាត់បន្ថយកម្លាំងទិញ សម្រាប់ស្ថេរភាពសេដ្ឋកិច្ចរបស់គ្រួសារដែលធ្វើកសិកម្មជាលក្ខណៈគ្រួសារ គួរតែលើកឡើងដើម្បីធានាបាននូវសុវត្ថិភាពស្បៀងអាហាររបស់ពួកគាត់ ។ ប្រព័ន្ធសុវត្ថិភាពសង្គម មានដូចជា : ការផ្ទេរប្រាក់ដោយកិច្ចសន្យា និងលទ្ធភាពពង្រីកនូវសេវាថែទាំសុខភាព គឺជាការងារចាំបាច់សម្រាប់រយៈពេលខ្លី*** ។ ចំណែកឯកុមារប្រឈមនឹងអត្រាខ្ពស់នៃជំងឺផ្សេងៗ ។ ដូច្នេះការផ្តល់លទ្ធភាពជម្រុញផ្គត់ផ្គង់ប្រភពទឹកស្អាត និងការរស់នៅដោយមានអនាម័យគួរតែត្រូវបានយកចិត្តទុកដាក់ ។ កិច្ចអន្តរាគមន៍នានាដែលទាក់ទងទៅនឹងបញ្ហាកង្វះមីក្រូសារជាតិ ក៏អាចដើរតួយ៉ាងសំខាន់ក្នុងការទប់ស្កាត់ការឆ្លងជម្ងឺ ហើយត្រូវយកមកពិភាក្សាបន្ថែមទៀតក្រោមប្រធានបទ តើកិច្ចអន្តរាគមន៍អាហារូបត្ថម្ភប្រភេទណាមួយគួរតែអនុវត្ត ។

***នៅក្នុងបរិបទបច្ចុប្បន្នស្តីអំពីការបន្តនូវភាពងាយរងគ្រោះនេះ វាជាការចាំបាច់ណាស់ដែលបញ្ហានេះ ត្រូវបានត្រួតពិនិត្យយ៉ាងម៉ត់ចត់ជាមួយនឹងប្រព័ន្ធជាតិគ្រប់គ្រងអាហារូបត្ថម្ភ*** ។ ជាងនេះទៀត គោលដៅសំខាន់ គឺផ្តល់ព័ត៌មានជាមុនឱ្យ បានទាន់ពេលវេលាអំពី ភាពប្រែប្រួលជាអវិជ្ជមានក្នុងស្ថានភាពអាហារូបត្ថម្ភ ហើយប្រព័ន្ធជាតិគួរតែព្យាយាមសម្រេចឱ្យបាននូវគោលបំណងជាច្រើន រួមទាំង ការកំណត់អត្តសញ្ញាណនៅក្នុងថ្នាក់ស្រុក ឬសហគមន៍ណាដែលជួបប្រទះនូវបញ្ហាអាហារូបត្ថម្ភខ្សត់ខ្សោយ ។ ការធ្វើឱ្យប្រសើឡើងនៅប្រភពទិន្នន័យដែលមានស្រាប់ និងការលើកកម្ពស់ កិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ដោយផ្អែកលើភស្តុតាងដែលមាន សំដៅជួយតាមដានត្រួតពិនិត្យ ការធ្វើអន្តរាគមន៍ផ្នែកអាហារូបត្ថម្ភឱ្យមានប្រសិទ្ធិភាព ។

រហូតមកដល់ពេលនេះ យើងបានយកចិត្តទុកដាក់ទៅលើការតាមដានត្រួតពិនិត្យជម្ងឺរបស់កុមារ ការព្យាបាលកង្វះអាហារូបត្ថម្ភ និងវិធានការការពារភាពខ្សត់ខ្សោយអាហារូបត្ថម្ភ ដែលបណ្តាលមកពីភាពក្រីក្រ ។ ប៉ុន្តែគួរបញ្ជាក់ថា ភាពក្រីក្រមិនមែនជាមូលហេតុតែមួយគត់បណ្តាលឱ្យមានអាហារូបត្ថម្ភខ្សត់ខ្សោយនោះទេ ។ សូម្បីតែកុមារដែលរស់នៅជាមួយគ្រួសារមានកម្រិតទ្រព្យសម្បត្តិស្តុកស្តម្ភក៏ជួបនូវបញ្ហាកង្វះអាហារូបត្ថម្ភដែរ (សូចនាករនានារបស់កុមារ) ។ ការប្រៀបធៀបស្ថានភាពអាហារូបត្ថម្ភរបស់កុមារតាមទ្រព្យធន លក្ខណៈប្រវត្តិរបស់ឪពុកម្តាយ និងតំបន់ដែលកុមារ

កំពុងរស់នៅបង្ហាញថាអាហារូបត្ថម្ភជាបញ្ហារបស់ជាតិ ដែលមានឥទ្ធិពលលើគ្រប់វិស័យទាំងអស់របស់សង្គម ។ នេះបញ្ជាក់ឱ្យឃើញថា ថវិកា ឬក៏លទ្ធភាពទិញអាហារ គឺមិនមែនជាកត្តាដែលសំខាន់ជាងគេនោះទេ សម្រាប់អាហារូបត្ថម្ភ ។ វិធីសាស្ត្រចិញ្ចឹម និងរបៀបថែរក្សាកុមារគឺសំខាន់បំផុតដូចគ្នានឹងភាពក្រីក្រដែរ ក្នុងការចូលរួមចំណែកបង្កជាអាហារូបត្ថម្ភខ្សត់ខ្សោយកុំរ៉ៃរបស់កុមារទូទាំងប្រទេស ។

ត្រូវចងចាំផងដែរថា អាហារូបត្ថម្ភខ្សត់ខ្សោយកុំរ៉ៃនៅតែជាបញ្ហាប្រឈមផ្នែកអាហារូបត្ថម្ភដល់កុមារនៅកម្ពុជា ។ កម្រិតរីកចម្រើនផ្នែកអាហារូបត្ថម្ភខ្សត់ខ្សោយកុំរ៉ៃនាពេលកន្លងមកនេះ នឹងចាប់ផ្ដើមរលាយបាត់ទៅវិញ ។ ដូច្នេះ ដើម្បីការពារបញ្ហានេះ ហើយដើម្បីជៀសវាងកង្វះអាហារូបត្ថម្ភនៅពេលអនាគត ការធ្វើអន្តរាគមន៍រយៈពេលមធ្យម និងវែង គួរតែជាសកម្មភាពត្រូវតែយកចិត្តទុកដាក់បន្ថែមទៀត ។ សកម្មភាពមួយចំនួនដូចជា : ***ជម្រុញឥរិយាបទថែទាំកុមារ តាមរយៈការអប់រំ គួរតែជាអាទិភាពរយៈពេលវែង*** ។ ការធ្វើអន្តរាគមន៍អាហារូបត្ថម្ភពាក់ពន្ធ័នឹងឥរិយាបទថែទាំកុមារ ត្រូវធ្វើការពិភាក្សាថែមទៀតនៅក្រោមប្រធានបទ តើការធ្វើអន្តរាគមន៍លើអាហារូបត្ថម្ភណាខ្លះ ដែលត្រូវតែអនុវត្តន៍បន្ត ។

## ទីតាំង និងក្រុមគោលដៅ ដែលត្រូវធ្វើអន្តរាគមន៍ពាក់ពន្ធ័នឹងអាហារូបត្ថម្ភ

ការធ្វើអន្តរាគមន៍ដល់ផ្នែកសុខភាពដែលពាក់ពន្ធ័ទៅនឹងអាហារូបត្ថម្ភកុមារ គួរតែធ្វើក្នុងក្របខ័ណ្ឌទូទាំងប្រទេស ។ ចំពោះការធ្វើអន្តរាគមន៍ណាដែលមិនអាចអនុវត្តន៍ទៅបានភ្លាមៗនោះទេ យើងគួរតែរកវិធីដោះស្រាយបន្ទាន់ ។ ហើយក្នុងពេលដំណាលគ្នានេះដែរ យើងគួរតែផ្ដោតទៅលើអាទិភាពណាដែលសំខាន់ និងទទួលបានជោគជ័យបំផុត មកធ្វើអន្តរាគមន៍ជាមុនសិន ដូចជា : តំបន់ដែលមានចំនួនកុមារខ្សត់ខ្សោយអាហារូបត្ថម្ភខ្លាំងជាងគេ ។ នៅគ្រប់តំបន់ទាំងអស់នៃការអង្កេតថ្នាក់ជាតិ កុមារក្រិនមានចំនួនជាង ៣០ ភាគរយ និងកុមារខ្វះទម្ងន់មានចំនួនមួយភាគប្រាំ លើកលែងតែតំបន់ភ្នំពេញចេញ ប៉ុណ្ណោះ ។ តំបន់ចំនួន ១៥ ក្នុងចំណោមតំបន់ទាំង ១៩ ទូទាំងប្រទេស មានភាពស្គមសរុបចំនួន ១០ ភាគរយ ហើយ ភាពស្គមស្លិតក្នុងចន្លោះចំនួន ៣ អត្រាភាគរយ ។ ខេត្តកំពង់ចាម មានចំនួនកុមារខ្សត់ខ្សោយ អាហារូបត្ថម្ភខ្ពស់ជាងគេ ។ ការប៉ាន់ស្មានរបស់អង្កេតមនុស្សមាត្រ ឆ្នាំ ២០០៨ បង្ហាញថា កុមារ ស្គមស្គាំងមានចំនួនប្រហែលជិត ១៨.០០០នាក់ កុមារខ្វះទម្ងន់មានចំនួន ៥៤.០០០នាក់ និងកុមារក្រិន មានចំនួន ៦៨.០០០នាក់ ។ ***ខេត្តកំពង់ចាម និងតំបន់ផ្សេងទៀតមាន ចំនួនកុមារខ្សត់ខ្សោយ អាហារូបត្ថម្ភមានខ្ពស់គួរឱ្យកត់សម្គាល់ ។ រីឯ***

***ខេត្តសៀមរាប និងខេត្តកណ្តាល ក៏ជាតំបន់ដែលមាន ភូលេខខ្ពស់ដែរ ។ ដូច្នេះ ក្រុមគោលដៅគួរតែជាកុមារដែលកំពុងរស់នៅក្នុងខេត្តទាំងអស់នេះ*** ។

នៅក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ កម្មវិធីអាហារូបត្ថម្ភ បានតម្រង់ទិសដៅទៅរកកុមារដែលមានអាយុតិចជាង ២ឆ្នាំ ហើយក្នុងពេលឆាប់ៗនេះនឹងតម្រង់ទៅរកម្តាយរបស់កុមារ ។ នេះគឺជាយុទ្ធសាស្ត្រប្រសើរបំផុត ពីព្រោះភាពខ្សត់ខ្សោយអាហារូបត្ថម្ភភាគច្រើនចាប់ផ្តើមនៅដំណាក់កាលតំបូងនៃជីវិត ។ ប៉ុន្តែអង្កេតមនុស្សមាត្រ ឆ្នាំ២០០៨ បង្ហាញថាភាពខ្សត់ខ្សោយអាហារូបត្ថម្ភក្នុងចំណោមកុមារដែលមានអាយុច្រើន ក៏ជាបញ្ហាគួរឱ្យព្រួយបារម្ភដែរ ។ លទ្ធផលបង្ហាញថា កម្រិតកង្វះអាហារូបត្ថម្ភក្នុងចំណោមកុមារដែលមានអាយុតិចជាង ១ ឆ្នាំ មានការថយចុះ នៅខណៈដែលគេបានរកឃើញថាមានការកើនឡើងក្នុងចំណោមកុមារដែលមានអាយុច្រើនទៅវិញ ។ និន្នាការនេះ ទំនងជាពាក់ពន្ធ័ទៅនឹងការរីកចម្រើនផ្នែកអាហារូបត្ថម្ភរបស់មាតា ដែលបានរកឃើញដោយអង្កេតមនុស្សមាត្រ ឆ្នាំ២០០៨ ។ ***សកម្មភាពអន្តរាគមន៍ដែលពាក់ពន្ធ័ទៅនឹងវិធានការការពាររយៈពេលខ្លី និងការព្យាបាលកង្វះអាហារូបត្ថម្ភគួរតែអនុវត្តន៍ចំពោះកុមារទាំងអស់ ដែលមានអាយុក្រោម ៥ ឆ្នាំ ហើយដែលជាក្រុមគោលដៅ*** ។

ម្តាយកុមារនៅតាមតំបន់ជនបទ មានកម្ពស់ទាប និងស្គមជាងម្តាយកុមារនៅតំបន់ទីប្រជុំជន ។ ហេតុផលនេះ ប្រហែលជាទាក់ទងទៅនឹងការអនុវត្តលទ្ធភាពផ្តល់កំណើត ។ ភាពខុសគ្នាខ្លាំងផ្នែកភូមិសាស្ត្រ បង្ហាញនូវភាគរយកម្ពស់ទាបរបស់ស្ត្រីដែលរស់នៅតាមតំបន់ខេត្តដាច់ស្រយាល ដូចជា : ខេត្តមណ្ឌលគីរី និងរតនៈគីរី (១៦,១ ភាគរយ) គឺខ្ពស់ជាងកំរិតមធ្យមនៅថ្នាក់ជាតិជិតបីដង ។ ខេត្តព្រះវិហារ និងខេត្តស្ទឹងត្រែង ម្តាយដែលមានកម្ពស់ទាបមានចំនួនខ្ពស់គួរសមដែរ ១១,៤ ភាគរយ ។ ***ភាគរយខ្ពស់របស់ម្តាយដែលមានកម្ពស់ទាបនៅតាមខេត្តដាច់ស្រយាល គួរតែធ្វើការសិក្សា ថែមទៀត ហើយតំបន់ទាំងនោះ អាចជាគោលដៅសម្រាប់ការធ្វើអន្តរាគមន៍អាហារូបត្ថម្ភម្តាយ*** ។

## ការធ្វើអន្តរាគមន៍ផ្នែកសុខភាពបែបណាពាក់ព័ន្ធនឹងអាហារូបត្ថម្ភដែលត្រូវពង្រីកការអនុវត្ត

ការធ្វើអន្តរាគមន៍ទាក់ទងនឹងបញ្ហាកង្វះមីក្រូសារជាតិ គឺមានសារៈសំខាន់សម្រាប់ការពារកុំឱ្យមានភាពខ្សត់ខ្សោយអាហារូបត្ថម្ភរ៉ាំរ៉ៃ ប៉ុន្តែក៏អាចមានផលប៉ះពាល់ល្អទៅដល់ស្ថានភាពអាហារូបត្ថម្ភធ្ងន់ធ្ងរ តាមរយៈការជួយកាត់បន្ថយភាពងាយរងគ្រោះដែលបណ្តាលមកពីជម្ងឺ ។ ការអង្កេតមនុស្សមាត្រ ឆ្នាំ២០០៨ បង្ហាញថាប្រជាជនកំពុងតែរកដំណោះស្រាយជាមួយនឹងតម្លៃទំនិញឡើងខ្ពស់ដោយមិនទិញអាហារណាដែលមានតំលៃថ្លៃ ដូចជា : ប្រភេទសាច់សម្រាប់ជាម្ហូបអាហារប្រចាំថ្ងៃនោះទេ ។ សាច់សត្វពាហនៈ គឺជាប្រភពមីក្រូសារជាតិសំខាន់ ហើយការផ្លាស់ប្តូររបបអាហារនេះ អាចធ្វើឱ្យកើនឡើងនូវបញ្ហាកង្វះមីក្រូសារជាតិ ។ នៅពេលថ្មីៗនេះ មានសកម្មភាពអន្តរាគមន៍ទាក់ទងនឹង

មីក្រូសារជាតិជាច្រើន នៅក្នុងដំណាក់កាលនៃការអនុវត្តដែលអាចជួយការពារភាពខ្សត់ខ្សោយអាហារូបត្ថម្ភរ៉ាំរ៉ៃ និងធ្ងន់ធ្ងរ ។ ការធ្វើអន្តរាគមន៍នៅពេលថ្មីៗនេះ ទាក់ទងនឹងបញ្ហាកង្វះមីក្រូសារជាតិសម្រាប់កុមារ រួមមាន : ការផ្តល់បន្ថែមគ្រាប់ថ្នាំជីវជាតិអា និងថ្នាំបញ្ចុះព្រូន ។ មានភាពប្រសើរឡើងក្នុងអត្រាគ្របដណ្តប់នៃសកម្មភាពអន្តរាគមន៍ ចាប់ពីឆ្នាំ២០០៥ ដល់ឆ្នាំ២០០៨ ។ ការប្រសើរឡើង នេះមកពីលទ្ធផលនៃការបង្កើនកិច្ចសហប្រតិបត្តិការ រវាងរាជរដ្ឋាភិបាលនិងដៃគូដែលពាក់ព័ន្ធនានា ។ យ៉ាងណាមិញ ការព្យាបាលជម្ងឺរាកដោយប្រើប្រាស់អូរ៉ាលីត ជាមួយនឹងសារជាតិសង្កសី (អាហារប្រភេទភេទសាច់គោ) អាចជួយកាត់បន្ថយតម្លៃម្ហូបអាហារដែលថ្លៃ ហើយក៏ជាមធ្យោបាយល្អសម្រាប់ការព្យាបាល និងការការពារពីជម្ងឺរាក ។ ***សម្រាប់អនាគត ថ្នាំបញ្ចុះព្រូន ការប្រើប្រាស់អូរ៉ាលីតជាមួយនឹងជាតិសង្កសី និងជីវជាតិអា គួរតែផ្តល់ដល់មណ្ឌលសុខភាពក្នុងអំឡុងពេលដែលផ្តល់សេវាកម្មមូលដ្ឋាន ព្រមគ្នាជាមួយនឹងតាមរយៈអ្នកស្ម័គ្រចិត្តសហគមន៍ ដើម្បីពង្រីកតំបន់គ្របដណ្តប់ឱ្យបានទូលំទូលាយជាអតិបរមា*** ។

ពុំមានអនុសាសន៍ក្នុងការផ្តល់បន្ថែមជាតិដែកដល់កុមារទេ ពីព្រោះតែមានការបារម្ភពាក់ពន្ធ័ទៅនឹងឥទ្ធិពលទៅវិញទៅមករវាងកំរិតខ្ពស់នៃជាតិដែក និងជម្ងឺឆ្លង ។ ភាពស្លេកស្លាំង ដោយសារបញ្ហាកង្វះជាតិដែកត្រូវបានទទួលស្គាល់ថា ជាបញ្ហាសុខភាពសាធារណៈធ្ងន់ធ្ងរនៅកម្ពុជា ហើយត្រូវតែយកចិត្តទុកដាក់ជាបន្ទាន់ ។ ***អាហារដែលបញ្ចូលមីក្រូសារជាតិសម្រាប់ប្រើប្រាស់តាមផ្ទះ តាមរយៈម្សៅមីក្រូសារជាតិចំរុះ នាពេលបច្ចុប្បន្ននេះ ត្រូវបានធ្វើការសិក្សាស្រាវជ្រាវអនុវត្តន៍នៅក្នុង ខេត្តមួយ ។ សកម្មភាពអន្តរាគមន៍នេះ ត្រូវបានប្រើប្រាស់ជាលក្ខណៈអន្តរជាតិ ហើយត្រូវតែពង្រីក ការអនុវត្តជាបន្ទាន់*** ។ នេះជាវិធី ដោះស្រាយចំពោះបញ្ហាកង្វះជាតិដែក និងជាវិធីសាស្រ្តមួយប្រសើរជាងការផ្តល់បន្ថែមមីក្រូសារជាតិ ដោយឡែកពីគ្នា ពីព្រោះថាបើកុមារម្នាក់ជាមួយនឹងមានបញ្ហាកង្វះមីក្រូសារជាតិមួយមុខ នឹងទំនងជាមានបញ្ហាកង្វះមីក្រូសារជាតិច្រើនមុខទៀត ។ ការផ្តល់មីក្រូសារជាតិបន្ថែម គួរតែយកចិត្តទុកដាក់ តម្រង់ទិសទៅរកអាហារដែលបញ្ចូលមីក្រូសារជាតិសម្រាប់ប្រើប្រាស់តាមផ្ទះ ហើយជៀសវាងការផ្តល់បន្ថែម ពីរដងក្នុងមួយឆ្នាំ ។ ប្រសិនបើធនធានសម្រាប់ការអនុវត្តជាទូទៅ មិនគ្រប់គ្រាន់ចំពោះក្រុមគោលដៅទាំងពីរនោះទេ គួរតែជ្រើសយកខេត្តណា ដែលមានចំនួនកុមារមានភាពខ្សត់ខ្សោយអាហារូបត្ថម្ភខ្ពស់ និងធ្ងន់ធ្ងរ ។ ***ការសិក្សាស្រាវជ្រាវកំពុងតែអនុវត្តន៍នៅប្រទេសបង់ក្លាដេស ស្តីពីអាហារដែលបញ្ចូលមីក្រូសារជាតិសម្រាប់ប្រើប្រាស់តាមផ្ទះដែលប្រើប្រាស់ដោយស្រ្តីមានផ្ទៃពោះ ហើយបញ្ហានេះគួរតែតាមដានឱ្យ បានម៉ត់ចត់ និងត្រូវតែមានផែនការច្បាស់លាស់សម្រាប់អនុវត្តន៍ ក្នុងប្រទេសកម្ពុជា*** ។

ការអង្កេតមុស្សមាត្រ ឆ្នាំ២០០៨ បង្ហាញថាប្រសិទ្ធិភាពនៃការការពារស្ថានភាពអាហារូបត្ថម្ភរបស់ម្តាយ មានអានុភាពដល់ស្ថានភាពអាហារូបត្ថម្ភរបស់កុមារ ។ ស្ថានភាពមីក្រូសារជាតិរបស់ម្តាយគឺជាសមាសធាតុដ៏មានសារៈសំខាន់មួយនៃប្រសិទ្ធិភាពការពារនេះ ហើយការធ្វើអន្តរាគមន៍ដែលពាក់ព័ន្ធទៅនឹងភាពខ្សត់ខ្សោយផ្នែកមីក្រូសារជាតិ ដែលមាននៅក្នុងខ្លួនស្ត្រីអាចជួយការពារកង្វះអាហារូបត្ថម្ភធ្ងន់ធ្ងរដល់កុមារ ។ នៅពេលបច្ចុប្បន្ននេះ អត្រាគ្របដណ្តប់សកម្មភាពអន្តរាគមន៍ដល់ស្ត្រីដើម្បីការពារកង្វះជាតិដែក ការផ្តល់បន្ថែមជាតិដែកហ្វូលិក មុន និងក្រោយពេលសម្រាលកូន ការផ្តល់ថ្នាំទម្លាក់ព្រូនក្នុងអំឡុងពេលមានផ្ទៃពោះ ការផ្តល់បន្ថែមគ្រាប់ថ្នាំជីវជាតិអា ក្រោយពេលសម្រាលកូនមានការប្រសើរឡើងពីឆ្នាំ២០០៥ ដល់ឆ្នាំ២០០៨ ។ ភាពប្រសើរឡើងនេះ ដោយសារកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល និងដៃគូក្នុងការខិតខំបង្កើនចំនួនស្ត្រីឱ្យបានច្រើនទៅពិនិត្យសុខភាពមុន និងក្រោយពេលសម្រាល ។ ***បន្តការធ្វើឱ្យប្រសើរឡើងនៃគុណភាពការថែទាំមុន និងក្រោយពេលសម្រាលកូនដោយធ្វើការយកចិត្តទុកដាក់ទៅដល់ការផ្តត់ផ្គង់ឱសថឱ្យបានគ្រប់គ្រាន់ និងបន្តធ្វើឱ្យប្រសើរឡើងការផ្តល់បន្ថែមមីក្រូសារជាតិដល់ម្តាយ ។ លើសពីនេះ ការថែទាំមុនពេលសម្រាលកូនគួរតែដាក់បញ្ចូលនូវការត្រួតពិនិត្យការឡើងទម្ងន់ក្នុងអំឡុងពេលមានផ្ទៃពោះ និងផ្តល់ព័ត៌មានស្តីពីការចិញ្ចឹមក្មេងឱ្យបានសមស្រប និងមានអនាម័យ*** ។

មានការធ្វើឱ្យប្រសើរឡើងផ្នែកអាហារូបត្ថម្ភ មានរយៈពេលវែងនៅទសវត្សន៍ចុងក្រោយនេះ ហើយនឹងកំពុងតែបន្តនូវភាពរីកចម្រើនតទៅមុខទៀត ។ ភាពប្រសើរឡើងអត្រាអនុវត្តលទ្ធភាពបង្កើតកូន ការកើនឡើងអត្រាបំបៅកូនដោយទឹកដោះម្តាយតែមួយមុខគត់ ការកើនឡើងអត្រាបញ្ចូលជាតិអ៊ីយ៉ូដទៅក្នុងអំបិល ទាំងអស់នេះគឺជាជោគជ័យដែលសម្រេចបាន ។ ការធ្វើឱ្យមានភាពរីកចម្រើនថែមទៀតនៃកម្មវិធីទាំងនេះ អាចធានាដល់ប្រជាជនទាំងអស់ ហើយជាការអនុវត្តនៃការធ្វើអន្តរាគមន៍រយៈពេលមធ្យម និងវែង ដែលមានសារៈសំខាន់សម្រាប់ការការពារភាពខ្សត់ខ្សោយអាហារូបត្ថម្ភប្រកបដោយស្ថេរភាព ។

ការធ្វើឱ្យប្រសើរឡើងលទ្ធភាពផ្តល់កំណើត ដែលជះឥទ្ធិពលដល់អាហារូបត្ថម្ភ មានការថយចុះជាមធ្យម និងធ្វើឱ្យមានគំលាតវែងនៃការមានកូន ។ វឌ្ឍនភាពនេះ ជាលទ្ធផលនៃការផ្លាស់ប្តូរមុខរបររបស់ប្រជាជនពីមុខរបរកសិករ ទៅមុខររបរទទួលប្រាក់បៀវត្សន៍ ។ ***ប៉ុន្តែ សេវាកម្មផែនការគ្រួសារ ក៏បានចូលរួមចំណែកផងដែរដល់ការផ្លាស់ប្តូរនេះ ។ កម្មវិធីផែនការគ្រួសារ គួរតែយកចិត្តទុកដាក់ទៅលើការធ្វើឱ្យប្រសើរឡើងផ្នែកអាហារូបត្ថម្ភ ជាពិសេសនៅតាមបណ្តាខេត្តដាច់ស្រយាល ដែលមានអត្រាកង្វះអាហារូបត្ថម្ភរបស់ម្តាយខ្ពស់ ។ បង្កើនការយល់ដឹងអំពីអត្ថប្រយោជន៍នៃ ការកើនទម្ងន់តាមរយៈការប្រាស្រ័យទាក់ទងផ្លាស់ប្តូរឥរិយាបថ*** ។

ការធ្វើឱ្យប្រសើរឡើងចំពោះការបំបៅកូនដោយទឹកដោះម្តាយតែមួយមុខគត់ គឺជាលទ្ធផលមកពីការប្រាស្រ័យទាក់ទងផ្លាស់ប្តូរឥរិយាបទដែលបានធ្វើឱ្យម្តាយទទួលស្គាល់ថា គាត់មិនត្រូវផ្តល់ទឹកទៅឱ្យកូនគាត់ឡើយ ។ ***ការប្រាស្រ័យទាក់ទងដើម្បីផ្លាស់ប្តូរឥរិយាបទក្នុងការបំបៅកូនដោយទឹកដោះម្តាយតែមួយមុខគត់ ត្រូវតែបន្តអនុវត្តន៍ និងធ្វើឱ្យបានប្រសើរឡើង ។ រីឯដំណាក់កាលដំបូងនៃការផ្តល់អាហារបន្ថែម ត្រូវបានផ្តល់ទៅឱ្យកុមារដែលមានអាយុពី ៦ ខែ ឡើងទៅ ស្របពេលដែលការបំបៅកូនដោយទឹកដោះម្តាយនៅតែបន្ត ។ ការប្រាស្រ័យទាក់ទងដើម្បីផ្លាស់ប្តូរឥរិយាបទ គួរតែរៀបចំផងដែរ ដើម្បីលើកឡើងពីឧបសគ្គនានា ចំពោះការបំបៅកូនដោយទឹកដោះម្តាយតែមួយមុខគត់នៅតំបន់ទីប្រជុំជន*** ពីព្រោះនៅពេលថ្មីៗនេះ នៅតំបន់ទាំងនោះ ត្រូវបានរកឃើញថាមានការថយចុះនៃអត្រាបំបៅកូនដោយទឹកដោះម្តាយតែមួយមុខគត់ ។ ការអង្កេតមនុស្សមាត្រ ឆ្នាំ២០០៨ បង្ហាញថាម្តាយភាគច្រើន បានពន្យាពេលក្នុងការផ្តល់អាហារបន្ថែមដល់កូន ហើយមិនបានផ្តល់របបអាហារចំរុះដល់កូនតូចៗឱ្យបានទាន់ពេលវេលា ។ ***ការធ្វើអន្តរាគមន៍ផ្តល់អាហារបន្ថែម ត្រូវបានអនុវត្តន៍ទូទាំងប្រទេសរួចមកហើយ ប៉ុន្តែចាំបាច់ត្រូវតែអនុវត្តន៍បន្តទៀត ។ ជាការចាំបាច់ផងដែរសម្រាប់យុទ្ធនាការប្រាស្រ័យទាក់ទងផ្លាស់ប្តូរឥរិយាបទ ដែលត្រូវផ្តោតជាសំខាន់ទៅលើការផ្តល់អាហារបន្ថែម*** ។

ការបញ្ចូលជាតិអ៊ីយ៉ូដទៅក្នុងអំបិល បានគ្របដណ្តប់ស្ទើរតែគ្រប់តំបន់ទាំងអស់ទូទាំងប្រទេស ប៉ុន្តែ នៅមានខេត្តពីរ-បីប៉ុណ្ណោះ ពុំទាន់ទទួលបានជោគជ័យ។ ការអប់រំជាឧបករណ៍ដ៏សំខាន់ក្នុងការធ្វើឱ្យប្រសើរឡើងនៅតំបន់ទាំងនោះ ។ ការបញ្ចូលជាតិអ៊ីយ៉ូដទៅក្នុងអំបិល ប្រហែលជាអាចសម្រេចបានជោគជ័យនូវការលុបបំបាត់ការខ្វះជាតិអ៊ីយ៉ូដទូទាំងប្រទេស ។ ***ការបញ្ចូលជាតិអ៊ីយ៉ូដទៅក្នុងអំបិល គឺជាដំណោះស្រាយរយៈពេលវែង ចំពោះភាពខ្សត់ខ្សោយផ្នែកអាហារូបត្ថម្ភ ។ ការបញ្ចូលមីក្រូសារជាតិចំរុះទៅក្នុងអាហារដែលបរិភោគជាប្រចាំ គឺជាអាទិភាពរយៈពេលមធ្យម/វែង*** ។

# ជំពូកទី៦

# វិធីសាស្ត្រធ្វើអង្កេត

ការវិភាគអង្កេតមនុស្សមាត្រកម្ពុជា ឆ្នាំ២០០៨ បានប្រើប្រាស់ទាំងស្រុងនូវវិធីសាស្ត្រ SPSS ១៧ របស់អង្កេតស្ថិតិ ។ កិច្ចខិតខំប្រឹងប្រែងជាពិសេស ត្រូវបានបង្កើតឡើងដើម្បីវិភាគលើនិន្នាការផ្លាស់ប្តូររបស់សូចនាករនិមួយៗ ។ ជាទូទៅរាល់សូចនាកររបស់ អ.ម.ក ២០០៨ ត្រូវបានគណនាដោយប្រើប្រាស់នូវវិធីសាស្ត្ររបស់ អ.ប្រ.ស.ក ឆ្នាំ២០០៥ ។ ការធ្វើដូច្នេះ គឺដើម្បីបន្សុីគ្នារវាងសូចនាករទាំងពីរ ។ រាល់ការប្រៀបធៀបអំពីនិន្នាការប្រែប្រួលដែលត្រូវបានបង្ហាញក្នុងរបាយការណ៍ បានប្រើប្រាស់តែការព្យាករណ៍ទាំងឡាយដែលអាចធ្វើការប្រៀបធៀបគ្នាបានប៉ុណ្ណោះ ។

## វិធីសាស្ត្រគណនាឡើងវិញរបស់អង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ឆ្នាំ២០០៥ បទដ្ឋានថ្មីរបស់វាស់វែងការលូតលាស់របស់អង្គការសុខភាពពិភពលោក

ដោយយោងតាមការផ្តល់អនុសាសន៍ពី គណៈកម្មាធិការអចិន្ត្រៃយ៍របស់អង្គការសហប្រជាជាតិស្តីពីអាហារូបត្ថម្ភ អង្កេតមនុស្សមាត្រកម្ពុជាប្រើប្រាស់នូវបទដ្ឋានវាស់វែងការលូតលាស់កុមាររបស់អង្គការសុខភាពពិភពលោក ឆ្នាំ២០០៦ គ្រប់បណ្តាសូចនាករទាំងអស់របស់មនុស្សមាត្រកុមារ ។ បទដ្ឋានថ្មីនេះជំនួសឱ្យបទដ្ឋានចាស់របស់មជ្ឈមណ្ឌលជាតិសម្រាប់ស្ថិតិសុខភាព ដែលជានិច្ចកាលបានកំណត់យកកុមារអាមេរិកប៉ុណ្ណោះធ្វើជាគោល ។ រីឯបទដ្ឋានថ្មីផ្តោតលើកុមារដែលមានសុខភាពល្អបរិបូណ៌ពីបណ្តាប្រទេសទាំងអស់ក្នុងពិភពលោក និងកុមារដែលម្តាយមានការអនុវត្តរស់នៅល្អដូចជា : ការចិញ្ចឹមកូន ដោយទឹកដោះម្តាយ និងម្តាយមិនជក់បារី ។

ផ្នែកវិភាគរបស់ អ.ម.ក ឆ្នាំ២០០៨ ប្រើប្រាស់នូវបទដ្ឋានកំណើនដែលផ្តល់ដោយអង្គការសុខភាពពិភពលោក ។ ហើយបទដ្ឋាននេះ ក៏បានបន្សុីផងដែរជាមួយនឹងវិធីសាស្ត្រវិភាគរបស់ អ.ប្រ.ស.ក ។ ការព្យាករណ៍សូចនាករមនុស្សមាត្រកុមារ ពីឆ្នាំ២០០០ និងឆ្នាំ២០០៥ ដែលចង្អុលបង្ហាញដោយ អ.ម.ក ២០០៨ ត្រូវបានធ្វើការគណនាជាថ្មីជាមួយនឹងបទដ្ឋានវាស់វែងការលូតលាស់ថ្មី។ ចំពោះការប្រៀបធៀបអង្កេត ឆ្នាំ២០០០ ឆ្នាំ២០០៥ និងឆ្នាំ២០០៨ យើងអាចទទួលយកបានដោយសារតែការប្រើប្រាស់នូវបទដ្ឋានថ្មីនេះ ។ ជាលទ្ធផល ការព្យាករណ៍ពីឆ្នាំ២០០០ និងឆ្នាំ២០០៥ ត្រូវបានធ្វើការរួមបញ្ចូលក្នុងរបាយការណ៍ឧបសម្ព័ន្ធ ។

## វិធីសាស្ត្រគណនាឡើងវិញរបស់អង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ឆ្នាំ២០០៥

សូចនាករមួយចំនួនដែលបានដកស្រង់ចេញពី អ.ម.ក ឆ្នាំ២០០៨ និង អ.ប្រ.ស.ក ឆ្នាំ២០០០ និងឆ្នាំ២០០៥ មានគោលដៅកំណត់រកប្រជាជនខុសគ្នា ពីព្រោះតែរបៀបបង្កើតអង្កេតខុសគ្នា ។ ហើយការប្រៀបធៀបសូចនាករទាំងអស់របស់ អ.ម.ក ឆ្នាំ២០០៨ អាចទទួលយកបានដោយការ

ព្យាករណ៍ក្នុង អ.ប្រ.ស.ក ។ សូចនាករខាងក្រោមនេះត្រូវបានកែឆ្នៃ ដើម្បីធ្វើឱ្យអង្កេតទាំងអស់អាចប្រៀបធៀបគ្នាបាន ។

- មនុស្សមាត្រស្ត្រី
- ជម្ងឺកុមារ
- សេវាថែទាំសុខភាពរបស់កុមារ

អ.ប្រ.ស.ក ឆ្នាំ២០០៥ ព្យាករណ៍អំពីសូចនាករមនុស្សមាត្រស្ត្រី ដែលក្នុងនោះរួមបញ្ចូលនូវស្ត្រីគ្រប់រូបដែលមានអាយុចន្លោះពី ១៥ ទៅ ៤៩ ឆ្នាំ ។ រីឯ អ.ម.ក ឆ្នាំ២០០៨ រួមបញ្ចូលតែស្ត្រីណាដែលមានអាយុចន្លោះពី ១៥ ទៅ ៤៩ ឆ្នាំ ហើយកំពុងមានកូនដែលមានអាយុតិចជាងគេបង្អស់ក្នុងចំណោមកូនដែលមានអាយុចាប់ពី ០ ទៅ ៥៩ ខែ ក្នុងបន្ទុកគ្រួសារប៉ុណ្ណោះ ។ ដូច្នេះដើម្បីធ្វើការប្រៀបធៀបគ្នាបានរវាងអង្កេតពីរខាងលើដែលមានលក្ខណៈខុសគ្នា យើងបានកែសម្រួលខ្លះក្នុង អ.ប្រ.ស.ក ឆ្នាំ២០០៥ នូវចំនុចមួយដ៏សំខាន់ (កំណត់យកតែស្ត្រីណាដែលមានកូនអាយុតិចជាងគេបង្អស់ក្នុងចំណោមកូនដែលមានអាយុពី ០ ទៅ ៥៩ ខែ តែប៉ុណ្ណោះ) ។

ដោយសារតែពេលវេលាមានកាលកំណត់ នោះស្ត្រីជាម្តាយដែលមានកូនអាយុតិចជាងគេបង្អស់ត្រូវបានសួរនាំតែអំពីប្រភេទជម្ងឺ និងសេវាថែទាំសុខភាពរបស់កុមារប៉ុណ្ណោះ ។ សរុបមកការរកឃើញនូវលទ្ធផលថ្មីៗតាមរយៈការកែប្រែនេះ នឹងបង្ហាញនៅក្នុងឧបសម្ព័ន្ធរបស់របាយការណ៍ ។ លើកលែងតែសេវាថែទាំសុខភាពរបស់កុមារប៉ុណ្ណោះ ដែលមិនត្រូវបានដាក់នៅក្នុងឧបសម្ព័ន្ធ ពីព្រោះតែមានបញ្ហាខ្លះជាមួយ នឹងរបៀបគណនាសូចនាករ ។

ចំពោះការផ្លាស់ប្តូរខ្លះៗក្នុងការកំណត់ប្រជាជនដែលជាក្រុមគោលដៅរបស់អង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ការប្រៀបធៀបសូចនាករមួយចំនួន ត្រូវបានផ្ទៀងផ្ទាត់ និងដាក់បញ្ចូលជាមួយគ្នាក្នុងតារាងតែមួយ ដូចជា : ការប្រៀបធៀបរកសូចនាករការផ្តល់គ្រាប់ថ្នាំទម្លាក់ព្រូន ការផ្តល់បន្ថែមគ្រាប់ថ្នាំជីវជាតិអា និងរោគសញ្ញាជម្ងឺរលាកផ្លូវដង្ហើមជាដើម ។ ការប្រៀបធៀបសូចនាករទាំងអស់ និងភាពមិនស៊ីសង្វាក់គ្នារបស់របាយការណ៍ អ.ប្រ.ស.ក ហើយនឹងការគណនាត្រូវបានបង្ហាញនៅក្នុងចំនុចវិភាគដែលបានបង្ហាញស្រាប់នៅក្នុងជំពូកទី ៤ ស្តីអំពី ***សេវាសុខភាពអាហារូបត្ថម្ភ*** ។

ជាចុងបញ្ចប់សូមធ្វើការកត់សម្គាល់ថា សំណួរសម្រាប់ការផ្តល់បន្ថែមគ្រាប់ថ្នាំជីវជាតិអាក្រោយពេលសម្រាលកូនរបស់អង្កេតឆ្នាំ២០០៨ គឺមានលក្ខណៈខុសគ្នាបន្តិចត្រង់ថា គោលនយោបាយ

ត្រូវបានផ្លាស់ប្តូរ ។ ពេលវេលានៃការផ្តល់បន្ថែមគ្រាប់ថ្នាំជីវជាតិអា ក្រោយពេលសម្រាលកូន បានកាត់បន្ថយពីរយៈពេល ២ ខែ មកនៅត្រឹម ៦ សប្តាហ៍ ។ ប៉ុន្តែទោះបីជាមានការកាត់បន្ថយពេលវេលាក៏ដោយ ក៏មិនបានធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរ លើសូចនាករផ្សេងៗដែរ ។

របាយការណ៍ក្នុង អ.ប្រ.ស.ក ឆ្នាំ២០០៥ អំពីប្រភេទអាហារដូចជា : សាច់មាន់ និងគ្រាប់ធញ្ញជាតិដែលជាផ្នែកនៃក្រុមអាហារចំរុះ ។ ទោះបីជាយ៉ាងណាក្តី ក៏ប្រភេទអាហារមួយចំនួន មិនត្រូវបានរួមបញ្ចូលក្នុងការគណនានេះទេ ។ ដូច្នេះ ដើម្បីលើកឡើងនូវបញ្ហានេះ ហើយនឹងដើម្បីផ្តល់នូវការសិក្សាឱ្យបានស៊ីជម្រៅទៅតាមការប្រើប្រាស់ក្រុមអាហារ អង្កេតមនុស្សមាត្រកម្ពុជា ឆ្នាំ ២០០៨ បានជ្រើសរើសយកនូវក្រុមអាហារចំនួន ១៤ ប្រភទ ដែលក្រុមអាហារទាំងអស់នេះ បានជ្រើសយកចេញពីលំនាំតាមអង្គការស្បៀងអាហារ និងកសិកម្ម ។ ការព្យាករណ៍ទិន្នន័យពី អ.ប្រ.ស.ក ឆ្នាំ ២០០៥ ក៏បានប្រើប្រាស់ផងដែរ នូវការគណនាតាមវិធីសាស្ត្រថ្មីសម្រាប់ប្រៀបធៀប ។

## កុមារស្គម

| Sampling error of child wasting (weight-for-height <-2 standard deviations) | | | | | | |
|---|---|---|---|---|---|---|
| | | | 95% Confidence Interval | | | |
| | Estimate | Standard Error | Lower | Upper | Population Size | Unweighted Count |
| **National** | 8.9% | 0.41% | 8.1% | 9.7% | 7019 | 7043 |
| **Residence** | | | | | | |
| Urban | 8.5% | 0.91% | 6.7% | 10.3% | 1217 | 1132 |
| Rural | 9.0% | 0.45% | 8.1% | 9.9% | 5801 | 5911 |
| **Domain** | | | | | | |
| Banteay Mean Chey | 11.7% | 1.74% | 8.3% | 15.1% | 318 | 343 |
| Kampong Cham | 10.0% | 1.52% | 7.0% | 13.0% | 888 | 343 |
| Kampong Chhnang | 11.0% | 1.73% | 7.6% | 14.4% | 306 | 416 |
| Kampong Speu | 10.9% | 1.60% | 7.8% | 14.0% | 471 | 396 |
| Kampong Thom | 9.6% | 1.54% | 6.6% | 12.6% | 188 | 369 |
| Kandal | 10.8% | 1.73% | 7.4% | 14.2% | 627 | 352 |
| Kratie | 8.9% | 1.51% | 6.0% | 11.9% | 164 | 388 |
| Phnom Penh | 5.6% | 1.35% | 2.9% | 8.2% | 658 | 402 |
| Prey Veng | 5.4% | 1.40% | 2.7% | 8.2% | 528 | 348 |
| Pursat | 11.2% | 1.68% | 7.9% | 14.5% | 186 | 378 |
| Siemreap | 8.7% | 1.28% | 6.1% | 11.2% | 629 | 415 |
| Svay Rieng | 11.0% | 1.71% | 7.7% | 14.4% | 272 | 372 |
| Takeo | 7.1% | 1.43% | 4.3% | 9.9% | 479 | 362 |
| Oddar Mean Chey | 9.7% | 2.14% | 5.5% | 13.9% | 78 | 345 |
| Battambang/Krong Pailin | 9.3% | 1.49% | 6.4% | 12.3% | 557 | 370 |
| Kampot/Krong Kep | 8.2% | 1.35% | 5.6% | 10.8% | 261 | 358 |
| Sihanouk Ville/Koh Kong | 7.1% | 1.46% | 4.2% | 9.9% | 181 | 376 |
| Preah Vihear/Stung Treng | 6.7% | 1.36% | 4.0% | 9.4% | 133 | 355 |
| Mondul Kiri/Rattanak Kiri | 6.6% | 1.59% | 3.5% | 9.7% | 96 | 355 |

## កុមារក្រិន

| Sampling error of child stunting (height-for-age <-2 standard deviations) | | | | | | |
|---|---|---|---|---|---|---|
| | | | **95% Confidence Interval** | | | |
| | **Estimate** | **Standard Error** | **Lower** | **Upper** | **Population Size** | **Unweighted Count** |
| **National** | 39.5% | 0.72% | 38.1% | 41.0% | 7019 | 7043 |
| **Residence** | | | | | | |
| Urban | 31.9% | 1.83% | 28.3% | 35.5% | 1217 | 1132 |
| Rural | 41.1% | 0.79% | 39.6% | 42.7% | 5801 | 5911 |
| **Domain** | | | | | | |
| Banteay Mean Chey | 38.4% | 3.26% | 32.0% | 44.8% | 318 | 343 |
| Kampong Cham | 38.0% | 2.90% | 32.3% | 43.6% | 888 | 343 |
| Kampong Chhnang | 45.3% | 2.15% | 41.1% | 49.5% | 306 | 416 |
| Kampong Speu | 37.6% | 2.39% | 32.9% | 42.3% | 471 | 396 |
| Kampong Thom | 47.1% | 3.42% | 40.4% | 53.8% | 188 | 369 |
| Kandal | 35.8% | 2.85% | 30.2% | 41.4% | 627 | 352 |
| Kratie | 46.1% | 2.36% | 41.5% | 50.8% | 164 | 388 |
| Phnom Penh | 33.6% | 3.57% | 26.6% | 40.6% | 658 | 402 |
| Prey Veng | 42.3% | 2.06% | 38.3% | 46.4% | 528 | 348 |
| Pursat | 36.3% | 2.29% | 31.8% | 40.7% | 186 | 378 |
| Siemreap | 46.0% | 2.17% | 41.7% | 50.3% | 629 | 415 |
| Svay Rieng | 36.1% | 4.01% | 28.2% | 44.0% | 272 | 372 |
| Takeo | 43.5% | 2.13% | 39.3% | 47.6% | 479 | 362 |
| Oddar Mean Chey | 40.7% | 3.12% | 34.6% | 46.9% | 78 | 345 |
| Battambang/Krong Pailin | 37.3% | 2.17% | 33.1% | 41.6% | 557 | 370 |
| Kampot/Krong Kep | 34.5% | 2.09% | 30.4% | 38.6% | 261 | 358 |
| Sihanouk Ville/Koh Kong | 40.1% | 2.32% | 35.5% | 44.6% | 181 | 376 |
| Preah Vihear/Stung Treng | 46.8% | 3.87% | 39.2% | 54.4% | 133 | 355 |
| Mondul Kiri/Rattanak Kiri | 41.9% | 3.46% | 35.1% | 48.7% | 96 | 355 |

## កុមារកង្វះទម្ងន់

| Sampling error of child underweight (weight-for-age -2 standard deviations | | | | | | |
|---|---|---|---|---|---|---|
| | | | **95% Confidence Interval** | | | |
| | **Estimate** | **Standard Error** | **Lower** | **Upper** | **Population Size** | **Unweighted Count** |
| **Naitonal** | 28.8% | 0.68% | 27.5% | 30.1% | 7019 | 7043 |
| **Residence** | | | | | | |
| Urban | 21.1% | 1.34% | 18.5% | 23.7% | 1217 | 1132 |
| Rural | 30.4% | 0.77% | 28.9% | 31.9% | 5801 | 5911 |
| **Domain** | | | | | | |
| Banteay Mean Chey | 29.6% | 2.53% | 24.7% | 34.6% | 318 | 343 |
| Kampong Cham | 30.1% | 2.47% | 25.2% | 34.9% | 888 | 343 |
| Kampong Chhnang | 37.4% | 2.64% | 32.2% | 42.6% | 306 | 416 |
| Kampong Speu | 27.8% | 2.43% | 23.1% | 32.6% | 471 | 396 |
| Kampong Thom | 33.5% | 3.56% | 26.5% | 40.5% | 188 | 369 |
| Kandal | 29.6% | 2.97% | 23.8% | 35.4% | 627 | 352 |
| Kratie | 29.2% | 2.42% | 24.4% | 33.9% | 164 | 388 |
| Phnom Penh | 18.6% | 2.57% | 13.6% | 23.7% | 658 | 402 |
| Prey Veng | 29.8% | 3.11% | 23.7% | 35.9% | 528 | 348 |
| Pursat | 33.2% | 2.18% | 28.9% | 37.5% | 186 | 378 |
| Siemreap | 34.7% | 2.20% | 30.4% | 39.0% | 629 | 415 |
| Svay Rieng | 30.7% | 3.25% | 24.4% | 37.1% | 272 | 372 |
| Takeo | 28.9% | 2.20% | 24.6% | 33.2% | 479 | 362 |
| Oddar Mean Chey | 26.2% | 2.24% | 21.8% | 30.6% | 78 | 345 |
| Battambang/Krong Pailin | 25.1% | 2.12% | 20.9% | 29.2% | 557 | 370 |
| Kampot/Krong Kep | 27.2% | 1.95% | 23.4% | 31.1% | 261 | 358 |
| Sihanouk Ville/Koh Kong | 26.2% | 1.89% | 22.5% | 29.9% | 181 | 376 |
| Preah Vihear/Stung Treng | 24.0% | 1.83% | 20.4% | 27.6% | 133 | 355 |
| Mondul Kiri/Rattanak Kiri | 27.1% | 3.02% | 21.2% | 33.1% | 96 | 355 |

## ស្ត្រីជាម្តាយដែលមានកម្ពស់ទាប

Sampling error of short mothers

| | Estimate | Standard Error | 95% Confidence Interval Lower | 95% Confidence Interval Upper | Population Size | Unweighted Count |
|---|---|---|---|---|---|---|
| **National** | 6.3% | 0.34% | 5.6% | 7.0% | 6888 | 6885 |
| **Residence** | | | | | | |
| Urban | 5.3% | 0.82% | 3.7% | 6.9% | 1144 | 1074 |
| Rural | 6.5% | 0.38% | 5.8% | 7.2% | 5744 | 5811 |
| **Domain** | | | | | | |
| Banteay Mean Chey | 5.0% | 1.12% | 2.8% | 7.2% | 318 | 338 |
| Kampong Cham | 5.2% | 1.18% | 2.9% | 7.5% | 918 | 346 |
| Kampong Chhnang | 6.3% | 1.35% | 3.6% | 9.0% | 278 | 376 |
| Kampong Speu | 6.3% | 1.21% | 3.9% | 8.7% | 439 | 367 |
| Kampong Thom | 7.5% | 1.32% | 4.9% | 10.0% | 194 | 380 |
| Kandal | 6.8% | 1.63% | 3.6% | 10.0% | 562 | 310 |
| Kratie | 5.6% | 1.20% | 3.3% | 8.0% | 164 | 380 |
| Phnom Penh | 4.5% | 1.24% | 2.1% | 7.0% | 655 | 397 |
| Prey Veng | 4.5% | 1.11% | 2.3% | 6.6% | 528 | 343 |
| Pursat | 7.4% | 1.30% | 4.9% | 10.0% | 186 | 373 |
| Siemreap | 6.9% | 1.36% | 4.2% | 9.6% | 572 | 376 |
| Svay Rieng | 8.2% | 1.49% | 5.2% | 11.1% | 258 | 355 |
| Takeo | 7.6% | 1.45% | 4.7% | 10.4% | 488 | 370 |
| Oddar Mean Chey | 6.0% | 1.29% | 3.4% | 8.5% | 85 | 371 |
| Battambang/Krong Pailin | 5.8% | 0.91% | 4.0% | 7.6% | 574 | 373 |
| Kampot/Krong Kep | 6.9% | 1.39% | 4.2% | 9.6% | 251 | 340 |
| Sihanouk Ville/Koh Kong | 6.4% | 1.47% | 3.5% | 9.3% | 173 | 356 |
| Preah Vihear/Stung Treng | 11.4% | 2.36% | 6.7% | 16.0% | 143 | 377 |
| Mondul Kiri/Rattanak Kiri | 16.1% | 1.68% | 12.8% | 19.4% | 100 | 357 |

## សន្ទស្សន៍មាឌរាងកាយរបស់ស្ត្រីជាមាតា

Sampling error of body mass index of mothers

| | Estimate | Standard Error | 95% Confidence Interval Lower | 95% Confidence Interval Upper | Population Size | Unweighted Count |
|---|---|---|---|---|---|---|
| **National** | 21.2 | 0.05 | 21.1 | 21.3 | 6099 | 6109 |
| **Residence** | | | | | | |
| Urban | 22.1 | 0.15 | 21.8 | 22.4 | 1048 | 964 |
| Rural | 21.1 | 0.05 | 21.0 | 21.2 | 5051 | 5145 |
| **DOMAIN** | | | | | | |
| Banteay Mean Chey | 22.1 | 0.21 | 21.7 | 22.5 | 292 | 310 |
| Kampong Cham | 21.3 | 0.14 | 21.0 | 21.6 | 810 | 308 |
| Kampong Chhnang | 20.9 | 0.17 | 20.6 | 21.3 | 239 | 328 |
| Kampong Speu | 20.8 | 0.20 | 20.5 | 21.2 | 383 | 321 |
| Kampong Thom | 21.1 | 0.21 | 20.7 | 21.5 | 171 | 335 |
| Kandal | 21.0 | 0.21 | 20.6 | 21.4 | 492 | 270 |
| Kratie | 21.1 | 0.22 | 20.7 | 21.5 | 144 | 335 |
| Phnom Penh | 21.8 | 0.23 | 21.4 | 22.3 | 602 | 372 |
| Prey Veng | 20.8 | 0.24 | 20.3 | 21.2 | 482 | 314 |
| Pursat | 21.1 | 0.14 | 20.9 | 21.4 | 167 | 334 |
| Siemreap | 21.4 | 0.21 | 21.0 | 21.8 | 465 | 307 |
| Svay Rieng | 20.3 | 0.17 | 20.0 | 20.6 | 238 | 326 |
| Takeo | 20.7 | 0.22 | 20.3 | 21.1 | 439 | 333 |
| Oddar Mean Chey | 21.1 | 0.15 | 20.8 | 21.4 | 75 | 330 |
| Battambang/Krong Pailin | 21.9 | 0.15 | 21.7 | 22.2 | 516 | 336 |
| Kampot/Krong Kep | 21.2 | 0.17 | 20.8 | 21.5 | 220 | 301 |
| Sihanouk Ville/Koh Kong | 21.6 | 0.17 | 21.2 | 21.9 | 151 | 312 |
| Preah Vihear/Stung Treng | 21.0 | 0.15 | 20.7 | 21.3 | 126 | 333 |
| Mondul Kiri/Rattanak Kiri | 20.9 | 0.15 | 20.6 | 21.2 | 85 | 304 |

## កុមារមានរោគសញ្ញាជម្ងឺរលាកផ្លូវដង្ហើម (តាមវិធីសាស្រ្តឆ្នាំ២០០៥)

Sampling error of child acute respiratory infection (2005 methodology)

| | Estimate | Standard Error | 95% Confidence Interval Lower | 95% Confidence Interval Upper | Population Size | Unweighted Count |
|---|---|---|---|---|---|---|
| **National** | 15.6% | 0.55% | 14.5% | 16.6% | 6826 | 6873 |
| **Residence** | | | | | | |
| Urban | 9.4% | 0.85% | 7.7% | 11.1% | 1149 | 1079 |
| Rural | 16.8% | 0.64% | 15.6% | 18.1% | 5677 | 5794 |
| **DOMAIN** | | | | | | |
| Banteay Mean Chey | 22.9% | 2.45% | 18.1% | 27.8% | 318 | 340 |
| Kampong Cham | 20.7% | 2.14% | 16.5% | 24.9% | 897 | 341 |
| Kampong Chhnang | 14.3% | 2.16% | 10.1% | 18.6% | 276 | 376 |
| Kampong Speu | 16.7% | 2.09% | 12.6% | 20.8% | 437 | 367 |
| Kampong Thom | 20.5% | 2.75% | 15.1% | 25.9% | 194 | 382 |
| Kandal | 17.2% | 2.09% | 13.1% | 21.3% | 561 | 311 |
| Kratie | 14.9% | 2.80% | 9.4% | 20.4% | 162 | 378 |
| Phnom Penh | 3.0% | 0.99% | 1.1% | 5.0% | 665 | 407 |
| Prey Veng | 13.8% | 1.99% | 9.9% | 17.7% | 520 | 340 |
